ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងអប់រំ យុវជន និងកីឡា

# ឧបសម្ព័ន្ធ

# ក្របខណ្ឌអប់រំស្ទែមកម្រិតសាលារៀន

គម្រោងវិទ្យាសាស្ត្រ និងបច្ចេកវិទ្យាសម្រាប់ការអប់រំ

កម្រិតមធ្យមសិក្សាទុតិយភូមិ (STEP UP)

ខែមិថុនា ឆ្នាំ២០២៥

# មាតិកា


មាតិកា ..... 2

តារាង ..... 4

រូប ..... 5

ឧបសម្ព័ន្ធ កៈ កញ្ចប់ឧបករណ៍ស្វែម ..... 6

សន្លឹកព័ត៌មានរបស់ក្របខណ្ឌអប់រំស្វែមកម្រិតសាលារៀន ..... 7

ជំហានទី១៖ ការណែនាំអំពីក្រុមអនុវត្តសកម្មភាពស្វែម ..... 15

ជំហានទី២៖ ឧបករណ៍ស្វ័យវង្វាយតម្លៃ ..... 19

សមាសភាគទី១៖ លទ្ធផលការសិក្សារបស់សិស្ស ..... 19

សមាសភាគទី២៖ ការបង្រៀន និងរៀន ..... 28

សមាសភាគទី៣៖ អភិបាលកិច្ចសាលារៀន ..... 58

សមាសភាគទី៤៖ ការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធ ..... 79

សមាសភាគទី៥៖ ការចូលរួមរបស់សហគមន៍ ..... 95

ជំហានទី៣៖ ឧបករណ៍ពិនិត្យឡើងវិញ និងកំណត់គោលដៅ ..... 105

១-ការកំណត់កម្រិតអភិវឌ្ឍន៍សរុប (ODL) ..... 107

២-ការពិនិត្យមើលកម្រិតអភិវឌ្ឍន៍លើសមាសភាគនីមួយៗ (DDLs) ..... 108

៣-កំណត់គោលដៅ ..... 109

ជំហានទី៤ ៖ ផែនការសកម្មភាពសម្រាប់ក្របខណ្ឌអប់រំស្វែមកម្រិតសាលារៀន ..... 111

សមាសភាគទី១ ៖ លទ្ធផលការសិក្សារបស់សិស្ស ..... 111

សមាសភាគទី២ ៖ ការបង្រៀន និងរៀន ..... 118

សមាសភាគទី៣ ៖ អភិបាលកិច្ចសាលារៀន ..... 139

សមាសភាគទី៤ ៖ ការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធ ..... 152

សមាសភាគទី៥ ៖ ការចូលរួមរបស់សហគមន៍ ..... 164

ជំហានទី៥៖ ឧបករណ៍ពិនិត្យតាមដានវឌ្ឍនភាពក្របខណ្ឌអប់រំស្វែមកម្រិតសាលារៀន ..... 175

១-ការត្រួតពិនិត្យពាក់កណ្ដាលឆ្នាំ ..... 176

២-ការត្រួតពិនិត្យវឌ្ឍនភាពនៅចុងឆ្នាំ ..... 181

ឧបសម្ព័ន្ធ ខ៖ សទ្ទានុក្រមរបស់ក្របខណ្ឌអប់រំស្ទែមកម្រិតសាលារៀន ........ 185
ឧបសម្ព័ន្ធ គ៖ បញ្ជីឈ្មោះសាលារៀនគោលដៅ ........ 194
ឧបសម្ព័ន្ធ ឃ៖ ក្របខណ្ឌអភិវឌ្ឍការអប់រំស្ទែមកម្រិតសាលារៀន ........ 196
១- គោលនយោបាយស្តីពីការអប់រំស្ទែម ........ 196
២- ឯកសារប្រតិបត្តិការអប់រំស្ទែម ........ 199
២.១- អភិបាលកិច្ចសាលារៀនស្ទែម ........ 199
២.២- ការបង្រៀនតាមបែបស្ទែម ........ 200
២.៣- ការអនុវត្តកម្មវិធីសិក្សា និងម៉ោងសិក្សាមុខវិជ្ជាស្ទែម ........ 201
២.៤- ការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធស្ទែម ........ 202
២.៥- ការចូលរួមរបស់សហគមន៍ ........ 202
២.៦- ការជ្រើសរើសសិស្សចូលរួមនៅក្នុងសាលារៀនស្ទែម ........ 202

# តារាង


តារាងទី 1៖ តារាងបង្ហាញពីកម្រិតអភិវឌ្ឍន៍របស់សាលារៀន ..... 10
តារាងទី 2៖ សេចក្ដីសង្ខេបសមាសភាគ  សមាសភាគរង និងប្រធានបទក្នុងក្របខណ្ឌអប់រំស្វែម..... 11
តារាងទី 3៖ សេចក្ដីលម្អិតសមាជិកក្រុមអនុវត្តសកម្មភាពស្វែម និងតួនាទី..... 17
តារាងទី 4 ៖ ការកំណត់កម្រិតអភិវឌ្ឍន៍សរុប(ODL) * ..... 107
តារាងទី 5៖ សេចក្ដីសង្ខេបនៃកម្រិតអភិវឌ្ឍន៍សរុប(ODL) និងការកំណត់សមាសភាពខ្លាំងនិងខ្សោយ..... 108
តារាងទី 6៖ ការកំណត់គោលដៅ និងការកំណត់ផែនការសកម្មភាពស្វែម ..... 109
តារាងទី 7៖ ការកំណត់គោលដៅ និងការកំណត់ផែនការសកម្មភាពស្វែម ..... 113
តារាងទី 8៖ ការកំណត់គោលដៅ និងការកំណត់ផែនការសកម្មភាពស្វែម ..... 121
តារាងទី 9៖ ការកំណត់គោលដៅ និងការកំណត់ផែនការសកម្មភាពស្វែម ..... 142
តារាងទី 10៖ ការកំណត់គោលដៅ និងការកំណត់ផែនការសកម្មភាពស្វែម ..... 154
តារាងទី 11៖ ការកំណត់គោលដៅ និងការកំណត់ផែនការសកម្មភាពស្វែម..... 166
តារាងទី 12៖ ការពិនិត្យមើលការរីកចម្រើនពាក់កណ្ដាលឆ្នាំ ..... 177
តារាងទី 13៖ ការប្រៀបធៀបកម្រិតអភិវឌ្ឍន៍តាមសមាសភាពស្វែមនៅដើមឆ្នាំ និងចុងឆ្នាំ..... 182
តារាងទី 14៖ ការត្រួតពិនិត្យវឌ្ឍនភាព ..... 183
តារាងទី 15៖ វឌ្ឍនភាពផ្អែកលើតម្លៃកម្រិតអភិវឌ្ឍន៍សរុប (ODL) ដែលបានវាយតម្លៃជាច្រើនដង ..... 184
តារាងទី 16៖  ម៉ោងសិក្សាមុខវិជ្ជាស្វែម..... 201

# រូប

រូបទី 1៖ សេចក្តីសង្ខេបនៃសមាជិកក្រុមអនុវត្តសកម្មភាពស្នែម និងតួនាទី ........................................................16
រូបទី 2៖ រចនាសម្ព័ន្ធគ្រប់គ្រងការអប់រំស្នែម........................................................................................199
រូបទី 3៖ តួនាទីរបស់នាយករងទទួលបន្ទុកស្នែម........................................................................................ 200
រូបទី 4៖ នីតិវិធីនៃការចូលរៀន ........................................................................................................ 202

## ឧបសម្ព័ន្ធ កៈ កញ្ចប់ឧបករណ៍ស្នែម

ឧបករណ៍នៅក្នុងឯកសារនេះអាចត្រូវបានចាត់ទុកថាជាឧបករណ៍ទម្រង់ជាក្រដាស។ ឧបករណ៍ទាំងនេះមានខ្លឹមសារ និងវិធីសាស្ត្រទាំងអស់សម្រាប់ការបង្ហាញជាឧបករណ៍បែបអន្តរកម្ម។



# សន្លឹកព័ត៌មានរបស់ក្របខណ្ឌអប់រំស្ទែមកម្រិតសាលារៀន

សន្លឹកព័ត៌មាននេះត្រូវបានរៀបចំឡើងសម្រាប់ជាឯកសារជំនួយដល់ក្រុមអនុវត្តសកម្មភាពស្ទែម ដើម្បីអនុវត្តជំហានទាំង៥ នៅក្នុងក្របខណ្ឌនេះ និងផ្តោតលើព័ត៌មានសំខាន់ៗអំពីក្របខណ្ឌ និងដើរតួជាឧបករណ៍យោង។

## ១-តើក្របខណ្ឌអប់រំស្ទែមកម្រិតសាលារៀនរបស់កម្ពុជាគឺជាអ្វី?

១.១-សំណុំឧបករណ៍ និងធនធានអនុវត្តជាក់ស្តែងសម្រាប់គណៈគ្រប់គ្រងសាលារៀន គ្រូបង្រៀន សិស្ស និងសហគមន៍ ដោយផ្តល់នូវគោលវិធី រចនាសម្ព័ន្ធច្បាស់លាស់សម្រាប់ការអនុវត្តស្ទែមប្រកបដោយប្រសិទ្ធភាពនៅកម្រិតសាលារៀន។

១.២-សមាសភាគធំៗមាន៥ (សមាសភាគស្ទែម) ដោយមានបញ្ចូលគោលដៅ លំនាំការអនុវត្ត ហើយក្របខណ្ឌគាំទ្រការវិវត្តនៃការអនុវត្តស្ទែមរបស់សាលារៀន។

១.៣-ការរៀបចំជាឧបករណ៍ស្វ័យជំនួយខ្លួនឯង ហើយក្របខណ្ឌនេះធ្វើទៅតាមនិងបំពេញបន្ថែមទៅលើឧបករណ៍ប្រមូលនិងវិភាគទិន្នន័យផ្សេងៗទៀត (ឧ SIS, ស្តង់ដាសាលារៀនគំរូ) ជាជាងការវិនិច្ឆ័យ ឬចាប់កំហុស។

## ២-និយមន័យស្ទែមរបស់កម្ពុជា

**ស្ទែម៖** ជាសមាសភាគដែលបង្កើតឡើងដោយបណ្តុំមុខវិជ្ជាបួន រួមមាន វិទ្យាសាស្ត្រ បច្ចេកវិទ្យា វិស្វកម្ម និងគណិតវិទ្យា។

**មុខវិជ្ជាស្ទែមនៅមធ្យមសិក្សាទុតិយភូមិ៖** មានមុខវិជ្ជាគណិតវិទ្យា រូបវិទ្យា គីមីវិទ្យា ជីវវិទ្យា បច្ចេកវិទ្យា (ICT) និងផែនដីវិទ្យា។

**ការអប់រំស្ទែមនៅមធ្យមសិក្សាទុតិយភូមិ៖** គឺជាការពង្រឹងការបង្រៀននិងការរៀនមុខវិជ្ជាស្ទែម តាមរយៈការដាក់បញ្ចូលខ្លឹមសារសិក្សាទៅក្នុងជីវភាពប្រចាំថ្ងៃឬក្នុងបរិបទជាក់ស្តែង ការគាំទ្រគោលវិធីបង្រៀនទំនើប និងការលើកទឹកចិត្តនៃការរីកចម្រើនបន្តិចម្តងៗឆ្ពោះទៅរកគោលវិធីបង្រៀនបែបអន្តរមុខវិជ្ជា។ ចំណុចសំខាន់ចំពោះគោលវិធីស្ទែម នេះគឺជាសកម្មភាពដែលបណ្តុះបំណិនសតវត្សទី២១ រួមមានសកម្មភាពបង្រៀនបែបគម្រោង ការបង្រៀនបែបដោះស្រាយបញ្ហា និងសកម្មភាពអនុវត្តដោយដៃផ្ទាល់ ដែលត្រូវបានពង្រឹងតាមរយៈបច្ចេកវិទ្យា (ICT) និងការបញ្ចូលគោលការណ៍សិល្បៈ/ការរចនាដែលសមស្រប។

**ការអនុវត្តស្ទែមនៅមធ្យមសិក្សាទុតិយភូមិ៖** ការអនុវត្តការបង្រៀនឬសកម្មភាពរៀនដែលស្របជាមួយគោលវិធីអប់រំស្ទែមនៅមធ្យមសិក្សាទុតិយភូមិ រួមមានសកម្មភាពអនុវត្តដោយដៃផ្ទាល់ ឬអនុវត្តជាក់ស្តែង ការពិសោធ ការប្រើប្រាស់បច្ចេកវិទ្យា កិច្ចសហការឬការងារក្រុមសកម្មភាពអន្តរមុខវិជ្ជា សកម្មភាពបែបគម្រោង និងបែបដោះស្រាយបញ្ហា និងគម្រោងនៅសហគមន៍។ល។

**គោលបំណង ៖**

- គាំទ្រឱ្យសាលារៀនមធ្យមសិក្សាទុតិយភូមិក្នុងការអនុវត្តការអប់រំស្ទែមប្រកបដោយប្រសិទ្ធភាព និងជួយឱ្យសិស្សទទួលបានបទពិសោធន៍អតិបរមានូវការអនុវត្តស្ទែម និងមានការអភិវឌ្ឍបំណិនសតវត្សរ៍ទី២១ សំខាន់ៗ
- សម្របសម្រួលដល់សិស្សក្នុងការផ្សាភ្ជាប់ការសិក្សាទៅនឹងជីវភាពរស់នៅ និងជួយឱ្យធ្វើការសម្រេចចិត្តអាជីពសម្រាប់អនាគត
- ផ្តល់ការណែនាំគណៈគ្រប់គ្រងសាលារៀននិងគ្រូបង្រៀនឱ្យដាក់បញ្ចូលសកម្មភាពអន្តរមុខវិជ្ជាស្ទែម។

## ៣-រចនាសម្ព័ន្ធនៃក្របខណ្ឌ

ក្របខណ្ឌអប់រំស្តែមកម្រិតសាលារៀនរៀបចំឡើងជា ៥ សមាសភាគ ហើយសមាសភាគនីមួយៗមាន ៥ កម្រិតអភិវឌ្ឍន៍ ព្រមទាំងមានការណែនាំអំពីអនុវត្តជំហានទាំង៥ ដោយប្រើកញ្ចប់ឧបករណ៍ស្តែម ដើម្បីគាំទ្រដល់ការអនុវត្តការអប់រំស្តែមប្រកបដោយប្រសិទ្ធភាព។




សមាសភាគស្តែមទាំង៥

កម្រិតអភិវឌ្ឍន៍ទាំង៥




លំនាំនៃជំហានទាំង៥៖

1. រៀបចំក្រុមអនុវត្តសកម្មភាពស្តែម
2. ធ្វើស្វ័យវាយតម្លៃការអនុវត្តស្តែមនាពេលបច្ចុប្បន្ន និងកំណត់កម្រិតអភិវឌ្ឍន៍
3. ពិនិត្យឡើងវិញ និងកំណត់គោលដៅ
4. អនុវត្តផែនការសកម្មភាពស្តែម
5. ត្រួតពិនិត្យវឌ្ឍនភាព និងអនុវត្តជាប្រចាំឆ្នាំ




លំនាំនៃជំហានទាំង៥ និងកញ្ចប់ឧបករណ៍ស្តែម

## ៤-កម្រិតអភិវឌ្ឍន៍របស់សាលារៀន

តារាងទី១ បង្ហាញពីកម្រិតអភិវឌ្ឍន៍របស់សាលារៀនទាំង៥ ដោយផ្អែកលើការអនុវត្តរបស់សិស្ស គ្រូបង្រៀន គណៈគ្រប់គ្រងសាលារៀន និងសហគមន៍។ ដំណើរការទាំង ៥ ជំហាននៃក្របខណ្ឌអប់រំស្ទែមកម្រិតសាលារៀន និង កញ្ចប់ឧបករណ៍ស្ទែម នឹងជួយឱ្យសាលារៀនកំណត់បានកម្រិតអភិវឌ្ឍន៍នាពេលបច្ចុប្បន្នរបស់ខ្លួន កំណត់បានគោលដៅ និងអនុវត្តសកម្មភាពដើម្បីដឹកនាំការអប់រំស្ទែមប្រកបដោយប្រសិទ្ធភាពនៅតាមសាលារៀន។

**តារាងទី 1៖ តារាងបង្ហាញពីកម្រិតអភិវឌ្ឍន៍របស់សាលារៀន**

| | កម្រិតសាលារៀនទី១ | កម្រិតសាលារៀនទី២ | កម្រិតសាលារៀនទី៣ | កម្រិតសាលារៀនទី៤ | កម្រិតសាលារៀនទី៥ |
|---|---|---|---|---|---|
| | ការត្រៀមខ្លួន | ការយល់ដឹង | ការកែលម្អ | ការរីកចម្រើន | ការធ្វើជាគំរូ |
| សិស្ស | សិស្សគ្មានឱកាសសហការប្រើប្រាស់បច្ចេកវិទ្យាឬ ចូលរួមសកម្មភាពស្ទែមអនុវត្តដោយដៃផ្ទាល់។ | សិស្សមានឱកាសសហការម្តងម្កាលប្រើប្រាស់បច្ចេកវិទ្យា និងចូលរួមសកម្មភាពស្ទែមអនុវត្តដោយដៃផ្ទាល់។ | សិស្សសហការជាញឹកញាប់ ប្រើប្រាស់បច្ចេកវិទ្យា និងចូលរួមសកម្មភាពស្ទែមអនុវត្តដោយដៃផ្ទាល់។ ពួកគេបង្កើតគម្រោងស្ទែម និងចូលរួមព្រឹត្តិការណ៍ស្ទែមម្តងម្កាល។ | សិស្សសហការជាប្រចាំ, ប្រើប្រាស់បច្ចេកវិទ្យា និងចូលរួមសកម្មភាពស្ទែមអនុវត្តដោយដៃផ្ទាល់ និងអន្តរមុខវិជ្ជា។ ក្នុងមេរៀនមុខវិជ្ជាស្ទែម ពួកគេចូលរួមជាទៀងទាត់នៅក្នុងព្រឹត្តិការណ៍ស្ទែម។ | សិស្សប្រើបច្ចេកវិទ្យារៀងរាល់ថ្ងៃនិងតែងតែចូលរួមឬសហការក្នុងគម្រោង និងសកម្មភាពស្ទែមគ្រប់មុខវិជ្ជា។ ពួកគេតែងតែចូលរួមព្រឹត្តិការណ៍ស្ទែមថ្នាក់តំបន់ ជាតិ និងអន្តរជាតិ។ |
| គ្រូបង្រៀន | គ្រូបង្រៀនមិនទាន់យល់ដឹងពីគោលវិធីស្ទែម ជំនាញឌីជីថលនៅមានកម្រិត ប្រើវិធីបង្រៀនបែបបុរាណដោយមិនដាក់បញ្ចូលសកម្មភាពអនុវត្តដោយដៃផ្ទាល់ ធ្វើការតែឯងដោយមិនស្វែងរកការគាំទ្រពីអ្នករួមការងារ។ | គ្រូបង្រៀនស្គាល់ពីគោលវិធីស្ទែម ប៉ុន្តែកម្រស្វែងយល់ពីវា ឬការអនុវត្តការបង្រៀនតាមបែបទំនើបផ្សេងទៀត។ ពួកគាត់ប្រើបច្ចេកវិទ្យា និងសកម្មភាពអនុវត្តដោយដៃផ្ទាល់មិនជាប់លាប់ ហើយចែករំលែកបទពិសោធន៍ជាមួយអ្នករួមការងារម្តងម្កាល។ | គ្រូបង្រៀនអនុវត្តការបង្រៀនតាមបែបទំនើបញឹកញាប់, បញ្ចូលសកម្មភាពអនុវត្តដោយដៃផ្ទាល់ និងប្រើប្រាស់ធនធានឌីជីថលដែលមានស្រាប់ញឹកញាប់ ការស្វែងរកគោលវិធីអន្តរមុខវិជ្ជា។ ពួកគាត់ចូលរួមសហគមន៍សិក្សាវិជ្ជាជីវៈ ចែករំលែកបទពិសោធន៍ជាមួយអ្នករួមការងារ។ | គ្រូបង្រៀនអនុវត្តការបង្រៀនតាមបែបទំនើបញឹកញាប់ បញ្ចូលសកម្មភាពអនុវត្តដោយដៃផ្ទាល់ ស្វែងរកធនធានឌីជីថលថ្មីៗនិងទទួលយកគោលវិធីអន្តរមុខវិជ្ជាក្នុងការបង្រៀន។ ពួកគាត់ជាសមាជិកសកម្មនៃសហគមន៍សិក្សាវិជ្ជាជីវៈគាំទ្រអ្នកដទៃ និងការចែករំលែកធនធានឬចំណេះដឹង។ | គ្រូបង្រៀនប្រើវិធីបង្រៀនតាមបែបទំនើបជាស្តង់ដាសំដៅទៅរកការបង្រៀនបែបអន្តរមុខវិជ្ជា។ ចូលរួមបង្កើតធនធានឌីជីថលថ្មីៗដឹកនាំសហគមន៍សិក្សាវិជ្ជាជីវៈ គាំទ្រអ្នកដទៃ និងការចែករំលែកធនធាន ឬចំណេះដឹង។ |
| គណៈគ្រប់គ្រង | គណៈគ្រប់គ្រងសាលារៀនមិនទាន់យល់ពីគោលវិធីស្ទែម និងមិនទាន់ដឹងពីតួនាទីក្នុងការលើក | គណៈគ្រប់គ្រងសាលារៀនកំពុង កសាងចំណេះដឹងអំពីគោលវិធីស្ទែម ចាប់ផ្តើមដឹងពីតម្រូវការពាក់ព័ន្ធនៅក្នុង | គណៈគ្រប់គ្រងសាលារៀនយល់ពីគោលវិធីស្ទែមគាំទ្រគ្រូបង្រៀនស្ទែម និងបុរេសកម្មស្វែងរកដំណោះស្រាយបញ្ហាប្រឈមការ | គណៈគ្រប់គ្រងសាលារៀនបង្ហាញពីការប្តេជ្ញាចិត្តយ៉ាងមុតមាំ ក្នុងការបញ្ចូលគោលវិធីស្ទែម និងបុរេសកម្មស្វែងរកធ្វើ | គណៈគ្រប់គ្រងសាលារៀនគាំទ្រគោលវិធីស្ទែមបង្កលក្ខណៈនិងស្វែងរកសកម្មភាពស្ទែមអន្តរសាលារៀន និង |

| | | | | | |
|---|---|---|---|---|---|
| | កម្ពស់បរិស្ថានអំណោយផលដល់ការអប់រំស្ទែមប្រកបដោយប្រសិទ្ធភាព ។ | សាលារៀននិងតួនាទីក្នុងការដោះស្រាយតម្រូវការទាំងនោះ។ | អនុវត្តស្ទែម នៅក្នុងស្ថានភាពរបស់សាលារៀន។ | ឱ្យប្រសើរឡើងសមត្ថភាពស្ទែមនៅក្នុងស្ថានភាពសាលារៀន។ | ជួយគាំទ្រសាលារៀនជិតខាង។ |
| សហគមន៍ | គ្រួសារ និងសមាជិកសហគមន៍មិនបានផ្សារភ្ជាប់ជាមួយសកម្មភាពសាលារៀន។ ពួកគេដឹងតួនាទីអប់រំបរិស្ថានស្ទែមឱ្យមានការរីកចម្រើននៅសាលារៀន។ | គ្រួសារ និងសមាជិកសហគមន៍យល់ដឹងពីសារៈសំខាន់ស្ទែម និងតួនាទីដែលពួកគេជួយដល់សាលារៀន។ | គ្រួសារ និងសមាជិកសហគមន៍គាំទ្រសាលារៀនហើយចូលរួមម្តងម្កាលក្នុងសកម្មភាពស្ទែម។ | គ្រួសារ និងសមាជិកសហគមន៍គាំទ្រយ៉ាងសកម្មដល់សាលារៀនចូលរួមជាទៀងទាត់ក្នុងសកម្មភាពស្ទែម និងផ្តល់ឱកាសមួយចំនួនសម្រាប់ចូលរួមជាបទពិសោធន៍ជាក់ស្តែង។ | គ្រួសារ និងសមាជិកសហគមន៍ប្តេជ្ញាគាំទ្រសាលារៀននិងដើរតួនាទីសំខាន់នៅក្នុងសកម្មភាពឬព្រឹត្តិការណ៍ស្ទែម បង្កើតឱកាសមួយចំនួនសម្រាប់ចូលរួមជាបទពិសោធន៍ជាក់ស្តែង ។ |

## ៥- សេចក្តីសង្ខេបអំពីសមាសភាគ សមាសភាគរង និងប្រធានបទក្នុងក្របខណ្ឌអប់រំស្ទែមកម្រិតសាលារៀន

ដើម្បីសម្របសម្រួលគោលវិធីចំពោះការអប់រំស្ទែមនៅកម្រិតសាលារៀន ក្របខណ្ឌអប់រំស្ទែមកម្រិតសាលារៀននេះរៀបចំជា៥ សមាសភាគ ហើយសមាសភាគនីមួយៗចែកចេញជាសមាសភាគរង និងប្រធានបទ ដូចបានសង្ខេបនៅក្នុងតារាង2 ខាងក្រោម។

**តារាងទី 2៖ សេចក្តីសង្ខេបសមាសភាគ សមាសភាគរង និងប្រធានបទក្នុងក្របខណ្ឌអប់រំស្ទែម**

| ល.រ | សមាសភាគ | ល.រ | សមាសភាគរង | ល.រ | ប្រធានបទ |
|---|---|---|---|---|---|
| ១ | លទ្ធផលការសិក្សារបស់សិស្ស | ១.១ | ការប្រមូលសិស្សឱ្យចូលរៀន | ១.១.១ | ការចុះឈ្មោះចូលរៀនរបស់សិស្សស្រីក្នុងបណ្តុំវិទ្យាសាស្ត្រ |
| | | | | ១.១.២ | ការចុះឈ្មោះចូលរៀនរបស់សិស្សប្រុសក្នុងបណ្តុំវិទ្យាសាស្ត្រ |
| | | ១.២ | ការរក្សាសិស្សបានគង់វង្សក្នុងសាលារៀន | ១.២.១ | ការមិនបន្តរៀនរបស់សិស្សស្រីក្នុងបណ្តុំវិទ្យាសាស្ត្រ |
| | | | | ១.២.២ | ការមិនបន្តរៀនរបស់សិស្សប្រុសក្នុងបណ្តុំវិទ្យាសាស្ត្រ |
| | | ១.៣ | លទ្ធផលការសិក្សា | ១.៣.១ | លទ្ធផលសិក្សារបស់សិស្សស្រីក្នុងបណ្តុំវិទ្យាសាស្ត្រ |
| | | | | ១.៣.២ | លទ្ធផលសិក្សារបស់សិស្សប្រុសក្នុងបណ្តុំវិទ្យាសាស្ត្រ |

| | | | | | |
|---|---|---|---|---|---|
| ២ | ការបង្រៀន និងរៀន | ២.១ | ការអភិវឌ្ឍវិជ្ជាជីវៈជាប្រចាំ | ២.១.១ | លទ្ធភាពទទួលបានការអភិវឌ្ឍវិជ្ជាជីវៈជាប្រចាំ |
| | | | | ២.១.២ | ខ្លឹមសារបណ្ដុះបណ្ដាល |
| | | | | ២.១.៣ | ប្រធានបទពិសេស |
| | | | | ២.១.៤ | គុណភាព |
| | | | | ២.១.៥ | ការឆ្លើយតបនឹងយេនឌ័រ |
| | | ២.២ | បំណិនឌីជីថល | ២.២.១ | បំណិនឌីជីថលសម្រាប់គ្រូបង្រៀនស្ទែម |
| | | ២.៣ | ការពង្រឹងកម្មវិធីសិក្សា | ២.៣.១ | សម្ភារគាំទ្រ |
| | | | | ២.៣.២ | ការបញ្ចូលខ្លឹមសារកម្មវិធីសិក្សាស្ទែម |
| | | | | ២.៣.៣ | បទពិសោធន៍រៀនស្ទែមជាក់ស្ដែង |
| | | | | ២.៣.៤ | ការសម្របតាមសមត្ថភាពសិស្ស |
| | | ២.៤ | ការបញ្ចូលបច្ចេកវិទ្យា | ២.៤.១ | បច្ចេកវិទ្យានៅក្នុងថ្នាក់រៀន |
| | | | | ២.៤.២ | ធនធានឌីជីថល |
| | | | | ២.៤.៣ | បច្ចេកវិទ្យាអប់រំ |
| | | ២.៥ | ការជួយគាំទ្រសិស្ស | ២.៥.១ | ការរៀបចំសៀវភៅកិច្ចការផ្ទះ |
| | | | | ២.៥.២ | ការបំប៉នសិស្សក្រៅម៉ោងសិក្សា |
| | | ២.៦ | ការផ្សារភ្ជាប់ទៅនឹងជីវភាពរស់នៅ | ២.៦.១ | បរិបទជីវភាពរស់នៅ |
| | | | | ២.៦.២ | ការយល់ដឹងអាជីពស្ទែមក្នុង និងក្រៅថ្នាក់រៀន |
| | | ២.៧ | វង្វាយតម្លៃ | ២.៧.១ | វិធីសាស្ត្រវង្វាយតម្លៃ |
| | | | | ២.៧.២ | លក្ខណៈវិនិច្ឆ័យនៃវង្វាយតម្លៃ |
| | | | | ២.៧.៣ | ការឆ្លុះបញ្ចាំង និងព័ត៌មានត្រឡប់ |
| | | | | ២.៧.៤ | ការធ្វើបទបង្ហាញរបស់សិស្ស |
| | | | | ២.៧.៥ | ការវាយតម្លៃតាមអេឡិចត្រូនិក |
| | | ២.៨ | ការធ្វើអធិការកិច្ចផ្ទៃក្នុង | ២.៨.១ | ការសង្កេតថ្នាក់រៀន |
| | | | | ២.៨.២ | ការប្រឹក្សា |
| | | | | ២.៨.៣ | ការរៀបចំថ្នាក់និទស្សន៍ |
| | | ២.៩ | សហគមន៍សិក្សាវិជ្ជាជីវៈ | ២.៩.១ | សហគមន៍វិជ្ជាជីវៈ |
| | | ២.១០ | ការបង្រៀន | ២.១០.១ | ការបង្រៀនក្នុងថ្នាក់រៀន |
| | | | | ២.១០.២ | ការអនុវត្តការបង្រៀនតាមបែបទំនើប |
| | | | | ២.១០.៣ | គោលវិធីអន្តរមុខវិជ្ជា |
| | | | | ២.១០.៤ | ការប្រើប្រាស់ធនធាន |
| | | | | ២.១០.៥ | សកម្មភាពស្ទែមជាក់ស្ដែង |
| | | | | ២.១០.៦ | ការឆ្លើយតបនឹងយេនឌ័រ |
| ៣ | អភិបាលកិច្ចសាលារៀន | ៣.១ | វប្បធម៌ស្ទែម | ៣.១.១ | ឥរិយាបថ និងការប្ដេជ្ញាចិត្ត៖ របៀបវារៈស្ទែម |
| | | | | ៣.១.២ | ឥរិយាបថ និងការប្ដេជ្ញាចិត្ត៖ ទំនាក់ទំនង |

| | | | | | |
|---|---|---|---|---|---|
| | | | | ៣.១.៣ | ឥរិយាបថ និងការប្តេជ្ញាចិត្តៈ បុគ្គលិក |
| | | ៣.២ | ភាពជាអ្នកដឹកនាំសាលារៀន | ៣.២.១ | ការយល់ដឹង |
| | | | | ៣.២.២ | តួនាទី |
| | | | | ៣.២.៣ | ការគ្រប់គ្រងទីកន្លែងនៅក្នុងសាលារៀន |
| | | | | ៣.២.៤ | ការគ្រប់គ្រងពេលវេលា |
| | | | | ៣.២.៥ | បំណិនឌីជីថល និងបញ្ញាសិប្បនិម្មិត |
| | | | | ៣.២.៦ | ការយល់ដឹងយេនឌ័រ |
| | | ៣.៣ | ការរៀបចំផែនការអភិវឌ្ឍសាលារៀន | ៣.៣.១ | ការរៀបចំផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍សាលា |
| | | ៣.៤ | រចនាសម្ព័ន្ធគាំទ្រ | ៣.៤.១ | ក្រុមគ្រូបង្រៀន/សហគមន៍សិក្សាវិជ្ជាជីវៈ |
| | | | | ៣.៤.២ | សហគមន៍សិក្សាវិជ្ជាជីវៈសម្រាប់គណៈគ្រប់គ្រង |
| | | | | ៣.៤.៣ | ការប្រឹក្សា ឬការបង្វឹក |
| | | ៣.៥ | ការគ្រប់គ្រងធនធាន | ៣.៥.១ | ការបែងចែកថវិកា |
| | | | | ៣.៥.២ | ភាពជាដៃគូជាមួយអ្នកខាងក្រៅ |
| | | | | ៣.៥.៣ | ការវិភាជថវិកា |
| | | ៣.៦ | ការគ្រប់គ្រងទិន្នន័យ | ៣.៦.១ | ការគ្រប់គ្រងទិន្នន័យ |
| | | | | ៣.៦.២ | ទិន្នន័យតាមក្រុម |
| | | ៣.៧ | ការវាយតម្លៃ | ៣.៧.១ | ការវាយតម្លៃការងារបុគ្គលិក |
| | | | | ៣.៧.២ | ការរៀបចំតេស្តស្តង់ដា |
| | | ៣.៨ | ការទទួលស្គាល់ពីថ្នាក់ជាតិ | ៣.៨.១ | ការវាយតម្លៃសាលាប្រចាំឆ្នាំ |
| ៤ | ការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធ | ៤.១ | សម្ភាររូបវន្ត | ៤.១.១ | សម្ភាររូបវន្តស្ទែម |
| | | | | ៤.១.២ | សម្ភាររូបវន្តបច្ចេកវិទ្យា |
| | | | | ៤.១.៣ | បណ្ណាល័យ |
| | | | | ៤.១.៤ | សុវត្ថិភាព |
| | | | | ៤.១.៥ | ការឆ្លើយតបនឹងយេនឌ័រ |
| | | ៤.២ | លទ្ធភាពប្រើប្រាស់ | ៤.២.១ | លទ្ធភាពចូលប្រើប្រាស់បន្ទប់ពិសោធន៍ ឬបន្ទប់រៀនវិទ្យាសាស្ត្រ |
| | | | | ៤.២.២ | លទ្ធភាពចូលប្រើប្រាស់បន្ទប់ ICT |
| | | | | ៤.២.៣ | លទ្ធភាពចូលប្រើប្រាស់ប្រកបដោយបរិយាបន្ន |
| | | ៤.៣ | បរិក្ខារ | ៤.៣.១ | បរិក្ខារស្ទែម |
| | | | | ៤.៣.២ | សម្ភារគម្រោងស្ទែម |
| | | | | ៤.៣.៣ | សម្ភារស្ទែមប្រើបានតែម្តង |
| | | | | ៤.៣.៤ | បរិក្ខារបច្ចេកវិទ្យាអប់រំ |
| | | ៤.៤ | ការភ្ជាប់សេវាសាធារណៈ | ៤.៤.១ | អគ្គិសនី |
| | | | | ៤.៤.២ | អ៊ីនធឺណិត |

| | | | | | |
|---|---|---|---|---|---|
| | | | | ៤.៤.៣ | អនាម័យ ការសម្អាត និងទឹក |
| ៥ | ការចូលរួមរបស់សហគមន៍ | ៥.១ | ការចូលរួម និងគាំទ្ររបស់សហគមន៍ | ៥.១.១ | ការប្រាស្រ័យទាក់ទង |
| | | | | ៥.១.២ | ការចូលរួមគាំទ្រ |
| | | | | ៥.១.៣ | គ្រួសារ និងផ្នត់គំនិតអំពីយេនឌ័រក្នុងស្ទែម |
| | | ៥.២ | ភាពជាដៃគូយុទ្ធសាស្ត្រ | ៥.២.១ | ភាពជាដៃគូស្ទែម |
| | | | | ៥.២.២ | ការប្រាស្រ័យទាក់ទងជាមួយអ្នកពាក់ព័ន្ធស្ទែម |
| | | | | ៥.២.៣ | ភាពជាដៃគូជាមួយសាលារៀនផ្សេងៗ |
| | | ៥.៣ | សកម្មភាពស្ទែមក្រៅម៉ោងសិក្សា | ៥.៣.១ | ក្លឹបសិក្សាស្ទែមក្រៅសាលារៀន |
| | | | | ៥.៣.២ | ការតាំងពិពណ៌ស្ទែមនៅក្នុងសាលារៀន |
| | | | | ៥.៣.៣ | ព្រឹត្តិការណ៍ស្ទែម ឬការប្រកួតប្រជែងស្ទែម |

# ជំហានទី១៖ ការណែនាំអំពីក្រុមអនុវត្តសកម្មភាពស្ទែម




| | |
|---|---|
| **ឈ្មោះឧបករណ៍** | ការណែនាំអំពីក្រុមអនុវត្តសកម្មភាពស្ទែមក្នុងក្របខណ្ឌអប់រំស្ទែមកម្រិតសាលារៀន |
| **អ្នកទទួលខុសត្រូវ** | គណៈគ្រប់គ្រងសាលារៀន |
| **លំនាំដំណើរការ** | ការរៀបចំក្រុមអនុវត្តសកម្មភាពស្ទែមជាជំហានទី១ នៃជំហានទាំង៥ របស់ក្របខណ្ឌអប់រំស្ទែម។ |
| **គោលបំណងឧបករណ៍** | សេចក្តីណែនាំអំពីក្រុមអនុវត្តសកម្មភាពស្ទែមក្នុងក្របខណ្ឌអប់រំស្ទែមកម្រិតសាលារៀនជួយឱ្យគណៈគ្រប់គ្រងសាលាបង្កើតក្រុមដែលមានសមត្ថភាព ដើម្បីជំរុញឱ្យមានការផ្លាស់ប្តូរកម្រិតសាលារៀន និងកែលម្អការអប់រំស្ទែមនៅក្នុងសហគមន៍សាលារៀន។ |
| **ការណែនាំក្រុមសកម្មភាព STEM** | គណៈគ្រប់គ្រងសាលាត្រូវចាត់តាំងក្រុមអនុវត្តសកម្មភាពស្ទែម (សូមមើលតារាងទី11)។ លោក លោកស្រីមានសិទ្ធិជ្រើសរើសសមាជិកក្រុម ដោយអាស្រ័យនឹងស្ថានភាពសាលារៀនរបស់លោក លោកស្រី។ ខាងក្រោមនេះគឺជាចំណុចសំខាន់ៗដែលគួរពិចារណាក្នុងការជ្រើសរើស៖<br>១.ក្រុមអនុវត្តសកម្មភាពស្ទែមត្រូវមាន ប្រធានក្រុមម្នាក់ និងសមាជិកនៃក្រុមទាំងពីរប្រភេទ ដែលក្រុមទី១ ជាក្រុមគាំទ្រ និងក្រុមទី២ ជាក្រុមបង្គោល (សូមមើលរូបទី4)។<br>២.ត្រូវយល់ច្បាស់ពីដំណើរការទាំង ៥ជំហាននៃក្របខណ្ឌអប់រំស្ទែមកម្រិតសាលារៀន និងសមាសភាគស្ទែមនីមួយៗ (សូមមើល សន្លឹកព័ត៌មាន) ដើម្បីយល់ដឹងពីដំណើរការ និងចំណុចសំខាន់ៗដែលនឹងត្រូវផ្តោតការយកចិត្តទុកដាក់ក្នុងក្រុមអនុវត្តសកម្មភាពស្ទែម។<br>៣.ត្រូវមានសមធម៌យេនឌ័រក្នុងក្រុមអនុវត្តសកម្មភាពស្ទែម។<br>៤.ដំបូងជ្រើសរើសសមាជិកបង្គោល។ សូមចំណាំថាសមាសភាគស្ទែមទាំង៥ ត្រូវបែងចែកឱ្យសមាជិកបង្គោលនីមួយៗទទួលខុសត្រូវ ដើម្បីជៀសវាងមានបន្ទុកការងារច្រើនពេក។ ដោយសារសមាជិកបង្គោលមានបំណិននិងចំណេះដឹងមិនដូចគ្នា ដូចនេះសមាជិកបង្គោលម្នាក់គួរទទួលបន្ទុកតែមួយសមាសភាគ (សូមមើលលម្អិតតារាងទី11)។<br>៥.ចាត់តាំងប្រធានក្រុមអនុវត្តសកម្មភាពស្ទែម ឱ្យដឹកនាំសមាជិកបង្គោល។<br>៦.ជួយប្រធានក្រុមអនុវត្តសកម្មភាពស្ទែម ក្នុងបែងចែកសមាសភាគស្ទែមទៅឱ្យសមាជិកបង្គោលទទួលបន្ទុក៖ |

| | |
|---|---|
| | ក. លោក លោកស្រីបែងចែកសមាសភាគទី១ ឬ ២ ទៅឱ្យសមាជិកបង្គោលម្នាក់ ដោយអាស្រ័យលើ បំណិន ឬជំនាញ ឬលទ្ធភាព<br>ខ.គណៈគ្រប់គ្រងសាលារៀនគួរយកសមាសភាគទី ១ ឬ ២ (ហេដ្ឋារចនាសម្ព័ន្ធ និង វប្បធម៌សាលារៀន និងអភិបាលកិច្ច) ចំណែកឯគ្រូបង្រៀនស្ទែមគួរជ្រើសយកសមាសភាគទី៣ ឬ ៤ (សមត្ថភាពរបស់គ្រូបង្រៀននិងលទ្ធផលការសិក្សារបស់សិស្ស និងដំណើរការបង្រៀននិងរៀន)។ គណៈគ្រប់គ្រងសាលារៀន ឬគ្រូបង្រៀនក៏បាន គួរជ្រើសរើសយកសមាសភាគទី៥ (ការចូលរួមរបស់សហគមន៍)។ នេះជាគ្រាន់តែជាការផ្តល់យោបល់ វាមិនមែនតម្រូវឱ្យធ្វើតាមទាំងស្រុងនោះទេ។<br>គ.សរសេរឈ្មោះសមាជិកបង្គោលនៃក្រុមអនុវត្តសកម្មភាពស្ទែមនៅក្នុងតារាង១៥ ខាងក្រោម ដែលមានបង្ហាញពីការទទួលខុសត្រូវចំពោះសមាសភាគនីមួយៗ។<br>៧.ដោយមានធាតុចូលពីសមាជិកបង្គោល សូមជ្រើសរើសនិងចាត់តាំងសមាជិកគាំទ្រ<br>៨. ដាក់ស្តែង ក្រុមអនុវត្តសកម្មភាពស្ទែមរបស់លោក លោកស្រី(សមាជិកបង្គោល និងសមាជិកគាំទ្រ) គួរជ្រើសរើសយកបុគ្គលដែលយល់ពីតួនាទីរបស់ស្ទែមនាពេលអនាគតរបស់ប្រទេសកម្ពុជា និងជាអ្នកដោះស្រាយបញ្ហាប្រកបដោយប្រសិទ្ធភាព ខ្ជាប់ខ្ជួន ឧស្សាហ៍ព្យាយាម និងមានសមត្ថភាពគ្រប់គ្រងស្ទែមនៅក្នុងសាលារៀន។ |

**រូបទី 1៖ សេចក្តីសង្ខេបនៃសមាជិកក្រុមអនុវត្តសកម្មភាពស្ទែម និងតួនាទី**



# តារាងទី ៣៖ សេចក្តីលម្អិតសមាជិកក្រុមអនុវត្តសកម្មភាពស្នែម និងតួនាទី

| ប្រភេទសមាជិកក្រុមអនុវត្តសកម្មភាពស្នែម | សមាជិកគាំទ្រ | សមាជិកបង្គោល |
|---|---|---|
| ចំនួន | មានសមាជិកប្រហែលពី៤ ទៅ ៦នាក់ | ប្រធាន ១នាក់ និងសមាជិកប្រហែលពី ៣ ទៅ ៥ នាក់ |
| មុខសញ្ញាចូលរួម | សមាជិកក្រុមគាំទ្រអាចជា៖<br>• នាយកសាលារៀន<br>• តំណាងការិយាល័យអ យ ក ស្រុក ឬ តំណាងមន្ទីរអ យ ក ខេត្ត<br>• តំណាងសហគមន៍ ប្រសិនបើមាន ឬមាតាបិតាស្ម័គ្រចិត្ត<br>• សមាជិកឧស្សាហកម្មស្នែមក្នុងស្រុក/និយោជកទាក់ទងនឹងស្នែម (ឧស្សាហកម្មដែលទាក់ទងនឹងស្នែម ឧទាហរណ៍ រោងចក្រ សេវាកម្មព័ត៌មានវិទ្យា វិស័យវេជ្ជសាស្ត្រ ឧស្សាហកម្មអាហារ មេកានិក និងអគ្គិសនី ជាដើម)<br>• ក្រុមប្រឹក្សាយុវជន ឬ ប្រធានក្លឹបស្នែម (សិស្សដែលអាចចងសម្ព័ន្ធទំនាក់ទំនងរវាងអ្នកអប់រំ និងសិស្ស)<br>• ភាគីពាក់ព័ន្ធស្នែមផ្សេងទៀតនៅក្នុងសហគមន៍សាលារៀន<br>• គ្រូបង្រៀនវិទ្យាសាស្ត្រសង្គម (អាចរួមចំណែកគំនិតបញ្ចូលប្រធានបទជាក់ស្តែងក្នុងការបង្រៀនស្នែម) | ប្រធានក្រុមបង្គោល ឬ សមាជិកបង្គោលអាចជា៖<br>• យ៉ាងហោចណាស់មានគណៈគ្រប់គ្រងសាលារៀន ១នាក់<br>• ប្រធានក្រុមបច្ចេកទេសស្នែម<br>• គ្រូបង្រៀនមុខវិជ្ជាស្នែម<br>• បរិវិច្ឆការី បើអាចមាន |
| តួនាទី | • ជួយសមាជិកបង្គោលក្នុងការធ្វើសេចក្តីសម្រេចចិត្ត<br>• ជួយគាំទ្រ នៅពេលវេលាសមស្របណាមួយ | • ជំរុញដំណើរការទាំង ៥ជំហាននៃក្របខណ្ឌស្នែមកម្រិតសាលារៀន<br>• អនុវត្តការផ្លាស់ប្តូរ<br>• ដោះស្រាយបញ្ហា<br>• បន្តគាំទ្រដល់សមាជិកគាំទ្រ |
| | • យល់ដឹងច្បាស់លាស់អំពីការអប់រំស្នែម និងតួនាទីក្នុងការអប់រំបំណិនសតវត្សទី២១ និងនាំឱ្យមានលក្ខណៈត្រៀមជាស្រេចសម្រាប់ទៅមហាវិទ្យាល័យ។ | • យល់ដឹងច្បាស់លាស់អំពីការអប់រំស្នែម និងតួនាទីក្នុងការអប់រំបំណិនសតវត្សទី២១ ព្រមទាំងនាំឱ្យមានលក្ខណៈត្រៀមជាស្រេចសម្រាប់ទៅមហាវិទ្យាល័យ |

| | | |
|---|---|---|
| **បុគ្គលិកលក្ខណៈ ឬ បំណិន** | • មានការប្តេជ្ញាចិត្តក្នុងការធ្វើឱ្យប្រសើរឡើងនូវការអប់រំ ស្នែមនៅសាលារៀនលោក លោកស្រី<br>• មានលទ្ធភាពនិងមានឆន្ទៈចូលរួមសកម្មភាពស្នែម<br>• សមាជិកគាំទ្រមួយចំនួនគួរមានសាវតារទាក់ទងនឹងបច្ចេកទេសស្នែម។ | • ការលើកទឹកចិត្ត និងការលះបង់ខ្ពស់ដើម្បីកែលម្អការអប់រំស្នែមនៅសាលារៀនលោក លោកស្រី<br>• ការចេះដឹងពីបញ្ហាប្រឈម ដែលគ្រូបង្រៀនស្នែមជួបប្រទះ<br>• ជាអ្នកដោះស្រាយបញ្ហាប្រកបដោយភាពច្នៃប្រឌិត និងជាអ្នកព្យាយាម<br>• មានសមត្ថភាពធ្វើឱ្យការអប់រំស្នែមនៅកម្រិតសាលារៀនជោគជ័យ តាមរយៈបំផុសគំនិតអ្នកដទៃលើកឡើងពីបញ្ហាប្រឈម |
| **ការទទួលខុសត្រូវ** | • ចូលរួមប្រជុំតាមការអញ្ជើញ (យ៉ាងហោចណាស់ ម្តងក្នុងមួយត្រីមាស)<br>• យល់ច្បាស់លាស់ពីជំហានទាំងអស់ក្នុងដំណើរការទាំង ៥ ជំហានរបស់ក្របខណ្ឌអប់រំស្នែមកម្រិតសាលារៀន<br>• ទទួលស្គាល់ថាដំណើរការនេះប្រើពេលវេលាច្រើន និងខិតខំប្រឹងប្រែងនៅគ្រប់កម្រិតនៃសហគមន៍សាលារៀន<br>• បំផុសគំនិតសហគមន៍សាលារៀនឱ្យមានទំនុកចិត្ត មានការទទួលខុសត្រូវក្នុងការដោះស្រាយពេលជួបបញ្ហាប្រឈម<br>• គាំទ្រសមាជិកបង្គោលក្នុងពេលដំណើរការនៃក្របខណ្ឌអប់រំស្នែមកម្រិតសាលារៀន<br>• ចូលរួមក្នុងជំហានសំខាន់ៗយ៉ាងសកម្ម ដូចជាការកំណត់គោលដៅ<br>• គាំទ្រសមាជិកបង្គោលនៅពេលអនុវត្តផែនការសកម្មភាពស្នែម | • ចូលរួមប្រជុំទៀងទាត់ (ពីរសប្តាហ៍ម្តង)<br>• ធ្វើបច្ចុប្បន្នកម្មសមាជិកគាំទ្រ ស្តីពីវឌ្ឍនភាពយ៉ាងហោចណាស់ម្តងក្នុងមួយត្រីមាស<br>• ជំរុញឱ្យការអនុវត្តដំណើរការទាំង៥ជំហាននៃក្របខណ្ឌអប់រំស្នែមកម្រិតសាលារៀន ជាលក្ខណៈក្រុម<br>• ទទួលខុសត្រូវសមាសភាគមួយ ឬច្រើន ដូចដែលបានព្រមព្រៀងគ្នាក្នុងក្រុម<br>• បំពេញឧបករណ៍ស្វ័យវាយតម្លៃ ចំពោះសមាសភាគស្នែមដែលទទួលខុសត្រូវ<br>• ពិនិត្យឡើងវិញនិងកំណត់ឱ្យបានពីកម្រិតអភិវឌ្ឍន៍ចំពោះសមាសភាគស្នែមដែលទទួលខុសត្រូវ<br>• ពិគ្រោះយោបល់ជាមួយសមាជិកគាំទ្រជាក្រុម ហើយកំណត់គោលដៅសម្រាប់សាលារៀន<br>• ធ្វើការជាមួយសមាជិកបង្គោលដើម្បីតាមដានផែនការសកម្មភាពស្នែមដែលមានភាពពាក់ព័ន្ធគ្នាស្របតាមគោលដៅរបស់សាលារៀន។<br>• លើកទឹកចិត្តសហគមន៍សាលារៀន ដើម្បីគាំទ្រដំណើរការ និងផ្ទេរភារកិច្ចនៅពេលណាសមស្រប<br>• តាមដានវឌ្ឍនភាព និងពិនិត្យឡើងវិញនៅចុងឆ្នាំ។ |

# ជំហានទី២៖ ឧបករណ៍ស្វ័យវាយតម្លៃ

## សមាសភាគទី១៖ លទ្ធផលការសិក្សារបស់សិស្ស

| | |
|---|---|
| **សមាសភាគទី១** | លទ្ធផលការសិក្សារបស់សិស្ស |
| **អ្នកទទួលខុសត្រូវ** | សមាជិកបង្គោល ដែលទទួលខុសត្រូវសមាសភាគនេះត្រូវក្នុងការបំពេញឧបករណ៍ស្វ័យវាយតម្លៃ។ ពួកគាត់គួរតែស្នើសុំជាតុចូលពីសមាជិកគាំទ្របុគ្គលិកសាលារៀនដទៃទៀត។ |
| **សមាជិកបង្គោលសម្រាប់សមាសភាគនេះ** | |
| **ឆ្នាំទី** | ( ឧ. ឆ្នាំទី១៖ ឆ្នាំសិក្សា២០២៤-២០២៥ ) |
| **លំនាំដំណើរការ** | ក្របខណ្ឌអប់រំស្ដែមកម្រិតសាលារៀនជួយសាលារៀនដើម្បីកែលម្អការបង្រៀននិងការរៀនមុខវិជ្ជាស្ដែមតាមរយៈដំណើរការ ៥ ជំហាន។ ឧបករណ៍ស្វ័យវាយតម្លៃរបស់ក្របខណ្ឌអប់រំស្ដែមកម្រិតសាលារៀននេះគឺជាជំហានទី១ នៃដំណើរការទាំង៥ជំហាន ។<br><br>ឧបករណ៍ស្វ័យវាយតម្លៃរបស់ក្របខណ្ឌអប់រំស្ដែមកម្រិតសាលារៀនសម្រាប់សមាសភាគស្ដែមទី១ គឺ លទ្ធផលការសិក្សារបស់សិស្ស ដែលមានសមាសភាគរង៖<br>១.១ ការប្រមូលសិស្សឱ្យចូលរៀន<br>១.២ ការរក្សាសិស្សបានគង់វង្សក្នុងសាលារៀន<br>១.៣ លទ្ធផលការសិក្សា<br> |
| **គោលបំណងរបស់ឧបករណ៍** | ឧបករណ៍ស្វ័យវាយតម្លៃនឹងជួយក្រុមអនុវត្តសកម្មភាពស្ដែមរបស់សាលារៀនរបស់លោក លោកស្រីដើម្បីពិនិត្យមើលឡើងវិញការអនុវត្តស្ដែមនាពេលបច្ចុប្បន្ន និងកំណត់កម្រិតនៃក្របខណ្ឌណាមួយដែលសមស្របបំផុតនឹងស្ថានភាពបច្ចុប្បន្នរបស់សាលារៀនលោក |

| | |
|---|---|
| | លោកស្រី។ ឧបករណ៍នេះនឹងជួយលោក លោកស្រីកំណត់ចំណុចដែលត្រូវយកចិត្តទុកដាក់ និងណែនាំលោក លោកស្រីក្នុងការកំណត់គោលដៅសម្រាប់អភិវឌ្ឍនាឆ្នាំខាងមុខ។ ឧបករណ៍នេះផងដែរបង្កើតឡើងមិនមែនក្នុងបំណងដើរតួជាឧបករណ៍វិនិច្ឆ័យ ឬវង្វាយតម្លៃនេះទេ។ លោក លោកស្រីត្រូវបានលើកទឹកចិត្តឱ្យធ្វើការឆ្លុះបញ្ចាំងដោយភាពស្មោះត្រង់លើការអនុវត្តរបស់សាលារៀនលោក លោកស្រី ដើម្បីធានាថាការផ្តល់អនុសាសន៍គឺសមស្របនឹងសមត្ថភាពសាលារៀន និងផ្តល់អត្ថប្រយោជន៍ដល់សាលារៀនលោក លោកស្រី។ |
| **ការណែនាំ** | 1. បោះពុម្ពឧបករណ៍ស្វ័យវាយតម្លៃដាក់នៅខាងក្រោយឯកសារ<br>2. បោះពុម្ពឧបករណ៍ស្វ័យវាយតម្លៃដាក់ ដែលនៅផ្នែកខាងក្រោយនៃក្របខណ្ឌ<br>3. បំពេញតារាងខាងក្រោម ដោយជ្រើសរើសចម្លើយស្របតាមសំណួរនីមួយៗនៅក្នុងសមាសភាគរង និងប្រធានបទ សូមឆ្លុះបញ្ចាំងដោយភាពស្មោះត្រង់លើស្ថានភាពនៃការអនុវត្តនៅសាលារៀនរបស់លោក លោកស្រី បន្ទាប់មក សូមកំណត់កម្រិតអភិវឌ្ឍន៍ដែលស័ក្តិសមបំផុត។ លោក លោកស្រីប្រហែលរកឃើញស្ថានភាពសាលារៀនក្នុងកម្រិតខុសៗគ្នា អាស្រ័យលើប្រធានបទ<br>4. ពិនិត្យមើលត្រង់ចំណុចសម្គាល់សម្រាប់សំណួរនីមួយៗ ដើម្បីផ្ទៀងផ្ទាត់ឡើងវិញទៅលើខ្លឹមសារណាដែលមិនច្បាស់<br>5. កត់ត្រាចម្លើយរបស់លោក លោកស្រីនៅលើឧបករណ៍ស្វ័យវាយតម្លៃនៅផ្នែកខាងក្រោយនៃក្របខណ្ឌ ដោយគូសសញ្ញា (✓) ដែលត្រូវនឹងស្ថានភាពបច្ចុប្បន្នរបស់សាលារៀន<br>6. នៅពេលគូសរួចរាល់ លោក លោកស្រីត្រូវបូកសរុបពិន្ទុដោយរាប់ចំនួនសញ្ញា (✓) នៅតាមកម្រិតនីមួយៗ<br>7. អនុវត្តតាមការណែនាំនៅផ្នែកខាងក្រោយនៃក្របខណ្ឌ ដើម្បីកំណត់កម្រិតអភិវឌ្ឍន៍តាមសមាសភាគ (DDL) សម្រាប់សមាសភាគនេះ (កម្រិត ដែលមានសញ្ញា (✓) ច្រើនជាងគេបំផុត) កំណត់បានចំណុចខ្លាំង និងកំណត់ចំណុចដែលត្រូវពង្រឹង។ |

| | | | | | |
|---|---|---|---|---|---|
| ១.១.១ | ១.១.ការប្រមូលសិស្សឱ្យចូលរៀន | | | | |
| | ភាគរយសិស្សស្រីថ្នាក់ទី១១ ដែលបានចុះឈ្មោះចូលរៀនក្នុងបណ្តុំវិទ្យាសាស្ត្រនៅដើមឆ្នាំសិក្សា៖ | | | | |
| | កម្រិតសាលារៀនទី១ | កម្រិតសាលារៀនទី២ | កម្រិតសាលារៀនទី៣ | កម្រិតសាលារៀនទី៤ | កម្រិតសាលារៀនទី៥ |
| ការចុះឈ្មោះចូលរៀនរបស់សិស្សស្រីក្នុងបណ្តុំវិទ្យាសាស្ត្រ | រហូតដល់ ៥០% នៃសិស្សស្រីថ្នាក់ទី១១ សរុប។ | ចាប់ពី ៥១%ទៅ ៦០%នៃសិស្សស្រីថ្នាក់ទី១១ សរុប។ | ចាប់ពី ៦១%ទៅ ៧០%នៃសិស្សស្រីថ្នាក់ទី១១ សរុប។ | ចាប់ពី ៧១%ទៅ ៨០% នៃសិស្សស្រីថ្នាក់ទី១១ សរុប។ | លើសពី ៨០%នៃសិស្សស្រីថ្នាក់ទី១១ សរុប។ |
| កំណត់សម្គាល់ | ប្រសិនបើមិនមានទិន្នន័យតាមក្រុមទេ សូមជ្រើសរើសយកកម្រិតសាលារៀនទី១។ | | | | |
| ១.១.២ | ភាគរយសិស្សប្រុសថ្នាក់ទី១១ ដែលបានចុះឈ្មោះចូលរៀនក្នុងបណ្តុំវិទ្យាសាស្ត្រនៅដើមឆ្នាំសិក្សា៖ | | | | |
| | កម្រិតសាលារៀនទី១ | កម្រិតសាលារៀនទី២ | កម្រិតសាលារៀនទី៣ | កម្រិតសាលារៀនទី៤ | កម្រិតសាលារៀនទី៥ |

| | | | | | |
|---|---|---|---|---|---|
| ការចុះឈ្មោះចូលរៀនរបស់សិស្សប្រុសក្នុងបណ្ដុំវិទ្យាសាស្ត្រ | រហូតដល់ ៥០% នៃសិស្សប្រុសថ្នាក់ទី១១ សរុប។ | ចាប់ពី ៥១% ទៅ ៦០%នៃសិស្សប្រុសថ្នាក់ទី១១ សរុប។ | ចាប់ពី ៦១% ទៅ ៧០%នៃសិស្សប្រុសថ្នាក់ទី១១ សរុប។ | ចាប់ពី ៧១% ទៅ ៨០% នៃសិស្សប្រុសថ្នាក់ទី១១ សរុប។ | លើសពី ៨០% នៃសិស្សប្រុសថ្នាក់ទី១១ សរុប។ |
| កំណត់សម្គាល់ | ប្រសិនបើមិនមានទិន្នន័យតាមក្រុមទេ សូមជ្រើសរើសយកកម្រិតសាលារៀនទី១។ | | | | |

| ១.២.១ | ១.២. ការរក្សាសិស្សបានគង់វង្សក្នុងសាលារៀន | | | | |
|---|---|---|---|---|---|
| | ភាគរយសិស្សស្រីដែលមិនបន្តរៀនក្នុងបណ្ដុំវិទ្យាសាស្ត្រនៅថ្នាក់ទី១២៖ | | | | |
| | កម្រិតសាលារៀនទី១ | កម្រិតសាលារៀនទី២ | កម្រិតសាលារៀនទី៣ | កម្រិតសាលារៀនទី៤ | កម្រិតសាលារៀនទី៥ |
| ភាគរយសិស្សស្រីដែលមិនបន្តរៀនក្នុងបណ្ដុំវិទ្យាសាស្ត្រ | ច្រើនជាង ២៥% (ធៀបនឹងសិស្សស្រីថ្នាក់ទី១១ ចុងឆ្នាំ ដែលបានរៀនក្នុងបណ្ដុះវិទ្យាសាស្ត្រ)។ | ចាប់ពី ២១% ទៅ ២៥% | ចាប់ពី ១៦% ទៅ ២០% | ចាប់ពី ១១% ទៅ ១៥% | ចាប់ពី 0% ទៅ ១០% |

| | | | | | |
|---|---|---|---|---|---|
| កំណត់សម្គាល់ | ប្រសិនបើមិនមានទិន្នន័យតាមក្រុមទេ សូមជ្រើសរើសយកកម្រិតសាលារៀនទី១។ | | | | |
| ១.២.២ | **ភាគរយសិស្សប្រុសដែលមិនបន្តរៀនក្នុងបណ្ដុំវិទ្យាសាស្ត្រនៅថ្នាក់ទី១២៖** | | | | |
| | **កម្រិតសាលារៀនទី១** | **កម្រិតសាលារៀនទី២** | **កម្រិតសាលារៀនទី៣** | **កម្រិតសាលារៀនទី៤** | **កម្រិតសាលារៀនទី៥** |
| ភាគរយសិស្សប្រុសដែលមិនបន្តរៀនក្នុងបណ្ដុំវិទ្យាសាស្ត្រ | ច្រើនជាង ២៥% (ធៀបនឹងសិស្សប្រុសថ្នាក់ទី១១ ចុងឆ្នាំ ដែលបានរៀនក្នុងបណ្ដុះវិទ្យាសាស្ត្រ)។ | ចាប់ពី ២១% ទៅ ២៥% | ចាប់ពី ១៦% ទៅ ២០% | ចាប់ពី ១១% ទៅ ១៥% | ចាប់ពី 0% ទៅ ១0% |
| កំណត់សម្គាល់ | ប្រសិនបើមិនមានទិន្នន័យតាមក្រុមទេ សូមជ្រើសរើសយកកម្រិតសាលារៀនទី១។ | | | | |

| | | | | | |
|---|---|---|---|---|---|
| ១.៣.១ | ១.៣. លទ្ធផលការសិក្សា | | | | |
| | ភាគរយសិស្សស្រីដែលរៀនក្នុងបណ្ដុំវិទ្យាសាស្ត្រទទួលបានទិន្នេស A, B, ឬ C នៅបញ្ចប់ឆ្នាំសិក្សាថ្នាក់ទី១២៖ | | | | |
| | កម្រិតសាលារៀនទី១ | កម្រិតសាលារៀនទី២ | កម្រិតសាលារៀនទី៣ | កម្រិតសាលារៀនទី៤ | កម្រិតសាលារៀនទី៥ |
| លទ្ធផលសិក្សារបស់សិស្សស្រី ក្នុងបណ្ដុំវិទ្យាសាស្ត្រ | ចាប់ពី 0% ទៅ ១0% (ធៀបនឹងសិស្សស្រីដែលចូលរួមប្រឡង) | ចាប់ពី ២១% ទៅ ៣៥% | ចាប់ពី ៣៦% ទៅ ៥0% | ចាប់ពី ៥១% ទៅ ៧0% | ៧១% ឬច្រើនជាងនេះ។ |
| កំណត់សម្គាល់ | ប្រសិនបើមិនមានទិន្នន័យតាមក្រុមទេ សូមជ្រើសរើសយកកម្រិតសាលារៀនទី១។ | | | | |
| ១.៣.២ | ភាគរយសិស្សប្រុសដែលរៀនក្នុងបណ្ដុំវិទ្យាសាស្ត្រទទួលបានទិន្នេស A, B, ឬ C នៅបញ្ចប់ឆ្នាំសិក្សាថ្នាក់ទី១២៖ | | | | |
| | កម្រិតសាលារៀនទី១ | កម្រិតសាលារៀនទី២ | កម្រិតសាលារៀនទី៣ | កម្រិតសាលារៀនទី៤ | កម្រិតសាលារៀនទី៥ |

| ១.៣.១ | ១.៣. លទ្ធផលការសិក្សា | | | | |
|---|---|---|---|---|---|
| | ភាគរយសិស្សស្រីដែលរៀនក្នុងបណ្ដុំវិទ្យាសាស្ត្រទទួលបានទិន្នេស A, B, ឬ C នៅបញ្ចប់ឆ្នាំសិក្សាថ្នាក់ទី១២៖ | | | | |
| | កម្រិតសាលារៀនទី១ | កម្រិតសាលារៀនទី២ | កម្រិតសាលារៀនទី៣ | កម្រិតសាលារៀនទី៤ | កម្រិតសាលារៀនទី៥ |
| លទ្ធផលសិក្សារបស់សិស្សប្រុស ក្នុងបណ្ដុំវិទ្យាសាស្ត្រ | ចាប់ពី ០% ទៅ ១០% (ធៀបនឹងសិស្សប្រុស ដែលចូលរួមប្រឡង) | ចាប់ពី ២១% ទៅ ៣៥% | ចាប់ពី ៣៦% ទៅ ៥០% | ចាប់ពី ៥១% ទៅ ៧០% | ៧១% ឬច្រើនជាងនេះ។ |

# ឧបករណ៍ស្វ័យវាយតម្លៃ

## សមាសភាគទី១ ៖ លទ្ធផលការសិក្សារបស់សិស្ស

សូមពិនិត្យបច្ចុប្បន្នភាពនៃស្ថានភាពសាលារៀនតាមសំណួរ ឬការពិពណ៌នារបស់ឧបករណ៍ស្វ័យវាយតម្លៃនៅក្នុងតារាងខាងក្រោមនេះដោយគូសសញ្ញា (✓) ក្នុងជួរឈរ ដែលត្រូវជាមួយស្ថានភាពសាលារៀនលោក លោកស្រី។

| ល.រ | សមាសភាគរង | ល.រ | ប្រធានបទ | កម្រិតសាលារៀនទី១ | កម្រិតសាលារៀនទី២ | កម្រិតសាលារៀនទី៣ | កម្រិតសាលារៀនទី៤ | កម្រិតសាលារៀនទី៥ |
|---|---|---|---|---|---|---|---|---|
| ១.១ | ការប្រមូលសិស្សឱ្យចូលរៀន | ១.១.១ | ការចុះឈ្មោះចូលរៀនរបស់សិស្សស្រីក្នុងបណ្តុំវិទ្យាសាស្ត្រ | | | | | |
| | | ១.១.២ | ការចុះឈ្មោះចូលរៀនរបស់សិស្សប្រុសក្នុងបណ្តុំវិទ្យាសាស្ត្រ | | | | | |
| ១.២ | ការរក្សាសិស្សបានគង់វង្សក្នុងសាលារៀន | ១.២.១ | ការមិនបន្តរៀនរបស់សិស្សស្រីក្នុងបណ្តុំវិទ្យាសាស្ត្រ | | | | | |
| | | ១.២.២ | ការមិនបន្តរៀនរបស់សិស្សប្រុសក្នុងបណ្តុំវិទ្យាសាស្ត្រ | | | | | |
| ១.៣ | លទ្ធផលការសិក្សា | ១.៣.១ | លទ្ធផលសិក្សារបស់សិស្សស្រីក្នុងបណ្តុំវិទ្យាសាស្ត្រ | | | | | |
| | | ១.៣.២ | លទ្ធផលសិក្សារបស់សិស្សប្រុសក្នុងបណ្តុំវិទ្យាសាស្ត្រ | | | | | |
| **សរុប** | | | | /6 | /6 | /6 | /6 | /6 |

**ការណែនាំការប្រើប្រាស់ឧបករណ៍ស្វ័យវាយតម្លៃនៃក្របខណ្ឌអប់រំស្នែមកម្រិតសាលារៀន៖**

1. ក្នុងប្រធានបទនីមួយៗ សូមគូសសញ្ញា (✓) ដែលត្រូវជាមួយស្ថានភាព/ការអនុវត្តរបស់សាលារៀនលោក លោកស្រី
2. បូកសរុបចំនួនសញ្ញា (✓) ក្នុងកម្រិតនីមួយៗ
3. កម្រិតមួយណាដែលមានសញ្ញា (✓) ច្រើនជាងគេនោះវាជា កម្រិតអភិវឌ្ឍន៍តាមសមាសភាគ (DDL)
4. កត់ត្រាលទ្ធផលសម្រាប់ប្រើប្រាស់ក្នុងការពិនិត្យឡើងវិញ និងនិងប្រើប្រាស់នៅក្នុងឧបករណ៍កំណត់គោលដៅ (ជំហានទី៣)

> **កម្រិតអភិវឌ្ឍន៍តាមសមាសភាគ (DDL)**
>
> កម្រិតអភិវឌ្ឍន៍របស់សាលារៀនសម្រាប់សមាសភាគ ណាមួយអាស្រ័យលើពិន្ទុនៃសមត្ថភាពស្នែមពីកម្រិតសាលារៀនទី១ ដល់ ៥។

**ការកំណត់កម្រិតអភិវឌ្ឍន៍តាមសមាសភាគ (DDL)** សម្រាប់សមាសភាគនេះ៖ សាលារៀនយើងមានសញ្ញា (✓) ច្រើនជាងគេនៅកម្រិតសាលារៀនទី________។ដូច្នេះវា ជាកម្រិតអភិវឌ្ឍន៍សម្រាប់សមាសភាគនេះ ដែលត្រូវជាមួយស្ថានភាព/ការអនុវត្តរបស់សាលារៀនយើង ។

**ចំណុចខ្លាំង**

សមាសភាគរង/ប្រធានបទមួយចំនួនមានពិន្ទុខ្ពស់ជាងកម្រិតអភិវឌ្ឍន៍តាមសមាសភាគ (DDL)។ ដូច្នេះភាពខ្លាំងរបស់សមាសភាគរង/ប្រធានបទគឺ៖

---

(រៀបចំជាតារាងបញ្ជីសមាសភាគរង/ប្រធានបទដែលមានចំនួនសញ្ញា (✓) ច្រើនជាងនៅក្នុងកម្រិតអភិវឌ្ឍន៍ដែលបានកំណត់)

**ឱកាសសម្រាប់អភិវឌ្ឍ (ចំណុចខ្សោយ)៖**

សមាសភាគរង/ប្រធានបទមួយចំនួនមានពិន្ទុទាបជាងកម្រិតអភិវឌ្ឍន៍តាមសមាសភាគ (DDL)។ ដូច្នេះឱកាសសម្រាប់អភិវឌ្ឍ គឺស្ថិតនៅក្នុងសមាសភាគរង/ប្រធានបទដូចខាងក្រោម៖

---

(រៀបចំជាតារាងបញ្ជីសមាសភាគរង/ប្រធានបទដែលមានចំនួនសញ្ញា (✓) តិចជាងនៅក្នុងកម្រិតអភិវឌ្ឍន៍ដែលបានកំណត់)

## ជំហានទី២៖ ឧបករណ៍ស្វ័យវាយតម្លៃ
## សមាសភាគទី២៖ ការបង្រៀន និងរៀន

| | |
|---|---|
| **សមាសភាគទី២** | ការបង្រៀន និងរៀន |
| **អ្នកទទួលខុសត្រូវ** | សមាជិកបង្គោល ដែលទទួលខុសត្រូវសមាសភាគនេះត្រូវក្នុងការបំពេញឧបករណ៍ស្វ័យវាយតម្លៃ។ ពួកគាត់គួរតែស្នើសុំជាតុចូលពីសមាជិកគាំទ្រឬក៏បុគ្គលិកសាលារៀនដទៃទៀត។ |
| **សមាជិកបង្គោលសម្រាប់សមាសភាគនេះ** | |
| **ឆ្នាំទី** | ( ឧ. ឆ្នាំទី១៖ ឆ្នាំសិក្សា២០២៤-២០២៥ ) |
| **លំនាំដំណើរការ** | ក្របខណ្ឌអប់រំស្វែមកម្រិតសាលារៀនជួយសាលារៀន ដើម្បីកែលម្អការបង្រៀននិងការរៀនមុខវិជ្ជាស្វែមតាមរយៈដំណើរការ ៥ ជំហាន។ ឧបករណ៍ស្វ័យវាយតម្លៃរបស់ក្របខណ្ឌអប់រំស្វែមកម្រិតសាលារៀននេះគឺជាជំហានទី២ នៃដំណើរការទាំង៥ជំហាន។ ឧបករណ៍ស្វ័យវាយតម្លៃរបស់ក្របខណ្ឌអប់រំស្វែមកម្រិតសាលារៀន សម្រាប់សមាសភាគស្វែមទី២ គឺការបង្រៀន និងរៀន ដែលមានសមាសភាគរង៖<br>២.១ ការអភិវឌ្ឍវិជ្ជាជីវៈជាប្រចាំ<br>២.២ បំណិនឌីជីថល<br>២.៣ ការពង្រឹងកម្មវិធីសិក្សា<br>២.៤ ការបញ្ចូលបច្ចេកវិទ្យា<br>២.៥ ការជួយគាំទ្រសិស្ស<br>២.៦ ការផ្សារភ្ជាប់ទៅនឹងជីវភាពរស់នៅ<br>២.៧ វង្វាយតម្លៃ<br>២.៨ ការធ្វើអធិការកិច្ចផ្ទៃក្នុង<br>២.៩ សហគមន៍សិក្សាវិជ្ជាជីវៈ<br>២.១០ ការបង្រៀនការបង្រៀន<br><br> |

| | |
|---|---|
| **គោលបំណងរបស់ឧបករណ៍** | ឧបករណ៍ស្វ័យវាយតម្លៃនឹងជួយក្រុមអនុវត្តសកម្មភាពស្វែមរបស់សាលារៀនរបស់លោក លោកស្រីដើម្បីពិនិត្យមើលឡើងវិញការអនុវត្តស្វែម នាពេលបច្ចុប្បន្ន និងកំណត់កម្រិតនៃក្របខណ្ឌណាមួយដែលសមស្របបំផុតនឹងស្ថានភាពបច្ចុប្បន្នរបស់សាលារៀនលោក លោកស្រី។ ឧបករណ៍នេះនឹងជួយលោក លោកស្រីកំណត់ចំណុចដែលត្រូវយកចិត្តទុកដាក់ និងណែនាំលោក លោកស្រីក្នុងការកំណត់គោលដៅសម្រាប់អភិវឌ្ឍនាឆ្នាំខាងមុខ។ ឧបករណ៍នេះផងដែរបង្កើតឡើងមិនមែនក្នុងបំណងដើរតួជាឧបករណ៍វិនិច្ឆ័យ ឬវង្វាយតម្លៃនេះទេ។ លោក លោកស្រីត្រូវបានលើកទឹកចិត្តឱ្យធ្វើការឆ្លុះបញ្ចាំងដោយភាពស្មោះត្រង់លើការអនុវត្តរបស់សាលារៀនលោក លោកស្រី ដើម្បីធានាថាការផ្តល់អនុសាសន៍គឺសមស្របនឹងសមត្ថភាពសាលារៀន និងផ្តល់អត្ថប្រយោជន៍ដល់សាលារៀនលោក លោកស្រី។ |
| **ការណែនាំ** | 1. បោះពុម្ពឧបករណ៍ស្វ័យវាយតម្លៃដាក់នៅខាងក្រោយឯកសារ<br>2. បោះពុម្ពឧបករណ៍ស្វ័យវាយតម្លៃដាក់ ដែលនៅផ្នែកខាងក្រោយនៃក្របខណ្ឌ<br>3. បំពេញតារាងខាងក្រោម ដោយជ្រើសរើសចម្លើយស្របតាមសំណួរនីមួយៗនៅក្នុងសមាសភាគរង និងប្រធានបទ សូមឆ្លុះបញ្ចាំងដោយភាពស្មោះត្រង់លើស្ថានភាពនៃការអនុវត្តនៅសាលារៀនរបស់លោក លោកស្រី បន្ទាប់មក សូមកំណត់កម្រិតអភិវឌ្ឍន៍ដែលស័ក្តិសមបំផុត។ លោក លោកស្រីប្រហែលរកឃើញស្ថានភាពសាលារៀនក្នុងកម្រិតខុសៗគ្នា អាស្រ័យលើប្រធានបទ<br>4. ពិនិត្យមើលត្រង់ចំណុចសម្គាល់សម្រាប់សំណួរនីមួយៗ ដើម្បីផ្ទៀងផ្ទាត់ឡើងវិញទៅលើខ្លឹមសារណាដែលមិនច្បាស់<br>5. កត់ត្រាចម្លើយរបស់លោក លោកស្រីនៅលើឧបករណ៍ស្វ័យវាយតម្លៃនៅផ្នែកខាងក្រោយនៃក្របខណ្ឌ ដោយគូសសញ្ញា (✓) ដែលត្រូវនឹងស្ថានភាពបច្ចុប្បន្នរបស់សាលារៀន<br>6. នៅពេលគូសរួចរាល់ លោក លោកស្រីត្រូវបូកសរុបពិន្ទុដោយរាប់ចំនួនសញ្ញា (✓) នៅតាមកម្រិតនីមួយៗ<br>7. អនុវត្តតាមការណែនាំនៅផ្នែកខាងក្រោយនៃក្របខណ្ឌ ដើម្បីកំណត់កម្រិតអភិវឌ្ឍន៍តាមសមាសភាគ (DDL) សម្រាប់សមាសភាគនេះ (កម្រិត ដែលមានសញ្ញា (✓) ច្រើនជាងគេបំផុត) កំណត់បានចំណុចខ្លាំង និងកំណត់ចំណុចដែលត្រូវពង្រឹង។ |

| ២.១.១ | ២.១ ការអភិវឌ្ឍវិជ្ជាជីវៈជាប្រចាំ | | | | |
|---|---|---|---|---|---|
| | តើខ្លឹមសារមួយណាដែលសមស្របបំផុតជាមួយស្ថានភាពសាលារៀនរបស់លោក លោកស្រី? | | | | |
| | កម្រិតសាលារៀនទី១ | កម្រិតសាលារៀនទី២ | កម្រិតសាលារៀនទី៣ | កម្រិតសាលារៀនទី៤ | កម្រិតសាលារៀនទី៥ |
| លទ្ធភាពទទួលបានការអភិវឌ្ឍវិជ្ជាជីវៈជាប្រចាំ | គ្រូបង្រៀនស្ទែមរបស់យើង មិនទទួលបានឱកាស សម្រាប់ការអភិវឌ្ឍវិជ្ជាជីវៈ ជាប្រចាំ។ | គ្រូបង្រៀនស្ទែមរបស់យើង ទទួលបានឱកាសសម្រាប់ការ អភិវឌ្ឍវិជ្ជាជីវៈជាប្រចាំនៅ មានកម្រិត។ មានតែគ្រូ បង្រៀនស្ទែមដែលគេជ្រើស រើសប៉ុណ្ណោះបានចូលរួម ហើយធ្វើឡើងរាល់ ២ ឆ្នាំម្ដង។ | ទទួលបានឱកាសអភិវឌ្ឍវិជ្ជា ជីវៈជាប្រចាំបានគ្រប់គ្រាន់ សម្រាប់ប្រធានក្រុមមុខវិជ្ជា ស្ទែមក្នុងមួយឆ្នាំម្ដង។ | ទទួលបានឱកាសអភិវឌ្ឍវិជ្ជា ជីវៈជាប្រចាំបានគ្រប់គ្រាន់ សម្រាប់គ្រូបង្រៀនស្ទែមភាគ ច្រើនក្នុងមួយឆ្នាំម្ដង។ | ទទួលបានឱកាសអភិវឌ្ឍវិជ្ជាជីវៈ ជាប្រចាំបានពេញលេញសម្រាប់ គ្រូបង្រៀនស្ទែមទាំងអស់ យ៉ាង ហោចណាស់២ដងក្នុងមួយឆ្នាំ ជាមួយអ្នកឯកទេសលើប្រធានបទ បច្ចេកទេសជាក់លាក់ និងបច្ចេក វិទ្យានវានុវត្តន៍ (ឧ. ម៉ាស៊ីនពុម្ព 3D, ឧបករណ៍អេឡិចត្រូនិក។ល។)។ |
| កំណត់សម្គាល់ | ការអភិវឌ្ឍវិជ្ជាជីវៈជាប្រចាំ សំដៅដល់ការបណ្ដុះបណ្ដាលដែលផ្ដល់ដោយអ្នកមកពីខាងក្រៅសាលារៀន ឧ. ក្រសួងអប់រំ យុវជន និងកីឡា, វិទ្យាស្ថានជាតិអប់រំ, អង្គការ VSO, STEMEOC, STTC ។ល។<br>(ការបណ្ដុះបណ្ដាល ឬការបង្វឹកក្នុងសាលារៀន គឺធ្វើឡើងដោយគ្រូបង្វឹក ឬសហគមន៍សិក្សាវិជ្ជាជីវៈរបស់សាលារៀន) | | | | |

| ២.១.២ | តើខ្លឹមសារមួយណាដែលសមស្របបំផុតជាមួយស្ថានភាពសាលារៀនរបស់លោក លោកស្រី? | | | | |
|---|---|---|---|---|---|
| | កម្រិតសាលារៀនទី១ | កម្រិតសាលារៀនទី២ | កម្រិតសាលារៀនទី៣ | កម្រិតសាលារៀនទី៤ | កម្រិតសាលារៀនទី៥ |
| ខ្លឹមសារបណ្ដុះបណ្ដាល | គ្រូបង្រៀនស្ទែមរបស់យើង មិនទទួលបានឱកាស សម្រាប់ការអភិវឌ្ឍវិជ្ជាជីវៈ ជាប្រចាំ។ | ការបណ្ដុះបណ្ដាលស្ដីពីការ អភិវឌ្ឍវិជ្ជាជីវៈជាប្រចាំ ទទួល បានឱកាសចំពោះគ្រូបង្រៀន ដោយផ្ដោតជាសំខាន់លើ ជំនាញបច្ចេកទេសស្ទែមមួយ គត់ ដូចនេះគ្រូបង្រៀនយើង | ការបណ្ដុះបណ្ដាលស្ដីពីការ អភិវឌ្ឍវិជ្ជាជីវៈជាប្រចាំ រៀបចំឡើង ដើម្បីកសាង ទាំងជំនាញបច្ចេកទេសស្ទែម និងវិធីសាស្ត្របង្រៀនស្ទែម។ | ការបណ្ដុះបណ្ដាលស្ដីពីការ អភិវឌ្ឍវិជ្ជាជីវៈជាប្រចាំ រៀបចំ ឡើងដើម្បីកសាងជំនាញ បច្ចេកទេសស្ទែម និងវិធីសាស្ត្រ បង្រៀនស្ទែម។ | ការបណ្ដុះបណ្ដាលស្ដីពីការអភិវឌ្ឍ វិជ្ជាជីវៈជាប្រចាំ រៀបចំឡើងដើម្បី កសាងជំនាញបច្ចេកទេសស្ទែម និងវិធីសាស្ត្របង្រៀនស្ទែម។ |

| | | | | | |
|---|---|---|---|---|---|
| | | មិនយល់ដឹងអំពីវិធីសាស្ត្របង្រៀនស្នែម។ | | គ្រូបង្រៀនត្រូវបានប្រឹក្សាមុនពេលបណ្តុះបណ្តាល ដើម្បីកំណត់បានពីតម្រូវការ។ ការបណ្តុះបណ្តាលរៀបចំឡើងមុនពេលអនុវត្តក្នុងថ្នាក់រៀន។ | គ្រូបង្រៀនដើរតួនាទីយ៉ាងសកម្មក្នុងការអភិវឌ្ឍខ្លឹមសារបណ្តុះបណ្តាល ផ្តល់មតិកែលម្អ សាកល្បងសម្ភារបណ្តុះបណ្តាលថ្មី ផ្តល់យោបល់សម្រាប់ការកែលម្អ និងប្រធានបទថ្មីៗ។ |
| កំណត់សម្គាល់ | | | | | |
| ២.១.៣ | តើខ្លឹមសារមួយណាដែលសមស្របបំផុតជាមួយស្ថានភាពសាលារៀនរបស់លោក លោកស្រី? | | | | |
| | កម្រិតសាលារៀនទី១ | កម្រិតសាលារៀនទី២ | កម្រិតសាលារៀនទី៣ | កម្រិតសាលារៀនទី៤ | កម្រិតសាលារៀនទី៥ |
| ប្រធានបទពិសេស | គ្រូបង្រៀនស្នែមរបស់យើងមិនទទួលបានឱកាសសម្រាប់ការអភិវឌ្ឍវិជ្ជាជីវៈជាប្រចាំ។ | ការបណ្តុះបណ្តាលស្តីពីការអភិវឌ្ឍវិជ្ជាជីវៈជាប្រចាំ លុបចោលប្រធានបទដែលនឹងគាំទ្រដល់បរិយាកាសសុវត្ថិភាព និងអំណោយផលសម្រាប់សកម្មភាពពង្រឹងស្នែម (ឧ. សុវត្ថិភាពមន្ទីរពិសោធន៍ ការពង្រឹងវិទ្យាសាស្ត្រ។ល។) | ប្រធានបទដែលនឹងគាំទ្រដល់បរិយាកាសសុវត្ថិភាព និងអំណោយផលសម្រាប់សកម្មភាពពង្រឹងស្នែម (ឧ. សុវត្ថិភាពមន្ទីរពិសោធន៍ ការពង្រឹងវិទ្យាសាស្ត្រ។ល។) ត្រូវបានបញ្ចូលក្នុងការបណ្តុះបណ្តាលស្តីពីការអភិវឌ្ឍវិជ្ជាជីវៈជាប្រចាំ។ | ប្រធានបទដែលនឹងគាំទ្រដល់បរិយាកាសសុវត្ថិភាព និងអំណោយផលសម្រាប់សកម្មភាពពង្រឹងស្នែម (ឧ. សុវត្ថិភាពមន្ទីរពិសោធន៍ ការពង្រឹងវិទ្យាសាស្ត្រ។ល។) ត្រូវបានបញ្ចូលក្នុងការបណ្តុះបណ្តាលស្តីពីការអភិវឌ្ឍវិជ្ជាជីវៈជាប្រចាំ រួមជាមួយនឹងការបណ្តុះបណ្តាលសម្រាប់បរិក្ខារច្នៃប្រឌិត ដែលយើងអាចប្រើបាន (ឧ. ម៉ាស៊ីនបោះពុម្ព 3D, | ប្រធានបទដែលនឹងគាំទ្រដល់បរិយាកាសសុវត្ថិភាព និងអំណោយផលសម្រាប់សកម្មភាពពង្រឹងស្នែម (ឧ. សុវត្ថិភាពមន្ទីរពិសោធន៍ ការពង្រឹងវិទ្យាសាស្ត្រ។ល។) ត្រូវបានបញ្ចូលក្នុងការបណ្តុះបណ្តាលស្តីពីការអភិវឌ្ឍវិជ្ជាជីវៈជាប្រចាំ រួមជាមួយនឹងការបណ្តុះបណ្តាលសម្រាប់បរិក្ខារច្នៃប្រឌិត ដែលយើងអាចប្រើបាន (ឧ. ម៉ាស៊ីនបោះពុម្ព 3D, កញ្ចប់ឧបករណ៍គ្រឿងបង្គុំ ។ល។) |

| | | | | | |
|---|---|---|---|---|---|
| | | | | កញ្ចប់ឧបករណ៍គ្រឿងបង្គុំ ។ល។) | គ្រូបង្រៀនរបស់យើងដឹកនាំការអភិវឌ្ឍសម្ភារបណ្តុះបណ្តាលសម្រាប់ប្រធានបទទាំងនេះ។ |
| កំណត់សម្គាល់ | **ការពង្រឹងវិទ្យាសាស្ត្រ** ជាការប្រើប្រាស់សម្ភារប្រចាំថ្ងៃប្រកបដោយភាពច្នៃប្រឌិត ដើម្បីធ្វើការពិសោធបែបវិទ្យាសាស្ត្រ នៅពេលមិនមានសម្ភារពិសោធន៍ស្តង់ដា។ វាជំរុញការរៀនដោយអនុវត្តសកម្មភាពជាក់ស្តែង ការដោះស្រាយបញ្ហា និងការច្នៃប្រឌិតស្របតាមធនធានក្នុងស្រុក ដើម្បីស្វែងរកចំណេះដឹងវិទ្យាសាស្ត្រ។<br>**បរិក្ខារច្នៃប្រឌិត** ជាបរិក្ខារស្ទែមក្រៅពីបរិក្ខារពិសោធន៍ងាយៗ (ឧ. ម៉ាស៊ីនបោះពុម្ព 3D, កញ្ចប់ឧបករណ៍គ្រឿងបង្គុំ)។ | | | | |
| ២.១.៤ | **តើខ្លឹមសារមួយណាដែលសមស្របបំផុតជាមួយស្ថានភាពសាលារៀនរបស់លោក លោកស្រី?** | | | | |
| | **កម្រិតសាលារៀនទី១** | **កម្រិតសាលារៀនទី២** | **កម្រិតសាលារៀនទី៣** | **កម្រិតសាលារៀនទី៤** | **កម្រិតសាលារៀនទី៥** |
| គុណភាព | គ្រូបង្រៀនស្ទែមរបស់យើងមិនទទួលបានឱកាសសម្រាប់ការអភិវឌ្ឍវិជ្ជាជីវៈជាប្រចាំ។ | មិនមានប្រព័ន្ធតាមដាន ឬយន្តការផ្តល់មតិត្រឡប់ក្រោយការបណ្តុះបណ្តាលដើម្បីធានាថាការបណ្តុះបណ្តាលគឺមានភាពពាក់ព័ន្ធ និងមានប្រសិទ្ធភាព ព្រមទាំងចែករំលែកក្នុងកម្រិតសាលារៀន ឬអនុវត្តបានក្នុងថ្នាក់រៀន។ | មានយន្តការផ្តល់មតិត្រឡប់ដើម្បីធានាថាការបណ្តុះបណ្តាលគឺមានភាពពាក់ព័ន្ធ និងមានប្រសិទ្ធភាព។ តែមិនមានប្រព័ន្ធតាមដានដើម្បីធានាថា ខ្លឹមសារត្រូវបានចែករំលែកបន្តដល់ក្រុមគ្រូបង្រៀនស្ទែមនៅកម្រិតសាលារៀន ឬការអនុវត្តក្នុងថ្នាក់រៀន។ | មានយន្តការផ្តល់មតិត្រឡប់ដើម្បីធានាថាការបណ្តុះបណ្តាលគឺមានភាពពាក់ព័ន្ធ និងមានប្រសិទ្ធភាព។ លើសពីនេះមានប្រព័ន្ធតាមដាន ដើម្បីធានាថាការបណ្តុះបណ្តាលបានយកទៅអនុវត្តក្នុងថ្នាក់រៀនតែប្រព័ន្ធនេះមិនផ្លូវការទេ។ | មានយន្តការផ្តល់មតិត្រឡប់ដើម្បីធានាថាការបណ្តុះបណ្តាលគឺមានភាពពាក់ព័ន្ធនិងមានប្រសិទ្ធភាព។ លើសពីនេះមានប្រព័ន្ធតាមដានផ្លូវការ មានការកត់ត្រា និងអនុវត្តជាប្រចាំ ដើម្បីធានាថាការបណ្តុះបណ្តាលបានយកទៅអនុវត្តក្នុងថ្នាក់រៀន។ |
| កំណត់សម្គាល់ | **សម្គាល់៖** ជាការល្អប្រសើរបំផុត អ្នកផ្តល់ការបណ្តុះបណ្តាលស្តីពីការអភិវឌ្ឍវិជ្ជាជីវៈជាប្រចាំ មកពីខាងក្រៅសាលារៀនគួរតែបញ្ជ្រាបយន្តការផ្តល់មតិត្រឡប់ និងប្រព័ន្ធតាមដាននៅក្នុងការបណ្តុះបណ្តាល។ ទោះបីជា សាលារៀនត្រូវធានាថាការបណ្តុះបណ្តាលត្រូវបានចែករំលែក និងអនុវត្តបន្តដល់គ្រូបង្រៀនស្ទែមដទៃទៀត។ | | | | |

| ២.១.៥ | តើខ្លឹមសារមួយណាដែលសមស្របបំផុតជាមួយស្ថានភាពសាលារៀនរបស់លោក លោកស្រី? | | | | |
|---|---|---|---|---|---|
| | កម្រិតសាលារៀនទី១ | កម្រិតសាលារៀនទី២ | កម្រិតសាលារៀនទី៣ | កម្រិតសាលារៀនទី៤ | កម្រិតសាលារៀនទី៥ |
| ការឆ្លើយតបនឹងយេនឌ័រ | មិនមានឱកាសសម្រាប់ទទួលបានការបណ្តុះបណ្តាលគរុកោសល្យដែលទាក់ទងនឹងការឆ្លើយតបនឹងយេនឌ័រនោះទេ។ | យ៉ាងហោចណាស់មានគ្រូបង្រៀនម្នាក់បានចូលរួមមួយថ្ងៃ នៅក្នុងការបណ្តុះបណ្តាលគរុកោសល្យដែលទាក់ទងនឹងការឆ្លើយតបនឹងយេនឌ័រ ហើយបានចែករំលែកមេរៀន និងសម្ភារសំខាន់ៗនៃវគ្គបណ្តុះបណ្តាលដល់គ្រូបង្រៀនដទៃទៀត។ | ប្រធានក្រុមមុខវិជ្ជាស្នែមទាំងអស់បានចូលរួមមួយថ្ងៃ នៅក្នុងការបណ្តុះបណ្តាលគរុកោសល្យដែលទាក់ទងនឹងការឆ្លើយតបនឹងយេនឌ័រ ហើយបានចែករំលែកមេរៀន និងសម្ភារសំខាន់ៗនៃវគ្គបណ្តុះបណ្តាលដល់ក្រុមគ្រូបង្រៀនស្នែម។ | ប្រធានក្រុមមុខវិជ្ជាស្នែមទាំងអស់បានចូលរួមជាច្រើនថ្ងៃ នៅក្នុងការបណ្តុះបណ្តាលគរុកោសល្យដែលទាក់ទងនឹងការឆ្លើយតបនឹងយេនឌ័រ ហើយផ្តោតទៅលើបញ្ហាយេនឌ័រដែលកើតមាននៅក្នុងថ្នាក់រៀនស្នែម។ | មានគ្រប់លក្ខខណ្ឌពីមុន បូករួមទាំងគណៈគ្រប់គ្រងសាលារៀនក៏បានទទួលការបណ្តុះបណ្តាលផងដែរ។ ប្រព័ន្ធតាមដានត្រូវបានដាក់ឱ្យដំណើរការ ដើម្បីធានាថាការបណ្តុះបណ្តាលកំពុងត្រូវបានយកទៅអនុវត្តនៅក្នុងថ្នាក់រៀន។ |
| កំណត់សម្គាល់ | ការបណ្តុះបណ្តាលគរុកោសល្យដែលឆ្លើយតបនឹងយេនឌ័រ គួរតែរួមបញ្ចូលគ្នានូវសកម្មភាពចូលរួម ការប្រើប្រាស់បច្ចេកវិទ្យា ការពិភាក្សាជាក្រុម និងការឆ្លុះបញ្ចាំងផ្ទាល់ខ្លួន។ ម៉ូឌុលគំរូ៖ ការមិនបានសិក្សាពីផ្នត់គំនិតយេនឌ័រជាឧបសគ្គចំពោះការអប់រំស្នែម ការប្រើប្រាស់ភាសាមិនលំអៀងចំពោះយេនឌ័រនៅក្នុងថ្នាក់រៀនស្នែម ការកំណត់ធនធានស្នែមឆ្លើយតបនឹងយេនឌ័រ។ | | | | |

| ២.២.១ | ២.២ បំណិនឌីជីថល | | | | |
|---|---|---|---|---|---|
| | គ្រូបង្រៀនស្វែមរបស់យើង | | | | |
| | កម្រិតសាលារៀនទី១ | កម្រិតសាលារៀនទី២ | កម្រិតសាលារៀនទី៣ | កម្រិតសាលារៀនទី៤ | កម្រិតសាលារៀនទី៥ |
| បំណិនឌីជីថល | គ្រូបង្រៀននៅខ្វះជំនាញឌីជីថលមូលដ្ឋាន លើសពីការប្រើប្រាស់ទូរសព្ទឬកម្មវិធីជជែក ឬកម្មវិធី Facebook។ ពួកគាត់ខិតខំប្រើប្រាស់កុំព្យូទ័រ ការស្វែងរកទិន្នន័យតាមអ៊ីនធឺណិត ការបង្កើត ឬកែសម្រួលឯកសារឌីជីថល។ គ្រូបង្រៀននៅមិនទាន់មានសមត្ថភាពក្នុងការស្វែងរក និងវាយតម្លៃធនធានអនឡាញសម្រាប់ប្រើប្រាស់ក្នុងថ្នាក់រៀននៅឡើយ។ | គ្រូបង្រៀនមានជំនាញឌីជីថលមូលដ្ឋាន។ ពួកគាត់មានសមត្ថភាពប្រើប្រាស់ទូរសព្ទឆ្លាតវៃ និងកម្មវិធីជជែក ហើយអាចប្រើប្រាស់កុំព្យូទ័រ អ៊ីនធឺណិត ឬបង្កើត ឬ កែសម្រួលឯកសារ។ ទោះបីជាយ៉ាងពួកគាត់នៅខ្វះទំនុកចិត្ត។ ពួកគាត់មានអារម្មណ៍មិនងាយស្រួលក្នុងការស្វែងរកទិន្នន័យ និងវាយតម្លៃធនធានអនឡាញសម្រាប់ប្រើប្រាស់ក្នុងថ្នាក់រៀននៅឡើយនោះទេ។ | គ្រូបង្រៀនមានជំនាញឌីជីថលគ្រប់គ្រាន់។ ពួកគាត់មានទំនុកចិត្តក្នុងការប្រើប្រាស់ទូរសព្ទឆ្លាតវៃ កុំព្យូទ័រ ការប្រើប្រាស់អ៊ីនធឺណិត អ៊ីមែល និងកម្មវិធីជជែកផ្សេងទៀត។ គ្រូបង្រៀនអាចបង្កើត ឬកែសម្រួលឯកសារឌីជីថល និងតារាង Excel និងប្រើប្រាស់កម្មវិធីអប់រំ ឬអែបអប់រំ។ ពួកគាត់អាចស្វែងរក និងវាយតម្លៃធនធានលើអ៊ីនធឺណិតបាន។ | គ្រូបង្រៀនមានជំនាញក្នុងការប្រើប្រាស់ទូរសព្ទឆ្លាតវៃ កុំព្យូទ័រ ការប្រើប្រាស់អ៊ីនធឺណិត អ៊ីមែល និងកម្មវិធីជជែក។ ពួកគាត់អាចបង្កើត និងកែសម្រួលឯកសារឬតារាង Excel ជាលក្ខណៈឌីជីថល ការប្រើប្រាស់កម្មវិធីអប់រំ ឬអែបអប់រំ ព្រមជាមួយការស្វែងរក និងវាយតម្លៃធនធានលើអ៊ីនធឺណិតប្រកបដោយប្រសិទ្ធភាព។ គ្រូបង្រៀនយល់ដឹងពីនិន្នាការកើនឡើងនៃការប្រើប្រាស់ឧបករណ៍ AI ក្នុងការអប់រំ ហើយស្គាល់ពីបច្ចេកទេសដោះស្រាយបញ្ហាជាមូលដ្ឋាន។ | គ្រូបង្រៀនមានជំនាញល្អប្រសើរបំផុតក្នុងការប្រើប្រាស់កុំព្យូទ័រ ការការប្រើប្រាស់អ៊ីនធឺណិត អ៊ីមែល និងកម្មវិធីជជែក។ ពួកគាត់អាចបង្កើត និងកែសម្រួលឯកសារឬតារាង Excel ជាលក្ខណៈឌីជីថល ប្រើប្រាស់កម្មវិធីអប់រំ ឬអែបអប់រំ ព្រមជាមួយការស្វែងរក និងវាយតម្លៃធនធានលើអ៊ីនធឺណិតប្រកបដោយប្រសិទ្ធភាព។ គ្រូបង្រៀនដឹងពីនិន្នាការកើនឡើងនៃការប្រើប្រាស់ឧបករណ៍ AI ក្នុងការអប់រំ ហើយស្គាល់ពីបច្ចេកទេសដោះស្រាយបញ្ហាងាយៗ ព្រមជាមួយការយល់ដឹងពីសុវត្ថិភាពឌីជីថល និងគោលការណ៍សុវត្ថិភាព។ |
| កំណត់សម្គាល់ | | | | | |

| ២.៣.១ | ២.៣ ការពង្រឹងកម្មវិធីសិក្សា | | | | |
|---|---|---|---|---|---|
| | សាលារៀនរបស់យើង៖ | | | | |
| | កម្រិតសាលារៀនទី១ | កម្រិតសាលារៀនទី២ | កម្រិតសាលារៀនទី៣ | កម្រិតសាលារៀនទី៤ | កម្រិតសាលារៀនទី៥ |
| សម្ភារគាំទ្រ | មិនមានលទ្ធភាពទទួលបានសម្ភារគាំទ្រដែលជួយសម្រួលដល់ការពង្រឹងកម្មវិធីសិក្សាតាមរយៈការអនុវត្តតាមបែបស្ទែមទេ។ | មានលទ្ធភាពទទួលបានសម្ភារគាំទ្រដែលជួយសម្រួលដល់ការពង្រឹងកម្មវិធីសិក្សាតាមរយៈការអនុវត្តតាមបែបស្ទែម តែកម្រប្រើ។ | មានលទ្ធភាពទទួលបានសម្ភារគាំទ្រ ហើយប្រើប្រាស់ម្តងម្កាលនូវសម្ភារគាំទ្រដែលជួយសម្រួលដល់ការពង្រឹងកម្មវិធីសិក្សាតាមរយៈការអនុវត្តតាមបែបស្ទែម។ | ប្រើប្រាស់ជាប្រចាំនូវសម្ភារគាំទ្រដែលជួយសម្រួលដល់ការពង្រឹងកម្មវិធីសិក្សាតាមរយៈការអនុវត្តតាមបែបស្ទែម។ ទាំងនេះរួមមានផែនទីកម្មវិធីសិក្សាដែលពង្រឹងការអប់រំស្ទែម បំណែងចែកកម្មវិធីសិក្សា និងកិច្ចតែងការ ដែលរៀបរាប់លម្អិតអំពីឱកាសសម្រាប់ការអនុវត្តចំណេះដឹងស្ទែមទៅក្នុងជីវភាពរស់នៅ។ | ដើរតួនាទីយ៉ាងសកម្មក្នុងការអភិវឌ្ឍន៍សម្ភារដើម្បីគាំទ្រដល់ការពង្រឹងកម្មវិធីសិក្សាតាមរយៈការអនុវត្តតាមបែបស្ទែម។ សម្ភារទាំងនេះត្រូវបានប្រើប្រាស់ជាប្រចាំផ្អែកលើផែនការ និងកម្មវិធីសិក្សាដែលបានកំណត់ ហើយត្រូវបានចែករំលែកទៅសាលារៀនផ្សេងទៀតតាមរយៈសហគមន៍សិក្សាវិជ្ជាជីវៈ។ |
| កំណត់សម្គាល់ | ឧទាហរណ៍នៃសម្ភារគាំទ្រ៖ ផែនទីកម្មវិធីសិក្សាដែលពង្រឹងការអប់រំស្ទែម បំណែងចែកកម្មវិធីសិក្សា និងកិច្ចតែងការ ដែលរៀបរាប់លម្អិតអំពីឱកាសសម្រាប់ការអនុវត្តចំណេះដឹងស្ទែមទៅក្នុងជីវភាពរស់នៅ។ | | | | |
| ២.៣.២ | នៅក្នុងសាលារៀនរបស់យើង៖ | | | | |
| | កម្រិតសាលារៀនទី១ | កម្រិតសាលារៀនទី២ | កម្រិតសាលារៀនទី៣ | កម្រិតសាលារៀនទី៤ | កម្រិតសាលារៀនទី៥ |

| | | | | | |
|---|---|---|---|---|---|
| ការបញ្ចូលខ្លឹមសារស្ទែម | មុខវិជ្ជាស្ទែមតែងតែត្រូវបានបង្រៀនជាមុខវិជ្ជាដាច់ដោយឡែក។ | ខ្លឹមសារនៃមុខវិជ្ជាស្ទែមត្រូវបានបញ្ចូលជាបន្តបន្ទាប់គ្នានៅក្នុងចំណោមមុខវិជ្ជាស្ទែមតាមរយៈសកម្មភាពសិក្សាបែបរិះរក។ ម្តងក្នុងមួយត្រីមាស។ | ខ្លឹមសារនៃមុខវិជ្ជាស្ទែមត្រូវបានបញ្ចូលម្តងម្កាល និងដោយមានគោលបំណងនៅក្នុងចំណោមមុខវិជ្ជាស្ទែមតាមរយៈសកម្មភាពសិក្សាបែបរិះរកយ៉ាងហោចណាស់ពីរដងក្នុងមួយត្រីមាស។ | ខ្លឹមសារនៃមុខវិជ្ជាស្ទែមត្រូវបានបញ្ចូលជាទៀងទាត់ និងដោយមានគោលបំណងជាមួយនឹងការធ្វើផែនការសំខាន់ៗក្នុងចំណោមមុខវិជ្ជាស្ទែម ដោយប្រើវិធីសាស្ត្រអន្តរកម្មមុខវិជ្ជា សម្រាប់មេរៀនភាគច្រើននៃមុខវិជ្ជាស្ទែម។ | ការបញ្ចូលខ្លឹមសារនៃមុខវិជ្ជាស្ទែមមានមានគោលបំណង និងស្របគ្នាលើមុខវិជ្ជាស្ទែម។ ការបង្រៀនខិតខំឆ្ពោះទៅរកការសម្រេចបាននូវវិធីសាស្ត្របង្កើតមុខវិជ្ជាថ្មីកើតពីបន្សំមុខវិជ្ជាច្រើន ជាមួយនឹងការរួមបញ្ចូលម្តងម្កាលនៃខ្លឹមសារមុខវិជ្ជាមិនមែនស្ទែម ។ |
| កំណត់សម្គាល់ | ការបញ្ចូលខ្លឹមសារស្ទែម នៅក្នុងសមាសភាគរងនេះសំដៅលើការរួមបញ្ចូលដោយមានគោលបំណង និងគម្រោងនៃការបញ្ចូលមុខវិជ្ជាស្ទែម ខុសពីការជាន់គ្នាពីធម្មជាតិ ដែលកើតឡើងនៅពេលបង្រៀន ឬរៀនមុខវិជ្ជាទាំងនេះជាមួយនឹងវិធីសាស្ត្រប្រពៃណី។<br>ការសិក្សាបែបរិះរក៖ វិធីសាស្ត្រនៃការអប់រំដែលផ្តោតលើការសាកសួរ ការរុករក និងការអង្កេត។ វាពាក់ព័ន្ធនឹងសិស្សចូលរួមយ៉ាងសកម្មក្នុងដំណើរការសិក្សា ដោយការសួរសំណួរ ធ្វើការស្រាវជ្រាវ និងការដោះស្រាយបញ្ហា ជាជាងការទទួលព័ត៌មានដោយអសកម្ម។ វិធីសាស្ត្រនេះលើកទឹកចិត្តដល់ការគិតបែបពិភាក្សា ភាពច្នៃប្រឌិត និងការយល់ដឹងកាន់តែស៊ីជម្រៅអំពីប្រធានបទ។ ឧទាហរណ៍៖ គម្រោង ឬការសិក្សាផ្អែកលើបញ្ហា។ | | | | |
| ២.៣.៣ | **នៅក្នុងសាលារៀនរបស់យើង៖** | | | | |
| | **កម្រិតសាលារៀនទី១** | **កម្រិតសាលារៀនទី២** | **កម្រិតសាលារៀនទី៣** | **កម្រិតសាលារៀនទី៤** | **កម្រិតសាលារៀនទី៥** |
| បទពិសោធន៍រៀនស្ទែមជាក់ស្តែង | គ្រូបង្រៀនរបស់យើងមិនបញ្ចូលបទពិសោធន៍រៀនស្ទែមជាក់ស្តែង ដើម្បីពង្រឹងកម្មវិធីសិក្សាស្ទែមដែលមានស្រាប់នោះទេ។ | គ្រូបង្រៀនរបស់យើងកម្រពង្រឹងកម្មវិធីសិក្សាស្ទែមដែលមានស្រាប់ដោយបញ្ចូលបទពិសោធន៍រៀនស្ទែមជាក់ស្តែង។ | គ្រូបង្រៀនរបស់យើងម្តងម្កាលពង្រឹងកម្មវិធីសិក្សាស្ទែមដែលមានស្រាប់ដោយបញ្ចូលបទពិសោធន៍សិក្សាស្ទែមជាក់ស្តែងដែលស្របតាមខ្លឹមសារកម្មវិធីសិក្សា។ | គ្រូបង្រៀនរបស់យើងពង្រឹងជាប្រចាំនូវកម្មវិធីសិក្សាស្ទែមដែលមានស្រាប់ដោយបញ្ចូលបទពិសោធន៍សិក្សាស្ទែមជាក់ស្តែងដែលស្របតាមខ្លឹមសារកម្មវិធីសិក្សា។ | គ្រូបង្រៀនរបស់យើងពង្រឹងជាប់លាប់នូវកម្មវិធីសិក្សាស្ទែមដែលមានស្រាប់ដោយបញ្ចូលបទពិសោធន៍សិក្សាស្ទែមជាក់ស្តែង ដែលស្របតាមខ្លឹមសារកម្មវិធីសិក្សា។ |

| | | | | | |
|---|---|---|---|---|---|
| កំណត់សម្គាល់ | បទពិសោធន៍រៀនជាក់ស្តែងជាសកម្មភាព ឬគម្រោងដែលអនុញ្ញាតឱ្យសិស្សចូលរួមក្នុងការអនុវត្តជាក់ស្តែងនិងផ្សារភ្ជាប់ទៅក្នុងជីវភាពរស់នៅនៃបញ្ញត្តិរបស់ស្ទែម។ ជាឧទាហរណ៍ ដូចជា ការសិក្សាបែបគម្រោង ឬការសិក្សាផ្អែកលើបញ្ហា ការរចនានិងការបង្កើតគំរូ ព្រមទាំងសហការជាមួយអ្នកដទៃ គម្រោងសហគមន៍ ការយល់ដឹងពីជំនាញស្ទែម និងឧស្សាហកម្មស្ទែម។ | | | | |
| ២.៣.៤ | **គ្រូបង្រៀនរបស់យើង៖** | | | | |
| | **កម្រិតសាលារៀនទី១** | **កម្រិតសាលារៀនទី២** | **កម្រិតសាលារៀនទី៣** | **កម្រិតសាលារៀនទី៤** | **កម្រិតសាលារៀនទី៥** |
| ការសម្របតាមសមត្ថភាពសិស្ស | មិនបានញែកកម្មវិធីសិក្សាមុខវិជ្ជាស្ទែមដើម្បីបំពេញតម្រូវការរបស់សិស្សទាំងអស់។ សិស្សទាំងអស់ទទួលបានខ្លឹមសារមេរៀនដូចគ្នា ប្រើប្រាស់ធនធានដូចគ្នា និងល្បឿននៃការបង្រៀនដូចគ្នា។ | កម្រនឹងញែកកម្មវិធីសិក្សាមុខវិជ្ជាស្ទែម ដើម្បីបំពេញតម្រូវការរបស់សិស្សទាំងអស់។ សិស្សទាំងអស់ទទួលបានខ្លឹមសារមេរៀនដូចគ្នា ប្រើប្រាស់ធនធានដូចគ្នា និងល្បឿននៃការបង្រៀនដូចគ្នា។ |ម្តងម្កាលញែកកម្មវិធីសិក្សាមុខវិជ្ជាស្ទែមខុសៗគ្នា ដើម្បីបំពេញតម្រូវការរបស់សិស្សទាំងអស់ ដោយកែសម្រួលវិធីសាស្ត្របង្រៀន សម្ភារ និងធនធានដើម្បីសម្រួលដល់របៀបរៀនសូត្ររបស់សិស្ស សមត្ថភាព និងចំណាប់អារម្មណ៍ខុសៗគ្នារបស់សិស្ស។ | តែងតែញែកកម្មវិធីសិក្សាមុខវិជ្ជាស្ទែម ដើម្បីបំពេញតម្រូវការរបស់សិស្សទាំងអស់ ដោយកែសម្រួលវិធីសាស្ត្របង្រៀន សម្ភារ និងធនធានដើម្បីសម្រួលដល់របៀបរៀនសូត្ររបស់សិស្ស សមត្ថភាព និងចំណាប់អារម្មណ៍ខុសៗគ្នារបស់សិស្ស។ | រៀបចំបញ្ជីព័ត៌មានសិស្សដើម្បីកំណត់ពីតម្រូវការ ដោយគោលបំណងញែកកម្មវិធីសិក្សាមុខវិជ្ជាស្ទែមមានភាពខុសប្លែកគ្នាតាមតម្រូវការរបស់សិស្សទាំងអស់ ដោយកែសម្រួលវិធីសាស្ត្របង្រៀន សម្ភារ និងធនធានដើម្បីសម្រួលដល់របៀបរៀនសូត្ររបស់សិស្ស សមត្ថភាព និងចំណាប់អារម្មណ៍ខុសៗគ្នារបស់សិស្ស។ |
| | **តើខ្លឹមសារមួយណាដែលសមស្របបំផុតជាមួយស្ថានភាពសាលារៀនរបស់លោក លោកស្រី?** | | | | |
| | **កម្រិតសាលារៀនទី១** | **កម្រិតសាលារៀនទី២** | **កម្រិតសាលារៀនទី៣** | **កម្រិតសាលារៀនទី៤** | **កម្រិតសាលារៀនទី៥** |
| **ការគ្រប់គ្រងទិន្នន័យ** | សាលារៀនរក្សាទិន្នន័យផ្តោតលើក្រដាសជាចម្បង។ | សាលារៀនរក្សាទិន្នន័យដោយកត់ត្រាទុកនៅលើក្រដាសផង និងឯកសារឌីជីថលផង (ទម្រង់ Excel)។ | ទិន្នន័យរបស់សាលារៀនត្រូវបានរក្សាទុកជាតារាង (ទម្រង់ Excel)។ នៅពេលសាលារៀនតម្រូវការប្រើប្រាស់ ឬចង់មានប្រព័ន្ធឌីជីថល EMIS  សាលារៀនមិនទាន់មានជំនាញគ្រប់គ្រាន់សម្រាប់គ្រប់គ្រងវាបានឡើយ។ | សាលារៀនចង់មានប្រព័ន្ធឌីជីថល SIS ឬ EMIS ហើយសាលារៀនមានជំនាញគ្រប់គ្រាន់សម្រាប់គ្រប់គ្រងវាបាន។ | សាលារៀនត្រៀមខ្លួនរួចជាស្រេច និងរង់ចាំតែដាក់ឱ្យអនុវត្តលើប្រព័ន្ធឌីជីថល SIS ឬ EMIS ហើយមានឆន្ទៈគាំទ្រទៅដល់  ការអនុវត្តនៅតាមសាលារៀនដទៃទៀតតាមរយៈសហគមន៍សិក្សាវិជ្ជាជីវៈ។ |
| **កំណត់សម្គាល់** | | | | | |
| ៣.៦.២ | **តើខ្លឹមសារមួយណាដែលសមស្របបំផុតជាមួយស្ថានភាពសាលារៀនរបស់លោក លោកស្រី?** | | | | |
| | **កម្រិតសាលារៀនទី១** | **កម្រិតសាលារៀនទី២** | **កម្រិតសាលារៀនទី៣** | **កម្រិតសាលារៀនទី៤** | **កម្រិតសាលារៀនទី៥** |
| **ទិន្នន័យតាមក្រុម** | សាលារៀនមិនបានកត់ត្រាទិន្នន័យតាមក្រុម (ភេទ ឬតាមក្រុមណាមួយ) | សាលារៀនកត់ត្រាទិន្នន័យតាមក្រុមបានតិចតួច ដោយត្រឹមតែបំពេញតម្រូវការរបស់ក្រសួងសព្វថ្ងៃ (ប្រព័ន្ធ SIS)។ | សាលារៀនទទួលស្គាល់តម្រូវការចាំបាច់សម្រាប់ការធ្វើឱ្យប្រសើរឡើងទិន្នន័យតាមក្រុមដើម្បីអាចធ្វើការសម្រេចចិត្តឱ្យចំគោលដៅ និងបើកចំហដល់ការកត់ត្រាទិន្នន័យគ្រប់ជ្រុង | សាលារៀនទទួលស្គាល់តម្រូវការចាំបាច់សម្រាប់ការធ្វើឱ្យប្រសើរឡើងទិន្នន័យតាមក្រុមដើម្បីអាចធ្វើការសម្រេចចិត្តឱ្យចំគោលដៅ ហើយអាចរៀបចំនិងមានសមត្ថភាពបំពេញ | សាលារៀនប្រើប្រាស់ប្រព័ន្ធ SIS របស់ខ្លួន ដើម្បីប្រមូលទិន្នន័យតាមក្រុមបានគ្រប់ជ្រុងជ្រោយ រួមមាន ភេទ ឬតាមក្រុមណាមួយ។ ពួកគាត់នឹងលើកកម្ពស់ការ |

| | | | | | |
|---|---|---|---|---|---|
| | | | ជ្រោយ។ តែសាលារៀននៅខ្វះ ជំនាញឌីជីថលសម្រាប់បំពេញ ការងារនេះ។ | ការងារនេះបាន បើសិនមានប្រព័ន្ធទិន្នន័យសម ស្រប។ | អនុវត្តឱ្យបានសកម្ម ជម្រុញ សាលារៀនដទៃទៀតឱ្យ អនុវត្តផងដែរ តាមរយៈសហគមន៍សិក្សាវិជ្ជាជីវៈ។ សាលារៀនត្រៀមខ្លួនរួចជាស្រេច ក្នុងការ អនុវត្តប្រព័ន្ធឌីជីថល EMIS។ |
| **កំណត់សម្គាល់** | | | | | |

| | | | | | |
|---|---|---|---|---|---|
| ៣.៧.១ | ៣.៧ ការវាយតម្លៃ | | | | |
| | តើខ្លឹមសារមួយណាដែលសមស្របបំផុតជាមួយស្ថានភាពសាលារៀនរបស់លោក លោកស្រី ? | | | | |
| | កម្រិតសាលារៀនទី១ | កម្រិតសាលារៀនទី២ | កម្រិតសាលារៀនទី៣ | កម្រិតសាលារៀនទី៤ | កម្រិតសាលារៀនទី៥ |
| ការវាយតម្លៃការងារបុគ្គលិក | សាលារៀនមិនមានការវាយតម្លៃគ្រូ និងបុគ្គលិកទេ។ | សាលារៀនមានការវាយតម្លៃការងារបុគ្គលិកដោយគណនាយកតែមួយភាគី។ | សាលារៀនមានការវាយតម្លៃការងារបុគ្គលិកដោយគណនាយក និងការស្វ័យវាយតម្លៃដោយគ្រូផ្ទាល់។ | សាលារៀនមានរៀបចំនីតិវិធីការវាយតម្លៃការងារបុគ្គលិកដោយគណនាយក គ្រូគាំទ្រ និងការស្វ័យវាយតម្លៃដោយគ្រូផ្ទាល់។ | សាលារៀនមានរៀបចំនីតិវិធីការវាយតម្លៃការងារបុគ្គលិកដោយគណនាយក គ្រូគាំទ្រ ការស្ទង់មតិពីសិស្ស និងការស្វ័យវាយតម្លៃដោយគ្រូផ្ទាល់។ |
| កំណត់សម្គាល់ | | | | | |
| ៣.៧.២ | តើខ្លឹមសារមួយណាដែលសមស្របបំផុតជាមួយស្ថានភាពសាលារៀនរបស់លោក លោកស្រី ? | | | | |
| | កម្រិតសាលារៀនទី១ | កម្រិតសាលារៀនទី២ | កម្រិតសាលារៀនទី៣ | កម្រិតសាលារៀនទី៤ | កម្រិតសាលារៀនទី៥ |
| ការរៀបចំតេស្តស្តង់ដា | សាលារៀនមិនបានរៀបចំតេស្តស្តង់ដាសម្រាប់សិស្ស។ | សាលារៀនបានរៀបចំតេស្ត តែមិនបានគិតពីស្តង់ដា។ | សាលារៀនបានរៀបចំតេស្តស្តង់ដា តែមិនបានវាយតម្លៃលទ្ធផលក្រោយទទួលបានលទ្ធផលតេស្ត។ | សាលារៀនបានរៀបចំតេស្តស្តង់ដា និងបានវាយតម្លៃលទ្ធផលក្រោយទទួលបានលទ្ធផលតេស្ត។ | សាលារៀនបានរៀបចំតេស្តស្តង់ដា និងបានវាយតម្លៃលទ្ធផលក្រោយទទួលបានលទ្ធផលតេស្ត។ បន្ទាប់មក |

| | | | | | |
|---|---|---|---|---|---|
| | | | | | យកការវាយតម្លៃទៅរៀបចំផែនការបន្ត សម្រាប់ការអភិវឌ្ឍ។ |
| កំណត់សម្គាល់ | | | | | |

| ៣.៨.១ | ៣.៨ ការទទួលស្គាល់ពីថ្នាក់ជាតិ | | | | |
|---|---|---|---|---|---|
| | សាលារៀនរបស់យើង | | | | |
| | កម្រិតសាលារៀនទី១ | កម្រិតសាលារៀនទី២ | កម្រិតសាលារៀនទី៣ | កម្រិតសាលារៀនទី៤ | កម្រិតសាលារៀនទី៥ |
| ការវាយតម្លៃសាលាប្រចាំឆ្នាំ | មិនមានការរៀបចំការវាយតម្លៃសាលាប្រចាំឆ្នាំ។ | បានរៀបចំការវាយតម្លៃប្រចាំឆ្នាំដោយប្រើប្រាស់លទ្ធផលការសិក្សាសិស្សជាប្រចាំ។ | បានរៀបចំវាយតម្លៃប្រចាំឆ្នាំដោយពិនិត្យមើលលទ្ធផលការសិក្សា និងការងារបុគ្គលិក។ | បានរៀបចំសូចនាករ និងការវាយតម្លៃប្រចាំឆ្នាំដោយមានការចូលរួមពីភាគីពាក់ព័ន្ធ។ | បានរៀបចំសូចនាករ និងការវាយតម្លៃប្រចាំឆ្នាំដោយមានការចូលរួមពីភាគីពាក់ព័ន្ធ ថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ។ |
| កំណត់សម្គាល់ | | | | | |

## ឧបករណ៍ស្វ័យវាយតម្លៃ

## សមាសភាគទី៣ ៖ អភិបាលកិច្ចសាលារៀន

សូមពិនិត្យបច្ចុប្បន្នភាពនៃស្ថានភាពសាលារៀនតាមសំណួរ ឬការពិពណ៌នារបស់ឧបករណ៍ស្វ័យវាយតម្លៃនៅក្នុងតារាងខាងក្រោមនេះដោយគូសសញ្ញា (✓) ក្នុងជួរឈរ ដែលត្រូវជាមួយស្ថានភាពសាលារៀនលោក លោកស្រី។

| ល.រ | សមាសភាគ | ល.រ | សមាសភាគរង | ល.រ | ប្រធានបទ | កម្រិតសាលារៀនទី១ | កម្រិតសាលារៀនទី២ | កម្រិតសាលារៀនទី៣ | កម្រិតសាលារៀនទី៤ | កម្រិតសាលារៀនទី៥ |
|---|---|---|---|---|---|---|---|---|---|---|
| ៣ | អភិបាលកិច្ចសាលារៀន | ៣.១ | វប្បធម៌ស្វែម | ៣.១.១ | ឥរិយាបថ និងការប្ដេជ្ញាចិត្ត៖ របៀបវារៈស្វែម | | | | | |
| | | | | ៣.១.២ | ឥរិយាបថ និងការប្ដេជ្ញាចិត្ត៖ ទំនាក់ទំនង | | | | | |
| | | | | ៣.១.៣ | ឥរិយាបថ និងការប្ដេជ្ញាចិត្ត៖ បុគ្គលិក | | | | | |
| | | ៣.២ | ភាពជាអ្នកដឹកនាំសាលារៀន | ៣.២.១ | ការយល់ដឹង | | | | | |
| | | | | ៣.២.២ | តួនាទី | | | | | |
| | | | | ៣.២.៣ | ការគ្រប់គ្រងទីកន្លែងនៅក្នុងសាលារៀន | | | | | |
| | | | | ៣.២.៤ | ការគ្រប់គ្រងពេលវេលា | | | | | |
| | | | | ៣.២.៥ | បំណិនឌីជីថល និងបញ្ញាសិប្បនិម្មិត | | | | | |
| | | | | ៣.២.៦ | ការយល់ដឹងយេនឌ័រ | | | | | |
| | | ៣.៣ | ការរៀបចំផែនការអភិវឌ្ឍសាលារៀន | ៣.៣.១ | ការរៀបចំផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍សាលា | | | | | |
| | | ៣.៤ | រចនាសម្ព័ន្ធគាំទ្រ | ៣.៤.១ | ក្រុមគ្រូបង្រៀន/សហគមន៍សិក្សាវិជ្ជាជីវៈ | | | | | |
| | | | | ៣.៤.២ | សហគមន៍សិក្សាវិជ្ជាជីវៈសម្រាប់គណៈគ្រប់គ្រង | | | | | |
| | | | | ៣.៤.៣ | ការប្រឹក្សា ឬការបង្វឹក | | | | | |
| | | ៣.៥ | ការគ្រប់គ្រងធនធាន | ៣.៥.១ | ការបែងចែកថវិកា | | | | | |

| | | | | | | | | | | |
|---|---|---|---|---|---|---|---|---|---|---|
| | | | | ៣.៥.២ | ភាពជាដៃគូជាមួយអ្នកខាងក្រៅ | | | | | |
| | | | | ៣.៥.៣ | ការវិភាជថវិកា | | | | | |
| | | ៣.៦ | ការគ្រប់គ្រងទិន្នន័យ | ៣.៦.១ | ការគ្រប់គ្រងទិន្នន័យ | | | | | |
| | | | | ៣.៦.២ | ទិន្នន័យតាមក្រុម | | | | | |
| | | ៣.៧ | ការវាយតម្លៃ | ៣.៧.១ | ការវាយតម្លៃការងារបុគ្គលិក | | | | | |
| | | | | ៣.៧.២ | ការរៀបចំតេស្តស្តង់ដា | | | | | |
| | | ៣.៨ | ការទទួលស្គាល់ពីថ្នាក់ជាតិ | ៣.៨.១ | ការវាយតម្លៃសាលាប្រចាំឆ្នាំ | | | | | |
| | | | | | **សរុប** | /21 | /21 | /21 | /21 | /21 |

**ការណែនាំការប្រើប្រាស់ឧបករណ៍ស្វ័យវាយតម្លៃនៃក្របខណ្ឌអប់រំស្នែមកម្រិតសាលារៀន៖**

1. ក្នុងប្រធានបទនីមួយៗ សូមគូសសញ្ញា (✓) ដែលត្រូវជាមួយស្ថានភាព/ការអនុវត្តរបស់សាលារៀនលោកលោកស្រី
2. បូកសរុបចំនួនសញ្ញា (✓) ក្នុងកម្រិតនីមួយៗ
3. កម្រិតមួយណាដែលមានសញ្ញា (✓) ច្រើនជាងគេនោះវាជា កម្រិតអភិវឌ្ឍន៍តាមសមាសភាគ (DDL)
4. កត់ត្រាលទ្ធផលសម្រាប់ប្រើប្រាស់ក្នុងការពិនិត្យឡើងវិញ និងនិងប្រើប្រាស់នៅក្នុងឧបករណ៍កំណត់គោលដៅ (ជំហានទី៣)

**កម្រិតអភិវឌ្ឍន៍តាមសមាសភាគ (DDL)**

កម្រិតអភិវឌ្ឍន៍របស់សាលារៀនសម្រាប់សមាសភាគ ណាមួយអាស្រ័យលើពិន្ទុនៃសមត្ថភាពស្នែមពីកម្រិតសាលារៀនទី១ ដល់ ៥។

**ការកំណត់កម្រិតអភិវឌ្ឍន៍តាមសមាសភាគ (DDL)** សម្រាប់សមាសភាគនេះ៖ សាលារៀនយើងមានសញ្ញា (✓) ច្រើនជាងគេនៅកម្រិតសាលារៀនទី________។ដូច្នេះវា ជាកម្រិតអភិវឌ្ឍន៍សម្រាប់សមាសភាគនេះ ដែលត្រូវជាមួយស្ថានភាព/ការអនុវត្តរបស់សាលារៀនយើង ។

**ចំណុចខ្លាំង**

សមាសភាគរង/ប្រធានបទមួយចំនួនមានពិន្ទុខ្ពស់ជាងកម្រិតអភិវឌ្ឍន៍តាមសមាសភាគ (DDL)។ ដូច្នេះភាពខ្លាំងរបស់សមាសភាគរង/ប្រធានបទគឺ៖

(រៀបចំជាតារាងបញ្ជីសមាសភាគរង/ប្រធានបទដែលមានចំនួនសញ្ញា (✓) ច្រើនជាងនៅក្នុងកម្រិតអភិវឌ្ឍន៍ដែលបានកំណត់)

**ឱកាសសម្រាប់អភិវឌ្ឍ (ចំណុចខ្សោយ)៖**

សមាសភាគរង/ប្រធានបទមួយចំនួនមានពិន្ទុទាបជាងកម្រិតអភិវឌ្ឍន៍តាមសមាសភាគ (DDL)។ ដូច្នេះឱកាសសម្រាប់អភិវឌ្ឍ គឺស្ថិតនៅក្នុងសមាសភាគរង/ប្រធានបទដូចខាងក្រោម៖

(រៀបចំជាតារាងបញ្ជីសមាសភាគរង/ប្រធានបទដែលមានចំនួនសញ្ញា (✓) តិចជាងនៅក្នុងកម្រិតអភិវឌ្ឍន៍ដែលបានកំណត់)

# ជំហានទី២៖ ឧបករណ៍ស្វ័យវាយតម្លៃ

## សមាសភាគទី៤៖ ការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធ

| | |
|---|---|
| **សមាសភាគទី៤** | ការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធ |
| **អ្នកទទួលខុសត្រូវ** | សមាជិកបង្គោល ដែលទទួលខុសត្រូវសមាសភាគនេះត្រូវក្នុងការបំពេញឧបករណ៍ស្វ័យវាយតម្លៃ។ ពួកគាត់គួរតែស្នើសុំធាតុចូលពី សមាជិកគាំទ្រឬក៏បុគ្គលិកសាលារៀនដទៃទៀត។ |
| **សមាជិកបង្គោលសម្រាប់សមាសភាគនេះ** | |
| **ឆ្នាំទី** | ( ឧ. ឆ្នាំទី១៖ ឆ្នាំសិក្សា២០២៤-២០២៥ ) |
| **ដំណើរការ** | ក្របខណ្ឌអប់រំស្តែមកម្រិតសាលារៀនជួយសាលារៀន ដើម្បីកែលម្អការបង្រៀននិងការរៀនមុខវិជ្ជាស្តែមតាមរយៈដំណើរការ ៥ ជំហាន។ ឧបករណ៍ស្វ័យវាយតម្លៃរបស់ក្របខណ្ឌស្តែមកម្រិតសាលារៀននេះគឺជាជំហានទី៤ នៃដំណើរការទាំង៥ជំហាន។<br>ឧបករណ៍ស្វ័យវាយតម្លៃរបស់ក្របខណ្ឌអប់រំស្តែមកម្រិតសាលារៀន សម្រាប់សមាសភាគស្តែមទី១ គឺការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធ ដែលមានសមាសភាគរង៖<br>៤.១ សម្ភាររូបវន្ត<br>៤.២ លទ្ធភាពប្រើប្រាស់<br>៤.៣ បរិក្ខារ<br>៤.៤ ការភ្ជាប់សេវាសាធារណៈ<br><br> |

| | |
|---|---|
| **គោលបំណងរបស់ឧបករណ៍** | ឧបករណ៍ស្វ័យវាយតម្លៃនឹងជួយក្រុមអនុវត្តសកម្មភាពស្វែមរបស់សាលារៀនរបស់លោក លោកស្រីដើម្បីពិនិត្យមើលឡើងវិញ ការអនុវត្តស្វែម នាពេលបច្ចុប្បន្ន និងកំណត់កម្រិតនៃក្របខណ្ឌណាមួយដែលសមស្របបំផុតនឹងស្ថានភាពបច្ចុប្បន្នរបស់សាលារៀនលោក លោកស្រី។ ឧបករណ៍នេះនឹងជួយលោក លោកស្រីកំណត់ចំណុចដែលត្រូវយកចិត្តទុកដាក់ និងណែនាំលោក លោកស្រីក្នុងការកំណត់គោលដៅសម្រាប់អភិវឌ្ឍនាឆ្នាំខាងមុខ។ ឧបករណ៍នេះផងដែរបង្កើតឡើងមិនមែនក្នុងបំណងដើរតួជាឧបករណ៍វិនិច្ឆ័យ ឬវាយតម្លៃនេះទេ។ លោក លោកស្រីត្រូវបានលើកទឹកចិត្តឱ្យធ្វើការឆ្លុះបញ្ចាំងដោយភាពស្មោះត្រង់លើការអនុវត្តរបស់សាលារៀនលោក លោកស្រី ដើម្បីធានាថាការផ្តល់អនុសាសន៍គឺសមស្របនឹងសមត្ថភាពសាលារៀន និងផ្តល់អត្ថប្រយោជន៍ដល់សាលារៀនលោក លោកស្រី។ |
| **ការណែនាំ** | 2. បោះពុម្ពឧបករណ៍ស្វ័យវាយតម្លៃដាក់ ដែលនៅផ្នែកខាងក្រោយនៃក្របខណ្ឌ<br>3. បំពេញតារាងខាងក្រោម ដោយជ្រើសរើសចម្លើយស្របតាមសំណួរនីមួយៗនៅក្នុងសមាសភាគរង និងប្រធានបទ សូមឆ្លុះបញ្ចាំងដោយភាពស្មោះត្រង់លើស្ថានភាពនៃការអនុវត្តនៅសាលារៀនរបស់លោក លោកស្រី បន្ទាប់មក សូមកំណត់កម្រិតអភិវឌ្ឍន៍ដែលស័ក្តិសមបំផុត។ លោក លោកស្រីប្រហែលរកឃើញស្ថានភាពសាលារៀនក្នុងកម្រិតខុសៗគ្នា អាស្រ័យលើប្រធានបទ<br>4. ពិនិត្យមើលត្រង់ចំណុចសម្គាល់សម្រាប់សំណួរនីមួយៗ ដើម្បីផ្ទៀងផ្ទាត់ឡើងវិញទៅលើខ្លឹមសារណាដែលមិនច្បាស់<br>5. កត់ត្រាចម្លើយរបស់លោក លោកស្រីនៅលើឧបករណ៍ស្វ័យវាយតម្លៃនៅផ្នែកខាងក្រោយនៃក្របខណ្ឌ ដោយគូសសញ្ញា (✓) ដែលត្រូវនឹងស្ថានភាពបច្ចុប្បន្នរបស់សាលារៀន<br>6. នៅពេលគូសរួចរាល់ លោក លោកស្រីត្រូវបូកសរុបពិន្ទុដោយរាប់ចំនួនសញ្ញា (✓) នៅតាមកម្រិតនីមួយៗ<br>7. អនុវត្តតាមការណែនាំនៅផ្នែកខាងក្រោយនៃក្របខណ្ឌ ដើម្បីកំណត់កម្រិតអភិវឌ្ឍន៍តាមសមាសភាគ (DDL) សម្រាប់សមាសភាគនេះ (កម្រិត ដែលមានសញ្ញា (✓) ច្រើនជាងគេបំផុត) កំណត់បានចំណុចខ្លាំង និងកំណត់ចំណុចដែលត្រូវពង្រឹង។ |

| | | | | | |
|---|---|---|---|---|---|
| ៤.១.១ | **៤.១ សម្ភាររូបវ័ន្ត** | | | | |
| | **ថាតើន័យសេចក្តីខាងក្រោមមួយណាត្រូវនឹងស្ថានភាពរបស់សាលារៀនលោក លោកស្រី៖** | | | | |
| | **កម្រិតសាលារៀនទី១** | **កម្រិតសាលារៀនទី២** | **កម្រិតសាលារៀនទី៣** | **កម្រិតសាលារៀនទី៤** | **កម្រិតសាលារៀនទី៥** |
| **សម្ភាររូបវ័ន្តស្ទែម** | សាលារៀន មិនមានបន្ទប់ពិសោធន៍ ឬ បន្ទប់រៀន វិទ្យាសាស្ត្រទេ។ មុខវិជ្ជាស្ទែម ត្រូវបានបង្រៀនក្នុងបន្ទប់ រៀនធម្មតា ដោយ មិនមានទឹកប្រើប្រាស់។ | សាលារៀនមានសម្ភារ រូបវ័ន្តស្ទែមចាំបាច់ តែមិន ទាន់គ្រប់គ្រាន់ ដូច ជាទំហំនិងការរៀបចំទី កន្លែងហើយកន្លែង ខ្លះមិនមានទឹកប្រើប្រាស់។ | សាលារៀនមានសម្ភាររូបវ័ន្ត ស្ទែមចាំបាច់គ្រប់គ្រាន់ សម្រាប់តម្រូវការរបស់យើង។ | សាលារៀនមានសម្ភាររូបវ័ន្តស្ទែម ដែលបានរៀបចំយ៉ាងល្អដូច ជាទំហំ និងការរៀបចំទីកន្លែង បរិក្ខារឌីជីថលដែលអំណោយផល ដល់ការអនុវត្តការបង្រៀនបែប ទំនើប (ឧទាហរណ៍ ការងារជាក្រុម)។ លើសពីនេះទៀត មានកន្លែង ប្រើទូទៅសម្រាប់ផ្តល់ លទ្ធភាពដល់ព្រឹត្តិការណ៍ស្ទែម (ឧទាហរណ៍ ការតាំងពិព័រណ៍ ស្ទែម)។ | សាលារៀនមានបំពាក់សម្ភាររូបវ័ន្ត គ្រប់គ្រាន់ បន្ទប់ពិសោធន៍រៀបចំ បានយ៉ាងល្អ ស្របតាម តម្រូវការសិស្សទាំងអស់ មានបរិក្ខា ល្អៗសព្វគ្រប់ឧបករណ៍ឌីជីថល មានប្រព័ន្ធការពារខ្យល់ចេញចូល។ មានកន្លែងប្រើទូទៅសម្រាប់ផ្តល់ លទ្ធភាពដល់ព្រឹត្តិការណ៍ ស្ទែម (ឧទាហរណ៍ ការតាំងពិព័រណ៍ ស្ទែម)។ មានអាគារពហុបំណង សម្រាប់ការងារគម្រោង (ឧ.រោង ជាង និងសិក្ខាសាលា។ល។)។ |
| **កំណត់សម្គាល់** | **សម្ភាររូបវ័ន្តស្ទែម៖** បន្ទប់ឯកទេស ឬបន្ទប់គាំទ្រចំពោះកិច្ចណាមួយ ដែលមានបំពាក់ធនធាននិងបរិក្ខារសម្រាប់ការបង្រៀននិងការរៀនមុខវិជ្ជាស្ទែមរួមមាន៖ បន្ទប់ពិសោធន៍ រោងជាង និងកន្លែងផ្សេងទៀតដើម្បីជួយសម្រួលដល់ការងារធ្វើដោយដៃផ្ទាល់ ការធ្វើពិសោធក្នុងមុខវិជ្ជាស្ទែម។ មិនមានបញ្ចូលក្នុងបន្ទប់រៀនធម្មតា។<br>**ការរៀបចំសម្ភាររូបវ័ន្តស្ទែម៖** បន្ទប់រៀនមួយគួរមានសិស្សប្រហែល៤០ នាក់ និងមានតុអាចរៀបចំសម្រាប់ការងារពិភាក្សាក្រុមបានយ៉ាងងាយស្រួល ព្រមទាំងអាចប្រើប្រាស់អគ្គិសនី និងទឹកបាន។<br>**បន្ទប់រៀនធម្មតា៖** បន្ទប់រៀនដែលមិនមានបរិក្ខារសម្រាប់បង្រៀនស្ទែម។ វាអាចប្រើប្រាស់សម្រាប់ការបង្រៀនមុខវិជ្ជាមិនមែនជាមុខវិជ្ជាស្ទែម។ | | | | |

| ៤.១.២ | ថាតើន័យសេចក្តីខាងក្រោមមួយណាត្រូវនឹងស្ថានភាពរបស់សាលារៀនលោក លោកស្រី៖ | | | | |
|---|---|---|---|---|---|
| | កម្រិតសាលារៀនទី១ | កម្រិតសាលារៀនទី២ | កម្រិតសាលារៀនទី៣ | កម្រិតសាលារៀនទី៤ | កម្រិតសាលារៀនទី៥ |
| សម្ភារបរិក្ខារបច្ចេកវិទ្យា | សាលារៀនគ្មានបន្ទប់ ICT ឬក៏គ្មានបរិក្ខារបច្ចេកវិទ្យាក្នុងបន្ទប់រៀន។ | សាលារៀនមានបន្ទប់ ICT ប៉ុន្តែបន្ទប់រៀនធម្មតាមួយចំនួនមានបំពាក់ម៉ាស៊ីនបញ្ចាំងស្លាយ។ | សាលារៀនមានបន្ទប់ ICT ហើយបន្ទប់រៀនខ្លះគឺជាបន្ទប់រៀនឆ្លាតវៃ។ | សាលារៀនមានបន្ទប់ ICT ហើយបន្ទប់រៀនភាគច្រើនគឺជាបន្ទប់រៀនឆ្លាតវៃ។ | សាលារៀនមានបន្ទប់ ICT ហើយបន្ទប់រៀនទាំងអស់គឺជាបន្ទប់រៀនឆ្លាតវៃ។ |
| កំណត់សម្គាល់ | **សម្ភារបរិក្ខារបច្ចេកវិទ្យា៖** បន្ទប់ឯកទេស ឬបន្ទប់គាំទ្រចំពោះកិច្ចណាមួយ ដែលមានបំពាក់បរិក្ខារបច្ចេកវិទ្យា។ នៅទីនេះសំដៅទៅលើបន្ទប់បំពាក់ដោយបរិក្ខារបច្ចេកវិទ្យាពេញលេញ(មិនមែនគ្រាន់តែគ្រឿងបន្លាស់/គ្រឿងបង្គុំទេ)។ ឧទាហរណ៍ បន្ទប់ពិសោធន៍ICT និងបន្ទប់រៀនឆ្លាតវៃ។<br>**បន្ទប់រៀនឆ្លាតវៃ**មានបរិក្ខារបច្ចេកវិទ្យាដូចជា ម៉ាស៊ីនបញ្ចាំង LCD, អេក្រង់បញ្ចាំង, កុំព្យូទ័រ, UPS, ប្រព័ន្ធសំឡេង។ | | | | |
| ៤.១.៣ | ថាតើន័យសេចក្តីខាងក្រោមមួយណាត្រូវនឹងស្ថានភាពសាលារៀនលោក លោកស្រី៖ | | | | |
| | កម្រិតសាលារៀនទី១ | កម្រិតសាលារៀនទី២ | កម្រិតសាលារៀនទី៣ | កម្រិតសាលារៀនទី៤ | កម្រិតសាលារៀនទី៥ |
| បណ្ណាល័យ | សាលារៀនគ្មានបណ្ណាល័យ។ | បណ្ណាល័យសាលារៀនមិនមានសម្ភារគ្រប់គ្រាន់ នៅខ្វះសម្ភារស្វែម កុំព្យូទ័រសម្រាប់ស្រាវជ្រាវតាមអ៊ីនធឺណិត ឬបញ្ជីឈ្មោះសៀវភៅជាឌីជីថល។ | បណ្ណាល័យសាលារៀនមានសម្ភារចាំបាច់គ្រប់គ្រាន់ ដែលក្នុងនោះរួមមានសម្ភារស្វែមដែលគេបោះពុម្ពនៅមានកម្រិត មានបញ្ជីឈ្មោះជាឌីជីថល តែមិនទាន់មានកុំព្យូទ័រសម្រាប់ស្រាវជ្រាវតាមអ៊ីនធឺណិត។ | បណ្ណាល័យសាលារៀនឆ្លើយតបតាមតម្រូវការបានល្អណាស់ដោយមាន កុំព្យូទ័រសម្រាប់ស្រាវជ្រាវតាមអ៊ីនធឺណិត បញ្ជីឈ្មោះជាឌីជីថល និងជម្រើសល្អៗនៃសម្ភារស្វែមដែលបានបោះពុម្ព និងមានបណ្ណាល័យអេឡិចត្រូនិក។ | បណ្ណាល័យជំរុញឱ្យមានបំណិនសតវត្សរ៍ទី២១ ដោយមានបញ្ជីឈ្មោះជាឌីជីថលសម្រាប់ជ្រើសរើសផ្សេងៗគ្នានៃសម្ភារដែលគេបោះពុម្ព និងសម្ភារអេឡិចត្រូនិច មានកុំព្យូទ័រច្រើនសម្រាប់ស្រាវជ្រាវ និងមានកន្លែងសហសិក្សាមួយសម្រាប់ធ្វើបទបង្ហាញ។ |

| | | | | | |
|---|---|---|---|---|---|
| កំណត់សម្គាល់ | បញ្ជីឈ្មោះជាឌីជីថល៖ បញ្ជីឈ្មោះនៃធនធានទាំងអស់ដែលអាចស្រាវជ្រាវបាននៅក្នុងបណ្ណាល័យតាមប្រធានបទ/ចំណងជើង/អ្នកនិពន្ធ | | | | |
| ៤.១.៤ | **ថាតើន័យសេចក្ដីខាងក្រោមមួយណាត្រូវនឹងស្ថានភាពរបស់សាលារៀនលោក លោកស្រី៖** | | | | |
| | **កម្រិតសាលារៀនទី១** | **កម្រិតសាលារៀនទី២** | **កម្រិតសាលារៀនទី៣** | **កម្រិតសាលារៀនទី៤** | **កម្រិតសាលារៀនទី៥** |
| សុវត្ថិភាព | សាលារៀនមិនមានបន្ទប់ពិសោធន៍ ឬបន្ទប់វិទ្យាសាស្ត្រទេ។ | សាលារៀនមានសម្ភារូបវន្តស្នែមជាមួយ លក្ខណៈសុវត្ថិភាពមិនគ្រប់គ្រាន់(គ្មានស្លាកសញ្ញាសុវត្ថិភាព ភួយពន្លត់ភ្លើង កន្លែងលុបមុខ ឬកញ្ចប់សង្គ្រោះបឋម)។ | សាលារៀនមានសម្ភារូបវន្តស្នែមជាមួយលក្ខណៈសុវត្ថិភាពគ្រប់គ្រាន់រួមមាន ស្លាកសញ្ញាសុវត្ថិភាព ភួយពន្លត់ភ្លើង កន្លែងលុបមុខ និងកញ្ចប់សង្គ្រោះបឋម) | សាលារៀនមានសម្ភារូបវន្តស្នែមជាមួយលក្ខណៈសុវត្ថិភាពគ្រប់គ្រាន់រួមមាន ស្លាកសញ្ញាសុវត្ថិភាព ភួយពន្លត់ភ្លើង កន្លែងលុបមុខ និងកញ្ចប់សង្គ្រោះបឋម។ នីតិវិធីសុវត្ថិភាពក្នុងការសិក្សាបានកំណត់ច្បាស់លាស់ និងបំប៉នគ្រូបង្រៀនស្នែម និងសិស្សទាំងអស់។ | សាលារៀនមានសម្ភារូបវន្តស្នែម បំពាក់ដោយស្លាកសញ្ញាសុវត្ថិភាព និងលក្ខណៈល្អ (សូមមើលបញ្ជី)។ វគ្គបំប៉នសុវត្ថិភាពពេញលេញត្រូវបានផ្ដល់ជូនដល់គ្រូបង្រៀនស្នែម និងសិស្សទាំងអស់។ នីតិវិធីសុវត្ថិភាពបានចងក្រងជាឯកសារនិងអាចរកបានសម្រាប់សាលាផ្សេងទៀតតាមរយៈសហគមន៍សិក្សាវិជ្ជាជីវៈ។ |
| កំណត់សម្គាល់ | លក្ខណៈសុវត្ថិភាពរួមមាន ស្លាកសញ្ញាសុវត្ថិភាព ភួយពន្លត់ភ្លើង កន្លែងខ្យល់ចេញចូល ទូបឺតផ្សែងឬឧស្ម័ន ឧបករណ៍លាងខ្លួនប្រាណ កន្លែងលុបមុខ កញ្ចប់សង្គ្រោះបឋម និងទូទុកសារធាតុគីមី។ | | | | |

| ៤.១.៥ | ចំពោះគោលការណ៍សេចក្តីខាងក្រោមមួយណាត្រូវនឹងស្ថានភាពរបស់សាលារៀនលោក លោកស្រី៖ | | | | |
|---|---|---|---|---|---|
| | កម្រិតសាលារៀនទី១ | កម្រិតសាលារៀនទី២ | កម្រិតសាលារៀនទី៣ | កម្រិតសាលារៀនទី៤ | កម្រិតសាលារៀនទី៥ |
| ការឆ្លើយតបនឹងយេនឌ័រ | សាលារៀនគ្មានសម្ភារបរិក្ខា។ | មានសម្ភាររូបវន្ត តែគ្មាននីតិវិធីសុវត្ថិភាព ឬស្លាកសញ្ញាសុវត្ថិភាព។ | បន្ទប់រៀនមានសម្ភាររូបវន្តស្វែម ជាមួយសញ្ញាសុវត្ថិភាព តែគ្មានការឆ្លើយតបនឹងយេនឌ័រ។ | មានសម្ភាររូបវន្តស្វែម ជាមួយនីតិវិធីការឆ្លើយតបនឹងយេនឌ័រ និងស្លាកសញ្ញាសុវត្ថិភាព។ | មានសម្ភាររូបវន្តស្វែម ជាមួយនីតិវិធីសុវត្ថិភាពការឆ្លើយតបនឹងយេនឌ័រនិងស្លាកសញ្ញាសុវត្ថិភាពដែលបានធ្វើបច្ចុប្បន្នកម្ម ហើយអាចចែករំលែកសាលារៀនដទៃទៀតតាមសហគមន៍សិក្សាវិជ្ជាជីវៈ។ |
| កំណត់សម្គាល់ | នីតិវិធីសុវត្ថិភាពការឆ្លើយតបនឹងយេនឌ័រ និងស្លាកសញ្ញាសំដៅលើវិធីសរសេរដោយប្រើប្រាស់ភាសាការឆ្លើយតបនឹងយេនឌ័រ និងមានការអនុវត្តសុវត្ថិភាពយេឌ័រទាំងអស់ (ឧ. ការចងសក់មកក្រោយ)។<br>ស្លាកសញ្ញាសុវត្ថិភាពការឆ្លើយតបនឹងយេនឌ័រ សំដៅលើស្លាកសញ្ញាដែលមិនប៉ះពាល់ដល់យេនឌ័រ។ | | | | |

| ៤.២.១ | ៤.២ លទ្ធភាពប្រើប្រាស់<br>លទ្ធភាពប្រើប្រាស់បន្ទប់ពិសោធន៍ ឬបន្ទប់វិទ្យាសាស្ត្រ | | | | |
|---|---|---|---|---|---|
| | កម្រិតសាលារៀនទី១ | កម្រិតសាលារៀនទី២ | កម្រិតសាលារៀនទី៣ | កម្រិតសាលារៀនទី៤ | កម្រិតសាលារៀនទី៥ |
| លទ្ធភាពចូលប្រើប្រាស់ បន្ទប់ពិសោធន៍ ឬបន្ទប់វិទ្យាសាស្ត្រ | គ្មានបន្ទប់ពិសោធន៍ឬបន្ទប់វិទ្យាសាស្ត្រ។ | សាលារៀនមានចំនួនសិស្សច្រើនបណ្ដាលឱ្យមានការរាំងស្ទះដល់ការចូលប្រើប្រាស់ប្រហែលមួយដងក្នុងមួយត្រីមាស។ | លទ្ធភាពចូលប្រើប្រាស់មានកម្រិត (ប្រហាក់ប្រហែល ១ដងក្នុង១ខែ) សម្រាប់សិស្សភាគច្រើនក្នុងម៉ោងសិក្សានៅសាលារៀន។ | លទ្ធភាពចូលប្រើប្រាស់សមស្រប ដោយ យ៉ាងហោចណាស់ពីរដងក្នុងមួយខែ សម្រាប់សិស្សទាំងអស់ក្នុងម៉ោងសិក្សានៅសាលារៀន ក៏ដូចជាលទ្ធភាពចូលប្រើប្រាស់ បន្ទាប់ពីសកម្មភាពក្លឹបសិក្សានៅសាលារៀន ឬសកម្មភាពក្រៅកម្មវិធីសិក្សា។ | លទ្ធភាព ចូលប្រើប្រាស់យ៉ាងហោចមួយសប្ដាហ៍ម្ដងសម្រាប់សិស្សទាំងអស់ក្នុងម៉ោងសិក្សានៅសាលារៀន និង បន្ទាប់ពីសកម្មភាពក្លឹបសិក្សានៅសាលារៀន ឬសកម្មភាពក្រៅកម្មវិធីសិក្សា។ |
| កំណត់សម្គាល់ | លទ្ធភាពចូលប្រើ៖<br>• រាំងស្ទះ៖ ប្រហាក់ប្រហែលម្ដងក្នុងមួយត្រីមាស<br>• មានកម្រិត៖ ប្រហាក់ប្រហែលម្ដងក្នុងមួយខែ<br>• សមរម្យ៖ យ៉ាងហោចពីរដងក្នុងមួយខែ<br>• ជាការល្អ៖ យ៉ាងហោចម្ដងក្នុងមួយសប្ដាហ៍ | | | | |
| ៤.២.២ | លទ្ធភាពចូលប្រើប្រាស់បន្ទប់ ICT | | | | |
| | កម្រិតសាលារៀនទី១ | កម្រិតសាលារៀនទី២ | កម្រិតសាលារៀនទី៣ | កម្រិតសាលារៀនទី៤ | កម្រិតសាលារៀនទី៥ |
| លទ្ធភាពចូលប្រើប្រាស់បន្ទប់ ICT | គ្មានបន្ទប់ ICT ។ | រាំងស្ទះ ដោយចូលប្រើប្រាស់ត្រឹមប្រហែលមួយដងក្នុងមួយខែដោយសារបន្ទប់ ICT មិនអាចផ្ទុកសិស្ស | នៅមានកម្រិត ដោយ ចូលប្រើប្រាស់បានម្ដងក្នុង១សប្ដាហ៍ សម្រាប់សិស្សភាគច្រើនក្នុង | លទ្ធភាពសមរម្យក្នុងការចូលប្រើប្រាស់ ដោយប្រហែលពីរដងក្នុងមួយសប្ដាហ៍សម្រាប់សិស្ស និងគ្រូបង្រៀនក្នុងពេលម៉ោងសិក្សា | មានលទ្ធភាពបរិបូរក្នុងការចូលប្រើប្រាស់រាល់ថ្ងៃ។ សិស្សនិងគ្រូបង្រៀនទាំងអស់អាចចូលប្រើប្រាស់បានគ្រប់មុខវិជ្ជាក្នុង |

| | | | | | |
|---|---|---|---|---|---|
| | | និងគ្រូបង្រៀននៅក្នុងសាលារៀន។ | ម៉ោងសិក្សា។ | ក៏ដូចជាបន្ទាប់ពីសកម្មភាពក្លឹបសិក្សានៅសាលារៀន ឬសកម្មភាពក្រៅកម្មវិធីសិក្សា។ | ពេលម៉ោងសិក្សាក៏ដូចជាបន្ទាប់ពីសកម្មភាពក្លឹបសិក្សានៅសាលារៀន ឬសកម្មភាពក្រៅកម្មវិធីសិក្សា។ |
| កំណត់សំគាល់ | លទ្ធភាពចូលប្រើ៖<br>• រាំងស្ទះ៖ ប្រហែលម្តងក្នុងមួយខែ<br>• មានកម្រិត៖ ប្រហែលម្តងក្នុងមួយសប្តាហ៍<br>• សមរម្យ៖ យ៉ាងហោចពីរដងក្នុងសប្តាហ៍<br>• បរិបូរណ៍៖ រៀងរាល់ថ្ងៃ | | | | |
| ៤.២.៣ | សាលារៀនយើង៖ | | | | |
| | **កម្រិតសាលារៀនទី១** | **កម្រិតសាលារៀនទី២** | **កម្រិតសាលារៀនទី៣** | **កម្រិតសាលារៀនទី៤** | **កម្រិតសាលារៀនទី៥** |
| លទ្ធភាពចូលប្រើប្រាស់ប្រកបដោយបរិយាបន្ន | គ្មានបន្ទប់ពិសោធន៍ឬបន្ទប់វិទ្យាសាស្ត្រ។ | មានបន្ទប់ពិសោធន៍ឬបន្ទប់វិទ្យាសាស្ត្រ ប៉ុន្តែលទ្ធភាពប្រើប្រាស់មានកំណត់ដោយសារកត្តាជាច្រើនដូចជា យេនឌ័រ សមត្ថភាព ជនជាតិភាគតិចឬស្ថានភាពសេដ្ឋកិច្ច-សង្គម។ | សិស្សភាគច្រើនមានលទ្ធភាពស្មើគ្នាក្នុងការចូលប្រើប្រាស់បន្ទប់ពិសោធន៍ឬបន្ទប់វិទ្យាសាស្ត្រដោយមិនគិតពីយេនឌ័រ ជនជាតិភាគតិចឬស្ថានភាពសង្គម-សេដ្ឋកិច្ច ទោះបដោយ៉ាងណាក៏ដោយបញ្ហាលទ្ធភាពប្រើប្រាស់មួយចំនួននៅតែមាន។ | សិស្សទាំងអស់មានលទ្ធភាពស្មើគ្នាចូលប្រើបន្ទប់ពិសោធន៍ ឬបន្ទប់វិទ្យាសាស្ត្រ ដោយមិនគិតពីយេនឌ័រ សមត្ថភាព ជនជាតិភាគតិចឬស្ថានភាពសេដ្ឋកិច្ច-សង្គម។ សកម្មភាពបរិយាបន្នបានចាប់ផ្តើមលើកទឹកចិត្តយ៉ាងសកម្មឱ្យមានការចូលរួមទាំងអស់គ្នា។ | សិស្សទាំងអស់មានលទ្ធភាពស្មើគ្នាចូលប្រើបន្ទប់ពិសោធន៍ឬបន្ទប់វិទ្យាសាស្ត្រទាំងក្នុងម៉ោងសិក្សា និងក្រោយពេលម៉ោងសិក្សាដោយមិនគិតយេនឌ័រ សមត្ថភាព ជនជាតិភាគតិច ឬស្ថានភាពសេដ្ឋកិច្ច-សង្គម។ សកម្មភាពបរិយាបន្នបានចាប់ផ្តើមលើកទឹកចិត្ត យ៉ាងសកម្មឱ្យមានការចូលរួមទាំងអស់គ្នា។ កម្មវិធីពិសេសត្រូវបានបង្កើតឡើងសំដៅទៅអ្នកមានលទ្ធភាពតិចតួចចូលប្រើប្រាស់បន្ទប់ពិសោធន៍ឬ |

| | | | | | |
|---|---|---|---|---|---|
| | | | | | បន្ទប់វិទ្យាសាស្ត្រ (ឧទាហរណ៍ សិស្សស្រី)។ |
| កំណត់សម្គាល់ | ពិចារណាទៅលើកត្តាផ្សេងៗដូចជា ទីតាំងនៅពេលធ្លុះបញ្ចាំងលើស្ថានភាពបច្ចុប្បន្នរបស់សាលារៀនលោក លោកស្រី។ ( ឧ .តើសិស្សទាំងអស់អាចមានលទ្ធភាពចូលបន្ទប់វិទ្យាសាស្ត្រ ដែលនៅទីខ្ពស់បានឬទេ ? ឬប្រសិនបើទំហំបន្ទប់តូច តើសាលារៀនផ្តល់ឱកាសដល់សិស្សពូកែ ដែរឬទេ ? ) | | | | |

| | | | | | |
|---|---|---|---|---|---|
| ៤.៣.១ | ៤.៣ បរិក្ខារ<br>តើបរិក្ខារស្នែមនៅក្នុងសាលារៀនលោក លោកស្រីស្ថិតក្នុងស្ថានភាពយ៉ាងដូចម្តេច? | | | | |
| | កម្រិតសាលារៀនទី១ | កម្រិតសាលារៀនទី២ | កម្រិតសាលារៀនទី៣ | កម្រិតសាលារៀនទី៤ | កម្រិតសាលារៀនទី៥ |
| បរិក្ខារស្នែម | គ្មានបរិក្ខារស្នែម។ | មានបរិក្ខារស្នែម ប៉ុន្តែស្ទើរតែមិនអាចប្រើបាន និងកម្រមានការថែទាំ។ | បរិក្ខារស្នែមមានដំណើរការបានជាធម្មតា ប៉ុន្តែមិនមានប្រព័ន្ធថែទាំជាប្រចាំ។ | បរិក្ខារស្នែមមានដំណើរការបានពេញលេញ និងមានការថែទាំតាមការស្នើសុំ។ | បរិក្ខារស្នែមមានដំណើរការបានពេញលេញ និងមានការថែទាំជាប្រចាំ។ |
| កំណត់សម្គាល់ | បរិក្ខារស្នែមសំដៅលើបរិក្ខារដែលបានប្រើប្រាស់សម្រាប់ពិសោធន៍វិទ្យាសាស្ត្រ ឧ. កែវពិសោធន៍ បរិក្ខារអេឡិចត្រូនិក មីក្រូទស្សន៍ និង pH ម៉ែត្រ។ល។ | | | | |
| ៤.៣.២ | តើសម្ភារគម្រោងស្នែមនៅក្នុងសាលារៀនលោក លោកស្រីស្ថិតក្នុងស្ថានភាពយ៉ាងដូចម្តេច? | | | | |
| | កម្រិតសាលារៀនទី១ | កម្រិតសាលារៀនទី២ | កម្រិតសាលារៀនទី៣ | កម្រិតសាលារៀនទី៤ | កម្រិតសាលារៀនទី៥ |
| សម្ភារគម្រោងស្នែម | សាលារៀនមិនបានប្រមូលសម្ភារគម្រោងស្នែមទុកទេ។ | សាលារៀនយល់ដឹងពីតម្រូវការសម្ភារក្នុងការបង្កើតសម្ភារគម្រោងស្នែម ប៉ុន្តែមិនទាន់បានធ្វើផែនការដើម្បីប្រមូលពួកវា។ | សាលារៀនបានរៀបចំកន្លែងទុកដាក់សម្រាប់ប្រមូលសម្ភារគម្រោងស្នែមទុកហើយ ប៉ុន្តែនៅមានកម្រិតក្នុងការទាក់ទងជាមួយសិស្ស ឬគ្រួសារសិស្សអំពីការប្រមូលផ្តុំសម្ភារគម្រោងនៅផ្ទះសម្រាប់គោលបំណងនេះ។ | សាលារៀនបានរៀបចំកន្លែងទុកដាក់សម្រាប់ប្រមូលសម្ភារគម្រោងស្នែម និងទំនាក់ទំនងប្រកបដោយប្រសិទ្ធភាពជាមួយសិស្សនិងក្រុមគ្រួសារអំពីសម្ភារដែលសមស្របអាចផ្តល់ឱ្យ។ | សាលារៀនបានរៀបចំកន្លែងទុកដាក់សម្រាប់ប្រមូលសម្ភារគម្រោងស្នែមមាន ទំនាក់ទំនងនិងលើកទឹកចិត្តសិស្សនិងគ្រួសារ ដើម្បីស្វែងសម្ភារ យ៉ាងសកម្មពីអាជីវកម្មក្នុងស្រុកនៅក្នុងសហគមន៍។ |
| កំណត់សម្គាល់ | សម្ភារគម្រោងស្នែម៖ សម្ភារ ឬបរិក្ខារសម្រាប់ការបង្កើតគម្រោងស្នែម ដែលមានច្រើនប្រភេទ ឧ.ប្រអប់ក្រដាស កូនសោ សម្ភារការិយាល័យ ថ្នាំលាប កាវ សម្ភារសំណល់ល្អ និងដប ជាដើម។ | | | | |

| ៤.៣.៣ | តើសម្ភារស្ទែមប្រើបានតែម្តងនៅក្នុងសាលារៀនលោក លោកស្រីស្ថិតក្នុងស្ថានភាពយ៉ាងដូចម្តេច? | | | | |
|---|---|---|---|---|---|
| | កម្រិតសាលារៀនទី១ | កម្រិតសាលារៀនទី២ | កម្រិតសាលារៀនទី៣ | កម្រិតសាលារៀនទី៤ | កម្រិតសាលារៀនទី៥ |
| សម្ភារស្ទែមប្រើបានតែម្តង | គ្មានសម្ភារស្ទែមប្រើបានតែម្តងនោះទេ។ | លទ្ធភាពនៅមានកម្រិតក្នុងការប្រើប្រាស់សម្ភារស្ទែមប្រើបានតែម្តង ហើយប្រភេទសម្ភារខ្លះមិនមានរយៈពេលយូរមកហើយ។ | សម្ភារស្ទែមប្រើបានតែម្តងត្រូវបានប្រើប្រាស់ស្ទើរតែគ្រប់ពេលវេលា ប៉ុន្តែការរក្សាឱ្យវាសម្រាប់ប្រើប្រាស់តែងតែមានការពិបាក។ | សម្ភារស្ទែមប្រើបានតែម្តងត្រូវបានប្រើប្រាស់គ្រប់ពេលវេលា ហើយវាមានជាប្រព័ន្ធដាក់ឱ្យប្រើក្នុងការទទួលបានសម្ភារ និងបំពេញបន្ថែមនៅពេលមានសំណើ។ | វាមានប្រព័ន្ធដាក់ឱ្យប្រើក្នុងការទទួលបាន និងបំពេញបន្ថែមទៀងទាត់នូវសម្ភារស្ទែមប្រើបានតែម្តង។ សាលារៀនចែករំលែកបទពិសោធន៍ និងទំនាក់ទំនងសម្រាប់ទទួលសម្ភារជាមួយសាលារៀនផ្សេងទៀតតាមរយៈសហគមន៍សិក្សាវិជ្ជាជីវៈ។ |
| កំណត់សម្គាល់ | សម្ភារស្ទែមប្រើបានតែម្តងគឺជាសម្ភារ ឬបរិក្ខារដែលប្រាស់ប្រាស់បានតែម្តង។ នៅពេលវាអស់ ឬប្រើរួច ហើយត្រូវបញ្ចូល ឬជំនួសមកវិញ។ ឧទាហរណ៍ ប្លាស្ទិក បំពង់សារធាតុគីមី ស្រោមដៃ និងក្រដាស pH ។ល។ | | | | |
| ៤.៣.៤ | តើបរិក្ខារបច្ចេកវិទ្យាអប់រំនៅក្នុងសាលារៀនលោក លោកស្រីស្ថិតក្នុងស្ថានភាពយ៉ាងដូចម្តេច? | | | | |
| | កម្រិតសាលារៀនទី១ | កម្រិតសាលារៀនទី២ | កម្រិតសាលារៀនទី៣ | កម្រិតសាលារៀនទី៤ | កម្រិតសាលារៀនទី៥ |
| បរិក្ខារបច្ចេកវិទ្យាអប់រំ | គ្មានបរិក្ខារបច្ចេកវិទ្យាអប់រំ។ | មានបរិក្ខារបច្ចេកវិទ្យាអប់រំ ប៉ុន្តែមិនអាចដំណើរការបាន និងកម្រមានការថែទាំ។ | បរិក្ខារបច្ចេកវិទ្យាអប់រំនៅដំណើរការ បានជាធម្មតាប៉ុន្តែមិនមានប្រព័ន្ធការថែទាំជាប្រចាំនោះទេ។ | បរិក្ខារបច្ចេកវិទ្យាអប់រំនៅដំណើរការបានពេញលេញ និងមានការថែទាំតាមការស្នើសុំ។ មានឧបករណ៍កាន់នឹងដៃបាននៅក្នុងបន្ទប់រៀនជាមួយកញ្ចប់កញ្ចប់ឧបករណ៍គ្រឿងបង្គុំនិងបណ្ណាល័យអេឡិចត្រូនិកផងដែរ។ | បរិក្ខារបច្ចេកវិទ្យាអប់រំនៅដំណើរការបានពេញលេញនិងមានការថែទាំជាប្រចាំ។ មានឧបករណ៍កាន់នឹងដៃបាន បណ្ណាល័យអេឡិចត្រូនិក និងបរិក្ខារបច្ចេកវិទ្យាកម្រិតខ្ពស់ (ឧទាហរណ៍ ម៉ាស៊ីនបោះពុម្ព 3D កញ្ចប់ឧបករណ៍គ្រឿងបង្គុំ)។ សាលារៀនចែករំលែកបទ |

| | | | | | |
|---|---|---|---|---|---|
| | | | | | ពិសោធន៍ដល់សាលារៀនដទៃតាមរយៈ សហគមន៍សិក្សាវិជ្ជាជីវៈពីរបៀបថែទាំបរិក្ខារបច្ចេកវិទ្យាអប់រំ។ |
| កំណត់សម្គាល់ | បរិក្ខារបច្ចេកវិទ្យាអប់រំសំដៅដល់ កុំព្យូទ័រ កញ្ចប់ឧបករណ៍គ្រឿងបង្គុំ( maker kits ) និងម៉ាស៊ីនបោះពុម្ព 3D ។ល។ | | | | |

| ៤.៤.១ | ៤.៤ ការភ្ជាប់សេវាសាធារណៈ | | | | |
|---|---|---|---|---|---|
| | តើសាលារៀនមានលទ្ធភាពផ្គត់ផ្គង់អគ្គិសនីបានសម្រាប់សកម្មភាពដែរក្នុងពេលម៉ោងសិក្សា ដែរឬទេ? | | | | |
| | កម្រិតសាលារៀនទី១ | កម្រិតសាលារៀនទី២ | កម្រិតសាលារៀនទី៣ | កម្រិតសាលារៀនទី៤ | កម្រិតសាលារៀនទី៥ |
| អគ្គិសនី | មិនមានអគ្គិសនី។ | មានអគ្គិសនីតែនៅក្នុងបន្ទប់រដ្ឋបាល(ទីចាត់ការ)។ | មានអគ្គិសនីតែនៅក្នុងបន្ទប់រដ្ឋបាល (ទីចាត់ការ) បន្ទប់ ICT និងបន្ទប់វិទ្យាសាស្ត្រ។ | មានអគ្គិសនីតែនៅក្នុងបន្ទប់រដ្ឋបាល (ទីចាត់ការ) បន្ទប់រៀន បន្ទប់ ICT និងបន្ទប់វិទ្យាសាស្ត្រ។ | មានអគ្គិសនីតែនៅក្នុងបន្ទប់រដ្ឋបាល (ទីចាត់ការ) បន្ទប់រៀន បន្ទប់ ICT និងបន្ទប់វិទ្យាសាស្ត្រ និងប្រើប្រាស់បានគ្រប់គ្រាន់។ |
| កំណត់សម្គាល់ | | | | | |
| ៤.៤.២ | ន័យសេចក្ដីខាងក្រោមនេះតើកម្រិតមួយណាល្អបំផុតត្រូវនឹងស្ថានភាពសាលារៀនលោក លោកស្រី | | | | |
| | កម្រិតសាលារៀនទី១ | កម្រិតសាលារៀនទី២ | កម្រិតសាលារៀនទី៣ | កម្រិតសាលារៀនទី៤ | កម្រិតសាលារៀនទី៥ |
| អ៊ីនធឺណិត | គ្មានអ៊ីនធឺណិតនៅតំបន់របស់យើង។ | មានអ៊ីនធឺណិតនៅតំបន់របស់យើង។ គ្រូបង្រៀននិងសិស្សនៅសាលារៀនរបស់យើងអាចភ្ជាប់អ៊ីនធឺណិតពីឧបករណ៍របស់ពួកគាត់ផ្ទាល់។ | សាលារៀនមានអ៊ីនធឺណិតបាននៅទីតាំងខ្លះៗតាមរយៈ WiFi ហើយមិនមានតាមបន្ទប់រៀននោះទេ។ | សាលារៀនភ្ជាប់អ៊ីនធឺណិតដល់គ្រូបង្រៀននិងសិស្សទាំងអស់គ្រប់ទីកន្លែងក្នុងសាលារៀនតាមរយៈ WiFi តែជួនកាលអ៊ីនធឺណិតខ្សោយ។ | សាលារៀនភ្ជាប់អ៊ីនធឺណិតល្បឿនលឿនដល់គ្រូបង្រៀន និងសិស្សទាំងអស់គ្រប់ទីកន្លែងក្នុងសាលារៀនតាមរយៈ WiFi។ |
| កំណត់សម្គាល់ | | | | | |

| ៤.៤.៣ | តើសាលារៀនមានបង្គន់អនាម័យ និងកន្លែងលាងដោយឡែកសម្រាប់សិស្សប្រុស និងសិស្សស្រី? តើមានការផ្គត់ផ្គង់ទឹកដំណើរការល្អ ផ្តល់សាប៊ូគ្រប់គ្រាន់ រក្សាទុកសំឡីអនាម័យដោយសុវត្ថិភាព មានពន្លឺគ្រប់គ្រាន់ និងមានសោចាក់ក្នុងបង្គន់បានកម្រិតណា? | | | | |
|---|---|---|---|---|---|
| | កម្រិតសាលារៀនទី១ | កម្រិតសាលារៀនទី២ | កម្រិតសាលារៀនទី៣ | កម្រិតសាលារៀនទី៤ | កម្រិតសាលារៀនទី៥ |
| អនាម័យ ការសម្អាត និងទឹក | មិនមានបង្គន់ និងកន្លែងលាងដៃ។ | មានបង្គន់និងកន្លែងលាងដៃ តែមិនគ្រប់គ្រាន់។ | មានបង្គន់និងកន្លែងលាងដៃ គ្រប់គ្រាន់ តែសម្ភារអនាម័យមិនគ្រប់គ្រាន់។ | មានបង្គន់និងកន្លែងលាងដៃ គ្រប់គ្រាន់ មានសុវត្ថិភាព និងមានសម្ភារអនាម័យគ្រប់គ្រាន់។ | មានបង្គន់និងកន្លែងលាងដៃ គ្រប់និយាម មានសុវត្ថិភាព មានពន្លឺគ្រប់គ្រាន់ និងមានសម្ភារអនាម័យគ្រប់គ្រាន់ ព្រមទាំងមានការសម្អាតជាប្រចាំ។ |
| កំណត់សម្គាល់ | | | | | |

# ឧបករណ៍ស្វ័យវាយតម្លៃ

## សមាសភាគទី៤ ៖ ការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធ

សូមពិនិត្យបច្ចុប្បន្នភាពនៃស្ថានភាពសាលារៀនតាមសំណួរ ឬការពិពណ៌នារបស់ឧបករណ៍ស្វ័យវាយតម្លៃនៅក្នុងតារាងខាងក្រោមនេះដោយគូសសញ្ញា (✓) ក្នុងជួរឈរ ដែលត្រូវជាមួយស្ថានភាពសាលារៀនលោក លោកស្រី។

| ល.រ | សមាសភាគរង | ល.រ | ប្រធានបទ | កម្រិតសាលារៀន ទី១ | កម្រិតសាលារៀន ទី២ | កម្រិតសាលារៀន ទី៣ | កម្រិតសាលារៀន ទី៤ | កម្រិតសាលារៀន ទី៥ |
|---|---|---|---|---|---|---|---|---|
| ៤ | សម្ភាររូបវន្ត | ៤.១.១ | សម្ភាររូបវន្តស្វែម | | | | | |
| | | ៤.១.២ | សម្ភាររូបវន្តបច្ចេកវិទ្យា | | | | | |
| | | ៤.១.៣ | បណ្ណាល័យ | | | | | |
| | | ៤.១.៤ | សុវត្ថិភាព | | | | | |
| | | ៤.១.៥ | ការឆ្លើយតបនឹងយេនឌ័រ | | | | | |
| | លទ្ធភាពប្រើប្រាស់ | ៤.២.១ | លទ្ធភាពចូលប្រើប្រាស់បន្ទប់ពិសោធន៍ ឬបន្ទប់រៀនវិទ្យាសាស្ត្រ | | | | | |
| | | ៤.២.២ | លទ្ធភាពចូលប្រើប្រាស់បន្ទប់ ICT | | | | | |
| | | ៤.២.៣ | លទ្ធភាពចូលប្រើប្រាស់ប្រកបដោយបរិយាបន្ន | | | | | |
| | បរិក្ខារ | ៤.៣.១ | បរិក្ខារស្វែម | | | | | |
| | | ៤.៣.២ | សម្ភារគម្រោងស្វែម | | | | | |
| | | ៤.៣.៣ | សម្ភារស្វែមប្រើបានតែម្តង | | | | | |
| | | ៤.៣.៤ | បរិក្ខារបច្ចេកវិទ្យាអប់រំ | | | | | |
| | ការភ្ជាប់សេវាសាធារណៈ | ៤.៤.១ | អគ្គិសនី | | | | | |
| | | ៤.៤.២ | អ៊ីនធឺណិត | | | | | |
| | | ៤.៤.៣ | អនាម័យ ការសម្អាត និងទឹក | | | | | |
| សរុប | | | | /15 | /15 | /15 | /15 | /15 |

**ការណែនាំការប្រើប្រាស់ឧបករណ៍ស្វ័យវាយតម្លៃនៃក្របខណ្ឌអប់រំស្នេមកម្រិតសាលារៀន៖**

1. ក្នុងប្រធានបទនីមួយៗ សូមគូសសញ្ញា (✓) ដែលត្រូវជាមួយស្ថានភាព/ការអនុវត្តរបស់សាលារៀនលោកលោកស្រី
2. បូកសរុបចំនួនសញ្ញា (✓) ក្នុងកម្រិតនីមួយៗ
3. កម្រិតមួយណាដែលមានសញ្ញា (✓) ច្រើនជាងគេនោះវាជា កម្រិតអភិវឌ្ឍន៍តាមសមាសភាគ (DDL)
4. កត់ត្រាលទ្ធផលសម្រាប់ប្រើប្រាស់ក្នុងការពិនិត្យឡើងវិញ និងនិងប្រើប្រាស់នៅក្នុងឧបករណ៍កំណត់គោលដៅ (ជំហានទី៣)

| កម្រិតអភិវឌ្ឍន៍តាមសមាសភាគ (DDL) |
|---|
| កម្រិតអភិវឌ្ឍន៍របស់សាលារៀនសម្រាប់សមាសភាគ ណាមួយអាស្រ័យលើពិន្ទុនៃសមត្ថភាពស្នេមពីកម្រិតសាលារៀនទី១ ដល់ ៥។ |

**ការកំណត់កម្រិតអភិវឌ្ឍន៍តាមសមាសភាគ (DDL)** សម្រាប់សមាសភាគនេះ៖ សាលារៀនយើងមានសញ្ញា (✓) ច្រើនជាងគេនៅកម្រិតសាលារៀនទី________។ដូច្នេះវា ជាកម្រិតអភិវឌ្ឍន៍សម្រាប់សមាសភាគនេះ ដែលត្រូវជាមួយស្ថានភាព/ការអនុវត្តរបស់សាលារៀនយើង ។

**ចំណុចខ្លាំង**

សមាសភាគរង/ប្រធានបទមួយចំនួនមានពិន្ទុខ្ពស់ជាងកម្រិតអភិវឌ្ឍន៍តាមសមាសភាគ (DDL)។ ដូច្នេះភាពខ្លាំងរបស់សមាសភាគរង/ប្រធានបទគឺ៖

(រៀបចំជាតារាងបញ្ជីសមាសភាគរង/ប្រធានបទដែលមានចំនួនសញ្ញា (✓) ច្រើនជាងនៅក្នុងកម្រិតអភិវឌ្ឍន៍ដែលបានកំណត់)

**ឱកាសសម្រាប់អភិវឌ្ឍ (ចំណុចខ្សោយ)៖**

សមាសភាគរង/ប្រធានបទមួយចំនួនមានពិន្ទុទាបជាងកម្រិតអភិវឌ្ឍន៍តាមសមាសភាគ (DDL)។ ដូច្នេះឱកាសសម្រាប់អភិវឌ្ឍ គឺស្ថិតនៅក្នុងសមាសភាគរង/ប្រធានបទដូចខាងក្រោម៖

(រៀបចំជាតារាងបញ្ជីសមាសភាគរង/ប្រធានបទដែលមានចំនួនសញ្ញា (✓) តិចជាងនៅក្នុងកម្រិតអភិវឌ្ឍន៍ដែលបានកំណត់)

# ជំហានទី២៖ ឧបករណ៍ស្វ័យវាយតម្លៃ

## សមាសភាគទី៥៖ ការចូលរួមរបស់សហគមន៍

| | |
|---|---|
| **សមាសភាគទី៥** | ការចូលរួមរបស់សហគមន៍ |
| **អ្នកទទួលខុសត្រូវ** | សមាជិកបង្គោល ដែលទទួលខុសត្រូវសមាសភាគនេះត្រូវក្នុងការបំពេញឧបករណ៍ស្វ័យវាយតម្លៃ។ ពួកគាត់គួរតែស្នើសុំជាតុចូលពីសមាជិកគាំទ្រឬក៏បុគ្គលិកសាលារៀនដទៃទៀត។ |
| **សមាជិកបង្គោលសម្រាប់សមាសភាគនេះ** | |
| **ឆ្នាំទី** | ( ឧ. ឆ្នាំទី១៖ ឆ្នាំសិក្សា២០២៤-២០២៥ ) |
| **លំនាំដំណើរការ** | ក្របខណ្ឌអប់រំស្ទែមកម្រិតសាលារៀនជួយសាលារៀន ដើម្បីកែលម្អការបង្រៀននិងការរៀនមុខវិជ្ជាស្ទែមតាមរយៈដំណើរការ ៥ ជំហាន។ ឧបករណ៍ស្វ័យវាយតម្លៃរបស់ក្របខណ្ឌអប់រំស្ទែមកម្រិតសាលារៀននេះគឺជាជំហានទី៥ នៃដំណើរការទាំង៥ជំហាន។ ឧបករណ៍ស្វ័យវាយតម្លៃរបស់ក្របខណ្ឌអប់រំស្ទែមកម្រិតសាលារៀន សម្រាប់សមាសភាគស្ទែមទី៥ គឺការចូលរួមរបស់សហគមន៍ ដែលមានសមាសភាគរង៖<br>៥.១ ការចូលរួម និងគាំទ្ររបស់សហគមន៍<br>៥.២ ភាពជាដៃគូយុទ្ធសាស្ត្រ<br>៥.៣ សកម្មភាពស្ទែមក្រៅម៉ោងសិក្សា<br> |

| | |
|---|---|
| **គោលបំណងរបស់ឧបករណ៍** | ឧបករណ៍ស្វ័យវាយតម្លៃនឹងជួយក្រុមអនុវត្តសកម្មភាពស្ទែមរបស់សាលារៀនរបស់លោក លោកស្រីដើម្បីពិនិត្យមើលឡើងវិញការអនុវត្តស្ទែម នាពេលបច្ចុប្បន្ន និងកំណត់កម្រិតនៃក្របខណ្ឌណាមួយដែលសមស្របបំផុតនឹងស្ថានភាពបច្ចុប្បន្នរបស់សាលារៀនលោក លោកស្រី។ ឧបករណ៍នេះនឹងជួយលោក លោកស្រីកំណត់ចំណុចដែលត្រូវយកចិត្តទុកដាក់ និងណែនាំលោក លោកស្រីក្នុងការកំណត់គោលដៅសម្រាប់អភិវឌ្ឍនាឆ្នាំខាងមុខ។ ឧបករណ៍នេះផងដែរបង្កើតឡើងមិនមែនក្នុងបំណងដើរតួជាឧបករណ៍វិនិច្ឆ័យ ឬវង្វាយតម្លៃនេះទេ។ លោក លោកស្រីត្រូវបានលើកទឹកចិត្តឱ្យធ្វើការឆ្លុះបញ្ចាំងដោយភាពស្មោះត្រង់លើការអនុវត្តរបស់សាលារៀនលោក លោកស្រី ដើម្បីធានាថាការផ្តល់អនុសាសន៍គឺសមស្របនឹងសមត្ថភាពសាលារៀន និងផ្តល់អត្ថប្រយោជន៍ដល់សាលារៀនលោក លោកស្រី។ |
| **ការណែនាំ** | 1. បោះពុម្ពឧបករណ៍ស្វ័យវាយតម្លៃដាក់នៅខាងក្រោយឯកសារ<br>2. បោះពុម្ពឧបករណ៍ស្វ័យវាយតម្លៃដាក់ ដែលនៅផ្នែកខាងក្រោយនៃក្របខណ្ឌ<br>3. បំពេញតារាងខាងក្រោម ដោយជ្រើសរើសចម្លើយស្របតាមសំណួរនីមួយៗនៅក្នុងសមាសភាគរង និងប្រធានបទ សូមឆ្លុះបញ្ចាំងដោយភាពស្មោះត្រង់លើស្ថានភាពនៃការអនុវត្តនៅសាលារៀនរបស់លោក លោកស្រី បន្ទាប់មក សូមកំណត់កម្រិតអភិវឌ្ឍន៍ដែលស័ក្តិសមបំផុត។ លោក លោកស្រីប្រហែលរកឃើញស្ថានភាពសាលារៀនក្នុងកម្រិតខុសៗគ្នា អាស្រ័យលើប្រធានបទ<br>4. ពិនិត្យមើលត្រង់ចំណុចសម្គាល់សម្រាប់សំណួរនីមួយៗ ដើម្បីផ្ទៀងផ្ទាត់ឡើងវិញទៅលើខ្លឹមសារណាដែលមិនច្បាស់<br>5. កត់ត្រាចម្លើយរបស់លោក លោកស្រីនៅលើឧបករណ៍ស្វ័យវាយតម្លៃនៅផ្នែកខាងក្រោយនៃក្របខណ្ឌ ដោយគូសសញ្ញា (✓) ដែលត្រូវនឹងស្ថានភាពបច្ចុប្បន្នរបស់សាលារៀន<br>6. នៅពេលគូសរួចរាល់ លោក លោកស្រីត្រូវបូកសរុបពិន្ទុដោយរាប់ចំនួនសញ្ញា (✓) នៅតាមកម្រិតនីមួយៗ<br>7. អនុវត្តតាមការណែនាំនៅផ្នែកខាងក្រោយនៃក្របខណ្ឌ ដើម្បីកំណត់កម្រិតអភិវឌ្ឍន៍តាមសមាសភាគ (DDL) សម្រាប់សមាសភាគនេះ (កម្រិត ដែលមានសញ្ញា (✓) ច្រើនជាងគេបំផុត) កំណត់បានចំណុចខ្លាំង និងកំណត់ចំណុចដែលត្រូវពង្រឹង។ |

| ៥.១.១ | ៥.១ ការចូលរួមរបស់សហគមន៍ | | | | |
|---|---|---|---|---|---|
| | តើខ្លឹមសារមួយណាដែលសមស្របបំផុតជាមួយស្ថានភាពសាលារៀនរបស់លោក លោកស្រី? | | | | |
| | កម្រិតសាលារៀនទី១ | កម្រិតសាលារៀនទី២ | កម្រិតសាលារៀនទី៣ | កម្រិតសាលារៀនទី៤ | កម្រិតសាលារៀនទី៥ |
| ការប្រាស្រ័យទាក់ទង | សាលារៀនរបស់យើងមិនបានប្រាស្រ័យទាក់ទងជាមួយគ្រួសារសិស្សលើការអប់រំស្ទែមនោះ ទេ។ | សាលារៀនរបស់យើងកម្រប្រាស្រ័យទាក់ទងជាមួយគ្រួសារសិស្សលើការអប់រំស្ទែម ដោយមិនផ្តោតជាពិសេសលើការលើកកម្ពស់ការយល់ដឹងអំពីជំនាញស្ទែមនោះទេ។ | សាលារៀនរបស់យើងប្រាស្រ័យទាក់ទងជាមួយក្រុមគ្រួសារសិស្សជាញឹកញាប់លើការអប់រំស្ទែម ដោយធ្វើឱ្យប្រសើរឡើងនូវការយល់ដឹងអំពីជំនាញស្ទែម។ | សាលារៀនរបស់យើងបានប្រាស្រ័យទាក់ទងជាមួយគ្រួសារសិស្សជាទៀងទាត់លើការអប់រំស្ទែម ដើម្បីធ្វើឱ្យប្រសើរឡើងនូវការយល់ដឹងអំពីជំនាញស្ទែម និងការលើកកម្ពស់ស្ទែមអាជីព។ | សាលារៀនរបស់យើងបានប្រាស្រ័យទាក់ទងជាប់លាប់ជាមួយគ្រួសារសិស្ស តាមវិធីសមស្របផ្សេងៗ សម្រាប់គ្រប់ស្ថានភាពសេដ្ឋកិច្ច-សង្គម ដើម្បីផ្តល់ព័ត៌មានប្រកបដោយប្រសិទ្ធភាពអំពីការអប់រំស្ទែម។ |
| កំណត់សម្គាល់ | កម្រ៖ ម្តងក្នុងមួយឆ្នាំ<br>ញឹកញាប់៖ ម្តងក្នុងមួយត្រីមាស<br>ទៀងទាត់៖ ប្រចាំខែ<br>ជាប់លាប់៖ ច្រើនជាងម្តងក្នុងមួយខែ | | | | |
| ៥.១.២ | តើខ្លឹមសារមួយណាដែលសមស្របបំផុតជាមួយស្ថានភាពសាលារៀនរបស់លោក លោកស្រី? | | | | |
| | កម្រិតសាលារៀនទី១ | កម្រិតសាលារៀនទី២ | កម្រិតសាលារៀនទី៣ | កម្រិតសាលារៀនទី៤ | កម្រិតសាលារៀនទី៥ |
| ការចូលរួមគាំទ្រ | សាលារៀនរបស់យើងមិនបានឱ្យគ្រួសារសិស្សចូលរួមក្នុងការអប់រំស្ទែមទេ។ | សាលារៀនរបស់យើងដឹងពីសារៈសំខាន់នៃការចូលរួមពីគ្រួសារសិស្សនៅក្នុងការអប់រំស្ទែម និងកំពុងបង្កើតផែនការដើម្បីអញ្ជើញគ្រួសារសិស្សឱ្យចូលរួមយ៉ាងហោចណាស់ម្តងក្នុងឆ្នាំសិក្សាខាងមុខនេះ។ | សាលារៀនរបស់យើងបានអញ្ជើញគ្រួសារសិស្សឱ្យចូលរួមសង្កេតនិងចូលរួមក្នុងសកម្មភាពសិក្សាស្ទែមយ៉ាងហោចណាស់ពីរដងក្នុងមួយឆ្នាំ។ សមាជិកគ្រួសារដែលធ្វើការក្នុងវិស័យស្ទែមបានចែករំលែកបទពិសោធន៍របស់ពួកគាត់នៅឱកាសមួយដ៏កម្រ។ | សាលារៀនរបស់យើងបានឱ្យគ្រួសារសិស្សចូលរួមជាមួយ និងលើកទឹកចិត្តឱ្យមានការចូលរួមរបស់ពួកគាត់នៅក្នុងសកម្មភាពសិក្សាស្ទែមយ៉ាងហោចណាស់ម្តងក្នុងមួយឆមាស។ សមាជិកគ្រួសារដែលធ្វើការក្នុងវិស័យស្ទែមបានចែករំលែកបទពិសោធន៍របស់ពួកគាត់។ | សាលារៀនរបស់យើងបានអញ្ជើញគ្រួសារសិស្សឱ្យចូលរួមក្នុងសកម្មភាពសិក្សាស្ទែមយ៉ាងហោចណាស់ម្តងក្នុងមួយឆមាស ព្រមទាំងប្រមូលមតិត្រឡប់ពីគ្រួសារសិស្សដើម្បីកែលម្អផលជះដែលកើតឡើងនាពេលអនាគត។ ការចែករំលែកបទពិសោធន៍របស់សមាជិកគ្រួសារសិស្សដែលធ្វើការក្នុងវិស័យស្ទែម |

| | | | | | |
|---|---|---|---|---|---|
| | | | | | ត្រូវបានធ្វើជាប្រចាំ និងផ្តោតលើការបន្សុីកម្មវិធីសិក្សា។ |
| កំណត់សម្គាល់ | ឧទាហរណ៍នៃសកម្មភាពសិក្សាស្នែម៖ ពិព័រណ៍ស្នែម ការពិភាក្សាលើអាជីពស្នែម និងក្លឹបសិក្សាស្នែម។ | | | | |
| ៥.១.៣ | **តើខ្លឹមសារមួយណាដែលសមស្របបំផុតជាមួយស្ថានភាពសាលារៀនរបស់លោក លោកស្រី ?** | | | | |
| | **កម្រិតសាលារៀនទី១** | **កម្រិតសាលារៀនទី២** | **កម្រិតសាលារៀនទី៣** | **កម្រិតសាលារៀនទី៤** | **កម្រិតសាលារៀនទី៥** |
| គ្រួសារ និងផ្នត់គំនិតយេនឌ័រនៅក្នុងស្នែម | សាលារៀនរបស់យើងមិនបាននិយាយច្បាស់អំពីផ្នត់គំនិតយេនឌ័រក្នុងសហគមន៍សាលារៀនរបស់យើងទេ។ | សាលារៀនរបស់យើងដឹងពីតួនាទីរបស់ខ្លួនក្នុងការដោះស្រាយបញ្ហាផ្នត់គំនិតយេនឌ័រនៅក្នុងបរិបទនៃស្នែមអាជីព ប៉ុន្តែមិនទាន់ច្បាស់អំពីរបៀបដោះស្រាយបញ្ហានៅក្នុងសហគមន៍នៅសាលារៀនរបស់យើងទេ។ | សាលារៀនរបស់យើងបានខិតខំដោះស្រាយបញ្ហាផ្នត់គំនិតយេនឌ័រក្នុងស្នែមអាជីព ដោយប្រើភាសាឆ្លើយតបនឹងយេនឌ័រក្នុងទំនាក់ទំនងលើការសិក្សាស្នែម។ | សាលារៀនរបស់យើងបានខិតខំដោះស្រាយបញ្ហាផ្នត់គំនិតយេនឌ័រក្នុងស្នែមអាជីព ដោយប្រើភាសាឆ្លើយតបនឹងយេនឌ័រក្នុងទំនាក់ទំនងលើការសិក្សាស្នែម ព្រមទាំងធ្វើផែនការដើម្បីឱ្យមានសមភាពយេនឌ័រ នៅពេលជ្រើសរើសអ្នកជំនាញស្នែមចេញពីក្រុមគ្រួសារសិស្សឱ្យចូលរួមក្នុងព្រឹត្តិការណ៍ស្នែមនៅក្នុងសាលារៀន។ | សាលារៀនរបស់យើងបានលើកកម្ពស់យ៉ាងសកម្មអំពីស្នែមអាជីពសម្រាប់សិស្សស្រី និងស្ត្រី តាមរយៈការប្រើប្រាស់ភាសាឆ្លើយតបនឹងយេនឌ័រ និងរៀបចំព្រឹត្តិការណ៍ដែលផ្តោតលើអ្នកជំនាញស្នែមជាស្ត្រី។ សាលារៀនរបស់យើងក៏ដោះស្រាយកង្វល់ទាំងឡាយដែលជួបប្រទះដោយក្រុមគ្រួសាររបស់សិស្សស្រីដែលកំពុងស្វែងរកស្នែមអាជីពផងដែរ។ |
| កំណត់សម្គាល់ | | | | | |

| ៥.២.១ | ៥.២ ភាពជាដៃយុទ្ធសាស្ត្រ | | | | |
|---|---|---|---|---|---|
| | តើខ្លឹមសារមួយណាដែលសមស្របបំផុតជាមួយស្ថានភាពសាលារៀនរបស់លោក លោកស្រី? | | | | |
| | កម្រិតសាលារៀនទី១ | កម្រិតសាលារៀនទី២ | កម្រិតសាលារៀនទី៣ | កម្រិតសាលារៀនទី៤ | កម្រិតសាលារៀនទី៥ |
| ភាពជាដៃគូស្ទែម | សាលារៀនរបស់យើងមិនបានទាក់ទងជាមួយអ្នកពាក់ព័ន្ធដែលមានជំនាញស្ទែមពីខាងក្រៅទេ។ | សាលារៀនរបស់យើងបានកំណត់អំពីអ្នកពាក់ព័ន្ធដែលមានជំនាញស្ទែមពីខាងក្រៅដែលមានសក្តានុពល ហើយគ្រោងនឹងបង្កើតកិច្ចសហប្រតិបត្តិការលើជំនាញស្ទែមដើម្បីលើកកម្ពស់ការរៀនមុខវិជ្ជា ស្ទែមក្នុងឆ្នាំសិក្សាខាងមុខនេះ។ | សាលារៀនរបស់យើងបានបង្កើតកិច្ចសហប្រតិបត្តិការជាមួយអ្នកពាក់ព័ន្ធដែលមានជំនាញស្ទែមពីខាងក្រៅតែនៅមានកម្រិត។ | សាលារៀនរបស់យើងបានបង្កើតកិច្ចសហប្រតិបត្តិការរយៈពេលខ្លីជាមួយអ្នកពាក់ព័ន្ធដែលមានជំនាញស្ទែមពីខាងក្រៅ។ | សាលារៀនរបស់យើងបានបង្កើតកិច្ចសហប្រតិបត្តិការរយៈពេលវែងជាមួយអ្នកពាក់ព័ន្ធដែលមានជំនាញស្ទែមពីខាងក្រៅ។ |
| កំណត់សម្គាល់ | អ្នកពាក់ព័ន្ធដែលមានជំនាញស្ទែម៖ បុគ្គល អង្គការ ឬក្រុមហ៊ុនដែលមានចំណាប់អារម្មណ៍លើផ្នែកស្ទែម។ ឧទាហរណ៍ដូចជា៖ សមាជិកគ្រួសារសិស្សដែលធ្វើការលើជំនាញស្ទែម សាលារៀនផ្សេងៗទៀត អង្គការសហគមន៍មូលដ្ឋាន អាជីវកម្ម គ្រឹះស្ថានឧត្តមសិក្សា និងមជ្ឈមណ្ឌលវិទ្យាសាស្ត្រនិងបច្ចេកវិទ្យា<br>កិច្ចសហប្រតិបត្តិការរយៈពេលវែង៖ យ៉ាងតិច ២ឆ្នាំ។ | | | | |
| ៥.២.២ | តើខ្លឹមសារមួយណាដែលសមស្របបំផុតជាមួយស្ថានភាពសាលារៀនរបស់លោក លោកស្រី? | | | | |
| | កម្រិតសាលារៀនទី១ | កម្រិតសាលារៀនទី២ | កម្រិតសាលារៀនទី៣ | កម្រិតសាលារៀនទី៤ | កម្រិតសាលារៀនទី៥ |
| ការប្រាស្រ័យទាក់ទងជាមួយអ្នកពាក់ព័ន្ធស្ទែម | សាលារៀនរបស់យើងមិនបានប្រាស្រ័យទាក់ទងជាមួយអ្នកពាក់ព័ន្ធដែលមានជំនាញស្ទែមពីខាងក្រៅទាក់ទងនឹងការអប់រំស្ទែម។ | សាលារៀនរបស់យើងមិនបានប្រាស្រ័យទាក់ទងជាមួយអ្នកពាក់ព័ន្ធដែលមានជំនាញស្ទែមពីខាងក្រៅ ប៉ុន្តែគ្រោងនឹងធ្វើនៅឆ្នាំសិក្សាខាងមុខ។ | សាលារៀនរបស់យើងបានប្រាស្រ័យទាក់ទងជាមួយអ្នកពាក់ព័ន្ធដែលមានជំនាញស្ទែមពីខាងក្រៅជាញឹកញាប់។ | សាលារៀនរបស់យើងបានប្រាស្រ័យទាក់ទង ជាមួយអ្នកពាក់ព័ន្ធដែលមានជំនាញស្ទែមពីខាងក្រៅជាទៀងទាត់។ | សាលារៀនរបស់យើងបានប្រាស្រ័យទាក់ទង ជាមួយអ្នកពាក់ព័ន្ធដែលមានជំនាញស្ទែមពីខាងក្រៅជាទៀងទាត់ តាមរយៈកម្មវិធីដូចជា អ៊ីមែល, គេហទំព័រ, ទស្សនាវដ្តី និងប្រព័ន្ធផ្សព្វផ្សាយសង្គមដទៃទៀត។ |

| | | | | | |
|---|---|---|---|---|---|
| កំណត់សម្គាល់ | ឧទាហរណ៍នៃកម្មវិធីទំនាក់ទំនង៖ អ៊ីមែល, គេហទំព័រ, ទស្សនាវដ្ដី និងប្រព័ន្ធផ្សព្វផ្សាយសង្គមដទៃទៀត។ | | | | |
| ៥.២.៣ | **តើខ្លឹមសារមួយណាដែលសមស្របបំផុតជាមួយស្ថានភាពសាលារៀនរបស់លោក លោកស្រី ?** | | | | |
| | **កម្រិតសាលារៀនទី១** | **កម្រិតសាលារៀនទី២** | **កម្រិតសាលារៀនទី៣** | **កម្រិតសាលារៀនទី៤** | **កម្រិតសាលារៀនទី៥** |
| ភាពជាដៃគូជាមួយសាលារៀនផ្សេងៗ | សាលារៀនរបស់យើងមិនបានប្រាស្រ័យទាក់ទងជាមួយសាលារៀនដទៃទាក់ទងនឹងការអប់រំស្ទែម។ | កម្រមានឱកាសក្នុងការសហការ និង/ឬទស្សនកិច្ចសិក្សានៅសាលារៀនផ្សេងៗទៀតដែលមានការអនុវត្តការអប់រំស្ទែមស្រដៀងគ្នា។ | សាលារៀនរបស់យើងមានឱកាសតិចតួចក្នុងការសហការ និង/ឬទស្សនកិច្ចសិក្សានៅសាលារៀនផ្សេងៗទៀតដែលមានការអនុវត្ត ការអប់រំស្ទែមស្រដៀងគ្នា។ | សាលារបស់យើងបានសហការ និង/ឬទស្សនកិច្ចសិក្សាយ៉ាងទៀងទាត់ នៅសាលារៀនផ្សេងៗទៀតដែលមានការអនុវត្តការអប់រំស្ទែមស្រដៀងគ្នា។ | សាលារៀនរបស់យើងបានបង្កើតឱកាសយ៉ាងសកម្មសម្រាប់ការសហការជាមួយសាលារៀនផ្សេងៗទៀតដែលមានការអនុវត្តការអប់រំស្ទែមស្រដៀងគ្នា។ |
| កំណត់សម្គាល់ | សាលារៀន៖ គណៈគ្រប់គ្រងសាលារៀន គ្រូ និង/ឬសិស្ស | | | | |

| | | | | | |
|---|---|---|---|---|---|
| ៥.៣.១ | **៥.៣ សកម្មភាពស្ទែមក្រៅម៉ោងសិក្សា** | | | | |
| | ចំណាំ៖ សកម្មភាពស្ទែមក្រៅកម្មវិធីសិក្សា គឺជាសកម្មភាពទាក់ទងនឹងបំណិនស្ទែម ដែលជាធម្មតាកើតឡើងនៅក្នុង ឬនៅក្រៅសាលារៀននៅថ្ងៃរៀនធម្មតា ដោយពង្រឹងការបង្រៀននិងការរៀនលើមុខវិជ្ជាស្ទែម។ ឧទាហរណ៍ដូចជា ក្លិបសិក្សាក្រៅម៉ោងសិក្សា, កម្មវិធីសិក្សានៅថ្ងៃឈប់សម្រាក, ពិព័រណ៍ស្ទែម, ការប្រកួតប្រជែងស្ទែម និងការពិភាក្សាអាជីពស្ទែម ជាដើម។ (ក្លិបសិក្សានៅសាលារៀនដែលមានការបង្រៀនអំពីទ្រឹស្តីលើបំណិនស្ទែមមិនត្រូវបានចាត់ទុកថាជាសកម្មភាពសិក្សាក្រៅកម្មវិធីសិក្សានៅក្នុងបរិបទនេះទេ។) | | | | |
| | **សាលារៀនរបស់យើង៖** | | | | |
| | **កម្រិតសាលារៀនទី១** | **កម្រិតសាលារៀនទី២** | **កម្រិតសាលារៀនទី៣** | **កម្រិតសាលារៀនទី៤** | **កម្រិតសាលារៀនទី៥** |
| ក្លឹបសិក្សាស្ទែមក្រៅសាលារៀន | មិនបានរៀបចំក្លឹបសិក្សាស្ទែមក្រៅសាលារៀនទេ។ | កំពុងរៀបចំដើម្បីដំណើរការក្លឹបសិក្សាស្ទែមក្រៅសាលារៀនក្នុងឆ្នាំសិក្សាខាងមុខនេះ។ | រៀបចំក្លឹបសិក្សាស្ទែមក្រៅសាលារៀនសម្រាប់សិស្សមួយចំនួននៅក្នុងកម្រិតណាមួយ ដោយប្រើកម្មវិធី ឬសម្ភារដែលបានគ្រោងទុកជាមុនដែលមាននៅលើអ៊ីនធឺណិត ឬបានពីក្រសួងអ.យ.ក។ | រៀបចំក្លឹបសិក្សាស្ទែមក្រៅសាលារៀនសម្រាប់សិស្សទាំងអស់ដែលចង់ចូលរួម។ ក្លឹបទាំងនេះប្រើប្រាស់កម្មវិធី ឬសម្ភារចម្រុះ ដោយប្រើកម្មវិធី ឬសម្ភារដែលបានគ្រោងទុកជាមុនដែលមាននៅលើអ៊ីនធឺណិត ឬបានពីក្រសួងអ.យ.ក ដោយមានការចូលរួមពីគ្រូស្ទែមមួយចំនួនរបស់យើង។ | រៀបចំក្លឹបសិក្សាស្ទែមក្រៅសាលារៀនសម្រាប់សិស្សទាំងអស់ដែលចង់ចូលរួម។ គ្រូស្ទែមរបស់យើងស្រាវជ្រាវជាទៀងទាត់សម្រាប់គំនិត ឬធនធានថ្មីៗដែលមាននៅលើអ៊ីនធឺណិត ដើម្បីសម្របនឹងតម្រូវការរបស់យើង។ ពួកគាត់ចែករំលែកសម្ភារទាំងនេះផងដែរ និងជួយដល់សាលារៀនផ្សេងទៀតតាមរយៈសហគមន៍សិក្សាវិជ្ជាជីវៈ។ |
| កំណត់សម្គាល់ | | | | | |
| ៥.៣.២ | **សាលារៀនរបស់យើង៖** | | | | |
| | **កម្រិតសាលារៀនទី១** | **កម្រិតសាលារៀនទី២** | **កម្រិតសាលារៀនទី៣** | **កម្រិតសាលារៀនទី៤** | **កម្រិតសាលារៀនទី៥** |

| | | | | | |
|---|---|---|---|---|---|
| ការតាំងពិព័រណ៍ស្ទែមនៅក្នុងសាលារៀន | មិនបានរៀបចំពិព័រណ៍ស្ទែមនៅក្នុងសាលារៀនទេ។ | កំពុងរៀបចំពិព័រណ៍ស្ទែមនៅក្នុងសាលារៀនក្នុងឆ្នាំសិក្សាខាងមុខនេះ។ | បានរៀបចំពិព័រណ៍ស្ទែមនៅក្នុងសាលារៀនម្តងក្នុងមួយឆ្នាំ។ | បានរៀបចំពិព័រណ៍ស្ទែមនៅក្នុងសាលារៀនម្តងក្នុងមួយឆ្នាំ ដោយអញ្ជើញគ្រួសារសិស្ស និងសាលារៀនក្នុងតំបន់ឱ្យចូលរួម។ | សាលារៀនរបស់យើងបានរៀបចំពិព័រណ៍ស្ទែមជាប្រចាំឆ្នាំនៅក្នុងសាលារៀន ដោយអញ្ជើញគ្រួសារសិស្ស និងសាលារៀនក្នុងស្រុកមួយចំនួនឱ្យចូលរួម។ យើងក៏ចែករំលែកនូវនីតិវិធី និងការណែនាំដើម្បីគាំទ្រដល់សាលារៀនផ្សេងៗទៀតក្នុងការធ្វើជាម្ចាស់ផ្ទះក្នុងការរៀបចំពិព័រណ៍ស្ទែមតាមរយៈសហគមន៍សិក្សាវិជ្ជាជីវៈ។ |
| កំណត់សម្គាល់ | | | | | |
| ៥.៣.៣ | **សាលារៀនរបស់យើង៖** | | | | |
| | **កម្រិតសាលារៀនទី១** | **កម្រិតសាលារៀនទី២** | **កម្រិតសាលារៀនទី៣** | **កម្រិតសាលារៀនទី៤** | **កម្រិតសាលារៀនទី៥** |
| ព្រឹត្តិការណ៍ស្ទែម ឬការប្រកួតប្រជែងស្ទែម | មិនបានចូលរួមក្នុងការប្រកួតប្រជែងស្ទែមឬទស្សនាព្រឹត្តិការណ៍ស្ទែម ហើយមិនមានគម្រោងចូលរួម។ | កំពុងស្វែងរកជម្រើសសម្រាប់ព្រឹត្តិការណ៍ស្ទែម ឬការប្រកួតប្រជែងស្ទែមដែលសមស្របសម្រាប់សិស្សរបស់យើងក្នុងការចូលរួមនៅក្នុងឆ្នាំសិក្សាខាងមុខនេះ។ | ផ្តល់ឱកាសដល់សិស្សដែលចង់ចូលរួមក្នុងព្រឹត្តិការណ៍ និងការប្រកួតប្រជែងលើបំណិនស្ទែមថ្នាក់ជាតិ។ | បានលើកទឹកចិត្តដល់សិស្សទាំងអស់ឱ្យចូលរួមជាប្រចាំក្នុងព្រឹត្តិការណ៍ស្ទែម ឬការប្រកួតប្រជែងស្ទែមថ្នាក់ជាតិ និងអន្តរជាតិ។ | បានចូលរួមយ៉ាងទៀងទាត់ និងជួយរៀបចំព្រឹត្តិការណ៍ស្ទែម ឬការប្រកួតប្រជែងស្ទែមថ្នាក់ជាតិ និងអន្តរជាតិ ដោយបានផ្តល់ការគាំទ្រ និងសម្ភារបរិក្ខារ ដូចជាទីកន្លែង។ |
| កំណត់សម្គាល់ | | | | | |

# ឧបករណ៍ស្វ័យវាយតម្លៃ

## សមាសភាគទី៥ ៖ ការចូលរួមរបស់សហគមន៍

សូមពិនិត្យបច្ចុប្បន្នភាពនៃស្ថានភាពសាលារៀនតាមសំណួរ ឬការពិពណ៌នារបស់ឧបករណ៍ស្វ័យវាយតម្លៃនៅក្នុងតារាងខាងក្រោមនេះដោយគូសសញ្ញា (✓) ក្នុងជួរឈរ ដែលត្រូវជាមួយស្ថានភាពសាលារៀនលោក លោកស្រី។

| ល.រ | សមាសភាគរង | ល.រ | ប្រធានបទ | កម្រិតសាលារៀនទី១ | កម្រិតសាលារៀនទី២ | កម្រិតសាលារៀនទី៣ | កម្រិតសាលារៀនទី៤ | កម្រិតសាលារៀនទី៥ |
|---|---|---|---|---|---|---|---|---|
| ៥ | ការចូលរួម និងគាំទ្ររបស់សហគមន៍ | ៥.១.១ | ការប្រាស្រ័យទាក់ទង | | | | | |
| | | ៥.១.២ | ការចូលរួមគាំទ្រ | | | | | |
| | | ៥.១.៣ | គ្រួសារ និងផ្នត់គំនិតអំពីយេនឌ័រក្នុងស្ទែម | | | | | |
| | ភាពជាដៃគូយុទ្ធសាស្ត្រ | ៥.២.១ | ភាពជាដៃគូស្ទែម | | | | | |
| | | ៥.២.២ | ការប្រាស្រ័យទាក់ទងជាមួយអ្នកពាក់ព័ន្ធស្ទែម | | | | | |
| | | ៥.២.៣ | ភាពជាដៃគូជាមួយសាលារៀនផ្សេងៗ | | | | | |
| | សកម្មភាពស្ទែមក្រៅម៉ោងសិក្សា | ៥.៣.១ | ក្លឹបសិក្សាស្ទែមក្រៅសាលារៀន | | | | | |
| | | ៥.៣.២ | ការតាំងពិពណ៌ស្ទែមនៅក្នុងសាលារៀន | | | | | |
| | | ៥.៣.៣ | ព្រឹត្តិការណ៍ស្ទែម ឬការប្រកួតប្រជែងស្ទែម | | | | | |
| | | | សរុប | /9 | /9 | /9 | /9 | /9 |

**ការណែនាំការប្រើប្រាស់ឧបករណ៍ស្វ័យវាយតម្លៃនៃក្របខណ្ឌអប់រំស្វែមកម្រិតសាលារៀន៖**

1. ក្នុងប្រធានបទនីមួយៗ សូមគូសសញ្ញា (✓) ដែលត្រូវជាមួយស្ថានភាព/ការអនុវត្តរបស់សាលារៀនលោកលោកស្រី
2. បូកសរុបចំនួនសញ្ញា (✓) ក្នុងកម្រិតនីមួយៗ
3. កម្រិតមួយណាដែលមានសញ្ញា (✓) ច្រើនជាងគេនោះវាជា កម្រិតអភិវឌ្ឍន៍តាមសមាសភាគ (DDL)
4. កត់ត្រាលទ្ធផលសម្រាប់ប្រើប្រាស់ក្នុងការពិនិត្យឡើងវិញ និងនិងប្រើប្រាស់នៅក្នុងឧបករណ៍កំណត់គោលដៅ (ជំហានទី៣)

| កម្រិតអភិវឌ្ឍន៍តាមសមាសភាគ (DDL) |
|---|
| កម្រិតអភិវឌ្ឍន៍របស់សាលារៀនសម្រាប់សមាសភាគ ណាមួយអាស្រ័យលើពិន្ទុនៃសមត្ថភាពស្វែមពីកម្រិតសាលារៀនទី១ ដល់ ៥។ |

**ការកំណត់កម្រិតអភិវឌ្ឍន៍តាមសមាសភាគ (DDL)** សម្រាប់សមាសភាគនេះ៖ សាលារៀនយើងមានសញ្ញា (✓) ច្រើនជាងគេនៅកម្រិតសាលារៀនទី________។ដូច្នេះវា ជាកម្រិតអភិវឌ្ឍន៍សម្រាប់សមាសភាគនេះ ដែលត្រូវជាមួយស្ថានភាព/ការអនុវត្តរបស់សាលារៀនយើង ។

**ចំណុចខ្លាំង**

សមាសភាគរង/ប្រធានបទមួយចំនួនមានពិន្ទុខ្ពស់ជាងកម្រិតអភិវឌ្ឍន៍តាមសមាសភាគ (DDL)។ ដូច្នេះភាពខ្លាំងរបស់សមាសភាគរង/ប្រធានបទគឺ៖

(រៀបចំជាតារាងបញ្ជីសមាសភាគរង/ប្រធានបទដែលមានចំនួនសញ្ញា (✓) ច្រើនជាងនៅក្នុងកម្រិតអភិវឌ្ឍន៍ដែលបានកំណត់)

**ឱកាសសម្រាប់អភិវឌ្ឍ (ចំណុចខ្សោយ)៖**

សមាសភាគរង/ប្រធានបទមួយចំនួនមានពិន្ទុទាបជាងកម្រិតអភិវឌ្ឍន៍តាមសមាសភាគ (DDL)។ ដូច្នេះឱកាសសម្រាប់អភិវឌ្ឍ គឺស្ថិតនៅក្នុងសមាសភាគរង/ប្រធានបទដូចខាងក្រោម៖

(រៀបចំជាតារាងបញ្ជីសមាសភាគរង/ប្រធានបទដែលមានចំនួនសញ្ញា (✓) តិចជាងនៅក្នុងកម្រិតអភិវឌ្ឍន៍ដែលបានកំណត់)

# ជំហានទី៣៖ ឧបករណ៍ពិនិត្យឡើងវិញ និងកំណត់គោលដៅ

## ជំហានទី៣ ៖ ឧបករណ៍ពិនិត្យឡើងវិញ និងឧបករណ៍កំណត់គោលដៅ

## សមាសភាគទី១ ដល់ ទី៥




| | |
|---|---|
| **សមាសភាគ** | ទី១ ដល់ ទី៥ |
| **អ្នកទទួលខុសត្រូវ** | • ក្រុមការងារអនុវត្តសកម្មភាពស្វែម៖ សមាជិកបង្គោល។<br>• ប្រធានក្រុមអនុវត្តសកម្មភាពស្វែម និងសមាជិកបង្គោលត្រូវបំពេញឧបករណ៍នេះ ដោយយកត់ត្រាតម្លៃកម្រិតអភិវឌ្ឍន៍តាមសមាសភាគ (DDL) សម្រាប់សមាសភាគនីមួយៗ នៃសមាសភាគទាំង៥ បន្ទាប់មកកំណត់កម្រិតអភិវឌ្ឍន៍សរុប (ODL) ។<br>• ប្រធានក្រុមអនុវត្តសកម្មភាពស្វែម និងសមាជិកបង្គោលត្រូវជ្រើសរើសគោលដៅសមស្រប ឬស្វែងរកធាតុចូល ឬការគាំទ្រពីសមាជិកគាំទ្រ  និងគណៈគ្រប់គ្រងសាលារៀនដើម្បីធ្វើការសម្រេចចិត្តចុងក្រោយរួមគ្នា។ |
| **ឆ្នាំទី** | (ឧ. ឆ្នាំទី១៖ ឆ្នាំសិក្សា២០២៤-២០២៥) |
| **លំនាំដំណើរការ** | <br>ក្របខណ្ឌអប់រំស្វែមកម្រិតសាលារៀនមាន ៥ ជំហានដើម្បីជួយដល់សាលារៀនក្នុងការកែលម្អការបង្រៀន និងការរៀនលើមុខវិជ្ជាស្វែម។ ឧបករណ៍កំណត់គោលដៅនេះគឺជាជំហានទី៣នៃដំណើរការរបស់ក្របខណ្ឌ។ ដើម្បីប្រើប្រាស់ឧបករណ៍នេះឱ្យមានប្រសិទ្ធភាព លោក លោកស្រីគួរតែអនុវត្តជំហានទី១ និងទី២ រួចជាមុនសិន។<br><br>ឧបករណ៍កំណត់គោលដៅនេះប្រើសម្រាប់សមាសភាគស្វែមទី១  ដល់ទី៥៖<br>1. លទ្ធផលការសិក្សារបស់សិស្ស<br>2. ការបង្រៀន និងរៀន<br>3. អភិបាលកិច្ចសាលារៀន<br>4. ការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធ<br>5. ការចូលរួមរបស់សហគមន៍ |

| | |
|---|---|
| **គោលបំណងរបស់ឧបករណ៍** | ឧបករណ៍ពិនិត្យឡើងវិញ និងឧបករណ៍កំណត់គោលដៅមានគោលបំណង៖<br>• ជួយក្រុមការងារអនុវត្តសកម្មភាពស្ទែមនៅតាមសាលារៀនដើម្បីកំណត់កម្រិតអភិវឌ្ឍន៍សរុប (ODL)និងពិនិត្យមើលលើដំណើរការរបស់សាលារៀននៅលើសមាសភាគស្ទែមទាំង៥<br>• កំណត់គោលដៅសម្រាប់ឆ្នាំខាងមុខឱ្យបានសមស្រប<br>• ជួយរៀបចំផែនការសកម្មភាពសម្រាប់អនុវត្តនៅជំហានទី៤ នៃដំណើរការទាំង៥ជំហានរបស់ក្របខណ្ឌ។ |
| **ការណែនាំ** | 1. កំណត់កម្រិតអភិវឌ្ឍន៍សរុបលើសមាសភាគទាំង៥ របស់សាលារៀន (តារាងទី១៧)។<br>2. ពិនិត្យមើលកម្រិតអភិវឌ្ឍន៍តាមសមាសភាគ (DDLs) របស់សមាសភាគនីមួយៗ (តារាងទី១៨)។<br>3. កំណត់គោលដៅសម្រាប់ឆ្នាំខាងមុខ (តារាងទី១៩)។<br>4. កំណត់ផែនការសកម្មភាពស្ទែមណាដែលលោក លោកស្រីនឹងអនុវត្តដើម្បីសម្រេចបាននូវគោលដៅនេះ។<br>5. ប្រសិនបើគោលដៅដែលបានជ្រើសរើសដោយក្រុមអនុវត្តសកម្មភាពស្ទែមនឹងមិនបានដោះស្រាយសម្រាប់សមាសភាគទាំង៥ នោះទេ ប្រធានក្រុមអនុវត្តសកម្មភាពស្ទែមគួរតែពិនិត្យមើលការកំណត់សមាសភាគឱ្យសមាជិកនៃក្រុមអនុវត្តសកម្មភាពស្ទែម និងអាចកំណត់ឡើងវិញ ដើម្បីធានាថាការទទួលការងារដោយភាពស្មើភាព។ |

# ការពិនិត្យឡើងវិញនៃកម្រិតអភិវឌ្ឍន៍នៅកម្រិតសាលារៀន

## ១-ការកំណត់កម្រិតអភិវឌ្ឍន៍សរុប ( ODL )

សូមបំពេញក្នុងតារាងទី4 ដោយយោងតាមឧបករណ៍ស្វ័យវាយតម្លៃពីសមាសភាគទី១ ដល់ទី៥ ដូចខាងក្រោម៖

**តារាងទី 4 ៖ ការកំណត់កម្រិតអភិវឌ្ឍន៍សរុប( ODL ) ***

| ល.រ | សមាសភាគស្វែម | កម្រិតអភិវឌ្ឍន៍តាមសមាសភាគ ( DDLs ) * |
|---|---|---|
| 1 | លទ្ធផលការសិក្សារបស់សិស្ស | |
| 2 | ការបង្រៀន និងរៀន | |
| 3 | អភិបាលកិច្ចសាលារៀន | |
| 4 | ការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធ | |
| 5 | ការចូលរួមរបស់សហគមន៍ | |
| | **តម្លៃសរុប** | |
| | **កម្រិតអភិវឌ្ឍន៍សរុប( ODL ) = តម្លៃសរុប /5** | |

*តម្លៃនៅតារាងនេះយកពីលទ្ធផលចេញពីជំហានទី២៖ ឧបករណ៍ស្វ័យវាយតម្លៃ

កម្រិតអភិវឌ្ឍន៍សរុប( ជាតម្លៃមធ្យមនៃកម្រិតអភិវឌ្ឍន៍ទាំង៥សមាសភាគ ) គឺកម្រិតសាលារៀនទី_______ ។

**កម្រិតអភិវឌ្ឍន៍សរុប ( ODL )**

បង្ហាញពីកម្រិតអភិវឌ្ឍន៍របស់សាលារៀនតាមសមាសភាគស្វែមទាំង៥ ដោយអាស្រ័យលើពិន្ទុនៃសមត្ថភាពស្វែមពីកម្រិតសាលារៀនទី១ ដល់ ៥។

## ២-ការពិនិត្យមើលកម្រិតអភិវឌ្ឍន៍លើសមាសភាគនីមួយៗ (DDLs)

សូមប្រើតារាងទី5 ដើម្បីកត់ត្រាពីស្ថានភាពបច្ចុប្បន្ននៃសាលារៀននៅក្នុងសមាសភាគនីមួយៗ។

- តើមានសមាសភាគណា ដែលសាលារៀនមានដំណើរការតិចតួចដែរឬទេ បើប្រៀបធៀបទៅនឹងកម្រិតអភិវឌ្ឍន៍សរុប (ODL)? សមាសភាគទាំងនេះគឺជាសមាសភាគស្នែមខ្សោយ ដែលត្រូវការអភិវឌ្ឍបន្ថែម។
- តើមានសមាសភាគណា មានតម្លៃកម្រិតអភិវឌ្ឍខ្ពស់ជាងតម្លៃកម្រិតអភិវឌ្ឍន៍សរុប (ODL) (ខ. ចំណុចខ្លាំងរបស់សាលារៀនលោក លោកស្រី) ដែរឬទេ? សមាសភាគទាំងនេះគឺជាសមាសភាគស្នែមខ្លាំង។

**តារាងទី 5៖ សេចក្តីសង្ខេបនៃកម្រិតអភិវឌ្ឍន៍សរុប(ODL) និងការកំណត់សមាសភាពខ្លាំងនិងខ្សោយ**

| តម្លៃ ODL | ល.រ | សមាសភាគ | តម្លៃ DDL | ជួរឈរ ក<br>សមាសភាគស្នែមខ្សោយ<br>✓ DDL ទាបជាង ODL | ជួរឈរ ខ<br>សមាសភាគស្នែមស្មើនឹង ODL<br>✓ DDL ស្មើ ODL | ជួរឈរ គ<br>សមាសភាគស្នែមខ្លាំង<br>✓ DDL ធំជាង ODL |
|---|---|---|---|---|---|---|
| តម្លៃ ODL<br>______ | 1 | លទ្ធផលការសិក្សារបស់សិស្ស | | | | |
| | 2 | ការបង្រៀន និងរៀន | | | | |
| | 3 | អភិបាលកិច្ចសាលារៀន | | | | |
| | 4 | ការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធ | | | | |
| | 5 | ការចូលរួមរបស់សហគមន៍ | | | | |

*គូសសញ្ញា ✓ តាមលទ្ធផលសម្រាប់សាលារៀនរបស់លោក លោកស្រី*

# ការកំណត់គោលដៅ

## ៣-កំណត់គោលដៅ

សូមពិចារណាពីស្ថានភាពជាក់ស្តែងរបស់សាលារៀន រួមទាំងកត្តាមួយចំនួនទៀត ដូចជាស្ថានភាពបច្ចុប្បន្ន កនៃសមាសភាគទាំង៥ សម្ភាររូបវន្ត ការប្តេជ្ញាចិត្តរបស់សាលារៀន និងសមត្ថភាពគ្រូបង្រៀន។ តើគោលដៅរបស់លោក លោកស្រីសម្រាប់ឆ្នាំខាងមុខនេះមានអ្វីខ្លះ?

ចំណាំ៖ យោងផែនការសកម្មភាពស្តែម ជំហានទី៤ នៃដំណើរការក្របខណ្ឌអប់រំស្តែមកម្រិតសាលារៀនទាំង៥ជំហាន ដើម្បីយល់ពីសកម្មភាពដែលបានណែនាំសម្រាប់ការកែលម្អការអនុវត្តនៅក្នុងកម្រិត/សមាសភាគនីមួយៗ។

**លោក លោកស្រីអាចជ្រើសរើស៖**

1. ពង្រឹងសមាសភាគទាំងឡាយណា ក្នុងចំណោមសមាសភាគទាំង ៥ ដែលបានកំណត់ថាខ្សោយ ដើម្បីឱ្យសមាសភាគទាំង៥ មានកម្រិតអភិវឌ្ឍស្មើគ្នា
2. ពង្រឹងសមាសភាគយ៉ាងហោចណាស់៣ ដើម្បីសម្រេចបាននូវកម្រិតអភិវឌ្ឍន៍បន្ទាប់។

**ការជ្រើសរើសគោលដៅរបស់លោក លោកស្រី៖**

សូមប្រើតារាងទី6 ដើម្បីបញ្ជាក់ពីគោលដៅ និងកំណត់ឱ្យបានច្បាស់លាស់ពីផែនការសកម្មភាពស្តែមមួយណាដែលគួរអនុវត្តតាមជំហានទី៤ នៅក្នុងដំណើរការទាំង៥ជំហាននៃក្របខណ្ឌអប់រំស្តែមកម្រិតសាលារៀន។

**តារាងទី 6៖ ការកំណត់គោលដៅ និងការកំណត់ផែនការសកម្មភាពស្តែម**

| *គោលដៅសម្រាប់ឆ្នាំខាងមុខ | | សមាសភាគស្តែមដែលត្រូវពង្រឹង | តម្លៃ DDL | សញ្ញា ✓ កំណត់ផែនការសកម្មភាពស្តែម*** | | | |
|---|---|---|---|---|---|---|---|
| | | | | កម្រិតទី១ ទៅ ២ | កម្រិតទី២ ទៅ ៣ | កម្រិតទី៣ ទៅ ៤ | កម្រិតទី៤ ទៅ ៥ |
| ☐ | **ជម្រើសទី១ ៖ សម្រេចឱ្យបានកម្រិតអភិវឌ្ឍស្មើៗគ្នាក ដោយព្យាយាមពង្រឹងសមាសភាគណាខ្សោយ(ជួរឈរ ក ក្នុងតារាងទី១៧) | ☐ លទ្ធផលការសិក្សារបស់សិស្ស | | | | | |
| | | ☐ ការបង្រៀន និងរៀន | | | | | |
| | | ☐ អភិបាលកិច្ចសាលារៀន | | | | | |
| | | ☐ ការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធ | | | | | |
| | | ☐ ការចូលរួមរបស់សហគមន៍ | | | | | |
| ឬ | | | | | | | |

| *គោលដៅសម្រាប់ឆ្នាំខាងមុខ | | សមាសភាគស្វែមដែលត្រូវពង្រឹង | តម្លៃ DDL | សញ្ញា ✓ កំណត់ផែនការសកម្មភាពស្វែម * * * | | | |
|---|---|---|---|---|---|---|---|
| | | | | កម្រិតទី១ ទៅ ២ | កម្រិតទី២ ទៅ ៣ | កម្រិតទី៣ ទៅ ៤ | កម្រិតទី៤ ទៅ ៥ |
| ☐ | ជម្រើសទី២ ៖ សម្រេចបានកម្រិតអភិវឌ្ឍន៍បន្ទាប់ ចំពោះសមាសភាគអាទិភាពចំនួន៣ | ☐ លទ្ធផលការសិក្សារបស់សិស្ស | | | | | |
| | | ☐ ការបង្រៀន និងរៀន | | | | | |
| | | ☐ អភិបាលកិច្ចសាលារៀន | | | | | |
| | | ☐ ការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធ | | | | | |
| | | ☐ ការចូលរួមរបស់សហគមន៍ | | | | | |

* ជ្រើសរើសជម្រើសទី១ ឬជម្រើសទី២ ដោយគ្រាន់តែគូសសញ្ញា ✓នៅក្នុងប្រអប់ខាងមុខ

* * ប្រសិនបើសាលារៀនលោក លោកស្រីកំពុងដំណើរការហើយមានកម្រិតអភិវឌ្ឍន៍សរុបទាំង៥សមាសភាគដូចគ្នា នោះគួរតែជ្រើសរើសជម្រើសទី២

* * * សូមគូសសញ្ញា ✓ លើផែនការសកម្មភាពស្វែម ដែលសមស្របនឹងជម្រើសនៃគោលដៅរបស់លោក លោកស្រី។ មិនចាំបាច់គូសសញ្ញា ✓លើផែនការសម្រាប់សមាសភាគទាំង៥នោះទេ បើមិនម្រេចចិត្តកអនុវត្តទាំង៥ សមាសភាគទេ។

ប្រធានក្រុមអនុវត្តសកម្មភាពស្វែមត្រូវយល់ដឹង៖ ប្រសិនបើគោលដៅដែលបានជ្រើសរើសហើយនិងមិនតម្រូវឱ្យមានសកម្មភាពទាំង៥ សមាសភាគនោះទេ លោក លោកស្រីគួរតែពិនិត្យមើលលើការចាត់តាំងសមាជិកបង្គោល ឱ្យទទួលខុសត្រូវលើសមាសភាគឡើងវិញ ដើម្បីធានាបាននូវបន្ទុកការងារដោយស្មើភាព ក្នុងក្រុម។

# ជំហានទី៤ ៖ ផែនការសកម្មភាពសម្រាប់ក្របខណ្ឌអប់រំស្ទែមកម្រិតសាលារៀន

## ជំហានទី៤ ៖ ផែនការសកម្មភាពសម្រាប់ក្របខណ្ឌអប់រំស្ទែមកម្រិតសាលារៀន

## សមាសភាគទី១ ៖ លទ្ធផលការសិក្សារបស់សិស្ស

| | |
|---|---|
| **សមាសភាគទី១** | លទ្ធផលការសិក្សារបស់សិស្ស |
| **អ្នកទទួលខុសត្រូវ** | សមាជិកបង្គោលនៃក្រុមអនុវត្តសកម្មភាពស្ទែមដែលត្រូវបានចាត់តាំងឱ្យទទួលខុសត្រូវសមាសភាគនេះ ដោយមានការគាំទ្រពីសមាជិកបង្គោល ឬសមាជិកគាំទ្រផ្សេងទៀត។<br>ចំណាំ៖ ប្រធានក្រុមអនុវត្តសកម្មភាពស្ទែមប្រហែលជាអាចត្រូវចាត់តាំងអ្នកទទួលខុសត្រូវចំពោះសមាសភាគនេះជាថ្មី នៅជំហានទី៣ ដើម្បីជានានូវទំហំការងារសមស្រប និងមានប្រសិទ្ធភាព។ |
| **សមាជិកក្រុមអនុវត្តសកម្មភាពស្ទែមសម្រាប់ទទួលខុសត្រូវសមាសភាគនេះ** | |
| **ឆ្នាំទី** | (ឧ. ឆ្នាំទី១៖ ឆ្នាំសិក្សា២០២៤-២០២៥) |

| | |
|---|---|
| **ដំណើរការ** | <br>ក្របខណ្ឌអប់រំស្ទែមកម្រិតសាលារៀនមាន ៥ជំហានដើម្បីគាំទ្រសាលារៀនក្នុងការបង្រៀន និងរៀនមុខវិជ្ជាស្ទែម។ ដើម្បីឱ្យជំហានទី៤នេះទទួលបានជោគជ័យត្រូវអនុវត្តជំហានទី១ ២ និង ៣ ប្រកបដោយប្រសិទ្ធិភាព។<br><br>ផែនការសកម្មភាពស្ទែម នៃក្របខណ្ឌអប់រំស្ទែមកម្រិតសាលារៀននេះ រៀបរាប់អំពីសកម្មភាពដែលអាចអនុវត្តបានដើម្បីពង្រឹងសមាសភាគទី១៖ លទ្ធផលការសិក្សារបស់សិស្ស ដែលមានសមាសភាគរង៖<br>១.១ ការប្រមូលសិស្សឱ្យចូលរៀន<br>១.២ ការរក្សាសិស្សបានគង់វង្សក្នុងសាលារៀន<br>១.៣ លទ្ធផលការសិក្សា |
| **គោលបំណងរបស់ឧបករណ៍** | ផែនការសកម្មភាពក្របខណ្ឌអប់រំស្ទែមកម្រិតសាលារៀនបង្ហាញពីជំហានជាក់ស្ដែង សម្រាប់ការលើកកម្ពស់ការអប់រំស្ទែមនៅសាលារៀន ដោយយោងតាមសមាសភាគនីមួយៗនៃសមាសភាគទាំង៥។ សកម្មភាពទាំងនេះត្រូវបានចាត់ថ្នាក់ដោយផ្អែកលើកម្រិតអភិវឌ្ឍន៍ ដូចនេះ យើងអនុវត្តតាមកម្រិតអភិវឌ្ឍន៍ដូចដែលបានកំណត់នៅក្នុងឧបករណ៍ស្វ័យវាយតម្លៃ (ជំហានទី៣)។ គោលវិធីនេះធានាថាសកម្មភាពដែលបានស្នើឡើងស្របតាមធនធាន និងសមត្ថភាពរបស់សាលារៀន។ខណៈយើងជួបនឹងការប្រឈមដូចជាសម្ភារបរិក្ខារ ឬថវិកានៅមានកម្រិត សូមអនុវត្តសកម្មភាពណាដែលអាចធ្វើទៅបាន។ តារាងខាងក្រោមខាងនេះដាក់បញ្ចូលគោលដៅដែលអាចសម្រេចបានហើយត្រូវជាមួយនឹងកម្រិតអភិវឌ្ឍន៍សាលារៀន ហើយគោលដៅនេះក៏ជារង្វាស់វឌ្ឍនភាពសាលារៀនលោក លោកស្រីផងដែរ។ |
| **ការណែនាំ** | 1. ពិនិត្យមើលទៅជំហានទី៣៖ ឧបករណ៍ពិនិត្យឡើងវិញ និងកំណត់គោលដៅ ដើម្បីកំណត់ផែនការសកម្មភាពស្ទែមសាលារៀនត្រូវអនុវត្តតាម<br>2. ពិចារណាលើសកម្មភាពបានលើកឡើងនៅក្នុងផែនការសកម្មភាពស្ទែម ដែលបានសង្ខេបក្នុងតារាងខាងក្រោមអំពីកម្រិតសាលារៀននៅក្នុងសមាសភាគនេះ៖ |

| | |
|---|---|
| | 3. ជ្រើសរើសសកម្មភាពអាចអនុវត្តបាន ដូចដែលបានរៀបរាប់នៅក្នុងតារាង ប្រសិនបើសកម្មភាពមានចំនួនច្រើន ចូរជ្រើសរើសតែសកម្មភាពណាលោក លោកស្រីអាចធ្វើទៅបានក្នុងឆ្នាំនេះ<br>4. ពិនិត្យប្រភពឯកសារ ឬតំណភ្ជាប់សំខាន់ៗដែលអាចជួយឱ្យលោក លោកស្រីរៀបចំផែនការ និងអនុវត្តសកម្មភាព<br>5. ពិនិត្យមើលនៅក្នុងសទ្ទានុក្រមសម្រាប់ពាក្យពិបាកយល់។ |

## ការរំឭកពីគោលដៅបានកំណត់

សូមមើលជំហានទី៣ និងកំណត់ចំណាំគោលដៅរបស់លោក លោកស្រីនៅទីនេះដើម្បីមានភាពងាយស្រួល។

**តារាងទី 7៖ ការកំណត់គោលដៅ និងការកំណត់ផែនការសកម្មភាពស្វែម**

| គោលដៅសម្រាប់ឆ្នាំបន្ទាប់៖ (✓ ជ្រើសរើសយកជម្រើសមួយ) | | ✓សមាសភាគស្វែម ដែលត្រូវពង្រឹង | តម្លៃ DDL | សញ្ញា ✓ ចង្អុលបង្ហាញពីផែនការសកម្មភាពដែលអនុវត្ត | | | |
|---|---|---|---|---|---|---|---|
| | | | | កម្រិតសាលារៀន ទី១ ទៅ ២ | កម្រិតសាលារៀន ទី២ ទៅ ៣ | កម្រិតសាលារៀន ទី៣ ទៅ ៤ | កម្រិតសាលារៀន ទី៤ ទៅ ៥ |
| ☐ | **ជម្រើសទី១៖** សម្រេចឱ្យបានលទ្ធផលប្រហាក់ប្រហែលគ្នាសមាសភាគទាំង៥ ដោយពង្រឹងសមាសភាគ ខ្សោយ។ | ☐ លទ្ធផលការសិក្សារបស់សិស្ស | | | | | |
| | | ☐ ការបង្រៀន និងរៀន | | | | | |
| | | ☐ អភិបាលកិច្ចសាលារៀន | | | | | |
| | | ☐ ការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធ | | | | | |
| | | ☐ ការចូលរួមរបស់សហគមន៍ | | | | | |
| | | | ឬ | | | | |
| គោលដៅសម្រាប់ឆ្នាំបន្ទាប់៖ | | ✓សមាសភាគស្វែម ដែលត្រូវពង្រឹង | តម្លៃ DDL | សញ្ញា ✓ ចង្អុលបង្ហាញពីផែនការសកម្មភាពដែលអនុវត្ត | | | |
| | | | | កម្រិតសាលារៀន ទី១ ទៅ ២ | កម្រិតសាលារៀន ទី២ ទៅ ៣ | កម្រិតសាលារៀន ទី៣ ទៅ ៤ | កម្រិតសាលារៀន ទី៤ ទៅ ៥ |

| | | | | | | | |
|---|---|---|---|---|---|---|---|
| ☐ | **ជម្រើសទី២៖** សម្រេចឱ្យបានកម្រិតអភិវឌ្ឍបន្ទាប់ នៃកសមាសភាគចំនួន៣ | ☐ លទ្ធផលការសិក្សារបស់សិស្ស | | | | | |
| | | ☐ ការបង្រៀន និងរៀន | | | | | |
| | | ☐ អភិបាលកិច្ចសាលារៀន | | | | | |
| | | ☐ ការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធ | | | | | |
| | | ☐ ការចូលរួមរបស់សហគមន៍ | | | | | |

## សេចក្តីរៀបរាប់៖ កម្រិតអភិវឌ្ឍន៍តាមសមាសភាគ (DDL) បច្ចុប្បន្ន និងគោលដៅសម្រាប់សមាសភាគនេះ៖

កម្រិតអភិវឌ្ឍន៍សាលារៀនយើង នៅត្រង់សមាសភាគនេះ គឺកម្រិតសាលារៀនទី ____ ។ គោលដៅសាលារៀនគឺឆ្ពោះទៅរកកម្រិតសាលារៀនទី__________ ដូចនេះយើងនឹងអនុវត្តតាមសកម្មភាពដែលបានស្នើឡើងដើម្បីអភិវឌ្ឍពីកម្រិត_______ទៅ កម្រិត_____នៅក្នុងតារាងខាងក្រោម ហើយសម្រេចគោលដៅតាមដែលយើងបានកំណត់។

*(ឧទាហរណ៍៖ កម្រិតអភិវឌ្ឍន៍សាលារៀនយើង នៅត្រង់សមាសភាគនេះ គឺកម្រិត __2__ ។ គោលដៅសាលារៀនដើម្បីឆ្ពោះទៅរកកម្រិត_3_ ដូចនេះយើងនឹងអនុវត្តតាមសកម្មភាពដែលបានស្នើឡើងដើម្បីអភិវឌ្ឍពីកម្រិត_2_ទៅ កម្រិត__3_នៅក្នុងតារាងខាងក្រោម ហើយសម្រេចគោលដៅតាមដែលយើងបានកំណត់។)*

## កូដពណ៌៖

| | ✓ | |
|---|---|---|
| សកម្មភាពមិនទាន់បានអនុវត្ត៖ សាលារៀននៅកម្រិតនេះមិនទាន់ត្រៀមសម្រាប់សកម្មភាពនេះ | សញ្ញា ✓ បង្ហាញថាសកម្មភាពនេះអាចអនុវត្តបានក្នុងសាលារៀនក្នុងកម្រិតនេះ | សាលារៀននៅក្នុងកម្រិតនេះគឺអាចសម្រេចបានសកម្មភាពដែលបានលើកឡើង |

| ១.១ | ១.១.ការប្រមូលសិស្សឱ្យចូលរៀន | | | | |
|---|---|---|---|---|---|
| | សកម្មភាពគួរអនុវត្ត | កម្រិតសាលារៀនទី ១ ដល់ ២ | កម្រិតសាលារៀនទី ២ ដល់ ៣ | កម្រិតសាលារៀនទី ៣ ដល់ ៤ | កម្រិតសាលារៀនទី៤ ដល់ ៥ |
| ការចុះឈ្មោះចូលរៀនរបស់សិស្សស្រី និងសិស្សប្រុសក្នុងបណ្តុំវិទ្យាសាស្ត្រ | – បង្កើនគុណភាពការបង្រៀនមុខវិជ្ជាវិទ្យាសាស្ត្រ<br>– ផ្តល់អាហារូបករណ៍ឬកម្មវិធីជំរុញសម្រាប់សិស្សរសចូលរៀននៅក្នុងបណ្តុំវិទ្យាសាស្ត្រ<br>– បង្កើតការយល់ដឹងអំពីអាជីពដែលពាក់ព័ន្ធនឹងវិទ្យាសាស្ត្រនៅកម្រិតមធ្យមសិក្សាបឋមភូមិ<br>– សហការជាមួយគ្រួសារ និងសហគមន៍ក្នុងការជុំរុញសិស្សចូលរៀនក្នុងបណ្តុំវិទ្យាសាស្ត្រ | | | | |
| ១.២ | ១.២. ការរក្សាសិស្សបានគង់វង្សក្នុងសាលារៀន | | | | |
| | សកម្មភាពគួរអនុវត្ត | កម្រិតសាលារៀនទី ១ ដល់ ២ | កម្រិតសាលារៀនទី ២ ដល់ ៣ | កម្រិតសាលារៀនទី ៣ ដល់ ៤ | កម្រិតសាលារៀនទី៤ ដល់ ៥ |
| ការរក្សាសិស្សស្រី និងសិស្សប្រុសក្នុងបណ្តុំវិទ្យាសាស្ត្រ | – **ការគាំទ្របច្ចេកទេស និងហិរញ្ញវត្ថុ**<br>• ផ្តល់អាហារូបករណ៍ជំរុញសិស្សនៅកម្រិតវិទ្យាល័យ<br>• បង្កើតបន្ទប់ពិសោធន៍ស្ទែម ដោយមានបរិក្ខារគ្រប់គ្រាន់ និងបង្រៀនដោយគ្រូបង្រៀនមានចំណេះដឹងលើការពិសោធ<br>– **ការពង្រឹងការណែនាំអាជីព**<br>• បង្ហាញអំពីអាជីពទាក់ទងនឹងស្ទែម ជាមួយមុខរបរដូចជា វេជ្ជបណ្ឌិត វិស្វករ អ្នកវិទ្យាសាស្ត្រ<br>• បង្កើតកម្មវិធីប្រឹក្សាអាជីព ដោយមានបញ្ចូលអ្នកជោគជ័យក្នុងមុខរបរទាំងនេះ | | | | |

| | | | | | |
|---|---|---|---|---|---|
| ការរក្សាសិស្សស្រី និងសិស្សប្រុសក្នុងបណ្តុំវិទ្យាសាស្ត្រ | – **វិធីសាស្ត្របង្រៀនច្នៃប្រឌិត**<br>• ការបង្កើតគម្រោងវិទ្យាសាស្ត្រជាក់ស្តែង<br>• ប្រើបច្ចេកវិទ្យាឌីជីថលក្នុងបន្ទប់សិក្សា<br>– **ការចូលរួមរបស់គ្រួសារ និងសហគមន៍**<br>• លើកទឹកចិត្តឱ្យឪពុកម្តាយគាំទ្រសិស្សបន្តសិក្សាក្នុងបណ្តុំវិទ្យាសាស្ត្រ<br>• ចាប់ដៃគូសហការជាមួយអង្គការមិនមែនរដ្ឋាភិបាល និងវិស័យឯកជន | | | | |
| ១.៣ | **១.៣. លទ្ធផលការសិក្សា** | | | | |
| | **សកម្មភាពគួរអនុវត្ត** | **កម្រិតសាលារៀនទី ១ ដល់ ២** | **កម្រិតសាលារៀនទី ២ ដល់ ៣** | **កម្រិតសាលារៀនទី ៣ ដល់ ៤** | **កម្រិតសាលារៀនទី៤ ដល់ ៥** |
| លទ្ធផលសិក្សារបស់សិស្សស្រី និងសិស្សប្រុសក្នុងបណ្តុំវិទ្យាសាស្ត្រ | – **បង្កើនគុណភាពការបង្រៀននិងសមត្ថភាពគ្រូ**<br>• បណ្តុះបណ្តាលគ្រូវិទ្យាសាស្ត្រឱ្យមានជំនាញជាក់ស្តែង<br>• ប្រើវិធីសាស្ត្របង្រៀនដូចជាការសិក្សាបែបរិះរក, ការសិក្សាបែបដោះស្រាយបញ្ហា, ការសិក្សាបែបគម្រោង...ជាដើម<br>• ពង្រឹងការអនុវត្តសហគមន៍សិក្សាវិជ្ជាជីវៈ (PLC)<br>– **ប្រើប្រាស់បច្ចេកវិទ្យា និងបរិក្ខារសិក្សាជាក់ស្តែង**<br>• បង្កើតបន្ទប់ពិសោធន៍ស្ទែម | | | | |

| | | | | | |
|---|---|---|---|---|---|
| លទ្ធផលសិក្សារបស់សិស្សស្រី និងសិស្សប្រុសក្នុងបណ្តុំវិទ្យាសាស្ត្រ | • ប្រើសៀវភៅអេឡិចត្រូនិក, កម្មវិធីពិសោធន៍និម្មិត (simulation) និងវីដេអូបង្រៀនវិទ្យាសាស្ត្រសម្រាប់សិស្ស<br>• អនុញ្ញាតឱ្យសិស្សធ្វើចាប់ផ្តើមគម្រោងស្រាវជ្រាវតូចៗដោយខ្លួនឯង<br>– **បង្កើនចំណាប់អារម្មណ៍របស់សិស្ស**<br>• បង្កើតក្លឹបស្ទែម, ពិពរណ៍វិទ្យាសាស្ត្រ ឬកម្មវិធីទាក់ទងនឹងវិទ្យាសាស្ត្រផ្សេងទៀត<br>• រៀបចំឱ្យមានវគ្គបំប៉នដល់សិស្ស<br>• រៀបចំឱ្យសិស្សអនុវត្តការសិក្សាបែបគម្រោង ដើម្បីអភិវឌ្ឍការគិតវិភាគ<br>• ឱ្យអនុវត្តឱ្យសិស្សចូលរួមកម្មវិធីអន្តរជាតិដូចជា science camp ឬ science competition<br>– **ការចូលរួមពីគ្រួសារ និងសហគមន៍**<br>• រៀបចំការជួបប្រជុំឪពុកម្តាយស្តីពីសារៈសំខាន់នៃការអប់រំស្ទែម<br>• ធ្វើទំនាក់ទំនងជាមួយស្ថាប័នឯកជន ឬសាកលវិទ្យាល័យសម្រាប់ការហាត់ការការងារ ឬការទស្សនកិច្ចសិក្សា<br>– **ការតាមដាន និងវាយតម្លៃលទ្ធផលសិក្សាជាប្រចាំ**<br>• អនុវត្តវង្វាយតម្លៃតាមដំណាក់ (formative assessment) ដូចជា quiz, class discussion, peer feedback...<br>• អនុវត្តវង្វាយតម្លៃផ្អែកលើសមត្ថភាពសិស្ស (Competency based assessment) នៅកម្រិតថ្នាក់រៀន | | | | |

# ជំហានទី៤ ៖ ផែនការសកម្មភាពសម្រាប់ក្របខណ្ឌអប់រំស្ទែមកម្រិតសាលារៀន

## សមាសភាគទី២ ៖ ការបង្រៀន និងរៀន

| | |
|---|---|
| **សមាសភាគទី៤** | ការបង្រៀន និងរៀន |
| **អ្នកទទួលខុសត្រូវ** | សមាជិកបង្គោលនៃក្រុមអនុវត្តសកម្មភាពស្ទែមដែលត្រូវបានចាត់តាំងឱ្យទទួលខុសត្រូវសមាសភាគនេះ ដោយមានការគាំទ្រពីសមាជិកបង្គោល ឬសមាជិកគាំទ្រផ្សេងទៀត។<br>ចំណាំ៖ ប្រធានក្រុមអនុវត្តសកម្មភាពស្ទែមប្រហែលជាអាចត្រូវចាត់តាំងអ្នកទទួលខុសត្រូវចំពោះសមាសភាគនេះជាថ្មី នៅជំហានទី៣ ដើម្បីជានានូវទំហំការងារសមស្រប និងមានប្រសិទ្ធភាព។ |
| **សមាជិកក្រុមអនុវត្តសកម្មភាពស្ទែមសម្រាប់ទទួលខុសត្រូវសមាសភាគនេះ** | |
| **ឆ្នាំទី** | (ឧ. ឆ្នាំទី១៖ ឆ្នាំសិក្សា២០២៤-២០២៥) |
| **ដំណើរការ** | <br>ក្របខណ្ឌអប់រំស្ទែមកម្រិតសាលារៀនមាន ៥ជំហានដើម្បីគាំទ្រសាលារៀនក្នុងការបង្រៀន និងរៀនមុខវិជ្ជាស្ទែម។ ដើម្បីឱ្យជំហានទី៤នេះទទួលបានជោគជ័យ លោក លោកស្រីត្រូវអនុវត្តជំហានទី១ ២ និង ៣ ប្រកបដោយប្រសិទ្ធិភាព។<br><br>ផែនការសកម្មភាពស្ទែម នៃក្របខណ្ឌអប់រំស្ទែមកម្រិតសាលារៀននេះរៀបរាប់អំពីសកម្មភាពដែលអាចអនុវត្តបានដើម្បីពង្រឹងសមាស |

| | |
|---|---|
| | ភាគទី៤៖ ការបង្រៀន និងរៀន ហើយអាចស្ថិតនៅក្នុងសមាសភាគរងខាងក្រោម៖<br>២.១ ការអភិវឌ្ឍវិជ្ជាជីវៈជាប្រចាំ<br>២.២ បំណិនឌីជីថល<br>២.៣ ការពង្រឹងកម្មវិធីសិក្សា<br>២.៤ ការបញ្ចូលបច្ចេកវិទ្យា<br>២.៥ ការជួយគាំទ្រសិស្ស<br>២.៦ ការផ្សាភ្ជាប់ទៅនឹងជីវភាពរស់នៅ<br>២.៧ វង្វាយតម្លៃ<br>២.៨ ការធ្វើអធិការកិច្ចផ្ទៃក្នុង<br>២.៩ សហគមន៍សិក្សាវិជ្ជាជីវៈ<br>២.១០ ការបង្រៀន |
| **គោលបំណងរបស់ឧបករណ៍** | ផែនការសកម្មភាពរបស់ក្របខណ្ឌអប់រំស្ទែមកម្រិតសាលារៀនបង្ហាញពីជំហានជាក់ស្តែង យោងទៅតាមសមាសភាគទាំង៥ នីមួយៗ សម្រាប់ការលើកកម្ពស់ការអប់រំស្ទែមនៅសាលារៀន។ សកម្មភាពទាំងនេះត្រូវបានចាត់ថ្នាក់ដោយផ្អែកលើកម្រិតអភិវឌ្ឍន៍ ដូចនេះលោក លោកស្រីអាចអនុវត្តតាមកម្រិតអភិវឌ្ឍន៍របស់សាលារៀន ដូចដែលបានកំណត់ដោយឧបករណ៍ស្វ័យវាយតម្លៃ (ជំហានទី៣)។ វិធីសាស្ត្រនេះធានាថាសកម្មភាពដែលបានណែនាំត្រូវបានកែសម្រួលទៅតាមធនធាន និងសមត្ថភាពរបស់សាលារៀន។ នៅពេលដែលលោក លោកស្រីជួបប្រទះនឹងឧបសគ្គដូចជាសម្ភារបរិក្ខារ ឬថវិកានៅមានកម្រិត សូមព្យាយាមឆ្ពោះទៅរកការអនុវត្តសកម្មភាពទាំងអស់ដែលអាចធ្វើទៅបាន។ តារាងខាងក្រោមក៏រួមបញ្ចូលផងដែរនូវគោលដៅដែលអាចសម្រេចបានដែលទាក់ទងទៅនឹងកម្រិតអភិវឌ្ឍន៍របស់សាលារៀនដោយបម្រើជាវង្វាស់នៃវឌ្ឍនភាពរបស់សាលារៀនលោក លោកស្រី។ |
| **ការណែនាំ** | 1. ពិនិត្យមើលទៅជំហានទី៣៖ ឧបករណ៍ពិនិត្យឡើងវិញ និងកំណត់គោលដៅ ដើម្បីកំណត់ផែនការសកម្មភាពស្ទែមដែលសាលារៀនត្រូវអនុវត្តតាម |

| | |
|---|---|
| | 2. ពិចារណាលើសកម្មភាពដែលបានលើកឡើងនៅក្នុងផែនការសកម្មភាពស្ទែម ដែលបានសង្ខេបក្នុងតារាងខាងក្រោមអំពីកម្រិតរបស់សាលារៀននៅក្នុងសមាសភាគនេះ<br>3. ជ្រើសរើសសកម្មភាពដែលអាចអនុវត្តបាន ដូចដែលបានរៀបរាប់នៅក្នុងតារាង ប្រសិនបើសកម្មភាពមានចំនួនច្រើន ចូរជ្រើសរើសតែសកម្មភាពណាដែលលោក លោកស្រីអាចធ្វើទៅបានក្នុងឆ្នាំនេះ<br>4. ពិនិត្យប្រភពឯកសារ ឬតំណភ្ជាប់សំខាន់ៗដែលអាចជួយឱ្យលោក លោកស្រីរៀបចំផែនការ និងអនុវត្តសកម្មភាព<br>5. ពិនិត្យមើលនៅក្នុងសទ្ទានុក្រមសម្រាប់ពាក្យពិបាកយល់។ |

# ការរម្លឹកពីគោលដៅដែលបានកំណត់

សូមមើលជំហានទី៣ និងកំណត់ចំណាំគោលដៅអ្នកនៅទីនេះដើម្បីមានភាពងាយស្រួល។

**តារាងទី ៨៖ ការកំណត់គោលដៅ និងការកំណត់ផែនការសកម្មភាពស្វែម**

| គោលដៅសម្រាប់ឆ្នាំបន្ទាប់៖ (✓ ជ្រើសរើសយកជម្រើសមួយ) | | ✓សមាសភាគស្វែម ដែលត្រូវពង្រឹង | តម្លៃ DDL | សញ្ញា ✓ ចង្អុលបង្ហាញពីផែនការសកម្មភាពដែលអនុវត្ត | | | |
|---|---|---|---|---|---|---|---|
| | | | | កម្រិតសាលារៀន ទី១ ទៅ ២ | កម្រិតសាលារៀន ទី២ ទៅ ៣ | កម្រិតសាលារៀន ទី៣ ទៅ ៤ | កម្រិតសាលារៀន ទី៤ ទៅ ៥ |
| ☐ | **ជម្រើសទី១៖** សម្រេចបានលទ្ធផលប្រហាក់ប្រហែលគ្នានៅក្នុងចំណោមសមាសភាគទាំង៥ ដោយព្យាយាមពង្រឹងលើសមាសភាគដែលខ្សោយ។ | ☐ ហេដ្ឋារចនាសម្ព័ន្ធ | | | | | |
| | | ☐ វប្បធម៌សាលារៀន និងអភិបាលកិច្ច | | | | | |
| | | ☐ សមត្ថភាពរបស់គ្រូបង្រៀន និងលទ្ធផលការសិក្សារបស់សិស្ស | | | | | |
| | | ☐ ដំណើរការបង្រៀន និងរៀន | | | | | |
| | | ☐ ការចូលរួមរបស់សហគមន៍ | | | | | |
| ឬ | | | | | | | |
| គោលដៅសម្រាប់ឆ្នាំបន្ទាប់៖ | | ✓សមាសភាគស្វែម ដែលត្រូវពង្រឹង | តម្លៃ DDL | សញ្ញា ✓ ចង្អុលបង្ហាញពីផែនការសកម្មភាពដែលអនុវត្ត | | | |
| | | | | កម្រិតសាលារៀន ទី១ ទៅ ២ | កម្រិតសាលារៀន ទី២ ទៅ ៣ | កម្រិតសាលារៀន ទី៣ ទៅ ៤ | កម្រិតសាលារៀន ទី៤ ទៅ ៥ |
| ☐ | **ជម្រើសទី២៖** សម្រេចបានកម្រិតបន្ទាប់ នៃកម្រិតអភិវឌ្ឍនៅក្នុងសមាសភាគចំនួន៣ | ☐ ហេដ្ឋារចនាសម្ព័ន្ធ | | | | | |
| | | ☐ វប្បធម៌សាលារៀន និងអភិបាលកិច្ច | | | | | |
| | | ☐ សមត្ថភាពរបស់គ្រូបង្រៀន និងលទ្ធផលការសិក្សារបស់សិស្ស | | | | | |
| | | ☐ ដំណើរការបង្រៀន និងរៀន | | | | | |
| | | ☐ ការចូលរួមរបស់សហគមន៍ | | | | | |

## សេចក្តីរៀបរាប់៖ កម្រិតអភិវឌ្ឍន៍តាមសមាសភាគ (DDL) បច្ចុប្បន្ន និងគោលដៅសម្រាប់សមាសភាគនេះ៖

កម្រិតអភិវឌ្ឍន៍របស់សាលារៀនយើង នៅត្រង់សមាសភាគនេះ គឺកម្រិត ____ ។ គោលដៅរបស់សាលារៀនដើម្បីឆ្ពោះទៅរកកម្រិត______ ដូចនេះយើងនឹងអនុវត្តតាមសកម្មភាពដែលបានណែនាំដើម្បីអភិវឌ្ឍពីកម្រិត_______ទៅ កម្រិត____នៅក្នុងតារាងខាងក្រោម និងខិតខំដើម្បីសម្រេចគោលដៅដែលបានកំណត់។

*(ឧទាហរណ៍៖ កម្រិតអភិវឌ្ឍន៍របស់សាលារៀនយើង នៅត្រង់សមាសភាគនេះ គឺកម្រិត __2__ ។ គោលដៅរបស់សាលារៀនដើម្បីឆ្ពោះទៅរកកម្រិត____3_____ ដូចនេះយើងនឹងអនុវត្តតាមសកម្មភាពដែលបានណែនាំដើម្បីអភិវឌ្ឍពីកម្រិត_____2_____ទៅ កម្រិត_____3_____នៅក្នុងតារាងខាងក្រោម និងខិតខំដើម្បីសម្រេចគោលដៅដែលបានកំណត់។)*

### កូដពណ៌៖

| | ✓ | |
|---|---|---|
| សកម្មភាពមិនទាន់បានអនុវត្ត៖ សាលារៀននៅកម្រិតនេះមិនទាន់ត្រៀមសម្រាប់សកម្មភាពនេះ | សញ្ញា ✓ បង្ហាញថាសកម្មភាពនេះអាចអនុវត្តបានក្នុងសាលារៀនក្នុងកម្រិតនេះ | សាលារៀននៅក្នុងកម្រិតនេះគឺអាចសម្រេចបានសកម្មភាពដែលបានលើកឡើង |

| ២.១ | ២.១ ការអភិវឌ្ឍន៍វិជ្ជាជីវៈជាប្រចាំ | | | | |
|---|---|---|---|---|---|
| | សកម្មភាពគួរអនុវត្ត | កម្រិតសាលារៀនទី ១ ដល់ ២ | កម្រិតសាលារៀនទី ២ ដល់ ៣ | កម្រិតសាលារៀនទី ៣ ដល់ ៤ | កម្រិតសាលារៀនទី ៤ ដល់ ៥ |
| ខ្លឹមសារបណ្តុះបណ្តាល | ក្រុមអនុវត្តសកម្មភាពស្ទែមពិគ្រោះជាមួយគ្រូស្ទែម ជាទៀងទាត់ដើម្បីកំណត់គម្លាតនៃចំណេះដឹង និងជំនាញ ព្រមទាំងទាក់ទងទៅកាន់អ្នកផ្តល់សេវាខាងក្រៅ។ គម្លាតណាមួយដែលអាចត្រូវបានដោះស្រាយដោយគ្រូនៅក្នុងសាលារៀន ក្រុមអនុវត្តសកម្មភាពស្ទែមគួរតែគូសបញ្ជាក់ចំណុចទាំងនេះសម្រាប់ការដាក់បញ្ចូលក្នុងសហគមន៍សិក្សាវិជ្ជាជីវៈនៅក្នុងសាលារៀន។ | ✓ | ✓ | | |
| | ក្រុមអនុវត្តសកម្មភាពស្ទែមសម្របសម្រួលជាមួយអ្នកផ្តល់ការបណ្តុះបណ្តាលខាងក្រៅដើម្បីធានាថាការកំណត់ពេលវេលានៃការបណ្តុះបណ្តាលគឺទទួលយកបានមុនពេលអនុវត្តក្នុងថ្នាក់រៀន។ | | | ✓ | |
| | ក្រុមអនុវត្តសកម្មភាពស្ទែមទាក់ទងជាមួយអ្នកផ្តល់សេវាខាងក្រៅដើម្បីជូនដំណឹងដល់ពួកគេថាគ្រូរបស់ពួកគេមានសមត្ថភាព និងឆន្ទៈក្នុងការដើរតួនាទីយ៉ាងសកម្មក្នុងការអភិវឌ្ឍខ្លឹមសារបណ្តុះបណ្តាល ផ្តល់មតិកែលម្អ សាកល្បងសម្ភារបណ្តុះបណ្តាលថ្មីៗ ផ្តល់យោបល់សម្រាប់ការកែលម្អនិងលើប្រធានបទថ្មី។ | | | | ✓ |
| គុណភាព | មតិកែលម្អការលើការបណ្តុះបណ្តាល៖ ក្រុមអនុវត្តសកម្មភាពស្ទែមគាំទ្រអ្នកផ្តល់ការបណ្តុះបណ្តាលខាងក្រៅដើម្បីអនុវត្តប្រព័ន្ធមួយដើម្បីប្រមូលមតិកែលម្អពីគ្រូបង្រៀនស្ទែម ដែលបានទទួលការបណ្តុះបណ្តាលដើម្បីវាយតម្លៃប្រសិទ្ធភាពនិងភាពពាក់ព័ន្ធរបស់វា។ ក្រុមអនុវត្តសកម្មភាពស្ទែមក៏មានភារកិច្ចក្នុងការប្រមូលយោបល់ពីគ្រូសម្រាប់ប្រធានបទបណ្តុះបណ្តាលនាពេលអនាគត រួមជាមួយនឹងមតិកែលម្អទៅកាន់អ្នកផ្តល់ការបណ្តុះបណ្តាលខាងក្រៅ។ ប្រព័ន្ធនេះអាចជាការពិភាក្សានៅក្នុងកិច្ចប្រជុំក្រុមបច្ចេកទេសស្ទែម សហគមន៍សិក្សាវិជ្ជាជីវៈ ឬការស្ទង់មតិសាមញ្ញ។ | ✓ | ✓ | | |
| | ការពិនិតត្យដានការបណ្តុះបណ្តាល៖ ក្រុមអនុវត្តសកម្មភាពស្ទែមបង្កើតយន្តការពិនិត្យតាមដានសាមញ្ញជាមួយគ្រូស្ទែម ដែលបានទទួលការបណ្តុះបណ្តាល។ គោលបំណងគឺដើម្បី៖ | ✓ | ✓ | ✓ | |

| | | | | | |
|---|---|---|---|---|---|
| | - ធានាថាការបណ្តុះបណ្តាលត្រូវបានចែករំលែកដល់លោកគ្រូអ្នកគ្រូ<br>- ធានាការបណ្តុះបណ្តាលត្រូវបានអនុវត្តនៅក្នុងថ្នាក់រៀន<br>យន្តការពិនិត្យតាមដានអាចរួមបញ្ចូលការសង្កេតក្នុងថ្នាក់រៀនងាយៗ ដោយមានការគាំទ្រពីគ្រូបង្វឹកស្នែម ឬការប្រឹក្សាជាដៃគូ។<br>យន្តការពិនិត្យតាមដានគួរតែត្រូវបានបង្កើតឡើងដោយអ្នកផ្តល់ការបណ្តុះបណ្តាលខាងក្រៅ ហើយអនុវត្តដោយក្រុមអនុវត្តសកម្មភាពស្នែម។ | | | | |
| ការឆ្លើយតបនឹងយេនឌ័រ | ប្រសិនបើគ្មានឱកាសសម្រាប់ការបណ្តុះបណ្តាលឆ្លើយតបនឹងយេនឌ័រទេ គ្រូបង្រៀនផ្នែកស្នែម គួរតែស្គាល់ខ្លួនឯងជាមួយនឹងគោលគំនិតនេះបើយោងតាមឯកសារដែលបានភ្ជាប់។ | ✓ | ✓ | ✓ | |
| ប្រភពធនធាន | កញ្ចប់បណ្តុះបណ្តាលគ្រូស្តីពីឆ្លើយតបនឹងយេនឌ័ថ្នាក់ជាតិ  រៀបចំដោយអង្គការយូនីសេហ្វ៖https://www.unicef.org/rwanda/reports/national-gender-responsive-teacher-training-package#:~:text=This%20National%20Gender%20Responsive%20Teacher,be%20used%20in%20classroom%20settings. | | | | |

| ២.២ | ២.២ ការពង្រឹងកម្មវិធីសិក្សា | | | | |
|---|---|---|---|---|---|
| | សកម្មភាពគួរអនុវត្ត | កម្រិតសាលារៀនទី ១ ដល់ ២ | កម្រិតសាលារៀនទី ២ ដល់ ៣ | កម្រិតសាលារៀនទី ៣ ដល់ ៤ | កម្រិតសាលារៀនទី៤ ដល់ ៥ |
| សម្ភារគាំទ្រ | គ្រូបង្រៀនស្នែម/ក្រុមអនុវត្តសកម្មភាពស្នែមព្យាយាមស្វែងរកសម្ភារគាំទ្រតាមរយៈសហគមន៍សិក្សាវិជ្ជាជីវៈ និងធនធានពីក្រសួងអ.យ.ក។ សូមពិភាក្សាជាមួយប្រធានក្រុមបច្ចេកទេស និងគ្រូបង្រៀនស្នែម ក្នុងអំឡុងកិច្ចប្រជុំបច្ចេក ទេស។ សូមពិគ្រោះយោបល់លើសម្ភារទាំងនេះ នៅពេលរៀបចំផែនការសកម្មភាពស្នែម ក្នុងថ្នាក់រៀន។ | ✓ | | | |
| | ប្រធានក្រុមបច្ចេកទេស/ក្រុមអនុវត្តសកម្មភាពស្នែមត្រូវធានាថាសម្ភារគាំទ្រត្រូវបានពិគ្រោះយោបល់ ក្នុងអំឡុងកិច្ចប្រជុំបច្ចេកទេសប្រចាំខែ។ | | ✓ | | |

| | | | | | |
|---|---|---|---|---|---|
| | ប្រធានក្រុមបច្ចេកទេស/ក្រុមអនុវត្តសកម្មភាពស្ទែមឧស្សាហ៍លើកឡើងពីសម្ភារគាំទ្រ តាមរយៈកិច្ចប្រជុំបច្ចេកទេសពីរដងក្នុងមួយខែ។ | | | ✓ | |
| | ប្រធានក្រុមបច្ចេកទេស/ក្រុមអនុវត្តសកម្មភាពស្ទែមត្រូវតែពន្យល់ឱ្យបានច្បាស់ពីសម្ភារគាំទ្រ និងលើកទឹកចិត្តក្នុងការចែករំលែកសម្ភារទាំងនេះ តាមរយៈសហគមន៍សិក្សាវិជ្ជាជីវៈអន្តរសាលាសម្រាប់គ្រូបង្រៀននិងគណៈគ្រប់គ្រងសាលារៀន។ | | | | ✓ |
| ការបញ្ចូលខ្លឹមសារកម្មវិធីសិក្សាស្ទែម និងបទពិសោធន៍រៀនស្ទែមជាក់ស្តែង | គ្រូបង្រៀនស្ទែមរៀបចំ និងផ្តល់សកម្មភាពបែបបិរិះរកដែលបញ្ចូលបញ្ញត្តិមួយចំនួន ចេញពីមុខវិជ្ជាលើសពីមួយ ដោយផ្អែកទៅលើគោលដៅខាងលើ (ចំណាំះ គោលដៅទាំងនេះ រួមបញ្ចូលទាំងគម្រោង ស្ទែម , សូមមើលផ្នែកបន្ទាប់)<br><br>សូមប្រើសម្ភារគាំទ្រ ដើម្បីជួយកំណត់សកម្មភាពសមស្រប (កម្មវិធីសិក្សា និងកិច្ចតែងការ ដែលលើកកម្ពស់ស្ទែម) និងធ្វើការជាមួយគ្រូដទៃទៀត ប្រសិនបើលោក លោកស្រីមានធនធានច្រើន។ សូមជ្រើសរើសសកម្មភាពដែលទាក់ទងនឹងជីវភាពរស់នៅ ដើម្បីធ្វើឱ្យពិសោធន៍ទាំងនេះជាក់ស្តែង (ឧទាហរណ៍ ការដោះស្រាយបញ្ហាជាក់ស្តែង)។ | យ៉ាងតិចម្តងក្នុងមួយត្រីមាស * | យ៉ាងតិចពីរដងក្នុងមួយត្រីមាស * | | |
| | សកម្មភាពបែបបិរិះរកគួរបញ្ចូលគម្រោងស្ទែម ព្រោះវាជាគំនិតល្អក្នុងការបញ្ចូលខ្លឹមសារនៃមុខវិជ្ជាស្ទែម ការបង្ហាញពីប្រធានបទពាក់ព័ន្ធនឹងជីវភាពរស់នៅ ការពង្រឹងសមត្ថភាពលើជំនាញក្នុងការទំនាក់ទំនង និងធ្វើបទបង្ហាញ។ គោលដៅសម្រាប់គម្រោងស្ទែមគឺះ | យ៉ាងតិចម្តងក្នុងមួយត្រីមាស | យ៉ាងតិចពីរដងក្នុងមួយត្រីមាស | | |

| | | | | | |
|---|---|---|---|---|---|
| | គ្រូបង្រៀនស្ទែមគួរតែមានផែនការ និងរៀបចំសកម្មភាពបែបរិះរកដោយបញ្ចូលខ្លឹមសារចេញពីអន្តរមុខវិជ្ជាស្ទែមស្ទើរគ្រប់មេរៀន ដោយប្រើវិធីសាស្ត្រអន្តរមុខវិជ្ជា។ សកម្មភាពទាំងនេះត្រូវស្របតាមកម្មវិធីសិក្សា។ | | | ✓ | |
| | គ្រូបង្រៀនស្ទែមសហការជាមួយគ្រូបង្រៀនវិទ្យាសាស្ត្រសង្គមដើម្បីស្វែងរកប្រធានបទដែលនាំឱ្យមានការបញ្ចូលខ្លឹមសារពីមុខវិជ្ជាមិនមែនស្ទែម ដើម្បីក្លាយជាវិធីសាស្ត្របង្កើតមុខវិជ្ជាថ្មីចេញពីបន្សំមុខវិជ្ជាច្រើន (transdisciplinary approach)។ ឧទាហរណ៍ ការសិក្សាពីប្រាសាទអង្គរវត្ត ជាបន្សំនៃបញ្ញត្តិស្ទែម ដូចជា ស្ថាបត្យកម្ម សម្ភារសាងសង់ ការថែរក្សាជាលក្ខណៈប្រវត្តិសាស្ត្រ)។ | | | | ✓ |
| ការសម្របតាមសមត្ថភាពសិស្ស | គ្រូបង្រៀនស្ទែមត្រូវស្គាល់សិស្សតាមរយៈការប្រមូលព័ត៌មានពីសមត្ថភាពសិស្ស វិធីសាស្ត្ររៀនសូត្រ និងចំណាប់អារម្មណ៍របស់សិស្ស។ ការប្រមូលនេះធ្វើឡើងតាមរយៈការស្ទង់មតិ ការសង្កេតឬការសន្ទនាក្នុងថ្នាក់រៀន។ សូមគិតអំពីភាពខុសគ្នារវាងកម្មវិធីសិក្សា និងតម្រូវការរបស់សិស្ស។ សូមពិចារណាចំណុចខាងក្រោម៖<br>-ផ្តល់ជម្រើសក្នុងការសិក្សាដល់សិស្ស និងឱ្យសិស្សបង្ហាញពីការយល់ដឹងរបស់ពួកគេ។ ឧទាហរណ៍ ឱ្យសិស្សជ្រើសរើសពីការបង្កើតគម្រោង ឬសរសេរពីប្រធានបទណាមួយ ។<br>-ផ្តល់ធនធានទៅតាមកម្រិតផ្សេងៗគ្នា យោងទៅលើសមត្ថភាពរបស់សិស្ស ដូច្នេះសិស្សទាំងនោះអាចទទួលការអភិវឌ្ឍ។<br>-ប្រើការវាយតម្លៃតាមដំណាក់ (លំហាត់) ដើម្បីតាមដានការសិក្សារបស់សិស្ស ពិនិត្យ និងកែសម្រួលវិធីសាស្ត្របង្រៀនរបស់លោក លោកស្រី។ | ព្យាយាមស្វែងរកការកែសម្រួលវិធីសាស្ត្របង្រៀនតាមរយៈកិច្ចប្រជុំបច្ចេកទេស ឬកិច្ចប្រជុំសហគមន៍សិក្សាវិជ្ជាជីវៈ | គ្រូបង្រៀនស្ទែមប្រើប្រាស់យ៉ាងតិចមួយវិធីសាស្ត្របង្រៀនដែលសម្របតាមសមត្ថភាពសិស្ស | គ្រូបង្រៀនស្ទែមប្រើប្រាស់វិធីសាស្ត្របង្រៀនដែលសម្របតាមសមត្ថភាពសិស្ស ជាប្រចាំ | |
| | សាលារៀនគួរតែបញ្ចូលសកម្មភាពដែលអាចបង្ហាញពីភាពខុសគ្នានៃខ្លឹមសារកម្មវិធីសិក្សា ដូចជា៖<br>-រៀបចំបណ្ណព័ត៌មានសិស្ស ដើម្បីកំណត់របៀបរៀនសូត្ររបស់សិស្ស សមត្ថភាព និងចំណង់ចំណូលចិត្ត | | | | ✓ |

| | | | | | |
|---|---|---|---|---|---|
| | -ផ្ដុំសិស្សតាមសមត្ថភាពសិស្ស និងសម្របសម្រួលវិធីបង្រៀនឱ្យសមស្របទៅតាមតម្រូវការរបស់សិស្ស។<br>-ប្រើឧបករណ៍បច្ចេកវិទ្យា ដែលអាចឱ្យទទួលបាននូវបទពិសោធន៍នៃការរៀនសូត្រ ដោយផ្ទាល់របស់សិស្ស។ ឧទាហរណ៍៖ កម្មវិធីរៀនដែលសម្របខ្លួន (adaptive learning software) ឬ បណ្ណាល័យដែលមានឯកសារឌីជីថល។ | | | | |
| ២.៣ | ២.៣ ការបញ្ចូលបច្ចេកវិទ្យា | | | | |
| | សកម្មភាពគួរអនុវត្ត | កម្រិតសាលារៀនទី ១ ដល់ ២ | កម្រិតសាលារៀនទី ២ ដល់ ៣ | កម្រិតសាលារៀនទី ៣ ដល់ ៤ | កម្រិតសាលារៀនទី៤ ដល់ ៥ |
| បច្ចេកវិទ្យាក្នុងថ្នាក់រៀន | ចំពោះសាលារៀនដែលមិនអាចប្រើប្រាស់ឧបករណ៍បញ្ចាំងស្លាយ (Projector) ឬថ្នាក់រៀនឆ្លាតវៃ៖ យោងទៅលើការអនុញ្ញាតពីគណៈគ្រប់គ្រងសាលា សូមពិចារណាក្នុងការឱ្យសិស្សយកទូរសព្ទមកសាលារៀនក្នុងថ្ងៃកំណត់ណាមួយ។ គោលដៅគឺទូរសព្ទ/ឧបករណ៍អេឡិចត្រូចនិចមួយសម្រាប់សិស្សបីនាក់។ | ✓ | | | |
| | ចំពោះសាលារៀនដែលមិនអាចប្រើប្រាស់ឧបករណ៍បញ្ចាំងស្លាយ (Projector) ឬថ្នាក់រៀនឆ្លាតវៃ៖ ឧបករណ៍បញ្ចាំងស្លាយពិតជាអាចបង្កើនការប្រើប្រាស់ថ្នាក់រៀនឱ្យមានប្រសិទ្ធភាព និងអាចស្រួលយកតាមខ្លួន។ ក្រុមអនុវត្តសកម្មភាពស្ទែមដឹកនាំការគៀងគរថវិកាក្នុងការទិញឧបករណ៍បញ្ចាំងស្លាយ ដោយយោងទៅតាមសមាសភាគទី៥ ភាពជាដៃគូយុទ្ធសាស្ត្រ។ | ✓ | | | |
| | គោលដៅចំពោះការប្រើប្រាស់បច្ចេកវិទ្យានៅក្នុងថ្នាក់រៀន។ | យ៉ាងហោចណាស់ម្ដងក្នុងមួយខែ | យ៉ាងហោចណាស់ម្ដងក្នុងមួយសប្ដាហ៍ | ប្រចាំថ្ងៃ បើអាច | |
| ធនធានឌីជីថល | គ្រូបង្រៀនស្ទែមប្រើប្រាស់ធនធានឌីជីថល (រូបភាព អក្សរ ឬវីដេអូ) ដែលសមស្របពីតំណភ្ជាប់របស់ក្រសួងអ.យ.ក។ សូមព្យាយាមប្រើប្រាស់វាឱ្យសមស្របទៅនឹងខ្លឹមសារមេរៀន ដោយប្រើប្រាស់សម្ភារគាំទ្រ (កិច្ចតែងការបង្រៀនដែលជំនួយដល់ការប្រើប្រាស់ស្ទែម)។ ធនធានទាំងនេះអាចនិយាយពីអាជីពស្ទែមដែលទាក់ទងនឹងខ្លឹមសារមេរៀនដែលលោក លោកស្រីកំពុងបង្រៀន ឬអំពីក្រុមហ៊ុន/សហគ្រាស ដែលមានបុគ្គលិកប្រើប្រាស់ជំនាញទាក់ទងនឹង | ✓ | ✓ | | |

| | | | | | |
|---|---|---|---|---|---|
| | ខ្លឹមសារនេះ។ សូមចែករំលែកបទពិសោធន៍ និងធនធានសមស្របជាមួយគ្រូបង្រៀនដទៃទៀតតាមរយៈកិច្ចប្រជុំក្រុមអនុវត្តសកម្មភាពស្ទែម។ | | | | |
| | គ្រូបង្រៀនស្ទែមស្វែងរកធនធានឌីជីថលបន្ថែមក្រៅពីក្រសួង.អ.យ.ក ផ្តល់ឱ្យតាមរយៈអ៊ីនធឺណិត។ ពួកគាត់គួរតែប្រើប្រាស់ធនធានទាំងនោះឱ្យស្របទៅនឹងតម្រូវការវប្បធម៌ និងភាសា និងដើម្បីឱ្យមានសមភាពយេនឌ័រ និងបញ្ឈប់ការប្រកាន់ផ្នត់គំនិត។<br><br>សូមចាត់ទុកថាព្យាយាមប្តូរប្រធានបទអំពីប្រទេសកម្ពុជាទៅជាបញ្ហាជាលក្ខណៈសកលវិញ។ ប្រសិនបើមានបញ្ហាក្នុងការប្រើប្រាស់ភាសាអង់គ្លេស ជួបជាមួយគ្រូភាសាអង់គ្លេស ដើម្បីឱ្យគាត់ជួយ។<br><br>សូមចែករំលែកធនធានសមស្របទៅឱ្យគ្រូបង្រៀនដទៃតាមរយៈការប្រជុំបច្ចេកទេស។ | | | ✓ | ✓ |
| បច្ចេកវិទ្យាអប់រំ និងការវាយតម្លៃអេឡិចត្រូនិក | ចំពោះសាលារៀនដែលមានដែនកំណត់ចំពោះការប្រើប្រាស់ឧបករណ៍បច្ចេកវិទ្យារបស់សិស្ស៖ គ្រូបង្រៀនស្ទែមលើកកម្ពស់បំណិនឌីជីថល និងការប្រើប្រាស់ឧបករណ៍បច្ចេកវិទ្យាសម្រាប់ការអប់រំ ដូចជា Moodle។ សូមចាប់ដៃគូជាមួយគ្រូដទៃទៀតដើម្បីកែលម្អជំនាញក្នុងការប្រើប្រាស់បច្ចេកវិទ្យាជាមួយគ្នា។ ជាងនេះទៀត ពួកគេគួរតែស្វែងរកការណែនាំពីគ្រូបង្រៀនដែលមានបទពិសោធន៍ឬក៏គ្រូជំនាញ ICT នៅពេលចាំបាច់។ | ✓ | ✓ | | |
| | ចំពោះសាលារៀនដែលមានសម្ភារបច្ចេកវិទ្យាគ្រប់គ្រាន់ សម្រាប់សិស្ស និងគ្រូ៖ គ្រូបង្រៀនស្ទែមពង្រីកការប្រើប្រាស់ឧបករណ៍បច្ចេកវិទ្យាអប់រំជាជាងឧបករណ៍ប្រើប្រាស់ដោយក្រសួងអ.យ.ក ( ឧ. Moodle )។ ពួកគាត់គួរតែធ្វើការស្វែងរក | | | ✓ | ✓ |

| | | | | | |
|---|---|---|---|---|---|
| | បន្ថែមនូវឧបករណ៍បច្ចេកវិទ្យាអប់រំផ្សេងៗដែលអាចលើកកម្ពស់ដល់ការរៀន និងរង្វាយតម្លៃក្នុងថ្នាក់រៀន។ វាអាចរាប់បញ្ចូលៈ ការបង្ហាញគំរូ (Simulation), សំណួរតេស្តអនឡាញ (Online quiz), ថ្នាលដាក់កូដ (Coding platform), ថ្នាលកែច្នៃល្បែង (Gamification platform), ឧបករណ៍រៀបចំស្លាយបទបង្ហាញ (Presentation tool) និងការប្រើប្រាស់កញ្ចប់គ្រឿងផ្គុំ (MarkerKits)។ | | | | |
| AI | គ្រូបង្រៀនស្ទែមចាប់ផ្តើមបន្សាំខ្លួនទៅនឹងការប្រើប្រាស់ AI ក្នុងវិស័យអប់រំ ដូចជាការប្រើប្រាស់កម្មវិធី Chat GPT។ សូមរៀនបន្ថែមពីការកំណត់ខ្លឹមសារដែលអាចប្រើប្រាស់ដោយ AI ដែលវាអាចជះឥទ្ធិពលដល់ការរៀន និងរង្វាយតម្លៃ។ សូមលើកយកការប្រើប្រាស់ AI ក្នុងកិច្ចប្រជុំក្រុមអនុវត្តសកម្មភាពស្ទែម និងចែករំលែកព័ត៌មាន។ | | | ✓ | ✓ |
| ប្រភពធនធាន | **ធនធានឌីជីថលៈ**<br>NGS YouTube channel:https://www.youtube.com/@ngspreahsisowath4702/playlists<br>CDDE:https://www.duraseksa.com/home<br>STEMEOC YouTube channel Example:https://www.youtube.com/playlist?list=PLFCyu-5h6q_DN_r3JlME5HtX4ZqRa4zSK<br>Sala:Digital School(moeys.gov.kh):https://sala.moeys.gov.kh/en<br><br>**ឧបករណ៍បច្ចេកវិទ្យាអប់រំៈ**<br>Phet Simulations:https://phet.colorado.edu/<br>Kahoot:https://kahoot.com/<br>Canva:https://www.canva.com/<br>TedEd:https://ed.ted.com/<br>SlidesGo:https://slidesgo.com/<br>Mentimeter:https://www.mentimeter.com/<br><br>**AI :**<br>https://www.unesco.org/en/articles/guidance-generative-ai-education-and-research | | | | |

| ២.៤ | ២.៤ ការផ្សារភ្ជាប់ទៅនឹងជីវភាពរស់នៅ |
|---|---|

| | សកម្មភាពគួរអនុវត្ត | កម្រិតសាលារៀនទី ១ ដល់ ២ | កម្រិតសាលារៀនទី ២ ដល់ ៣ | កម្រិតសាលារៀនទី ៣ ដល់ ៤ | កម្រិតសាលារៀនទី ៤ ដល់ ៥ |
|---|---|---|---|---|---|
| **បរិបទជីវភាពរស់នៅ** | គ្រូបង្រៀនស្ទែមស្វែងរកវិធីសាស្ត្រដែលគេអាចភ្ជាប់ខ្លឹមសារស្ទែមទៅនឹងជីវភាពរស់នៅជាក់ស្តែង។ សូមពិភាក្សាក្នុងកិច្ចប្រជុំក្រុមអនុវត្តសកម្មភាពស្ទែម និងសហគមន៍សិក្សាវិជ្ជាជីវៈ ព្រមទាំងចែករំលែកគំនិត និងធនធាន។ គោលដៅគឺបញ្ចូលការបង្រៀនតាមរយៈគោលដៅដូចខាងក្រោម៖<br><br>ខាងក្រោមនេះជាឧទាហរណ៍ពីរបៀបផ្សារភ្ជាប់នឹងជីវភាពរស់នៅ៖<br>**ក. បរិបទតំបន់៖** ប្រើប្រាស់ឧទាហរណ៍ និងមេរៀនជាក់ស្តែង ពីសហគមន៍ក្នុងតំបន់ ឬទីតាំងដែលសិស្សអាចពាក់ព័ន្ធ។<br>**ខ. វិទ្យាសាស្ត្រពលរដ្ឋ៖** ចូលរួមគម្រោងបែបវិទ្យាសាស្ត្របែបមនុស្ស ក្នុងប្រទេស<br>**គ. ការអនុវត្តជារៀងរាល់ថ្ងៃ៖** ផ្សារភ្ជាប់ខ្លឹមសារស្ទែមទៅនឹងជីវិតរស់នៅប្រចាំថ្ងៃ ដោយបង្ហាញពី បានប្រើប្រាស់ក្នុងសកម្មភាពឬបច្ចេកវិទ្យា<br>**ឃ. សកម្មភាពជាក់ស្តែង៖** ប្រើប្រាស់ការពិសោធន៍ឬគម្រោងជាក់ស្តែងដែលពាក់ព័ន្ធនឹងបញ្ញត្តិស្ទែម។<br>**ង. ករណីសិក្សា៖** ពិភាក្សាលើករណីសិក្សា ឬ រឿងអ្វីមួយដែលបង្ហាញពីបញ្ញត្តិស្ទែម ត្រូវបានប្រើប្រាស់សម្រាប់ដោះស្រាយបញ្ហាជាក់ស្តែង។<br>**ច. វាគ្មិន៖** អញ្ជើញវាគ្មិនពីវិស័យពាក់ព័ន្ធដើម្បីចែករំលែកបទពិសោធន៍ និងបង្ហាញពីទំនាក់ទំនងរបស់ស្ទែមទៅនឹងជីវភាពរស់នៅ។ | ម្តងម្កាល៖ យ៉ាងហោចណាស់ម្តងក្នុងមួយត្រីមាសសម្រាប់មុខវិជ្ជាស្ទែមយ៉ាងតិចមួយ។ | ជាញឹកញាប់៖ យ៉ាងហោចណាស់ពីរដងក្នុងមួយត្រីមាសសម្រាប់មុខវិជ្ជាស្ទែមនីមួយៗ | ជាប្រចាំ៖ យ៉ាងហោចណាស់ប្រចាំខែសម្រាប់មុខវិជ្ជាស្ទែម ទាំងអស់។ | ជាទម្លាប់៖ ប្រចាំសប្តាហ៍សម្រាប់មុខវិជ្ជាស្ទែមទាំងអស់ |
| **អាជីពស្ទែម** | គ្រូបង្រៀនស្ទែមព្យាយាមស្វែងរកភាពពាក់ព័ន្ធគ្នារវាងខ្លឹមសារមេរៀនស្ទែម និងអាជីព។ កែប្រែទម្រង់កិច្ចតែងការបង្រៀនដោយផ្សារភ្ជាប់អាជីពការងារទៅនឹងប្រធានបទនៃមេរៀន។ វាអាចជាភាពពាក់ព័ន្ធគ្នាលក្ខណៈធម្មតា ដោយមិនចាំបាច់ត្រូវការចំណេះដឹងជំនាញទាក់ទងនឹងអាជីពនីមួយៗ ឬគន្លងសិក្សា។ | ✓ | ✓ | | |

| | | | | | |
|---|---|---|---|---|---|
| | នៅពេលផ្សារភ្ជាប់ខ្លឹមសារស្ទែមជាមួយអាជីពស្ទែម ក្នុងកំឡុងពេលបង្រៀន លោកគ្រូព្យាយាមស្វែងរកកិច្ចសម្ភាសឬ រូបភាពណាមួយដែលពាក់ព័ន្ធនឹងអាជីពស្ទែម បង្ហាញទៅសិស្ស។ សូមប្រឹក្សាជាមួយអ្នកប្រឹក្សាអាជីព ប្រសិនបើមាននៅក្នុងសាលារៀន។ | | | ✓ | ✓ |
| | ពិភាក្សាពីការងារអនាគតជាមួយសិស្ស។ ស្រាវជ្រាវ និងរៀនសូត្រពីការប្រើប្រាស់បច្ចេកវិទ្យាថ្មីៗ និងជជែកជាមួយសិស្សពីជំនាញដែលគេត្រូវមាន និង ផលប៉ះពាល់ជាសក្តានុពលទៅលើជីវិតជាក់ស្តែង ក្នុងប្រទេសកម្ពុជា និងដទៃទៀត។ | | | ✓ | ✓ |
| | តែងតែមានគំនិតវៃឆ្លាត ពីគម្លាតយេនឌ័រនៅពេលធ្វើបទបង្ហាញពីការងារផ្នែកស្ទែម ឬក៏ជំនាញផ្នែកស្ទែម។ | ✓ | ✓ | ✓ | ✓ |
| ប្រភពធនធាន | **វិទ្យាសាស្ត្រពលរដ្ឋ៖**<br>វិទ្យាសាស្ត្រពលរដ្ឋគឺពាក់ព័ន្ធនឹងការចូលរួមជាលក្ខណៈសាធារណៈនៅក្នុងការស្រាវជ្រាវជាលក្ខណៈវិទ្យាសាស្ត្រ ដែលអាចឱ្យបុគ្គលម្នាក់ៗដែលមិនបានចូលវគ្គបណ្តុះបណ្តាលផ្នែកវិទ្យាសាស្ត្រ អាចចូលរួមចំណែកក្នុងការប្រមូលព័ត៌មាន វិភាគ និងផ្សព្វផ្សាយ។ វិធីសាស្ត្រនេះប្រើប្រាស់វិធីដោះស្រាយសំណួរបែបវិទ្យាសាស្ត្រដែលមានភាពស្មុគស្មាញ និងទទួលបានសំណុំទិន្នន័យធំ និងបានបង្កើនការទាក់ទងនឹងវិទ្យាសាស្ត្រ។<br><br>https://education.nationalgeographic.org/resource/citizen-science-projects/<br>https://science.nasa.gov/citizen-science/<br>https://www.societyforscience.org/research-at-home/citizen-science/<br><br>**អាជីពស្ទែម៖**<br>ស្ថានទូតអង់គ្លេសក្នុងប្រទេសកម្ពុជា៖<br>STEM Careers of the Future Downloadable Book:https://assets.publishing.service.gov.uk/media/5a7512e6ed915d5c54465553/STEM_Careers_of_the_Future.pdf | | | | |

| | | | | | |
|---|---|---|---|---|---|
| | STEMEOC:<br>STEM Sisters Cambodia Interviews:[https://stemcambodia.ngo/cycle-1-2019/](https://stemcambodia.ngo/cycle-1-2019/)<br>STEM Stars:[https://www.youtube.com/playlist?list=PLFCyu-5h6q_BS-iOLS2VAqfg9GdQbqdu](https://www.youtube.com/playlist?list=PLFCyu-5h6q_BS-iOLS2VAqfg9GdQbqdu) | | | | |

| ២.៥ | ២.៥ វាយតម្លៃ | | | | |
|---|---|---|---|---|---|
| | សកម្មភាពគួរអនុវត្ត | កម្រិតសាលារៀនទី ១ ដល់ ២ | កម្រិតសាលារៀនទី ២ ដល់ ៣ | កម្រិតសាលារៀនទី ៣ ដល់ ៤ | កម្រិតសាលារៀនទី ៤ ដល់ ៥ |
| វិធីសាស្ត្រវាយតម្លៃ | គ្រូបង្រៀនស្តែមបន្សាំខ្លួននឹងបញ្ញត្តិនៃវាយតម្លៃតាមដំណាក់ និងរបៀបប្រើប្រាស់លទ្ធផលដើម្បីកែលម្អការបង្រៀន ផ្តល់ព័ត៌មានត្រឡប់ និងលើកកម្ពស់ស្វ័យវាយតម្លៃសម្រាប់សិស្ស និងពង្រឹងលទ្ធផលការសិក្សារបស់សិស្ស។ | ម្តង ឬពីរដងក្នុងមួយត្រីមាស | ម្តងក្នុងមួយខែ | | |
| | គ្រូបង្រៀនស្តែមតែងតែប្រើប្រាស់វាយតម្លៃតាមដំណាក់ដើម្បីតាមដានវឌ្ឍនភាពការសិក្សារបស់សិស្ស។ បន្សាំខ្លួននឹងបញ្ញត្តិនៃវាយតម្លៃជាក់ស្តែង និងវាយតម្លៃផ្អែកលើសមត្ថភាព ព្រមទាំងបញ្ចូលប្រភេទនៃវាយតម្លៃទាំងនេះទៅក្នុងការវាយតម្លៃការសិក្សារបស់សិស្ស។ | | | ✓ | |
| | គ្រូបង្រៀនស្តែមតែងតែប្រើវាយតម្លៃតាមដំណាក់ដើម្បីតាមដានវឌ្ឍនភាពការសិក្សារបស់សិស្សគ្រប់មេរៀន និងអភិវឌ្ឍ ឬប្រើវាយតម្លៃផ្សេងៗទៀត ដើម្បីឱ្យបំពេញទៅលើតម្រូវការរៀនរបស់សិស្ស។ វាយតម្លៃទាំងនេះរួមមាន វាយតម្លៃជាក់ស្តែង វាយតម្លៃផ្អែកលើសមត្ថភាព វាយតម្លៃតាមអេឡិចត្រូនិក ឬថ្នាលការអប់រំ។ | | | | ✓ |

| | | | | | |
|---|---|---|---|---|---|
| លក្ខណៈវិនិច្ឆ័យនៃរង្វាយតម្លៃ | គ្រូបង្រៀនស្ទែមព្យាយាមឈ្វេងយល់ និងពង្រឹងចំណេះដឹងក្នុងការរៀបចំរង្វាយតម្លៃដោយមានលក្ខណៈវិនិច្ឆ័យច្បាស់លាស់សម្រាប់កម្រិតសមត្ថភាពរបស់នីមួយៗ (ឧ. និទ្ទេសបទ (rubric))។ | ✓ | ✓ | | |
| | គ្រូបង្រៀនស្ទែមរៀបចំរង្វាយតម្លៃដែលសមស្របទៅនឹងលទ្ធផលសិក្សារំពឹងទុក និងផ្អែកលើលក្ខណៈវិនិច្ឆ័យច្បាស់លាស់។ គ្រូបង្រៀនជជែកជាមួយសិស្សពីលក្ខណៈវិនិច្ឆ័យទាំងនេះមុននឹងធ្វើការវាយតម្លៃ និងប្រើប្រាស់វាសម្រាប់វាយតម្លៃកិច្ចការរបស់សិស្សប្រកបដោយសុក្រឹតភាព និងមានតម្លាភាព។ | | | ជាប្រចាំ | ជាប់លាប់ |
| ការឆ្លុះបញ្ចាំងនិងព័ត៌មានត្រឡប់ | គ្រូបង្រៀនស្ទែមប្រើប្រាស់រង្វាយតម្លៃជាឧបករណ៍សម្រាប់ធ្វើការសម្រេចចិត្តលើការបង្រៀន ឬក៏កែសម្រួលកម្មវិធីសិក្សា ជាជាងការវាយតម្លៃសមត្ថភាពរបស់សិស្ស។ គ្រូបង្រៀនធ្វើការឆ្លុះបញ្ចាំងសមត្ថភាពរបស់សិស្សដោយប្រើរង្វាយតម្លៃតាមដំណាក់ ដែលពួកគេត្រូវអនុវត្តក្នុងថ្នាក់រៀន និងគិតពីការផ្លាស់ប្តូរការបង្រៀនរបស់ពួកគេ ដើម្បីឱ្យលទ្ធផលការសិក្សារបស់សិស្សបានល្អប្រសើរជាងមុន។ សូមពិភាក្សាក្នុងកិច្ចប្រជុំក្រុមអនុវត្តសកម្មភាពស្ទែម។ | ✓ | ✓ | | |
| | គ្រូបង្រៀនស្ទែមរៀបចំរង្វាយតម្លៃពីការវិវឌ្ឍរបស់សិស្ស និងការយល់របស់ពួកគេដោយប្រើប្រាស់ព័ត៌មានសម្រាប់ការបង្រៀនរបស់ពួកគេ។ គ្រូបង្រៀនស្ទែមប្រើប្រាស់ពេលវេលាដើម្បីផ្តល់នូវព័ត៌មានត្រឡប់ទៅកាន់សិស្សម្នាក់ៗ ដើម្បីជំរុញពួកគេក្នុងការឆ្លុះបញ្ចាំងពីការរៀនរបស់ពួកគេ។ | | | ✓ | ✓ |
| ការធ្វើបទបង្ហាញរបស់សិស្ស | គ្រូបង្រៀនស្ទែមផ្តល់ឱកាសដល់សិស្សឡើងធ្វើបទបង្ហាញអំពីកិច្ចការរបស់ពួកគេដោយជាបុគ្គលឬជាក្រុម ទៅកាន់សិស្សដទៃទៀត។ វាជាការធម្មតាសម្រាប់ថ្នាក់ក្នុងការឃើញពីការឡើងបង្ហាញជាក្រុម ដែលជាផ្នែកមួយនៃសកម្មភាពស្ទែម។ បទពិសោធន៍ក្នុងការធ្វើបទបង្ហាញទៅលើអ្នកចូលរួមផ្សេងៗគឺពិតជាបទពិសោធន៍ដ៏ល្អសម្រាប់សិស្ស។ | ម្តង ឬពីរដងក្នុងមួយត្រីមាស | ម្តង ឬពីរដងក្នុងមួយឆ្នាំ | ប្រចាំខែ | ប្រចាំសប្តាហ៍ |
| | គ្រូបង្រៀនស្ទែមរៀបចំរង្វាយតម្លៃតាមដំណាក់ ដោយផ្អែកលើការធ្វើបទបង្ហាញរបស់សិស្ស ជាផ្នែកនៃឧបករណ៍រង្វាយតម្លៃ។ រង្វាយតម្លៃនេះគួរតែត្រូវបានកំណត់លក្ខណៈវិនិច្ឆ័យជាមុនធ្វើការវាយតម្លៃ។ | | | ✓ | ✓ |

| | | | | | |
|---|---|---|---|---|---|
| ប្រភពធនធាន | **វង្វាយតម្លៃ៖**<br>kapekh.org/files/report_file/362-en.pdf<br>kapekh.org/files/report_file/350-en.pdf<br>**គោលនយោបាយវង្វាយតម្លៃការសិក្សារបស់សិស្ស៖**<br>https://www.kapekh.org/files/report_file/363-en.pdf<br>**គោលនយោបាយស្តីពីការវាស់វែងការសិក្សាសិស្ស៖**<br>https://www.kapekh.org/files/report_file/364-en.pdf | | | | |

| ២.៦ | ២.៦ ការបង្រៀន | | | | |
|---|---|---|---|---|---|
| | សកម្មភាពគួរអនុវត្ត | កម្រិតសាលារៀនទី ១ ដល់ ២ | កម្រិតសាលារៀនទី ២ ដល់ ៣ | កម្រិតសាលារៀនទី ៣ ដល់ ៤ | កម្រិតសាលារៀនទី ៤ ដល់ ៥ |
| ការបង្រៀនក្នុងថ្នាក់រៀន និងការបង្រៀនតាមបែបទំនើប | គ្រូបង្រៀនស្ទែមត្រូវសម្របខ្លួនទៅតាមវិធីសាស្ត្របង្រៀនសិស្សមជ្ឈមណ្ឌល។ សូមពិភាក្សាគ្នាក្នុងកិច្ចប្រជុំជាមួយក្រុមអនុវត្តសកម្មភាពស្ទែម ឬសហគមន៍សិក្សាវិជ្ជាជីវៈ។ សូមស្វែងយល់ពីវិធីសាស្ត្របង្រៀនបែបទំនើប ចង្អុលបង្ហាញ និងរៀបរាប់ពីអត្ថប្រយោជន៍នៃការប្រើប្រាស់វា។ សូមពិភាក្សាអំពីការបង្រៀនបែបទំនើបដែលអាចប្រើប្រាស់ក្នុងថ្នាក់រៀនបាន និងចង្អុលបង្ហាញពីបញ្ហាប្រឈមដូចជាសមាមាត្រគ្រូ-សិស្ស និងទំហំថ្នាក់រៀន ជាដើម។ សូមផ្តល់យោបល់អំពីការប្រើប្រាស់វិធីសាស្ត្រណាមួយឱ្យបានជោគជ័យក្នុងថ្នាក់រៀន។ | បញ្ចូលការបង្រៀនបែបទំនើបយ៉ាងហោចណាស់ម្តងក្នុងមួយត្រីមាស | បញ្ចូលការបង្រៀនបែបទំនើបយ៉ាងហោចណាស់ម្តងក្នុងមួយខែ | | |
| | គ្រូបង្រៀនស្ទែមបញ្ចូលការបង្រៀនបែបទំនើបជាប្រចាំនៅក្នុងថ្នាក់រៀន និងបញ្ចូលសកម្មភាពរៀនបែបសកម្មទៅក្នុងមេរៀនជាប្រចាំសប្តាហ៍។ | | | ✓ | |
| | គ្រូបង្រៀនស្ទែមត្រូវប្រើប្រាស់វិធីសាស្ត្រសិស្សមជ្ឈមណ្ឌល ដោយប្រើប្រាស់ការប្រើប្រាស់ការបង្រៀនបែបទំនើប និងបញ្ចូលសកម្មភាពរៀនបែបសកម្មទៅក្នុងមេរៀន។ | | | | ✓ |

| | | | | | |
|---|---|---|---|---|---|
| | កិច្ចតែងការបង្រៀនត្រូវបានអភិវឌ្ឍ និងចែករំលែកទៅសាលារៀនដទៃតាមរយៈសមាគមន៍សិក្សាវិជ្ជាជីវៈ។ | | | | |
| គោលវិធីអន្តរមុខវិជ្ជា | គ្រូបង្រៀនស្ទែមត្រូវសម្របខ្លួនទៅនឹងគោលវិធីអន្តរមុខវិជ្ជា។ សូមពិភាក្សាចំណុចនេះទៅក្នុងការប្រជុំក្រុមអនុវត្តសកម្មភាពស្ទែម ឬក៏សមាគមន៍អភិវឌ្ឍអាជីព។ សហការជាមួយគ្រូបង្រៀនស្ទែមផ្សេងទៀត។ បង្ហាញពីសកម្មភាពអន្តរមុខវិជ្ជាតាមរយៈការបញ្ចូលមុខវិជ្ជាស្ទែមពីរផ្សេងទៀត និងសាកល្បងជាមួយសិស្សរបស់អ្នក។ បើសិនជាអ្នកជាអ្នកថ្មីសម្រាប់សកម្មភាពនេះ មុនដំបូងគឺចាប់ផ្តើមពីការប្រើប្រាស់គម្រោងស្ទែម ដែលត្រូវបញ្ចូលមុខវិជ្ជាស្ទែមជាមួយគ្នា។ ឧទាហរណ៍ ការប្រើប្រាស់ជំនាញបច្ចេកវិទ្យាក្នុងការស្រាវជ្រាវគម្រោងមុខវិជ្ជាជីវវិទ្យា។ សិស្សប្រើប្រាស់គណិតវិទ្យាដើម្បីគណនា និងវាស់វែងសំណង់ដែលបង្កើតឡើងនៅក្នុងសកម្មភាពរបស់មុខវិជ្ជារូបវិទ្យា។ | ម្តងឬពីរដងក្នុងមួយឆ្នាំ | យ៉ាងហោចណាស់ពីរដងក្នុងមួយឆមាស | | |
| | គ្រូបង្រៀនស្ទែមបញ្ចូលខ្លឹមសារមុខវិជ្ជាពីរឬច្រើនជាងនេះដើម្បីបង្កើតសកម្មភាពដោយប្រើប្រាស់គោលវិធីអន្តរមុខវិជ្ជាក្នុងការបង្រៀនរបស់ពួកគាត់។ | | | ពីរដងក្នុងមួយខែ | រៀងរាល់សប្តាហ៍ |
| | គ្រូបង្រៀនស្ទែមបញ្ចូលប្រធានបទដែលនាំឱ្យឈានទៅរកការបញ្ចូលខ្លឹមសារពីមុខវិជ្ជាមិនមែនស្ទែម ដើម្បីក្លាយទៅជាវិធីសាស្ត្របង្កើតមុខវិជ្ជាថ្មីចេញពីបន្សំមុខវិជ្ជាច្រើន។ | | | | ✓ |
| ការប្រើប្រាស់ធនធាន | គ្រូបង្រៀនស្ទែមប្រើប្រាស់ធនធានផ្សេងទៀតបានពីគេហទំព័រក្រសួងអ.យ.ក និងតំណភ្ជាប់ខាងក្រោម ដើម្បីជំនួសសៀវភៅសិក្សាគោល។ | ✓ | ✓ | | |
| | គ្រូបង្រៀនស្ទែមប្រើប្រាស់ឯកសារផ្តល់ពីក្រសួងអ.យ.ក តាមរយៈតំណភ្ជាប់។ សូមកែប្រែ និងពង្រឹងបន្ថែមដើម្បីឱ្យត្រូវនឹងវប្បធម៌ យេនឌ័រ និងតម្រូវការភាសា។ បើត្រូវការ អាចស្វែងរកជំនួយពីគ្រូបង្រៀនភាសាអង់គ្លេសដើម្បីកំណត់ធនធានជាភាសាអង់គ្លេស។ សូមប្រុងប្រយ័ត្នក្នុងការជ្រើសរើសធនធានដែលឆ្លើយតបនឹងយេនឌ័រ។ | | | ✓ | |

| | | | | | |
|---|---|---|---|---|---|
| | គ្រូបង្រៀនស្ទែមប្រើប្រាស់ធនធានផ្សេងៗក្នុងទម្រង់ជាក្រដាសឬឌីជីថល។ កំណត់ផ្នែកស្ទែមណាដែលខ្វះធនធានទម្រង់បើក (Open-access resource) និងបង្កើតសម្ភារស្របនឹងកម្មវិធីសិក្សារបស់កម្ពុជា ហើយឆ្លើយតបនឹងតម្រូវការភាសា យេនឌ័រ និងវប្បធម៌។ គាំទ្រ និងលើកទឹកចិត្តគ្រូបង្រៀនដទៃទៀតដោយមានការចែករំលែកធនធាន តាមរយៈសហគមន៍សិក្សាវិជ្ជាជីវៈក្នុងសាលា និងអន្តរសាលា។ | | | | ✓ |
| សកម្មភាពស្ទែមជាក់ស្តែង | សម្រាប់សាលារៀនដែលគ្មានសម្ភារស្ទែម៖ គ្រូបង្រៀនស្ទែមបន្សាំខ្លួននឹងអត្ថប្រយោជន៍នៃសកម្មភាពស្ទែមជាក់ស្តែងនៅក្នុងការបង្រៀនស្ទែម និងរបៀបបង្រៀនទ្រឹស្តី។ ពិភាក្សាពីអត្ថប្រយោជន៍នៃការបង្រៀនបែបនេះនៅក្នុងកិច្ចប្រជុំរបស់ក្រុមបច្ចេកទេស ឬសហគមន៍សិក្សាវិជ្ជាជីវៈ។ កំណត់បញ្ហាដែលគ្រូបង្រៀនអាចនឹងប្រឈម ដែលអាចជាឧបសគ្គក្នុងការអនុវត្តសកម្មភាពស្ទែមជាក់ស្តែង។ ឧទាហរណ៍ដូចជា ផលធៀបគ្រូ-សិស្ស កង្វះខាតសម្ភារបង្រៀន និងឧបករណ៍ដទៃទៀត។ ស្វែងរកដំណោះស្រាយចំពោះបញ្ហាទាំងនេះ។ ត្រូវដឹងថាសកម្មភាពស្ទែមជាក់ស្តែងជាច្រើនគឺអាចធ្វើទៅបានដោយមិនត្រូវការសម្ភារ ឧបករណ៍ ឬបន្ទប់ពិសោធន៍អ្វីឡើយ។ ស្រង់យកឯកសារឬធនធានពីក្រសួងអ.យ.ក ពីរបៀបធ្វើពិសោធន៍ដោយប្រើប្រាស់ឧបករណ៍មានតម្លៃថោក។ ឱ្យសិស្សប្រមូលឬបរិច្ចាកសម្ភារប្រើប្រាស់ណាដែលអាចយកមកប្រើបាន។ ពន្យល់ឱ្យបានច្បាស់ពីសារៈប្រយោជន៍នៃការផ្តល់នេះគឺសម្រាប់ការសិក្សាបែបសកម្មភាពស្ទែមជាក់ស្តែងដើម្បីបំពេញគោលដៅនៃការបង្រៀន និងរៀន។ | ម្តង ឬពីរដងក្នុងមួយត្រីមាស | | | |
| | សម្រាប់សាលារៀនដែលមានឧបករណ៍តិចតួច៖ គ្រូបង្រៀនស្ទែមបន្សាំខ្លួននឹងអត្ថប្រយោជន៍នៃសកម្មភាពស្ទែមជាក់ស្តែងនៅក្នុងការបង្រៀនស្ទែម និងរបៀបបង្រៀនទ្រឹស្តី។ ពិភាក្សាពីអត្ថប្រយោជន៍នៃការបង្រៀនបែបនេះនៅក្នុងកិច្ចប្រជុំរបស់ក្រុមបច្ចេកទេស ឬសហគមន៍សិក្សាវិជ្ជាជីវៈ។ កំណត់បញ្ហាដែលគ្រូបង្រៀនអាចនឹងប្រឈម ដែលអាចជាឧបសគ្គក្នុងការអនុវត្តសកម្មភាពស្ទែមជាក់ស្តែង។ | | យ៉ាងហោចណាស់ពីរដងក្នុងមួយខែ | | |

| | | | | | |
|---|---|---|---|---|---|
| | ឧទាហរណ៍ដូចជា ផលធៀបគ្រូ-សិស្ស កង្វះខាតសម្ភារបង្រៀន និងឧបករណ៍ដទៃទៀត។ ស្វែងរកដំណោះស្រាយចំពោះបញ្ហាទាំងនេះ។ ត្រូវដឹងថាសកម្មភាពស្ទែមជាក់ស្តែងជាច្រើនគឺអាចធ្វើទៅបានដោយមិនត្រូវការសម្ភារ ឧបករណ៍ ឬបន្ទប់ពិសោធន៍អ្វីឡើយ។ ប្រសិនបើឧបករណ៍បង្រៀនគឺមានកំណត់ សូមស្វែងរកសកម្មភាពណាដែលអាចធ្វើទៅរួចក្នុងថ្នាក់រៀនធម្មតា ឬក៏នៅក្រៅទីធ្លាសាលារៀន (ការគណនាកម្ពស់អាគារ ប្រមូលសំណាកទឹកសម្រាប់ការធ្វើតេស្ត)។ សូមកំណត់សកម្មភាពដែលអាចធ្វើទៅរួច និងពន្យល់ពីសារៈប្រយោជន៍នៃសកម្មភាពនេះទៅកាន់សិស្សរបស់អ្នក និងបញ្ចូលសកម្មភាពដូចខាងក្រោម។ | | | | |
| | សូមបញ្ចូលសកម្មភាពស្ទែមជាក់ស្តែងទៅក្នុងការបង្រៀនដូចខាងក្រោម៖ លើកទឹកចិត្តសាលារៀនដទៃទៀតឱ្យបញ្ចូលសកម្មភាពក្រៅថ្នាក់ទាំងនេះដោយមានការចែករំលែកធនធានឬឯកសារតាមរយៈសហគមន៍សិក្សាវិជ្ជាជីវៈអន្តរសាលា។ | | | ប្រចាំសប្តាហ៍ | ជាប្រចាំ បើអាច |
| ការឆ្លើយតបនឹងយេនឌ័រ | គ្រូបង្រៀននិងថ្នាក់ដឹកនាំសាលារៀនយល់ពីគោលការណ៍ឆ្លើយតបនឹងយេឌ័រក្នុងការបង្រៀន។ សូមមើលតំណភ្ជាប់ខាងក្រោម និងពិនិត្យមើលថាតើគោលការណ៍នេះអាចត្រូវបានបញ្ចូលក្នុងសាលារៀនរបស់ពួកគេ។ | ✓ | | | |
| | គ្រូបង្រៀននិងថ្នាក់ដឹកនាំសាលារៀនយល់ពីគោលការណ៍ឆ្លើយតបនឹងយេឌ័រក្នុងការបង្រៀនដូចខាងក្រោម។ | | ម្តងម្កាល | ជាប្រចាំ | ជាប់លាប់ |
| | គ្រូបង្រៀនស្ទែមនិងថ្នាក់ដឹកនាំសាលារៀនប្រមូល បង្កើត និងចែករំលែកឯកសារស្ទែមទាក់ទងនឹងការឆ្លើយតបនឹងយេនឌ័រឱ្យគ្រូបង្រៀនតាមរយៈសហគមន៍សិក្សាវិជ្ជាជីវៈអន្តរសាលា។ | | | | ✓ |
| ប្រភពធនធាន | **កិច្ចការគម្រោង៖**<br>https://www.kapekh.org/files/report_file/371-en.pdf<br><br>**ឯកសារឌីជីថលដើម្បីពង្រឹងកម្មវិធីសិក្សាស្ទែម៖**<br>Sala: Digital School ( moeys.gov.kh ):https://sala.moeys.gov.kh/en | | | | |

| | |
|---|---|
| | ឆាណែល YouTube របស់វិទ្យាល័យព្រះស៊ីសុវត្ថិ សាលារៀនជំនាន់ថ្មី៖<br><br>របៀបចូលធ្វើតេស្តតាមរយៈ App ក្នុងទូរសព្ទរបស់ **NGS MOBILEAPP (youtube.com)**<br>:https://www.youtube.com/@ngspreahsisowath4702/playlists<br>CDDE Duraseksa:https://www.duraseksa.com/home<br><br>STEMEOC:https://www.youtube.com/@StemCambodia/playlists<br><br>ការឆ្លើយតបនឹងយេនឌ័រសម្រាប់គ្រូបង្រៀន៖<br>សកម្មភាពសំខាន់ៗសម្រាប់ជំរុញដល់ការឆ្លើយតបនឹងយេនឌ័រនៅក្នុងសាលាបឋមសិក្សា និងអនុវិទ្យាល័យ<br>https://www.kapekh.org/files/report_file/170-en.pdf<br><br>ការឆ្លើយតបនឹងយេនឌ័រសម្រាប់គណៈគ្រប់សាលារៀន៖<br>សកម្មភាពសំខាន់ៗសម្រាប់ជំរុញដល់ការឆ្លើយតបនឹងយេនឌ័រនៅក្នុងសាលាបឋមសិក្សា និងអនុវិទ្យាល័យ<br>https://www.kapekh.org/files/report_file/171-en.pdf<br><br>សូមដាក់បន្ថែមធនធានជាភាសាខ្មែរ ប្រសិនបើមាន។ |

# ជំហានទី៤ ៖ ផែនការសកម្មភាពសម្រាប់ក្របខណ្ឌអប់រំស្ទែមកម្រិតសាលារៀន

## សមាសភាគទី៣ ៖ អភិបាលកិច្ចសាលារៀន

| | |
|---|---|
| **សមាសភាគទី៣** | អភិបាលកិច្ចសាលារៀន |
| **អ្នកទទួលខុសត្រូវ** | សមាជិកបង្គោលនៃក្រុមអនុវត្តសកម្មភាពស្ទែមដែលត្រូវបានចាត់តាំងឱ្យទទួលខុសត្រូវសមាសភាគនេះ ដោយមានការគាំទ្រពីសមាជិកបង្គោល ឬសមាជិកគាំទ្រផ្សេងទៀត។<br>ចំណាំ៖ ប្រធានក្រុមអនុវត្តសកម្មភាពស្ទែមប្រហែលជាអាចត្រូវចាត់តាំងអ្នកទទួលខុសត្រូវចំពោះសមាសភាគនេះជាថ្មី នៅជំហានទី៣ ដើម្បីធានានូវទំហំការងារសមស្រប និងមានប្រសិទ្ធភាព។ |
| **សមាជិកក្រុមអនុវត្តសកម្មភាពស្ទែមសម្រាប់ទទួលខុសត្រូវសមាសភាគនេះ** | |
| **ឆ្នាំទី** | (ឧ. ឆ្នាំទី១៖ ឆ្នាំសិក្សា២០២៤-២០២៥) |
| **ដំណើរការ** | <br>ក្របខណ្ឌអប់រំស្ទែមកម្រិតសាលារៀនមាន ៥ជំហានដើម្បីគាំទ្រសាលារៀនក្នុងការបង្រៀន និងរៀនមុខវិជ្ជាស្ទែម។ ដើម្បីឱ្យជំហានទី៤នេះទទួលបានជោគជ័យ លោក លោកស្រីត្រូវអនុវត្តជំហានទី១ ២ និង ៣ ប្រកបដោយប្រសិទ្ធិភាព។<br><br>ផែនការសកម្មភាពស្ទែម នៃក្របខណ្ឌអប់រំស្ទែមកម្រិតសាលារៀននេះរៀបរាប់អំពីសកម្មភាពដែលអាចអនុវត្តបានដើម្បីពង្រឹងសមាស |

| | |
|---|---|
| | ភាគទី២៖ អភិបាលកិច្ចសាលារៀន ហើយអាចស្ថិតនៅក្នុងសមាសភាគរងខាងក្រោម៖<br>៣.១ វប្បធម៌ស្នែម<br>៣.២ ភាពជាអ្នកដឹកនាំសាលារៀន<br>៣.៣ ការរៀបចំផែនការអភិវឌ្ឍសាលារៀន<br>៣.៤ រចនាសម្ព័ន្ធគាំទ្រ<br>៣.៥ ការគ្រប់គ្រងធនធាន<br>៣.៦ ការគ្រប់គ្រងទិន្នន័យ<br>៣.៧ ការវាយតម្លៃ<br>៣.៨ ការទទួលស្គាល់ពីថ្នាក់ជាតិ |
| **គោលបំណងរបស់ឧបករណ៍** | ផែនការសកម្មភាពរបស់ក្របខណ្ឌអប់រំស្នែមកម្រិតសាលារៀនបង្ហាញពីជំហានជាក់ស្តែង យោងទៅតាមសមាសភាគទាំង៥ នីមួយៗ សម្រាប់ការលើកកម្ពស់ការអប់រំស្នែមនៅសាលារៀន។ សកម្មភាពទាំងនេះត្រូវបានចាត់ថ្នាក់ដោយផ្អែកលើកម្រិតអភិវឌ្ឍន៍ ដូចនេះលោកលោកស្រីអាចអនុវត្តតាមកម្រិតអភិវឌ្ឍន៍របស់សាលារៀន ដូចដែលបានកំណត់ដោយឧបករណ៍ស្វ័យវាយតម្លៃ (ជំហានទី៣)។ វិធីសាស្ត្រនេះធានាថាសកម្មភាពដែលបានណែនាំត្រូវបានកែសម្រួលទៅតាមធនធាន និងសមត្ថភាពរបស់សាលារៀន។ នៅពេលដែលលោក លោកស្រីជួបប្រទះនឹងឧបសគ្គដូចជាសម្ភារបរិក្ខារ ឬថវិកានៅមានកម្រិត សូមព្យាយាមឆ្ពោះទៅរកការអនុវត្តសកម្មភាពទាំងអស់ដែលអាចធ្វើទៅបាន។ តារាងខាងក្រោមក៏រួមបញ្ចូលផងដែរនូវគោលដៅដែលអាចសម្រេចបានដែលទាក់ទងទៅនឹងកម្រិតអភិវឌ្ឍន៍របស់សាលារៀនដោយបម្រើជារង្វាស់នៃវឌ្ឍនភាពរបស់សាលារៀនលោក លោកស្រី។ |
| **ការណែនាំ** | 1. ពិនិត្យមើលទៅជំហានទី៣៖ ឧបករណ៍ពិនិត្យឡើងវិញ និងកំណត់គោលដៅ ដើម្បីកំណត់ផែនការសកម្មភាពស្នែមដែលសាលារៀនត្រូវអនុវត្តតាម<br>2. ពិចារណាលើសកម្មភាពដែលបានលើកឡើងនៅក្នុងផែនការសកម្មភាពស្នែម ដែលបានសង្ខេបក្នុងតារាងខាងក្រោមអំពីកម្រិតរបស់សាលារៀននៅក្នុងសមាសភាគនេះ |

| | |
|---|---|
| | 3. ជ្រើសរើសសកម្មភាពដែលអាចអនុវត្តបាន ដូចដែលបានរៀបរាប់នៅក្នុងតារាង ប្រសិនបើសកម្មភាពមានចំនួនច្រើន ចូរជ្រើសរើសតែសកម្មភាពណាដែលលោក លោកស្រីអាចធ្វើទៅបានក្នុងឆ្នាំនេះ<br>4. ពិនិត្យប្រភពឯកសារ ឬតំណភ្ជាប់សំខាន់ៗដែលអាចជួយឱ្យលោក លោកស្រីរៀបចំផែនការ និងអនុវត្តសកម្មភាព<br>5. ពិនិត្យមើលនៅក្នុងសទ្ទានុក្រមសម្រាប់ពាក្យពិបាកយល់។ |

# ការរម្លឹកពីគោលដៅដែលបានកំណត់

សូមមើលជំហានទី៣ និងកំណត់ចំណាំគោលដៅអ្នកនៅទីនេះដើម្បីមានភាពងាយស្រួល។

**តារាងទី ៩៖ ការកំណត់គោលដៅ និងការកំណត់ផែនការសកម្មភាពស្វែង**

| គោលដៅសម្រាប់ឆ្នាំបន្ទាប់៖ (✓ ជ្រើសរើសយកជម្រើសមួយ) | គោលដៅសម្រាប់ឆ្នាំបន្ទាប់៖ (✓ ជ្រើសរើសយកជម្រើសមួយ) | ✓សមាសភាគស្វែង ដែលត្រូវពង្រឹង | តម្លៃ DDL | សញ្ញា ✓ ចង្អុលបង្ហាញពីផែនការសកម្មភាពដែលអនុវត្ត | | | |
|---|---|---|---|---|---|---|---|
| | | | | កម្រិតសាលារៀន ទី១ ទៅ ២ | កម្រិតសាលារៀន ទី២ ទៅ ៣ | កម្រិតសាលារៀន ទី៣ ទៅ ៤ | កម្រិតសាលារៀន ទី៤ ទៅ ៥ |
| ☐ | **ជម្រើសទី១៖** សម្រេចបានលទ្ធផលប្រហាក់ប្រហែលគ្នានៅក្នុងចំណោមសមាសភាគទាំង៥ ដោយព្យាយាមពង្រឹងលើសមាសភាគដែលខ្សោយ។ | ☐ ហេដ្ឋារចនាសម្ព័ន្ធ | | | | | |
| | | ☐ វប្បធម៌សាលារៀន និងអភិបាលកិច្ច | | | | | |
| | | ☐ សមត្ថភាពរបស់គ្រូបង្រៀន និងលទ្ធផលការសិក្សារបស់សិស្ស | | | | | |
| | | ☐ ដំណើរការបង្រៀន និងរៀន | | | | | |
| | | ☐ ការចូលរួមរបស់សហគមន៍ | | | | | |
| ឬ | | | | | | | |
| គោលដៅសម្រាប់ឆ្នាំបន្ទាប់៖ | គោលដៅសម្រាប់ឆ្នាំបន្ទាប់៖ | ✓សមាសភាគស្វែង ដែលត្រូវពង្រឹង | តម្លៃ DDL | សញ្ញា ✓ ចង្អុលបង្ហាញពីផែនការសកម្មភាពដែលអនុវត្ត | | | |
| | | | | កម្រិតសាលារៀន ទី១ ទៅ ២ | កម្រិតសាលារៀន ទី២ ទៅ ៣ | កម្រិតសាលារៀន ទី៣ ទៅ ៤ | កម្រិតសាលារៀន ទី៤ ទៅ ៥ |
| ☐ | **ជម្រើសទី២៖** សម្រេចបានកម្រិតបន្ទាប់ នៃកម្រិតអភិវឌ្ឍនៅក្នុងសមាសភាគចំនួន៣ | ☐ ហេដ្ឋារចនាសម្ព័ន្ធ | | | | | |
| | | ☐ វប្បធម៌សាលារៀន និងអភិបាលកិច្ច | | | | | |
| | | ☐ សមត្ថភាពរបស់គ្រូបង្រៀន និងលទ្ធផលការសិក្សារបស់សិស្ស | | | | | |
| | | ☐ ដំណើរការបង្រៀន និងរៀន | | | | | |
| | | ☐ ការចូលរួមរបស់សហគមន៍ | | | | | |

## សេចក្តីរៀបរាប់៖ កម្រិតអភិវឌ្ឍន៍តាមសមាសភាគ (DDL) បច្ចុប្បន្ន និងគោលដៅសម្រាប់សមាសភាគនេះ៖

កម្រិតអភិវឌ្ឍន៍របស់សាលារៀនយើង នៅត្រង់សមាសភាគនេះ គឺកម្រិត ____ ។ គោលដៅរបស់សាលារៀនដើម្បីឆ្ពោះទៅរកកម្រិត______ ដូចនេះយើងនឹងអនុវត្តតាមសកម្មភាពដែលបានណែនាំដើម្បីអភិវឌ្ឍពីកម្រិត_______ទៅ កម្រិត____នៅក្នុងតារាងខាងក្រោម និងខិតខំដើម្បីសម្រេចគោលដៅដែលបានកំណត់។

*(ឧទាហរណ៍៖ កម្រិតអភិវឌ្ឍន៍របស់សាលារៀនយើង នៅត្រង់សមាសភាគនេះ គឺកម្រិត __2__ ។ គោលដៅរបស់សាលារៀនដើម្បីឆ្ពោះទៅរកកម្រិត____3_____ ដូចនេះយើងនឹងអនុវត្តតាមសកម្មភាពដែលបានណែនាំដើម្បីអភិវឌ្ឍពីកម្រិត_____2_____ទៅ កម្រិត_____3_____នៅក្នុងតារាងខាងក្រោម និងខិតខំដើម្បីសម្រេចគោលដៅដែលបានកំណត់។)*

## កូដពណ៌៖

| | ✓ | |
|---|---|---|
| សកម្មភាពមិនទាន់បានអនុវត្ត៖ សាលារៀននៅកម្រិតនេះមិនទាន់ត្រៀមសម្រាប់សកម្មភាពនេះ | សញ្ញា ✓ បង្ហាញថាសកម្មភាពនេះអាចអនុវត្តបានក្នុងសាលារៀនក្នុងកម្រិតនេះ | សាលារៀននៅក្នុងកម្រិតនេះគឺអាចសម្រេចបានសកម្មភាពដែលបានលើកឡើង |

| ៣.១ | ៣.១ វប្បធម៌ស្ទែម | | | | |
|---|---|---|---|---|---|
| | សកម្មភាពគួរអនុវត្ត | កម្រិតសាលារៀន ទី១ ដល់ ២ | កម្រិតសាលារៀន ទី២ ដល់ ៣ | កម្រិតសាលារៀន ទី៣ ដល់ ៤ | កម្រិតសាលារៀន ទី៤ ដល់ ៥ |
| គោលនយោបាយ និងការប្តេជ្ញាចិត្ត | ដាក់ប្រធានបទស្ទែមទៅក្នុងរបៀបវារៈកិច្ចប្រជុំបុគ្គលិកសាលារៀន និងកិច្ចប្រជុំគណៈគ្រប់គ្រងសាលារៀន<br>• ប្រើការប្រជុំទាំងនេះជាឱកាសដើម្បីបង្កើនការយល់ដឹងអំពីសារៈសំខាន់នៃស្ទែមសម្រាប់ប្រទេសកម្ពុជា សហគមន៍ និងជាមធ្យោបាយសម្រាប់សិស្សក្នុងការអភិវឌ្ឍជំនាញសតវត្សរ៍ទី២១ សំខាន់ៗ។ សូមចែករំលែកវីដេអូ ឬធនធានដើម្បីផ្សព្វផ្សាយរឿងស្ទែម (សូមមើលប្រភពធនធានខាងក្រោម)។<br>• ធ្វើបច្ចុប្បន្នកម្ម ឬជូនដំណឹងដល់គណៈគ្រប់គ្រងសាលារៀន និងបុគ្គលិកអំពីគោលដៅនៃក្របខណ្ឌអប់រំស្ទែមកម្រិតសាលារៀន និងវឌ្ឍនភាពក្នុងការអនុវត្តផែនការសកម្មភាពស្ទែម។ សូមផ្សព្វផ្សាយអំពីសមាសភាគទាំង៥។<br>• អញ្ជើញបុគ្គលិកឱ្យផ្តល់យោបល់អំពីរបៀបកែលម្អការបង្រៀនស្ទែម ឬចែករំលែកព័ត៌មាន ឬឱកាសសម្រាប់គ្រូបង្រៀនស្ទែម ដើម្បីបង្កើនសមត្ថភាព។ | យ៉ាងហោចណាស់ពីរដងក្នុងមួយឆ្នាំ | យ៉ាងហោចណាស់ម្តងក្នុងមួយត្រីមាស | ប្រចាំខែ | គ្រប់ការប្រជុំ។ ស្ទែមគឺជារឿងសំខាន់នៅក្នុងសាលារៀន។ |

| ៣.២ | ៣.២ ភាពជាអ្នកដឹកនាំសាលារៀន | | | | |
|---|---|---|---|---|---|
| | សកម្មភាពគួរអនុវត្ត | កម្រិតសាលារៀន ទី១ ដល់ ២ | កម្រិតសាលារៀន ទី២ ដល់ ៣ | កម្រិតសាលារៀនទី៣ ដល់ ៤ | កម្រិតសាលារៀនទី៤ ដល់ ៥ |
| ការយល់ដឹង | ក្រុមអនុវត្តសកម្មភាពស្ទែមលើកទឹកចិត្តគណៈគ្រប់គ្រងសាលារៀនឱ្យស្វែងរកព័ត៌មានបន្ថែមអំពីវិធីសាស្ត្រស្ទែម។ ប្រសិនបើគ្មានជម្រើសបណ្តុះបណ្តាលសម្រាប់គណៈគ្រប់គ្រងសាលារៀនទេ សូមចែករំលែកធនធានដែលនឹងធ្វើឱ្យការយល់ដឹងកាន់តែប្រសើរឡើង។<br>ឧទាហរណ៍៖ ឯកសារបណ្តុះបណ្តាលគ្រូ ឬវីដេអូ សូមមើលប្រភពធនធានខាងក្រោម។ | ✓ | ✓ | | |

| | | | | | |
|---|---|---|---|---|---|
| តួនាទី | ក្រុមអនុវត្តសកម្មភាពស្ទែមលើកឡើងតម្រូវការ ឬបញ្ហាប្រឈមស្ទែម ដល់គណៈគ្រប់គ្រងសាលារៀន ឧទាហរណ៍៖ ទីកន្លែងសម្រាប់គម្រោងស្ទែម, ពេលវេលាសម្រាប់សកម្មភាពស្ទែម, ប្លង់បន្ទប់រៀន។ សូមប្រើពេលវេលាសម្រាប់ស្ទែមនៅកិច្ចប្រជុំបុគ្គលិក ដើម្បីស្វែងរកដំណោះស្រាយចំពោះបញ្ហាប្រឈមទាំងនេះ។ | ✓ | ✓ | | |
| | គណៈគ្រប់គ្រងសាលារៀនដើម្បីពិនិត្យមើលសំណុំឧបករណ៍ត្រួតពិនិត្យ និងវាយតម្លៃស្ទែម (សូមមើលតំណខាងក្រោម) ហើយវាយតម្លៃស្ថានភាពស្ទែម នៅក្នុងសាលារៀនរបស់អ្នកដោយប្រើឧបករណ៍ដែលបានផ្តល់សម្រាប់គណៈគ្រប់គ្រងសាលារៀន។ | | | ✓ | ✓ |
| ការយល់ដឹងពីយេនឌ័រ | សកម្មភាពសម្រាប់គណៈគ្រប់គ្រងសាលារៀន៖ ការប្រើប្រាស់ជាគំរូនៃការប្រើប្រាស់ភាសាដែលឆ្លើយតបនឹងយេនឌ័រនៅក្នុងបរិបទស្ទែម គាំទ្រក្រុមអនុវត្តសកម្មភាពស្ទែមរួមទាំងអ្នកជំនាញផ្នែកស្ទែមជាស្ត្រីនៅក្នុងតំបន់ (សូមមើល សមាសភាគទី៥៖ ការចូលរួមរបស់គ្រួសារ/សហគមន៍) លើកទឹកចិត្តសិស្សស្រី សម្របសម្រួលកម្មវិធីដែលផ្តោតលើការចូលរួមរបស់សិស្សស្រីនៅក្នុងស្ទែម។ សូមធានាថាសិស្សស្រីត្រូវបានពិចារណាសម្រាប់ក្រុមស្ទែម ដែលប្រកួតប្រជែងក្នុងនាមសាលារៀន។ | ✓ | ✓ | ✓ | |
| | មានតុល្យភាពយេនឌ័រនៅក្នុងគណៈកម្មការគ្រប់គ្រងសាលារៀន ព្រឹត្តិការណ៍ស្ទែម និងពិពណ៌អាជីព។ល។ | ✓ | ✓ | ✓ | ✓ |
| បំណិនឌីជីថល និងបញ្ញាសប្បនិម្មិត | ក្រុមអនុវត្តសកម្មភាពស្ទែមចែករំលែកព័ត៌មានដល់គណៈគ្រប់គ្រងសាលារៀនអំពីវគ្គសិក្សាតាមអ៊ីនធឺណិតដោយឥតគិតថ្លៃ ដើម្បីបង្កើនជំនាញឌីជីថល។ ក្រុមអនុវត្តសកម្មភាពស្ទែមស្នើការគាំទ្រពីគ្រូបង្រៀន ICT តាមដែលសមស្រប។ គណៈគ្រប់គ្រងសាលាត្រូវតែធ្វើឱ្យប្រសើរឡើងនូវជំនាញឌីជីថលដល់កម្រិតមួយដែលនឹងអនុញ្ញាតឱ្យយល់អំពីផលជះនៃ AI ក្នុងប៉ុន្មានឆ្នាំខាងមុខនេះ រួមជាមួយនឹងការគ្រប់គ្រងទិន្នន័យដែលប្រសើរឡើង។ | ✓ | ✓ | | |

| | |
|---|---|
| ប្រភពធនធាន | តើស្ទែមជាអ្វី? https://youtu.be/2HelbHNqcSk?si=9aLcb75y7mPhFX7e<br>សៀវភៅណែនាំបណ្តុះបណ្តាលស្ទែមសម្រាប់គ្រូបង្រៀន៖ https://drive.google.com/file/d/1HRWzhA6c-HMfFLsWR2E9jOeEII7L9LJX/view?usp=sharing<br>កញ្ចប់ឧបករណ៍ត្រួតពិនិត្យ និងវាយតម្លៃស្ទែមសម្រាប់គណៈគ្រប់គ្រងសាលារៀន៖ https://sala.moeys.gov.kh/library/00001350<br>AI៖https://www.unesco.org/en/articles/guidance-generative-ai-education-and-research<br>យេនឌ័រ៖ សេចក្តីណែនាំស្តីពីការលើកកម្ពស់ការឆ្លើយតបនឹងយេនឌ័រនៅក្នុងសាលាបឋមសិក្សា និងអនុវិទ្យាល័យនៅកម្ពុជា៖<br>https://www.kapekh.org/files/report_file/171-en.pdf<br><br>តំណភ្ជាប់វគ្គជំនាញឌីជីថលតាមអ៊ីនធឺណិត របស់ក្រសួងអប់រំ យុវជន និងកីឡា ដែលត្រូវការនៅទីនេះ។ |

| ៣.៣ | ៣.៣ រចនាសម្ព័ន្ធគាំទ្រ | | | | |
|---|---|---|---|---|---|
| | សកម្មភាពគួរអនុវត្ត | កម្រិតសាលារៀនទី១ ដល់ ២ | កម្រិតសាលារៀនទី២ ដល់ ៣ | កម្រិតសាលារៀនទី៣ ដល់ ៤ | កម្រិតសាលារៀនទី៤ ដល់ ៥ |
| ក្រុមគ្រូបង្រៀនស្ទែម / ក្រុមអនុវត្តសកម្មភាពស្ទែម / សហគមន៍សិក្សាវិជ្ជាជីវៈ | ក្រុមអនុវត្តសកម្មភាពស្ទែមរៀបចំការជួបក្រៅផ្លូវការម្តងក្នុងមួយត្រីមាសសម្រាប់គ្រូបង្រៀនស្ទែម។ សមាជិកបង្គោលរបស់ក្រុមអនុវត្តសកម្មភាពស្ទែមដើរតួជាអ្នកដឹកនាំ។ គ្រូបង្រៀន ស្ទែមស្ម័គ្រចិត្តចែករំលែកបទពិសោធន៍ ធនធាន និងបទពិសោធន៍ជាមួយអ្នករួមការងារ។ សូមប្រើឱកាសនេះដើម្បីពិនិត្យមើលសម្ភារគាំទ្រ (ឧ. ផែនការកម្មវិធីសិក្សា/កិច្ចតែងការបង្រៀន ដែលបានពង្រឹងស្ទែម សូមមើល សមាសភាគទី៤៖ ក្នុងគោលបំណងបញ្ចូលទៅក្នុងការបង្រៀនក្នុងថ្នាក់។ ការប្រជុំទាំងនេះអាចជាពេលសម្រាក ឬអាហារថ្ងៃត្រង់ ឬ ពេលសម្រាកអាហារសម្រន់។<br><br>ការប្រជុំទាំងនេះជាសហគមន៍សិក្សាវិជ្ជាជីវៈក្រៅផ្លូវការ ហើយអាចក្លាយជាផ្លូវការជាមួយការជួបប្រជុំផ្ទាល់មុខ និងតាមបណ្តាញទំនាក់ទំនងជាទៀងទាត់ (ឧ. ក្រុម Telegram) ក្នុងរយៈពេលពេញមួយឆ្នាំ។ | ✓ | | | |

| | | | | | |
|---|---|---|---|---|---|
| | ក្រុមអនុវត្តសកម្មភាពស្ទែមរៀបចំក្រុមបច្ចេកទេសស្ទែមផ្លូវការ (TG) ឬសហគមន៍សិក្សាវិជ្ជាជីវៈ (PLC) ដោយចាប់ផ្ដើមក្នុងមួយមុខវិជ្ជាស្ទែម។ សូមរៀបចំពេលវេលា និងទីកន្លែងសម្រាប់ក្រុមដែលត្រូវជួប។ សូមតែងតាំងប្រធានតាមមុខវិជ្ជានីមួយៗ ដែលនឹងដឹកនាំក្រុមក្នុងការកំណត់គម្លាតនៃចំណេះដឹងឬបំណិន បញ្ហាប្រឈមក្នុងថ្នាក់រៀន និងពិនិត្យមើលសម្ភារ គាំទ្រ (ឧ. ផែនការកម្មវិធីសិក្សា/កិច្ចតែងការបង្រៀន ដែលបានពង្រឹងស្ទែម សូមមើល សមាសភាគទី៤)។ ប្រធាននៃក្រុមបច្ចេកទេសស្ទែមផ្លូវការ (TG) ឬ ប្រធាននៃសហគមន៍សិក្សាវិជ្ជាជីវៈ (PLC) នឹងសម្របសម្រួលការកំណត់គោលដៅក្នុងរយៈពេលខ្លីជួយដោះស្រាយបញ្ហាប្រឈមភ្លាមៗ ណែនាំការបង្វឹកនៅកន្លែង និងជំរុញការរៀនសូត្ររួមគ្នា។ | ✓ | ✓ | | |
| | ចំនួននៃការជួបជុំ កិច្ចប្រជុំនៃក្រុមអនុវត្តសកម្មភាពស្ទែម ឬ សហគមន៍សិក្សាវិជ្ជាជីវៈក្រៅផ្លូវការ។ | ម្តងក្នុងមួយត្រីមាស | ប្រចាំខែ | យ៉ាងហោចណាស់រៀងរាល់ពីរសប្តាហ៍ | យ៉ាងហោចណាស់រៀងរាល់ពីរសប្តាហ៍ |
| | ក្រុមអន្តរមុខវិជ្ជា៖ សូមចាប់ផ្ដើមដោយបង្កើតក្រុមអន្តរមុខវិជ្ជា ដោយមានសមាជិកជាគ្រូបង្រៀនមុខវិជ្ជាស្ទែម ២ ផ្សេងគ្នា ដែលធ្វើការសហការគ្នាដើម្បីបង្កើត និងអនុវត្តសកម្មភាពអន្តរកម្មមុខវិជ្ជានៅក្នុងថ្នាក់រៀនរបស់ពួកគេ (ឧ. ការដោះស្រាយបញ្ហាដែលតម្រូវឱ្យអនុវត្តចំណេះដឹងពីមុខវិជ្ជាស្ទែមទាំងពីរ)។ សូមពិចារណាអំពីការបង្កើតក្រុម៖ គីមីវិទ្យា និង រូបវិទ្យា; ជីវវិទ្យា និងផែនដីវិទ្យា; គណិតវិទ្យា និង ICT (ឬតាមស្ថានភាពសាលារៀនរបស់លោក លោកស្រី) | | | ✓ | |
| | ក្រុមអន្តរមុខវិជ្ជា៖ ឈានទៅដល់ក្រុមអន្តរមុខវិជ្ជា ដោយមានសមាជិកជាគ្រូបង្រៀនមុខវិជ្ជាស្ទែម ជាច្រើន ដែលធ្វើការសហការគ្នាដើម្បីបង្កើតសកម្មភាពអន្តរមុខវិជ្ជា (ឧ. គម្រោង, ការដោះស្រាយបញ្ហា) ការកែលម្អសកម្មភាពអន្តរមុខវិជ្ជា ឬការបង្រៀន។<br><br>ក្រុមអន្តរកម្មមុខវិជ្ជាទាំងនេះចែករំលែកការអនុវត្តល្អៗ បទពិសោធន៍ និងធនធានជាមួយគ្រូបង្រៀន និងសាលារៀនផ្សេងទៀតតាមរយៈសហគមន៍សិក្សាវិជ្ជាជីវៈអន្តរសាលា ដើម្បីពង្រឹងការបង្រៀនអន្តរមុខវិជ្ជានៅក្នុងសាលារៀនផ្សេងទៀត។ | | | | ✓ |

| | | | | | |
|---|---|---|---|---|---|
| | ក្រុមអន្តរមុខវិជ្ជា៖ ពិចារណាជាកបញ្ចូលគ្រូបង្រៀនវិទ្យាសាស្ត្រសង្គម (មិនមែនស្ទែម) ដើម្បីរៀបចំសកម្មភាពទាក់ទងនឹងមុខវិជ្ជា ប្រវត្តិវិទ្យា ភូមិវិទ្យា ឬសិល្បៈ ដើម្បីពង្រឹងការតភ្ជាប់ទៅកាន់ជីវិតរស់នៅជាក់ស្តែង។ សូមឱ្យគ្រូបង្រៀនវិទ្យាសាស្ត្រសង្គមឱ្យផ្តល់គំនិតសម្រាប់ប្រធានបទ ដែលកើតចេញពីទស្សនទានស្ទែម។ | | | | ✓ |
| | សហគមន៍សិក្សាវិជ្ជាជីវៈអន្តរសាលា៖ សាលារៀនរៀបចំ និងគាំទ្រសហគមន៍សិក្សាវិជ្ជាជីវៈអន្តរសាលា ដើម្បីពង្រឹងការបង្រៀននៅក្នុងសាលារៀនផ្សេងទៀតនៅក្នុងសហគមន៍។ | | | | ✓ |
| សហគមន៍សិក្សាវិជ្ជាជីវៈសម្រាប់គណៈគ្រប់គ្រងសាលារៀន | គណៈគ្រប់គ្រងសាលារៀនតំណាងឱ្យក្រុមបង្គោលនៃក្រុមអនុវត្តសកម្មភាពស្ទែមរៀបចំសហគមន៍សិក្សាវិជ្ជាជីវៈសម្រាប់គណៈគ្រប់គ្រងសាលាទាំងអស់នៅក្នុងសាលារៀន។ សូមកំណត់ពេលវេលា និងទីតាំងសមស្រប។ សកម្មភាពដែលបានស្នើរួមមានការដោះស្រាយបញ្ហារួមគ្នាចំពោះបញ្ហាដែលគ្រូបង្រៀនស្ទែមជួបប្រទ ការអភិវឌ្ឍន៍កម្មវិធីសិក្សា/ការវាយតម្លៃ ការពិភាក្សាលើទំនាក់ទំនងសហគមន៍ និងការចូលរួម សកម្មភាពឆ្លុះបញ្ចាំង/មតិកែលម្អ។<br><br>ចំនួននៃកិច្ចប្រជុំរបស់សហគមន៍សិក្សាវិជ្ជាជីវៈសម្រាប់គណៈគ្រប់គ្រងសាលារៀន។ | ម្តងក្នុងមួយត្រីមាស | ប្រចាំខែ | យ៉ាងហោចណាស់រៀងរាល់ពីរសប្តាហ៍ | (យ៉ាងហោចណាស់រៀងរាល់ពីរសប្តាហ៍) |
| | សហគមន៍សិក្សាវិជ្ជាជីវៈអន្តរសាលាសម្រាប់គណៈគ្រប់គ្រងសាលារៀន៖ គណៈគ្រប់គ្រងសាលាដើម្បីដឹកនាំការបង្កើត និងការរៀបចំសហគមន៍សិក្សាវិជ្ជាជីវៈអន្តរសាលាសម្រាប់គណៈគ្រប់គ្រងសាលារៀននៅក្នុងតំបន់។<br><br>ចំនួននៃកិច្ចប្រជុំរបស់សហគមន៍សិក្សាវិជ្ជាជីវៈអន្តរសាលាសម្រាប់គណៈគ្រប់គ្រងសាលារៀន។ | | | | ប្រចាំខែ |

| | | | | | |
|---|---|---|---|---|---|
| ការបង្វឹក | គណៈគ្រប់គ្រងសាលារៀនដោយមានការគាំទ្រពីក្រុមអនុវត្តសកម្មភាពស្វែមរៀបចំកម្មវិធីបង្វឹកសម្រាប់គ្រូបង្រៀនស្វែម។<br>- កំណត់គ្រូបង្វឹកសមស្រប (គ្រូដែលមានបទពិសោធន៍) នៅក្នុងសាលារៀន<br>- ផ្គូផ្គងគ្រូបង្វឹកជាមួយគ្រូបង្រៀនតាមជំនាញស្វែម<br>- សកម្មភាពសម្រាប់គ្រូបង្វឹក/គ្រូបង្រៀន៖ ការសង្កេតការបង្រៀន វគ្គផ្តល់យោបល់ ការចែករំលែកជំនាញបច្ចេកទេស ការពិនិត្យមើលជាប្រចាំ ការឆ្លុះបញ្ចាំង ការចែករំលែកធនធាន ការបង្រៀនរួមគ្នា<br><br>ចំនួនដងនៃការអនុវត្ត និងចំនួនគ្រូបង្រៀនស្វែមដែលចូលរួម៖ | ក្រៅផ្លូវការ ប្រចាំខែយ៉ាងហោចណាស់ ៥០% នៃគ្រូបង្រៀនស្វែម | ជាផ្លូវការ រៀងរាល់ពីរខែសម្រាប់យ៉ាងហោចណាស់ ៥០% នៃគ្រូបង្រៀនស្វែម | ជាផ្លូវការ រៀងរាល់ពីរខែសម្រាប់គ្រូបង្រៀនស្វែមទាំងអស់។ | |
| | ជំរុញការបង្វឹកដល់សាលាផ្សេងទៀតតាមរយៈសហគមន៍សិក្សាវិជ្ជាជីវៈអន្តរសាលា ការចែករំលែកបទពិសោធន៍ ប្រព័ន្ធដែលបានបង្កើតឡើង និងបទពិសោធន៍ល្អៗ។ | | | | ✓ |
| ការប្រឹក្សា | គណៈគ្រប់គ្រងសាលាជួយសម្រួលឱ្យមានកម្មវិធីប្រឹក្សាជាផ្លូវការ (គ្រូប្រឹក្សាដែលទទួលបានការបណ្តុះបណ្តាលនៅមជ្ឈមណ្ឌលស្រាវជ្រាវគរុកោសល្យជំនាន់ថ្មី) ប្រសិនបើមាននៅក្នុងសាលារបស់អ្នក។ | ✓ | ✓ | ✓ | ✓ |
| ប្រភពធនធាន | ប្រសិនបើមាន៖ ធនធាន ឬគោលការណ៍ណែនាំអំពីរបៀបរៀបចំ/គ្រប់គ្រងសហគមន៍សិក្សាវិជ្ជាជីវៈ របៀបវារៈកិច្ចប្រជុំ កិច្ចការ និងវិធីសាស្ត្រទំនាក់ទំនង។ល។ | | | | |

| | ៣.៤ ការគ្រប់គ្រងធនធាន | | | | |
|---|---|---|---|---|---|
| ៣.៤ | សកម្មភាពគួរអនុវត្ត | កម្រិតសាលារៀនទី ១ ដល់ ២ | កម្រិតសាលារៀនទី ២ ដល់ ៣ | កម្រិតសាលារៀនទី ៣ ដល់ ៤ | កម្រិតសាលារៀនទី៤ ដល់ ៥ |
| ភាពជាដៃគូជាមួយអ្នកខាងក្រៅ | បង្កើតភាពជាដៃគូខាងក្រៅ/កិច្ចព្រមព្រៀងឧបត្ថម្ភ៖<br>ក.ក្រុមអនុវត្តសកម្មភាពស្ទែមកំណត់អត្តសញ្ញាណឧបករណ៍ ឬសម្ភារស្ទែមដ៏មានសក្តានុពលដែលសមរម្យសម្រាប់ការឧបត្ថម្ភឬការផ្តល់មូលនិធិពីខាងក្រៅ ឧ. ម៉ាស៊ីនបញ្ចាំងរូបភាព ឧបករណ៍បំពងសម្លេង ឧបករណ៍សុវត្ថិភាព<br>ខ. ក្រុមអនុវត្តសកម្មភាពស្ទែមកំណត់ដៃគូខាងក្រៅដែលមានសក្តានុពល ជាឧទាហរណ៍ៗ អាជីវករក្នុងស្រុក អាជីវករថ្នាក់ជាតិ និងប្រមូលព័ត៌មានលម្អិតទំនាក់ទំនង<br>គ. ក្រុមអនុវត្តសកម្មភាពស្ទែមបង្កើតផែនការទំនាក់ទំនង៖<br>-សម្រេចចិត្តថាតើវិធីទំនាក់ទំនងមួយណា៖ អ៊ីមែល ទល់មុខ លិខិតផ្លូវការ ?<br>-រៀបចំលិខិតស្នើសុំ<br>-វិធីសាស្ត្រស្នើសុំ<br>ឃ. រៀបចំភាពជាដៃគូក្រៅផ្លូវការសម្រាប់ឆ្នាំសិក្សាខាងមុខ។<br>ចំនួនគោលដៅនៃភាពជាដៃគូ និងការផ្តល់មូលនិធិជាបន្តបន្ទាប់ពីប្រភពខាងក្រៅគឺ៖ | ភាពជាដៃគូខាងក្រៅ យ៉ាងហោចណាស់ 1 ត្រូវបានបង្កើតឡើង | យ៉ាងហោចណាស់ ភាពជាដៃគូខាងក្រៅ ចំនួន 2 ត្រូវបានបង្កើតឡើង និង/ឬមូលនិធិគឺ គ្រប់គ្រាន់សម្រាប់ តម្រូវការ មូលដ្ឋានភ្លាមៗ | យ៉ាងហោចណាស់ ភាពជាដៃគូខាងក្រៅ ចំនួន 3 ត្រូវបាន បង្កើតឡើង និង/ឬ មូលនិធិគឺ គ្រប់គ្រាន់ សម្រាប់តម្រូវការ មូលដ្ឋាន និង សកម្មភាព ពង្រឹង STEM | (បន្តភាពជាដៃគូ ដែលមាន ស្រាប់) |
| | បង្កើតភាពជាដៃគូខាងក្រៅជាផ្លូវការសម្រាប់ផែនការរយៈពេលវែង | | | | ✓ |
| ការវិភាជថវិកា | ក្រុមអនុវត្តសកម្មភាពស្ទែមទាក់ទងសាលារៀននៅក្នុងតំបន់ដើម្បីបង្កើតការវិភាជថវិកា ប្រសិនបើមានសក្តានុពលសម្រាប់ការទិញ ឬចែករំលែកការចំណាយច្រើនបាន។ | ✓ | ✓ | ✓ | |
| | សូមដឹកនាំក្នុងការបង្កើតភាពជាដៃគូសហការជាមួយសាលារៀនផ្សេងទៀត ដោយផ្តួចផ្តើមគំនិតក្នុងការចែករំលែកចំណាយ។ | | | | ✓ |

| ៣.៥ | ៣.៥ ការគ្រប់គ្រងទិន្នន័យ | | | | |
|---|---|---|---|---|---|
| | សកម្មភាពគួរអនុវត្ត | កម្រិតសាលារៀនទី ១ ដល់ ២ | កម្រិតសាលារៀនទី ២ ដល់ ៣ | កម្រិតសាលារៀនទី ៣ ដល់ ៤ | កម្រិតសាលារៀនទី ៤ ដល់ ៥ |
| បំណិនឌីជីថល | គណៈគ្រប់គ្រងសាលារៀនកែលម្អជំនាញឌីជីថលសម្រាប់ការគ្រប់គ្រងទិន្នន័យ យោងតាមសកម្មភាពដែលបានស្នើឡើងលើជំនាញឌីជីថលខាងលើ។ | ✓ | ✓ | ✓ | |
| ការទុកដាក់ទិន្នន័យ និងទិន្នន័យតាមក្រុម | គណៈគ្រប់គ្រងសាលារៀនពិនិត្យមើលវិធីសាស្ត្រប្រមូលទិន្នន័យនាពេលបច្ចុប្បន្ន និងកំណត់ផ្នែកសម្រាប់ការកែលម្អជាពិសេសទាក់ទងនឹង៖<br>ក. ការកត់ត្រាបែបឌីជីថល (ផ្ទុយពីក្រដាស)<br>ខ. ការប្រមូលទិន្នន័យជាក្រុមទាក់ទងនឹងភេទ និងបរិយាបន្ន។<br><br>គោលដៅគឺ៖ | យ៉ាងហោចណាស់ ៥០% នៃទិន្នន័យទាំងអស់ ដែលប្រមូលបាន ត្រូវបានរក្សាទុកក្នុងឯកសារឌីជីថល | យ៉ាងហោចណាស់ ៧៥% នៃទិន្នន័យទាំងអស់ ដែលប្រមូលបាន ត្រូវបានរក្សាទុកក្នុងឯកសារឌីជីថល | ទិន្នន័យទាំងអស់ត្រូវបានកត់ត្រាជាឌីជីថល ហើយសាលារៀនបានធ្វើឱ្យប្រសើរឡើងនូវការប្រមូលទិន្នន័យជាក្រុម | ទិន្នន័យទាំងអស់ត្រូវបានកត់ត្រាជាឌីជីថល ហើយសាលារៀនកត់ត្រាទិន្នន័យជាក្រុមគ្រប់ពេលវេលា។ |

## ជំហានទី៤ ៖ ផែនការសកម្មភាពសម្រាប់ក្របខណ្ឌអប់រំស្ទែមកម្រិតសាលារៀន

## សមាសភាគទី៤ ៖ ការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធ

| | |
|---|---|
| **សមាសភាគទី១** | ហេដ្ឋារចនាសម្ព័ន្ធ |
| **អ្នកទទួលខុសត្រូវ** | សមាជិកបង្គោលនៃក្រុមអនុវត្តសកម្មភាពស្ទែមដែលត្រូវបានចាត់តាំងឱ្យទទួលខុសត្រូវសមាសភាគនេះ ដោយមានការគាំទ្រពីសមាជិកបង្គោល ឬសមាជិកគាំទ្រផ្សេងទៀត។<br>ចំណាំ៖ ប្រធានក្រុមអនុវត្តសកម្មភាពស្ទែមប្រហែលជាអាចត្រូវចាត់តាំងអ្នកទទួលខុសត្រូវចំពោះសមាសភាគនេះជាថ្មី នៅជំហានទី៣ ដើម្បីធានានូវទំហំការងារសមស្រប និងមានប្រសិទ្ធភាព។ |
| **សមាជិកក្រុមអនុវត្តសកម្មភាពស្ទែមសម្រាប់ទទួលខុសត្រូវសមាសភាគនេះ** | |
| **ឆ្នាំទី** | (ឧ. ឆ្នាំទី១៖ ឆ្នាំសិក្សា២០២៤-២០២៥) |
| **ដំណើរការ** | <br><br>ក្របខណ្ឌអប់រំស្ទែមកម្រិតសាលារៀនមាន ៥ជំហានដើម្បីគាំទ្រសាលារៀនក្នុងការបង្រៀន និងរៀនមុខវិជ្ជាស្ទែម។ ដើម្បីឱ្យជំហានទី៤នេះទទួលបានជោគជ័យត្រូវអនុវត្តជំហានទី១ ២ និង ៣ ប្រកបដោយប្រសិទ្ធិភាព។<br><br>ផែនការសកម្មភាពស្ទែម នៃក្របខណ្ឌអប់រំស្ទែមកម្រិតសាលារៀននេះរៀបរាប់អំពីសកម្មភាពដែលអាចអនុវត្តបានដើម្បីពង្រឹងសមាសភាគទី១៖ ការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធ ដែលមានសមាសភាគរងខ៖ |

| | |
|---|---|
| | ៤.១ សម្ភាររូបវន្ត<br>៤.២ លទ្ធភាពប្រើប្រាស់<br>៤.៣ បរិក្ខារ<br>៤.៤ ការភ្ជាប់សេវាសាធារណៈ |
| **គោលបំណងរបស់ឧបករណ៍** | ផែនការសកម្មភាពក្របខណ្ឌអប់រំស្នែមកម្រិតសាលារៀនបង្ហាញពីជំហានជាក់ស្តែង សម្រាប់ការលើកកម្ពស់ការអប់រំស្នែមនៅសាលារៀន ដោយយោងតាមសមាសភាគនីមួយៗនៃសមាសភាគទាំង៥។ សកម្មភាពទាំងនេះត្រូវបានចាត់ថ្នាក់ដោយផ្អែកលើកម្រិតអភិវឌ្ឍន៍ ដូចនេះយើងអនុវត្តតាមកម្រិតអភិវឌ្ឍន៍ដូចដែលបានកំណត់នៅក្នុងឧបករណ៍ស្វ័យវាយតម្លៃ (ជំហានទី៣)។ គោលវិធីនេះធានាថាសកម្មភាពដែលបានស្នើឡើងស្របតាមធនធាន និងសមត្ថភាពរបស់សាលារៀន។ខណៈយើងជួបនឹងការប្រឈមដូចជាសម្ភារបរិក្ខារ ឬថវិកានៅមានកម្រិត សូមអនុវត្តសកម្មភាពណាដែលអាចធ្វើទៅបាន។ តារាងខាងក្រោមខាងនេះដាក់បញ្ចូលគោលដៅដែលអាចសម្រេចបានហើយត្រូវជាមួយនឹងកម្រិតអភិវឌ្ឍន៍សាលារៀន ហើយគោលដៅនេះក៏ជារង្វាស់វឌ្ឍនភាពសាលារៀនលោក លោកស្រីផងដែរ។ |
| **ការណែនាំ** | 6. ពិនិត្យមើលទៅជំហានទី៣៖ ឧបករណ៍ពិនិត្យឡើងវិញ និងកំណត់គោលដៅ ដើម្បីកំណត់ផែនការសកម្មភាពស្នែមសាលារៀនត្រូវអនុវត្តតាម<br>7. ពិចារណាលើសកម្មភាពបានលើកឡើងនៅក្នុងផែនការសកម្មភាពស្នែម ដែលបានសង្ខេបក្នុងតារាងខាងក្រោមអំពីកម្រិតសាលារៀននៅក្នុងសមាសភាគនេះ<br>8. ជ្រើសរើសសកម្មភាពអាចអនុវត្តបាន ដូចដែលបានរៀបរាប់នៅក្នុងតារាង ប្រសិនបើសកម្មភាពមានចំនួនច្រើន ចូរជ្រើសរើសតែសកម្មភាពណាលោក លោកស្រីអាចធ្វើទៅបានក្នុងឆ្នាំនេះ<br>9. ពិនិត្យប្រភពឯកសារ ឬតំណភ្ជាប់សំខាន់ៗដែលអាចជួយឱ្យលោក លោកស្រីរៀបចំផែនការ និងអនុវត្តសកម្មភាព<br>10. ពិនិត្យមើលនៅក្នុងសទ្ទានុក្រមសម្រាប់ពាក្យពិបាកយល់។ |

# ការរម្លឹកពីគោលដៅបានកំណត់

សូមមើលជំហានទី៣ និងកំណត់ចំណាំគោលដៅរបស់លោក លោកស្រីនៅទីនេះដើម្បីមានភាពងាយស្រួល។

**តារាងទី 10៖ ការកំណត់គោលដៅ និងការកំណត់ផែនការសកម្មភាពស្ទែម**

<table>
<tr><th colspan="2" rowspan="2">គោលដៅសម្រាប់ឆ្នាំបន្ទាប់៖<br>( ✓ ជ្រើសរើសយកជម្រើសមួយ )</th><th rowspan="2">✓សមាសភាគស្ទែម ដែលត្រូវពង្រឹង</th><th rowspan="2">តម្លៃ<br>DDL</th><th colspan="4">សញ្ញា ✓ ចង្អុលបង្ហាញពីផែនការសកម្មភាពដែលអនុវត្ត</th></tr>
<tr><th>កម្រិតសាលារៀន<br>ទី១ ទៅ ២</th><th>កម្រិតសាលារៀន<br>ទី២ ទៅ ៣</th><th>កម្រិតសាលារៀន<br>ទី៣ ទៅ ៤</th><th>កម្រិតសាលារៀន<br>ទី៤ ទៅ ៥</th></tr>
<tr><td rowspan="5">☐</td><td rowspan="5">ជម្រើសទី១៖ សម្រេចឱ្យបានលទ្ធផលប្រហាក់ប្រហែលគ្នាសមាសភាគទាំង៥ ដោយពង្រឹងសមាសភាគ ខ្សោយ។</td><td>☐ លទ្ធផលការសិក្សារបស់សិស្ស</td><td></td><td></td><td></td><td></td><td></td></tr>
<tr><td>☐ ការបង្រៀន និងរៀន</td><td></td><td></td><td></td><td></td><td></td></tr>
<tr><td>☐ អភិបាលកិច្ចសាលារៀន</td><td></td><td></td><td></td><td></td><td></td></tr>
<tr><td>☐ ការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធ</td><td></td><td></td><td></td><td></td><td></td></tr>
<tr><td>☐ ការចូលរួមរបស់សហគមន៍</td><td></td><td></td><td></td><td></td><td></td></tr>
<tr><td colspan="8">ឬ</td></tr>
<tr><th colspan="2" rowspan="2">គោលដៅសម្រាប់ឆ្នាំបន្ទាប់៖</th><th rowspan="2">✓សមាសភាគស្ទែម ដែលត្រូវពង្រឹង</th><th rowspan="2">តម្លៃ<br>DDL</th><th colspan="4">សញ្ញា ✓ ចង្អុលបង្ហាញពីផែនការសកម្មភាពដែលអនុវត្ត</th></tr>
<tr><th>កម្រិតសាលារៀន<br>ទី១ ទៅ ២</th><th>កម្រិតសាលារៀន<br>ទី២ ទៅ ៣</th><th>កម្រិតសាលារៀន<br>ទី៣ ទៅ ៤</th><th>កម្រិតសាលារៀន<br>ទី៤ ទៅ ៥</th></tr>
<tr><td rowspan="5">☐</td><td rowspan="5">ជម្រើសទី២៖ សម្រេចឱ្យបានកម្រិតអភិវឌ្ឍបន្ទាប់ នៃកសមាសភាគចំនួន៣</td><td>☐ លទ្ធផលការសិក្សារបស់សិស្ស</td><td></td><td></td><td></td><td></td><td></td></tr>
<tr><td>☐ ការបង្រៀន និងរៀន</td><td></td><td></td><td></td><td></td><td></td></tr>
<tr><td>☐ អភិបាលកិច្ចសាលារៀន</td><td></td><td></td><td></td><td></td><td></td></tr>
<tr><td>☐ ការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធ</td><td></td><td></td><td></td><td></td><td></td></tr>
<tr><td>☐ ការចូលរួមរបស់សហគមន៍</td><td></td><td></td><td></td><td></td><td></td></tr>
</table>

## សេចក្តីរៀបរាប់៖ កម្រិតអភិវឌ្ឍន៍តាមសមាសភាគ (DDL) បច្ចុប្បន្ន និងគោលដៅសម្រាប់សមាសភាគនេះ៖

កម្រិតអភិវឌ្ឍន៍សាលារៀនយើង នៅត្រង់សមាសភាគនេះ គឺកម្រិតសាលារៀនទី ____ ។ គោលដៅសាលារៀនគឺឆ្ពោះទៅរកកម្រិតសាលារៀនទី__________ ដូចនេះយើងនឹងអនុវត្តតាមសកម្មភាពដែលបានស្នើឡើងដើម្បីអភិវឌ្ឍពីកម្រិត_______ទៅ កម្រិត_____នៅក្នុងតារាងខាងក្រោម ហើយសម្រេចគោលដៅតាមដែលយើងបានកំណត់។

*(ឧទាហរណ៍៖ កម្រិតអភិវឌ្ឍន៍សាលារៀនយើង នៅត្រង់សមាសភាគនេះ គឺកម្រិត __2__ ។ គោលដៅសាលារៀនដើម្បីឆ្ពោះទៅរកកម្រិត_____3_____ ដូចនេះយើងនឹងអនុវត្តតាមសកម្មភាពដែលបានស្នើឡើងដើម្បីអភិវឌ្ឍពីកម្រិត____2_____ទៅ កម្រិត_____3______នៅក្នុងតារាងខាងក្រោម ហើយសម្រេចគោលដៅតាមដែលយើងបានកំណត់។)*

## កូដពណ៌៖

| | ✓ | |
|---|---|---|
| សកម្មភាពមិនទាន់បានអនុវត្ត៖ សាលារៀននៅកម្រិតនេះមិនទាន់ត្រៀមសម្រាប់សកម្មភាពនេះ | សញ្ញា ✓ បង្ហាញថាសកម្មភាពនេះអាចអនុវត្តបានក្នុងសាលារៀនក្នុងកម្រិតនេះ | សាលារៀននៅក្នុងកម្រិតនេះគឺអាចសម្រេចបានសកម្មភាពដែលបានលើកឡើង |

| ៤.១ | ៤.១ សម្ភាររូបវន្ត | | | | |
|---|---|---|---|---|---|
| | សកម្មភាពគួរអនុវត្ត | កម្រិតសាលារៀន ទី១ ដល់ ២ | កម្រិតសាលារៀន ទី២ ដល់ ៣ | កម្រិតសាលារៀន ទី៣ ដល់ ៤ | កម្រិតសាលារៀន ទី៤ ដល់ ៥ |
| សម្ភាររូបវន្តស្ទែម | លទ្ធភាពទទួលបានទឹក៖ ក្រុមអនុវត្តសកម្មភាពស្ទែមពិនិត្យមើលផែនការថ្នាក់រៀនរបស់សាលារៀនជាមួយគណៈគ្រប់គ្រងសាលារៀន (ឧ. (មុខវិជ្ជាណាត្រូវបានបង្រៀននៅក្នុងបន្ទប់ណា)។ សូមពិចារណាលើការបង្រៀនស្ទែមនៅក្នុងថ្នាក់រៀនដែលមានទឹកនៅជិត។ (អាចជា បណ្តាញទឹកស្អាត) ប្រសិនបើមានថ្នាក់រៀនសមរម្យ សូមពិចារណាការផ្លាស់ប្តូរក្នុងផែនការថ្នាក់រៀនរបស់សាលារៀន។ | ✓ | | | |
| | ប្លង់បន្ទប់រៀន៖ ក្រុមអនុវត្តសកម្មភាពស្ទែមពិនិត្យមើលប្លង់គ្រឿងសង្ហារឹមក្នុងបន្ទប់រៀនដែលការបង្រៀនស្ទែមកើតឡើង។ នៅពេលណាដែលអាចធ្វើទៅបាន សូមរៀបចំប្លង់ឡើងវិញដើម្បីសម្រួលដល់កិច្ចការក្រុម។ (សូមមើលប្រភពធនធានខាងក្រោម) | ✓ | ✓ | | |
| | ពិនិត្យមើលគ្រឿងសង្ហារឹមក្នុងបន្ទប់រៀន៖ តើមានតុ ឬតុរាបស្មើដែរឬទេ? បើមិនដូច្នេះទេ ក្រុមអនុវត្តសកម្មភាពស្ទែមពិនិត្យមើលគ្រឿងសង្ហារឹមដែលមាននៅក្នុងសាលារៀន ហើយពិចារណាផ្លាស់ប្តូរតុ ឬតុរាបស្មើទៅក្នុងថ្នាក់រៀនស្ទែម។ | ✓ | | | |
| | ក្រុមអនុវត្តសកម្មភាពស្ទែមពិនិត្យមើលបរិវេណសាលារៀន និងកំណត់កន្លែងសក្តានុពលដែលសមរម្យសម្រាប់កិច្ចការគម្រោងស្ទែម ឧទាហរណ៍ បន្ទប់រៀន ឬបន្ទប់ការិយាល័យដែលមិនប្រើ។ សូមស្នើសុំការអនុញ្ញាតពីគណៈគ្រប់គ្រងសាលារៀនដើម្បីកំណត់កន្លែងនេះសម្រាប់ការប្រើប្រាស់កិច្ចការគម្រោង។ | ✓ | ✓ | | |
| | កំណត់តំបន់ស្តុកទុកសម្រាប់ប្រមូលសម្ភារគម្រោងស្ទែម ដែលផ្តល់ដោយសហគមន៍ ឬគ្រួសារ (ឧទាហរណ៍ ប្រអប់ក្រដាសកាតុងធ្វើកេស ដបប្រើប្រាស់ សម្ភារវេចខ្ចប់ និងខ្សែភ្លើង។ល។) | ✓ | ✓ | ✓ | |
| សុវត្ថិភាព | ក្រុមអនុវត្តសកម្មភាពស្ទែមកំណត់ទីតាំងនៅក្នុងបន្ទប់បង្រៀនស្ទែមដើម្បីរក្សាទុកឧបករណ៍សុវត្ថិភាព។ វាគួរតែអាចចូលដំណើរការបានយ៉ាងងាយស្រួល និងមានស្លាកសញ្ញា | ✓ | | | |

| | | | | | |
|---|---|---|---|---|---|
| | ច្បាស់លាស់ ក្រុមអនុវត្តសកម្មភាពស្ទែម ដើម្បីរៀបចំការផ្តល់ឧបករណ៍សុវត្ថិភាពអប្បបរមា ឧទាហរណ៍៖<br>ក. ទឹកស្អាត (ដបទឹកផឹកបិទជិត) សម្រាប់ប្រើជាទឹកលាងភ្នែកសង្គ្រោះបន្ទាន់។ ទាំងនេះគួរតែត្រូវបានដាក់ស្លាកយ៉ាងច្បាស់សម្រាប់តែការប្រើប្រាស់សុវត្ថិភាពប៉ុណ្ណោះ។<br>ខ. ធុងខ្សាច់សម្រាប់ភ្លើង<br>គ. ឧបករណ៍សង្គ្រោះបឋម<br>ឃ. ផ្លាកសញ្ញាសុវត្ថិភាពពហុភាសា ប្រកាន់អក្សរតូចធំ យេនឌ័រ<br>(សូមមើលប្រភពធនធានខាងក្រោម) | | | | |
| | ក្រុមអនុវត្តសកម្មភាពស្ទែមកំណត់ទីតាំងនៅក្នុងបន្ទប់បង្រៀនស្ទែមដើម្បីរក្សាទុកឧបករណ៍សុវត្ថិភាព។ វាគួរតែអាចចូលដំណើរការបានយ៉ាងងាយស្រួល និងមានស្លាកសញ្ញាច្បាស់លាស់ ក្រុមអនុវត្តសកម្មភាពស្ទែម ដើម្បីរៀបចំការផ្តល់ឧបករណ៍សុវត្ថិភាពជាមូលដ្ឋានតាមដែលអាចធ្វើទៅបាន៖<br>ក. ភួយពន្លត់អគ្គិភ័យ<br>ខ. កន្លែងលាងភ្នែក និងផ្កាឈូក<br>គ. ឧបករណ៍សង្គ្រោះបឋម<br>ឃ. ផ្លាកសញ្ញាសុវត្ថិភាពពហុភាសា ផ្លាកសញ្ញាបង្ហាញបម្រុងប្រយ័ត្នយេនឌ័រ<br>ង. ការផ្ទុកដោយសុវត្ថិភាពសម្រាប់សារធាតុគីមី<br><br>ប្រសិនបើត្រូវការថវិកា សូមចំណាំចំណុចនេះថាបានពីការអែង្គាសថវិកា សូមមើលសមាសភាគទី២ ការគ្រប់គ្រងធនធាន។ | ទោះបីជាត្រូវការនៅកម្រិតនេះក៏ដោយ សូមពិចារណាសកម្មភាពនេះប្រសិនបើអាចធ្វើទៅបាន។ | ✓ | ✓ | ✓ |
| | សុវត្ថិភាព៖ អនុវត្តនីតិវិធីសុវត្ថិភាពដែលរៀបចំដោយគម្រោង STEP UP នៅពេលបោះពុម្ពផ្សាយ។ | ✓ | ✓ | ✓ | ✓ |
| | ហួតដល់ធនធានរបស់គម្រោង STEP UP ត្រូវបានបញ្ចប់រួចរាល់ សូមគាំទ្រសាលារៀនផ្សេងទៀតដោយការចែករំលែកនីតិវិធីសុវត្ថិភាព ឬផ្លាកសញ្ញាដែលកំពុងប្រើប្រាស់នៅក្នុងសាលារៀនរបស់លោក លោកស្រី។ | | | ✓ | ✓ |

| | | | | | |
|---|---|---|---|---|---|
| សម្ភារប្រើប្រាស់បច្ចេកវិទ្យា | ការចូលប្រើបច្ចេកវិទ្យារបស់គ្រូបង្រៀន៖ ពិចារណាផ្តល់ឧបករណ៍បញ្ចាំងរូបភាព (Projector) និងឧបករណ៍បំពងសម្លេងប្រើប្ល៊ូធូស ដូចនេះគ្រូបង្រៀនមានជម្រើសក្នុងការប្រើប្រាស់ធនធានឌីជីថលក្នុងការបង្រៀន។<br><br>ចំណាំថាសម្ភារទាំងនេះបានពីការអែង្គាសថវិកា សូមមើលសមាសភាគទី២ ការគ្រប់គ្រងធនធាន។ | ✓ | | | |
| បណ្ណាល័យ | សម្រាប់សាលារៀនដែលមានបណ្ណាល័យ៖<br>បញ្ជីសៀវភៅនៅក្នុងបណ្ណាល័យ៖ បង្កើតបញ្ជីឈ្មោះសៀវភៅឌីជីថលដែលអាចស្វែងរកបាន ឬបញ្ជីឈ្មោះធនធានទាំងអស់នៅក្នុងបណ្ណាល័យ ដែលយោងទៅតាមអ្នកនិពន្ធ / ចំណងជើង / ប្រធានបទ។ល។<br>ការចូលប្រើកុំព្យូទ័រ៖ ប្រសិនបើអាចធ្វើបាន សូមផ្តល់កុំព្យូទ័រយ៉ាងហោចណាស់ ១ គ្រឿងសម្រាប់បណ្ណាល័យ ក្នុងការចូលប្រើបញ្ជីឈ្មោះសៀវភៅឌីជីថល។ | ✓ | | | |
| | សម្រាប់សាលារៀនដែលគ្មានបណ្ណាល័យ ឬសាលារៀនដែលមានសម្ភារស្ទែមនៅមានកម្រិតនៅក្នុងបណ្ណាល័យ៖<br>សូមពិចារណាលើបណ្ណាល័យអេឡិចត្រូនិកដែលមានតម្លៃទាប (Hard Drive ខាងក្រៅ) ជាមួយនឹងការប្រមូលធនធានឌីជីថល ដើម្បីអាចប្រើប្រាស់ក្នុងការបង្រៀន។ វាអាចទៅរួច ទោះបីជាមិនមានបណ្ណាល័យផ្លូវការនៅលើគេហទំព័រក៏ដោយ។ សូមប្រមូល ឬទាញយកធនធានពីគេហទំព័រ MoEYS/NGS YouTube channel។ សូមស្វែងរកបទពិសោធន៍តាមរយៈសហគមន៍សិក្សាវិជ្ជាជីវៈអន្តរសាលារៀន។<br>ចំណាំថា Hard Drive ខាងក្រៅបានពីការអែង្គាសថវិកា សូមមើលសមាសភាគទី២ ការគ្រប់គ្រងធនធាន។ | ✓ | ✓ | | |
| | ប្លង់បណ្ណាល័យលើកកម្ពស់ជំនាញសតវត្សរ៍ទី២១៖<br><br>សូមពិចារណាលើការផ្លាស់ប្តូរប្លង់បណ្ណាល័យ ដើម្បីបញ្ចូលទីតាំងសម្រាប់ការសហការ ឬកិច្ចការជាក្រុម (សូមមើលប្រភពធនធានខាងក្រោម)។ | ✓ | ✓ | | |

| | |
|---|---|
| ប្រភពធនធាន | ប្លង់បន្ទប់រៀន ឬប្លង់បន្ទប់ពិសោធន៍ (Lab/science classroom layout)៖ https://www.kapekh.org/files/report_file/359-en.pdf<br>ការរៀបចំការអប់រំទំនើប (Modern educational designs)៖ Microsoft Word - New Education Design Framework.docx (kapekh.org)<br>សុវត្ថិភាព (Safety)៖ https://drive.google.com/file/d/1QzEjBxkyUwOq81sOLvdCbpLbbSioNYbS/view?usp=sharing<br>ចំណាំ សុវត្ថិភាព៖ ធនធានដែលបញ្ចូលឧបករណ៍សុវត្ថិភាព និងនីតិវិធីនឹងត្រូវបានបង្កើតឡើងជាផ្នែកមួយនៃគម្រោង STEP UP។<br>ការរៀបចំបណ្ណាល័យ (Library design)៖<br>https://www.kapekh.org/files/report_file/100-en.pdf<br>https://drive.google.com/file/d/1BoFRW4gNxgYLRcWk17fVPtAaNSmJp9lz/view?usp=sharing<br>https://drive.google.com/file/d/10Tw37LvFL7JgA0OG8pObgY4x-5a0R6WA/view?usp=sharing<br>https://drive.google.com/file/d/1kE9tRYBSrgojHFfjXz-xVD3WMDTg7dxf/view?usp=sharing |

| ៤.២ | ៤.២ លទ្ធភាពប្រើប្រាស់ | | | | |
|---|---|---|---|---|---|
| | សកម្មភាពគួរអនុវត្ត | កម្រិតសាលារៀន ទី១ ដល់ ២ | កម្រិតសាលារៀន ទី២ ដល់ ៣ | កម្រិតសាលារៀន ទី៣ ដល់ ៤ | កម្រិតសាលារៀន ទី៤ ដល់ ៥ |
| លទ្ធភាពចូលប្រើប្រាស់បន្ទប់ពិសោធន៍ ឬបន្ទប់រៀនវិទ្យា | លទ្ធភាពចូលប្រើប្រាស់បន្ទប់ពិសោធន៍ ឬបន្ទប់រៀនវិទ្យាសាស្ត្រ៖ ពិនិត្យមើលកាលវិភាគដើម្បីធានាថាសិស្សទាំងអស់ចូលប្រើប្រាស់បន្ទប់ពិសោធន៍ ឬបន្ទប់រៀនវិទ្យាសាស្ត្របានជាអតិបរមា។ | ✓ | ✓ | | |
| លទ្ធភាពចូលប្រើប្រាស់បន្ទប់ ICT | លទ្ធភាពចូលប្រើប្រាស់បន្ទប់ ICT ៖ ស្នើទៅគណៈគ្រប់គ្រងសាលារៀន ដើម្បីអនុញ្ញាតឱ្យសិស្សចូលរៀននៅពេលអាហារថ្ងៃត្រង់ ឬក្រោយចេញពីរៀន។ | ✓ | ✓ | | |

| | | | | | |
|---|---|---|---|---|---|
| លទ្ធភាពចូលប្រើប្រាស់ប្រកបដោយបរិយាបន្ន | លទ្ធភាពប្រើប្រាស់បណ្ណាល័យ ឬសម្ភាររូបវន្តស្ទែម៖ សូមពិនិត្យមើលបណ្ណាល័យ ឬសម្ភាររូបវន្តស្ទែម និងពិចារណាពីតម្រូវការពិសេសណាមួយ។ តើមានសកម្មភាពណាមួយដែលអ្នកអាចធ្វើដើម្បីធានាថាតម្រូវការទាំងអស់ត្រូវបានបំពេញ?<br>ពិចារណា៖<br>- តើមានបន្ទប់ដែលមានសម្រាប់រទេះរុញ ដែរឬទេ? តើបន្ទប់មានកាំជណ្ដើរដែរឬទេ? បើមិនមាន តើអ្នកអាចស្នើសុំជំនួយពីសហគមន៍ដើម្បីដោះស្រាយរឿងនេះបានដែរឬទេ?<br>- តើមានសៀវភៅជាសំឡេង ដែរឬទេ? តើបណ្ណាល័យមានសម្ភារចម្រុះដែលស័ក្តិសមនឹងលទ្ធភាព ឬចំណាប់អារម្មណ៍របស់សិស្សដែរឬទេ? | ✓ | ✓ | ✓ | |
| ប្រភពធនធាន | គោលនយោបាយសមភាពយេនឌ័រ ពិការភាព និងការដាក់បញ្ចូលសង្គម របស់អង្គការ KAPE៖ https://www.kapekh.org/files/report_file/360-en.pdf<br>ធនធានអំពីបរិយាបន្ន/លទ្ធភាពប្រើប្រាស់ ប្រសិនបើមាន។ | | | | |

| ៤.៣ | ៤.៣ បរិក្ខារ | | | | |
|---|---|---|---|---|---|
| | សកម្មភាពគួរអនុវត្ត | កម្រិតសាលារៀនទី១ ដល់ ២ | កម្រិតសាលារៀនទី២ ដល់ ៣ | កម្រិតសាលារៀនទី៣ ដល់ ៤ | កម្រិតសាលារៀនទី៤ ដល់ ៥ |
| បរិក្ខារស្ទែម | ពិនិត្យមើលស្ថានភាពនៃឧបករណ៍ស្ទែម រួចកំណត់ឧបករណ៍ដែលត្រូវការការថែទាំ។ សូមស្វែងរកអ្នកអាចជួយថែទាំ។ ប្រសិនបើមិនមាននៅក្នុងសាលារៀននោះទេ សូមស្វែងរកក្នុងសហគមន៍ ដោយស្នើសុំជំនួយតាមរយៈទំនាក់ទំនងរបស់សាលារៀន សូមមើលសមាសភាគទី៥ ការទំនាក់ទំនង។ ចំណាំថា ឧបករណ៍ដែលមិនអាចជួសជុលតាមរយៈការរៃអង្គាសប្រាក់ សូមមើលសមាភាគទី២ ការគ្រប់គ្រងធនធាន។ | ✓ | ✓ | ✓ | |
| សម្ភារគម្រោងស្ទែម | កំណត់ទីតាំងស្តុកទុកសម្ភារគម្រោងស្ទែម។ សូមសុំការអនុញ្ញាតពីគណៈគ្រប់គ្រងសាលារៀន។ សូមបង្កើតផែនការទំនាក់ទំនងទៅសិស្ស/មាតាបិតា ដើម្បីសុំការបរិច្ចាគ (សូមមើលសមាសភាគទី៥ ទំនាក់ទំនង)។ | ✓ | ✓ | | |

| | | | | | |
|---|---|---|---|---|---|
| សម្ភារស្នែមប្រើបានតែម្តង | កំណត់សម្ភារស្នែមប្រើបានតែម្តងដែលពិបាកផ្គត់ផ្គង់ និងស្វែងរកដំណោះស្រាយតាមរយៈសហគមន៍វិជ្ជាជីវៈអន្តរសាលារៀន។ | ✓ | ✓ | | |
| | ចែករំលែកដំណោះស្រាយសម្រាប់សម្ភារស្នែមប្រើបានតែម្តងដល់សាលារៀនផ្សេងទៀតតាមរយៈសហគមន៍វិជ្ជាជីវៈ។ សូមពិចារណាលើការចែករំលែកការចំណាយដោយការទិញភាគច្រើនក្នុងភាពជាដៃគូជាមួយសាលារៀនក្នុងស្រុក។ សូមមើលសមាសភាគទី២ ការគ្រប់គ្រងធនធាន។ | ✓ | ✓ | ✓ | ✓ |
| បរិក្ខារបច្ចេកវិទ្យាអប់រំ | កំណត់ឧបករណ៍ ឬកុំព្យូទ័រដែលត្រូវការការថែទាំ។ ប្រសិនបើគ្មាននរណាម្នាក់មានលក្ខណៈសម្បត្តិគ្រប់គ្រាន់ ឬមានសមត្ថភាពជួសជុលនៅក្នុងសាលារៀនទេ សូមរកមើលក្នុងសហគមន៍ (សូមមើលសមាសភាគទី៥ ទំនាក់ទំនង)។ | ✓ | ✓ | | |
| | ចែករំលែកបទពិសោធន៍ដល់សាលាផ្សេងទៀតអំពីរបៀបថែទាំបរិក្ខារបច្ចេកវិទ្យាអប់រំតាមរយៈ PLCs ។ (សូមមើលធនធានខាងក្រោម) | | | ✓ | ✓ |
| ប្រភពធនធាន | ចំពោះការប្រាស្រ័យទាក់ទង – ធ្វើការជាមួយសមាជិកនៃក្រុមអនុវត្តសកម្មភាពស្នែមដែលទទួលខុសត្រូវសមាសភាគទី៥។<br><br>បរិក្ខារបច្ចេកវិទ្យាអប់រំ– ការថែទាំកុំព្យូរបន្ទះ<br>https://www.kapekh.org/files/report_file/382-en.pdf | | | | |

| ៤.៤ | ៤.៤ ការភ្ជាប់សេវាសាធារណៈ | | | | |
|---|---|---|---|---|---|
| | សកម្មភាពគួរអនុវត្ត | កម្រិតសាលារៀនទី១ ដល់ ២ | កម្រិតសាលារៀនទី២ ដល់ ៣ | កម្រិតសាលារៀនទី៣ ដល់ ៤ | កម្រិតសាលារៀនទី៤ ដល់ ៥ |
| អគ្គិសនី | សម្រាប់សាលារៀនដែលខ្វះខាតការផ្គត់ផ្គង់អគ្គិសនីដែលអាចទុកចិត្តបាន៖ ស្វែងរកដំណោះស្រាយអប់រំជំនួសដោយមិនពឹងផ្អែកលើអគ្គិសនី។ ពិចារណាដំណោះស្រាយពន្លឺព្រះអាទិត្យ។ ស្វែងរកការឧបត្ថម្ភ ឬការបរិច្ចាគ ឬការគាំទ្រនៅក្នុងសហគមន៍ ដើម្បីបើកដំណើរការនេះ។ ឧទាហរណ៍ ថាមពលពន្លឺព្រះអាទិត្យក្នុងបណ្ណាល័យ (Solar SPELL)។ | ✓ | | | |

| | | | | | |
|---|---|---|---|---|---|
| អ៊ីនធឺណិត | សម្រាប់សាលារៀនដែលគ្មានអ៊ីនធឺណិត៖ ប្រសិនបើតំបន់របស់អ្នកមិនមានអ៊ីនធឺណិតទេ សូមពិចារណាដំឡើងអ៊ីនត្រាណិតជាមួយបណ្ណាល័យអេឡិចត្រូនិក។ ការតភ្ជាប់អ៊ីនត្រាណិតគឺជាការតបណ្តាញឯកជនដែលអនុញ្ញាតឱ្យសិស្ស និងបុគ្គលិកចែករំលែកធនធាន សហការ និងទំនាក់ទំនងនៅក្នុងសាលារៀន។ វាអាចផ្តល់អត្ថប្រយោជន៍ដល់សាលារៀននូវលទ្ធភាពទទួលបានសម្ភារអប់រំ បើកកិច្ចសហការលើគម្រោង និងគាំទ្រមុខងាររដ្ឋបាលទាំងអស់ដោយមិនចាំបាច់មានការតភ្ជាប់អ៊ីនធឺណិត។<br>សូមមើលឧបសម្ព័ន្ធ ខ៖ សទ្ទានុក្រមរបស់ក្របខណ្ឌអប់រំស្វែមកម្រិតសាលារៀន ដើម្បីស្វែងយល់អំពីឧបករណ៍អ្វីដែលអ្នកនឹងត្រូវការ។<br><br>ចំណាំចំណុចនេះសម្រាប់ការអង្កេតថវិកាតាមរយៈភាពជាដៃគូខាងក្រៅ សូមមើលសមាសភាគទី២។ ប្រសិនបើមិនមានការផ្តល់ថវិកាទេ សូមពិចារណាលើបណ្ណាល័យអេឡិចត្រូនិកសាមញ្ញមួយ ដោយប្រើ hard-drive ខាងក្រៅដែលអាចចូលប្រើបានក្នុងថ្នាក់រៀន។ | ✓ | | | |
| | សម្រាប់សាលារៀនដែលមានអ៊ីនធឺណិត ប៉ុន្តែមិនមានគ្រប់ទីតាំងនៃសាលារៀន៖ ប្រសិនបើសមរម្យសម្រាប់សាលារៀនរបស់អ្នក សូមពិចារណាដំឡើងឧបករណ៍ពង្រីកសេវា ដើម្បីសេវាអ៊ីនធឺណិតដល់បន្ទប់រៀន។<br><br>ចំណាំចំណុចនេះសម្រាប់ការអង្កេតថវិកាតាមរយៈភាពជាដៃគូខាងក្រៅ សូមមើលសមាសភាគទី២។ | ✓ | ✓ | ✓ | |

| | | | | | |
|---|---|---|---|---|---|
| **អនាម័យ ការសម្អាត និងទឹក** | សម្រាប់សាលារៀនដែលខ្វះខាតអនាម័យ ការសម្អាត និងទឹក ដែលអាចទទួលយកបាន៖ សូមពិនិត្យមើលបរិក្ខារអនាម័យ ការសម្អាត និងទឹក៖ តើមានបរិក្ខារអនាម័យ ការសម្អាត និងទឹកច្រើនដែរឬទេ? សូមស្វែងរកការអនុញ្ញាតដើម្បីរៀបចំសម្រាប់ការប្រើប្រាស់របស់ស្ត្រី។<br>សូមពិនិត្យ៖<br>ក. តើមានសោដែលនៅជំណើការនៅលើទ្វារដែរឬទេ?<br>ខ. តើមានកន្លែងសម្រាប់ការបោះចោលកាកសំណល់ផលិតផលអនាម័យដែរឬទេ?<br>គ. តើមានការផ្តល់សាប៊ូគ្រប់គ្រាន់ដែរឬទេ?<br><br>បើមិនមានទេ សូមស្វែងរកដំណោះស្រាយ។ សូមចូលទាក់ទងសហគមន៍សម្រាប់ការគាំទ្រ (សូមមើលសមាសភាគទី៥ ទំនាក់ទំនង) | ✓ | | | |
| **ប្រភពធនធាន** | https://solarspell.org/<br>**អនាម័យ ការសម្អាត និងទឹក** (**WASH**)៖ សូមប្រាប់ពីប្រភពធនធាន ប្រសិនជាមាន។ | | | | |

# ជំហានទី៤ ៖ ផែនការសកម្មភាពសម្រាប់ក្របខណ្ឌអប់រំស្ទែមកម្រិតសាលារៀន

## សមាសភាគទី៥ ៖ ការចូលរួមរបស់សហគមន៍

| | |
|---|---|
| **សមាសភាគទី៥** | ការចូលរួមរបស់សហគមន៍ |
| **អ្នកទទួលខុសត្រូវ** | សមាជិកបង្គោលនៃក្រុមអនុវត្តសកម្មភាពស្ទែមដែលត្រូវបានចាត់តាំងឱ្យទទួលខុសត្រូវសមាសភាគនេះ ដោយមានការគាំទ្រពីសមាជិកបង្គោល ឬសមាជិកគាំទ្រផ្សេងទៀត។<br>ចំណាំ៖ ប្រធានក្រុមអនុវត្តសកម្មភាពស្ទែមប្រហែលជាអាចត្រូវចាត់តាំងអ្នកទទួលខុសត្រូវចំពោះសមាសភាគនេះជាថ្មី នៅជំហានទី៣ ដើម្បីជានានូវទំហំការងារសមស្រប និងមានប្រសិទ្ធភាព។ |
| **សមាជិកក្រុមអនុវត្តសកម្មភាពស្ទែមសម្រាប់ទទួលខុសត្រូវសមាសភាគនេះ** | |
| **ឆ្នាំទី** | (ឧ. ឆ្នាំទី១៖ ឆ្នាំសិក្សា២០២៤-២០២៥) |
| **ដំណើរការ** |  <br>ក្របខណ្ឌអប់រំស្ទែមកម្រិតសាលារៀនមាន ៥ជំហានដើម្បីគាំទ្រសាលារៀនក្នុងការបង្រៀន និងរៀនមុខវិជ្ជាស្ទែម។ ដើម្បីឱ្យជំហានទី៤នេះទទួលបានជោគជ័យ លោក លោកស្រីត្រូវអនុវត្តជំហានទី១ ២ និង ៣ ប្រកបដោយប្រសិទ្ធិភាព។<br>ផែនការសកម្មភាពស្ទែម នៃក្របខណ្ឌអប់រំស្ទែមកម្រិតសាលារៀននេះ រៀបរាប់អំពីសកម្មភាពដែលអាចអនុវត្តបានដើម្បីពង្រឹងសមាសភាគទី |

| | |
|---|---|
| | ៥៖ ការចូលរួមរបស់សហគមន៍ ហើយអាចស្ថិតនៅក្នុងសមាសភាគរងខាងក្រោម៖<br>៥.១ ការចូលរួម និងគាំទ្ររបស់សហគមន៍<br>៥.២ ភាពជាដៃគូយុទ្ធសាស្ត្រ<br>៥.៣ សកម្មភាពស្នែមក្រៅម៉ោងសិក្សា |
| **គោលបំណងរបស់ឧបករណ៍** | ផែនការសកម្មភាពរបស់ក្របខណ្ឌអប់រំស្នែមកម្រិតសាលារៀនបង្ហាញពីជំហានជាក់ស្តែង យោងទៅតាមសមាសភាគទាំង៥ នីមួយៗ សម្រាប់ការលើកកម្ពស់ការអប់រំស្នែមនៅសាលារៀន។ សកម្មភាពទាំងនេះត្រូវបានចាត់ថ្នាក់ដោយផ្អែកលើកម្រិតអភិវឌ្ឍន៍ ដូចនេះលោក លោកស្រីអាចអនុវត្តតាមកម្រិតអភិវឌ្ឍន៍របស់សាលារៀន ដូចដែលបានកំណត់ដោយឧបករណ៍ស្វ័យវាយតម្លៃ (ជំហានទី៣)។ វិធីសាស្ត្រនេះធានាថាសកម្មភាពដែលបានណែនាំត្រូវបានកែសម្រួលទៅតាមធនធាន និងសមត្ថភាពរបស់សាលារៀន។ នៅពេលដែលលោក លោកស្រីជួបប្រទះនឹងឧបសគ្គដូចជាសម្ភារបរិក្ខារ ឬថវិកានៅមានកម្រិត សូមព្យាយាមផ្តោះទៅរកការអនុវត្តសកម្មភាពទាំងអស់ដែលអាចធ្វើទៅបាន។ តារាងខាងក្រោមក៏រួមបញ្ចូលផងដែរនូវគោលដៅដែលអាចសម្រេចបានដែលទាក់ទងទៅនឹងកម្រិតអភិវឌ្ឍន៍របស់សាលារៀនដោយបម្រើជាវង្វាស់នៃវឌ្ឍនភាពរបស់សាលារៀនលោក លោកស្រី។ |
| **ការណែនាំ** | 1. ពិនិត្យមើលទៅជំហានទី៣៖ ឧបករណ៍ពិនិត្យឡើងវិញ និងកំណត់គោលដៅ ដើម្បីកំណត់ផែនការសកម្មភាពស្នែមដែលសាលារៀនត្រូវអនុវត្តតាម<br>2. ពិចារណាលើសកម្មភាពដែលបានលើកឡើងនៅក្នុងផែនការសកម្មភាពស្នែម ដែលបានសង្ខេបក្នុងតារាងខាងក្រោមអំពីកម្រិតរបស់សាលារៀននៅក្នុងសមាសភាគនេះ<br>3. ជ្រើសរើសសកម្មភាពដែលអាចអនុវត្តបាន ដូចដែលបានរៀបរាប់នៅក្នុងតារាង ប្រសិនបើសកម្មភាពមានចំនួនច្រើន ចូរជ្រើសរើសតែសកម្មភាពណាដែលលោក លោកស្រីអាចធ្វើទៅបានក្នុងឆ្នាំនេះ<br>4. ពិនិត្យប្រភពឯកសារ ឬតំណភ្ជាប់សំខាន់ៗដែលអាចជួយឱ្យលោក លោកស្រីរៀបចំផែនការ និងអនុវត្តសកម្មភាព<br>5. ពិនិត្យមើលនៅក្នុងសទ្ទានុក្រមសម្រាប់ពាក្យពិបាកយល់។ |

## ការរម្លឹកពីគោលដៅដែលបានកំណត់

សូមមើលជំហានទី៣ និងកំណត់ចំណាំគោលដៅអ្នកនៅទីនេះដើម្បីមានភាពងាយស្រួល។

**តារាងទី 11៖ ការកំណត់គោលដៅ និងការកំណត់ផែនការសកម្មភាពស្នែម**

| គោលដៅសម្រាប់ឆ្នាំបន្ទាប់៖ (✓ ជ្រើសរើសយកជម្រើសមួយ) | | ✓សមាសភាគស្នែម ដែលត្រូវពង្រឹង | តម្លៃ DDL | សញ្ញា ✓ ចង្អុលបង្ហាញពីផែនការសកម្មភាពដែលអនុវត្ត | | | |
|---|---|---|---|---|---|---|---|
| | | | | កម្រិតសាលារៀន ទី១ ទៅ ២ | កម្រិតសាលារៀន ទី២ ទៅ ៣ | កម្រិតសាលារៀន ទី៣ ទៅ ៤ | កម្រិតសាលារៀន ទី៤ ទៅ ៥ |
| ☐ | **ជម្រើសទី១៖** សម្រេចបានលទ្ធផលប្រហាក់ប្រហែលគ្នានៅក្នុងចំណោមសមាសភាគទាំង៥ ដោយព្យាយាមពង្រឹងលើសមាសភាគដែលខ្សោយ។ | ☐ ហេដ្ឋារចនាសម្ព័ន្ធ | | | | | |
| | | ☐ វប្បធម៌សាលារៀន និងអភិបាលកិច្ច | | | | | |
| | | ☐ សមត្ថភាពរបស់គ្រូបង្រៀន និងលទ្ធផលការសិក្សារបស់សិស្ស | | | | | |
| | | ☐ ដំណើរការបង្រៀន និងរៀន | | | | | |
| | | ☐ ការចូលរួមរបស់សហគមន៍ | | | | | |
| ឬ | | | | | | | |
| គោលដៅសម្រាប់ឆ្នាំបន្ទាប់៖ | | ✓សមាសភាគស្នែម ដែលត្រូវពង្រឹង | តម្លៃ DDL | សញ្ញា ✓ ចង្អុលបង្ហាញពីផែនការសកម្មភាពដែលអនុវត្ត | | | |
| | | | | កម្រិតសាលារៀន ទី១ ទៅ ២ | កម្រិតសាលារៀន ទី២ ទៅ ៣ | កម្រិតសាលារៀន ទី៣ ទៅ ៤ | កម្រិតសាលារៀន ទី៤ ទៅ ៥ |
| ☐ | **ជម្រើសទី២៖** សម្រេចបានកម្រិតបន្ទាប់ នៃកម្រិតអភិវឌ្ឍនៅក្នុងសមាសភាគចំនួន៣ | ☐ ហេដ្ឋារចនាសម្ព័ន្ធ | | | | | |
| | | ☐ វប្បធម៌សាលារៀន និងអភិបាលកិច្ច | | | | | |
| | | ☐ សមត្ថភាពរបស់គ្រូបង្រៀន និងលទ្ធផលការសិក្សារបស់សិស្ស | | | | | |
| | | ☐ ដំណើរការបង្រៀន និងរៀន | | | | | |
| | | ☐ ការចូលរួមរបស់សហគមន៍ | | | | | |

## សេចក្តីរៀបរាប់៖ កម្រិតអភិវឌ្ឍន៍តាមសមាសភាគ (DDL) បច្ចុប្បន្ន និងគោលដៅសម្រាប់សមាសភាគនេះ៖

កម្រិតអភិវឌ្ឍន៍របស់សាលារៀនយើង នៅត្រង់សមាសភាគនេះ គឺកម្រិត ____ ។ គោលដៅរបស់សាលារៀនដើម្បីឆ្ពោះទៅរកកម្រិត______ ដូចនេះយើងនឹងអនុវត្តតាមសកម្មភាពដែលបានណែនាំដើម្បីអភិវឌ្ឍពីកម្រិត_______ទៅ កម្រិត____នៅក្នុងតារាងខាងក្រោម និងខិតខំដើម្បីសម្រេចគោលដៅដែលបានកំណត់។

*(ឧទាហរណ៍៖ កម្រិតអភិវឌ្ឍន៍របស់សាលារៀនយើង នៅត្រង់សមាសភាគនេះ គឺកម្រិត __2__ ។ គោលដៅរបស់សាលារៀនដើម្បីឆ្ពោះទៅរកកម្រិត____3_____ ដូចនេះយើងនឹងអនុវត្តតាមសកម្មភាពដែលបានណែនាំដើម្បីអភិវឌ្ឍពីកម្រិត_____2_____ទៅ កម្រិត_____3_____នៅក្នុងតារាងខាងក្រោម និងខិតខំដើម្បីសម្រេចគោលដៅដែលបានកំណត់។)*

## កូដពណ៌៖

| | ✓ | |
|---|---|---|
| សកម្មភាពមិនទាន់បានអនុវត្ត៖ សាលារៀននៅកម្រិតនេះមិនទាន់ត្រៀមសម្រាប់សកម្មភាពនេះ | សញ្ញា ✓ បង្ហាញថាសកម្មភាពនេះអាចអនុវត្តបានក្នុងសាលារៀនក្នុងកម្រិតនេះ | សាលារៀននៅក្នុងកម្រិតនេះគឺអាចសម្រេចបានសកម្មភាពដែលបានលើកឡើង |

| ៥.១ | ៥.១ ការចូលរួម និងគាំទ្ររបស់សហគមន៍ | | | | |
|---|---|---|---|---|---|
| | សកម្មភាពគួរអនុវត្ត | កម្រិតសាលារៀនទី ១ ដល់ ២ | កម្រិតសាលារៀនទី ២ ដល់ ៣ | កម្រិតសាលារៀនទី ៣ ដល់ ៤ | កម្រិតសាលារៀនទី ៤ ដល់ ៥ |
| ការប្រាស្រ័យទាក់ទង និងការចូលរួមគាំទ្រ | ក្រុមអនុវត្តសកម្មភាពស្ទែមរៀបចំផែនការទំនាក់ទំនងជាមួយគ្រួសារផ្តោតលើស្ទែម ដើម្បីពង្រីកការយល់ដឹងស្ទែមរបស់ពួកគាត់ វារួមបញ្ចូលដូចខាងក្រោម៖<br>- ពន្យល់អំពីអ្វីគឺជាស្ទែម? តើវាមកពីពាក្យអ្វី? តើការអនុវត្តស្ទែមអាចជួយពង្រឹងជំនាញសតវត្សទី២១ ដែលពួកគេត្រូវការយ៉ាងដូចម្តេច? បង្ហាញពីសក្តានុពលនៃការងារផ្នែកស្ទែម និងបញ្ជាក់ពីសារៈសំខាន់នៃស្ទែមសម្រាប់អនាគតរបស់ប្រទេសកម្ពុជា<br>- បង្ហាញពីការតាំងចិត្តរបស់សាលារៀនក្នុងការអនុវត្តស្ទែម និងសារៈសំខាន់ចំពោះសិស្សទទួលបានពីវា។<br>- ផ្តល់ព័ត៌មានទៅអ្នកអាណាព្យាបាលសិស្សថា ពួកគាត់នឹងទទួលព័ត៌មានផ្សេងៗអំពីចំណេះដឹងស្ទែមពីសាលារៀន ដូចជា ព្រឹត្តិការណ៍ស្ទែម ទំនាក់ទំនងសម្រាប់ការបរិច្ចាកសម្ភារផ្សេងៗ (ឧទាហរណ៍៖ សម្ភារងាយៗប្រចាំថ្ងៃដែលអាចបង្កើតគម្រោងស្ទែម)។<br>- ទំនាក់ទំនងអាណាព្យាបាលសម្រាប់ការគាំទ្រ និងការចូលរួម។ | ✓ | ✓ | | |
| | ក្រុមអនុវត្តសកម្មភាពស្ទែមរៀបចំផែនការ និងបញ្ចូលព្រឹត្តិការណ៍ស្ទែម ដែលពាក់ព័ន្ធនឹងអ្នកអាណាព្យាបាលសិស្ស។ ឧទាហរណ៍ ពិព័រណ៍អាជីពស្ទែម ឬ ពិព័រណ៍ស្នាដៃស្ទែម។<br>- ប្រសិនបើវាជារឿងថ្មីសម្រាប់សាលារៀនរបស់លោក លោកស្រី សូមពិចារណាអំពីការអញ្ជើញអ្នកអាណាព្យាបាលសិស្សចូលក្នុងក្លឹបស្ទែម ដើម្បីចូលរួមនិងសង្កេតមើលសកម្មភាពស្ទែមរបស់កូនរបស់ពួកគាត់។<br>- ពិព័រណ៍អាជីពស្ទែមធ្វើឱ្យមានការចូលរួមពីអ្នកជំនាញស្ទែមក្នុងតំបន់ អតីតសិស្ស និងឡើងនិយាយអំពីអាជីពរបស់ពួកគាត់។ សូមចាប់ផ្តើមដោយការ | ម្តងក្នុងឆ្នាំទី១ | យ៉ាងតិចពីរដងក្នុងមួយឆ្នាំ | យ៉ាងតិចម្តងក្នុងមួយត្រីមាស | |

| | | | | | |
|---|---|---|---|---|---|
| | អញ្ជើញអ្នកអាណាព្យាបាលទៅតាមកម្រិតថ្នាក់នីមួយៗ។ បើអាចទៅរួច សូមអញ្ជើញអ្នកអាណាព្យាបាលទៅតាមកម្រិតថ្នាក់ផ្សេងៗគ្នា។ | | | | |
| | សាលារៀនព្យាយាមទាក់ទងអ្នកអាណាព្យាបាលដែលមានកម្រិតជីវភាពខុសៗគ្នាដោយប្រើប្រាស់វិធីសាស្ត្រផ្សេងៗដើម្បីផ្តល់ព័ត៌មានអំពីស្ទែម។ សាលារៀនសុំឱ្យអាណាព្យាបាលផ្តល់នូវព័ត៌មានត្រឡប់ ដើម្បីកែលម្អ។ | | | ✓ | ✓ |
| | សូមគិតអំពីរញ្ជោចយេនឌ័រក្នុងការទាក់ទង និងនៅពេលអញ្ជើញអ្នកជំនាញស្ទែមឡើងនិយាយជាមួយអ្នកអាណាព្យាបាល។ | ✓ | ✓ | ✓ | ✓ |
| ប្រភពធនធាន | **តើស្ទែមជាអ្វី?** https://youtu.be/2HelbHNqcSk?si=9aLcb75y7mPhFX7e<br><br>**ប្រសិនបើមាន សូមបន្ថែមធនធានជាភាសាខ្មែរ។** | | | | |

| ៥.២ | ៥.២ ភាពជាដៃគូយុទ្ធសាស្ត្រ | | | | |
|---|---|---|---|---|---|
| | **សកម្មភាពគួរអនុវត្ត** | **កម្រិតសាលារៀនទី ១ ដល់ ២** | **កម្រិតសាលារៀនទី ២ ដល់ ៣** | **កម្រិតសាលារៀនទី ៣ ដល់ ៤** | **កម្រិតសាលារៀនទី ៤ ដល់ ៥** |
| ភាពជាដៃគូស្ទែម | ក្រុមអនុវត្តសកម្មភាពស្ទែមស្វែងរកបេក្ខជនដែលមានសក្តានុពលសម្រាប់ភាពជាដៃគូនៅក្នុងសហគមន៍សាលារៀន ឬលើសពីនេះនៅក្នុងតំបន់។ ប្រមូលព័ត៌មានទំនាក់ទំនងលម្អិត។ ចំណាំ ចំពោះផលប្រយោជន៍រួមណាមួយ (ឧទាហរណ៍ ក្រុមហ៊ុនរចនាក្រាហ្វិកអាចមានចំណាប់អារម្មណ៍ក្នុងការគាំទ្រការកែលម្អបំណិនឌីជីថល)។ ក្រុមអនុវត្តសកម្មភាពស្ទែមបង្កើតលិខិតងាយៗ/ទំនាក់ទំនងស្វែងរកដៃគូ ឬឧបត្ថម្ភ។ ប្រសិនបើនេះជាលើកទីមួយហើយដែលសាលារបស់អ្នក សូមស្វែងយល់ពីភាពជាដៃគូ សូមពិចារណាចាប់ផ្តើមជាមួយនឹងអ្វីដែលសាមញ្ញដូចជាការស្វែងរកជំនួយក្នុងការទិញម៉ាស៊ីនបញ្ចាំងរូបភាពសម្រាប់ប្រើប្រាស់ក្នុងការបង្រៀន | ✓ | | | |

| | | | | | |
|---|---|---|---|---|---|
| | ក្នុងថ្នាក់។ សូមរៀបចំបញ្ជីទំនាក់ទំនង និងបង្កើតផែនការទំនាក់ទំនងសម្រាប់ឆ្នាំសិក្សាបន្ទាប់។ រួមបញ្ចូលការធ្វើបច្ចុប្បន្នកម្មជាប្រចាំអំពីសកម្មភាពស្នេហ៍របស់សាលានៅក្នុងការទំនាក់ទំនង ដើម្បីធានាថាអ្នកពាក់ព័ន្ធផ្នែកស្នេហ៍ខាងក្រៅត្រូវបានរំឭកពីឱកាសដើម្បីចូលរួម និងគាំទ្រសហគមន៍សាលារៀន។ | | | | |
| | បង្កើតភាពជាដៃគូរយៈពេលខ្លីជាមួយភាគីពាក់ព័ន្ធស្នេហ៍ខាងក្រៅតំបន់ (ឧទាហរណ៍ អាជីវកម្ម/ឧស្សាហកម្មស្នេហ៍ក្នុងតំបន់)។ សូមប្រាស្រ័យទាក់ទងធ្វើបច្ចុប្បន្នកម្មជាទៀងទាត់ដល់អ្នកពាក់ព័ន្ធស្នេហ៍លើសកម្មភាពស្នេហ៍។ | | ✓ | ✓ | |
| | បង្កើតភាពជាដៃគូរយៈពេលវែងប្រកបដោយអត្ថន័យជាមួយនឹងអ្នកពាក់ព័ន្ធផ្នែកស្នេហ៍ខាងក្រៅក្នុងតំបន់ (ឧទាហរណ៍ អាជីវកម្ម/ឧស្សាហកម្មស្នេហ៍នៅក្នុងតំបន់)។ សូមធ្វើទំនាក់ទំនងធ្វើបច្ចុប្បន្នកម្មជាប្រចាំអ្នកពាក់ព័ន្ធស្នេហ៍តាមរយៈថ្នាលផ្សេងៗជាច្រើន (អ៊ីមែល ប្រព័ន្ធផ្សព្វផ្សាយសង្គម ជាដើម)។ | | | | ✓ |
| ដៃគូយុទ្ធសាស្ត្រជាមួយសាលារៀនដទៃ | ក្រុមអនុវត្តសកម្មភាពស្នេហ៍អង្កេតភាពជាដៃគូដែលមានសក្តានុពលជាមួយសាលារៀនក្នុងតំបន់ ដូចជាការសហការលើគម្រោងស្នេហ៍ឬគម្រោងសហគមន៍ ការរួមគ្នារៀបចំពិព័រណ៍ស្នេហ៍ ការចែករំលែកថវិកាសម្រាប់ទិញសម្ភារនិងឧបករណ៍ ឬសម្របសម្រួលការដឹកជញ្ជូនទៅកាន់ទីតាំងព្រឹត្តិការណ៍ស្នេហ៍។ ជាឧទាហរណ៍ សាលារៀនអាចឆ្លាស់គ្នារៀបចំពិព័រណ៍ស្នេហ៍ជារៀងរាល់ឆ្នាំ ដោយសិស្សមកពីសាលាដែលមិនមែនជាម្ចាស់ផ្ទះចូលរួមជាទស្សនិកជន។ | ✓ | | | |
| | សាលារៀនដើម្បីបង្កើតភាពជាដៃគូជាមួយសាលាផ្សេងទៀត។ | | ✓ | ✓ | |
| | សាលារៀនដើម្បីបង្កើតឱកាសសម្រាប់កិច្ចសហប្រតិបត្តិការជាមួយសាលាផ្សេងទៀតដែលមានចំណាប់អារម្មណ៍ស្រដៀងគ្នាក្នុងការអប់រំស្នេហ៍។ ឧទាហរណ៍ រៀបចំផែនការ និងដឹកនាំគម្រោងសហគមន៍ ដោយអញ្ជើញសាលាផ្សេងទៀតឱ្យចូលរួម។ | | | | ✓ |

| ប្រភពធនធាន | | | | | |
|---|---|---|---|---|---|

| ៥.៣ | ៥.៣ សកម្មភាពស្ទែមក្រៅម៉ោងសិក្សា | | | | |
|---|---|---|---|---|---|
| | សកម្មភាពគួរអនុវត្ត | កម្រិតសាលារៀនទី ១ ដល់ ២ | កម្រិតសាលារៀនទី ២ ដល់ ៣ | កម្រិតសាលារៀនទី ៣ ដល់ ៤ | កម្រិតសាលារៀនទី ៤ ដល់ ៥ |
| ក្លឹបសិក្សាស្ទែមក្រៅសាលារៀន | ក្រុមអនុវត្តសកម្មភាពស្ទែមស្វែងរកមធ្យោបាយក្នុងការបង្កើតក្លឹបសិក្សានៅថ្ងៃអនាគត។ សូមចំណាំថានេះមិនសំដៅលើក្លឹបសិក្សាដែលផ្តល់ការសិក្សាផ្នែកទ្រឹស្តីចំពោះមុខវិជ្ជាស្ទែម។ ផ្ទុយទៅវិញក្លឹបសិក្សាក្រៅម៉ោងផ្តល់ឱកាសដល់សិស្សដើម្បីអនុវត្តជាក់ស្តែង ការបង្កើតគម្រោងស្ទែម ឬរៀនជំនាញថ្មីដែលមិនបានរៀនម៉ោងរៀននៅសាលា។ ជំហានក្នុងការបង្កើតក្លឹបក្រៅម៉ោងសិក្សាអាចរាប់បញ្ចូលខាងក្រោម៖<br>- កំណត់ទីតាំង និងពេលវេលាសមស្រប។ សូមចងចាំថាមានសកម្មភាពស្ទែមជាច្រើនដែលមិនត្រូវការអ្នកជំនាញស្ទែម ឬក៏ឧបករណ៍សម្ភារអ្វីឡើយ។ ប្រសិនបើវាជាការងារថ្មីរបស់សាលាអ្នក ចូរគិតពីប្រមូលសិស្ស។ សូមសាកល្បងឱ្យពួកគេគិតពីខ្លឹមសារ និងលើកឡើងពីបញ្ហាផ្សេងៗគេជួបប្រទះ ព្រមទាំងរៀនសូត្រពីបទពិសោធន៍ល្អៗ ដើម្បីបង្កើនអ្នកចូលរួមនាពេលអនាគត។<br>- លើកឡើងពីតម្រូវការផ្សេងៗ។ តើគ្រូបង្រៀនស្ទែមអាចដាក់វេនគ្នាដោយផ្អែកលើមុខវិជ្ជាស្ទែម និងសកម្មភាពស្ទែមបានដែរឬទេ?<br>- កំណត់ខ្លឹមសារនៃក្លឹបសិក្សាស្ទែមដែលសមស្រប។ ប្រសិនបើវាជារឿងថ្មីសម្រាប់សាលារបស់អ្នក សូមពិចារណាអំពីសកម្មភាពស្ទែម ដែលណែនាំដោយ | ✓ | ✓ | | |

| | | | | | |
|---|---|---|---|---|---|
| | ក្រសួងអ.យ.ក ឬធនធានដែលមានតម្លៃទាបសម្រាប់ប្រើប្រាស់ឬពិនិត្យតំណភ្ជាប់ខាងក្រោម។<br>- ដឹកនាំដោយក្រុមអនុវត្តសកម្មភាពស្ទែម និងតំណាងសិស្ស។ ផ្សាយព័ត៌មានអំពីក្លឹបសិក្សា លើកពីចំណុចសំខាន់នៃក្លឹបសិក្សាទៅអ្នកចូលរួម (ពួកគេនឹងទទួលបានបំណិនស្ទែមដែលគេចូលចិត្ត និងជាសកម្មភាពសប្បាយទៀតផង)។<br>- ប្រមូលសម្ភារស្ទែម ដោយផ្អែកទៅលើសកម្មភាព ដែលបានរៀបចំ។ សូមទាក់ទងទៅដល់ក្រុមហ៊ុនក្នុងស្រុក អ្នកអាណាព្យាបាល និងសិស្ស សម្រាប់ការបរិច្ចាក បើអាចទៅរួច។ សូមចងចាំថាសម្ភារអាចជាឧបករណ៍បោះចោលពីក្រុមហ៊ុនផ្សេងៗ ឬសម្ភារផ្សេងៗពីទីផ្សារក្នុងស្រុក។ ប្រសិនបើបញ្ហាថវិកាជាឧបសគ្គ មានសកម្មភាពជាច្រើនទៀតដែលមិនត្រូវការចំណាយថវិកា។<br>- ឱ្យសិស្សបង្កើតគម្រោងស្ទែម ដែលគេអាចធ្វើបទបង្ហាញក្នុងកំឡុងពេលធ្វើពិព័រណ៍ស្ទែម។<br>- គិតអំពីរបៀបផ្សាភ្ជាប់ក្លឹបសិក្សា ទៅនឹងជីវភាពរស់នៅ និងឱ្យសិស្សដោះស្រាយបញ្ហានោះឡើង នៅក្នុងសហគមន៍តែម្តង។ | | | | |
| | សាលារៀបចំក្លឹបសិក្សាក្រៅម៉ោងសិក្សា ដូចបានរៀបរាប់ខាងលើ ជាមួយសិស្សជាច្រើន។<br>សូមស្វែងរកខ្លឹមសារអំពីក្លឹបសិក្សាពីធនធានផ្សេងៗក្នុងប្រទេស ឬលើសពីនេះ។ សូមផ្សាភ្ជាប់អាជីពស្ទែមទៅនឹងប្រធានបទ ឬផ្តោតអារម្មណ៍លើការស្វែងរកការងារផ្សេងៗតាមរយៈក្លឹបសិក្សានេះ (សូមមើលសកម្មភាពក្នុង STEM Sisters Cambodia STEM club) និងបង្កើតឱកាសសម្រាប់សិស្សដើម្បីចូលរួមក្នុងការស្រាវជ្រាវវិទ្យាសាស្ត្រ តាមរយៈគម្រោងវិទ្យាសាស្ត្រពលរដ្ឋ។ | | | ✓ | ✓ |
| | សាលារៀនត្រូវគិតគូបន្ថែមលើរំញោចយេនឌ័រសម្រាប់សកម្មភាពក្រៅម៉ោងសិក្សា។ សូមរៀបចំក្លឹបសិក្សាឱ្យត្រូវទៅតាមពេលវេលាសមស្របនៅទីកន្លែងមានសុវត្ថិភាព និងបើអាចទៅរួចមានការចូលរួមពីអ្នកគ្រូកាន់តែប្រសើរ។ សូមបង្កើតឱកាស | ✓ | ✓ | ✓ | ✓ |

| | | | | | |
|---|---|---|---|---|---|
| | សម្រាប់សិស្សស្រីឱ្យចូលរួមជាមួយសិស្សប្រុសក្នុងក្រុមតែមួយ និងផ្តល់ឱកាសស្មើភាពគ្នាក្នុងការដឹកនាំសកម្មភាពអ្វីមួយ។ | | | | |
| | សូមគិតក្នុងការបង្កើតទស្សនាវដ្តីអេឡិចត្រូនិច ដែលបង្កើតឡើងដោយសិស្សច្បង។ ទស្សនាវដ្តីនេះអាចចូលរួមក្នុងការឱ្យសិស្សដឹងពីប្រធានបទស្ទែម ឬការងារដែលពាក់ព័ន្ធស្ទែម ឬក៏ព័ត៌មានរបស់សាលារៀន។ ទស្សនាវដ្តីនេះដើរតួជាស្នាដៃរួមរបស់ពួកគ្នា ហើយសិស្សទាំងអស់មានឱកាសក្នុងការអភិវឌ្ឍចំណេះដឹងឌីជីថលរបស់ពួកគេ។ | | | ✓ | ✓ |
| ការតាំងពិព័រណ៍ស្ទែមនៅក្នុងសាលារៀន | សាលារៀនរៀបផែនការ និងរៀបចំការតាំងពិព័រណ៍ក្នុងសាលារៀន។ វាមើលទៅដូចជាស្រួលបើស្តាប់មើលទៅ។<br>- រៀបចំក្រុមមានសិស្ស៣ ឬ៤នាក់។ បើសិនជាការងារថ្មីសម្រាប់សាលាអ្នក សូមគិតតែកម្រិតមួយថ្នាក់។ ថ្នាក់ផ្សេងទៀតអាចជាអ្នកចូលមើលគម្រោងតាំងពិព័រណ៍នេះ។<br>- ឱ្យសិស្សដែលចូលរួមដើម្បីបង្កើតគម្រោងស្ទែម លើប្រធានបទដែលគាត់ចាប់អារម្មណ៍<br>- កំណត់ថ្ងៃ រៀបចំតុ កំណត់តុនីមួយៗសម្រាប់សិស្សមួយក្រុម និងអនុញ្ញាតឱ្យគេរៀបចំបទបង្ហាញផ្ទាល់របស់ពួកគេ។ (អាចបង្កើត Poster ពីកេសឡាំង)។<br>- អញ្ជើញសិស្សពីថ្នាក់ដទៃទៀតឱ្យចូលរួមទស្សនា។ អ្នកចូលរួមធ្វើបទបង្ហាញគម្រោងរបស់ពួកគេទៅកាន់មិត្តភក្តិរបស់គេ និងសួរសំណួរផ្សេងៗ។<br>- គិតអំពីសន្លឹកកិច្ចការវាយតម្លៃជាដៃគូ ឬក៏យកការងារនេះទៅឱ្យគ្រូបង្រៀន។<br>- ក្រុមដែលឈ្នះ ឧទាហរណ៍ ក្រុមឡើងនិយាយល្អជាងគេ ក្រុមឡើងបង្ហាញល្អជាងគេ ខ្លឹមសារល្អជាងគេ មានគំនិតច្នៃប្រឌិតជាងគេ ក្រុមមានអ្នកចូលមើលច្រើនជាងគេ និងរៀបចំឱ្យមានលក្ខណៈសប្បាយរីករាយ។<br>- គិតអំពីសុវត្ថិភាព សូមកុំឱ្យមានការឆាបឆេះ ឬសារធាតុគីមី ការគ្រប់គ្រងមនុស្សកុំឱ្យកកកុញ និងមានឧបករណ៍សង្គ្រោះបឋមនៅពេលមានបញ្ហា។ | ត្រៀមរៀបចំពិព័រណ៍ត្រៀមនៅឆ្នាំក្រោយ | រៀបចំពិព័រណ៍ស្ទែមនៅក្នុងសាលារៀនមួយឆ្នាំម្តង | រៀបចំពិព័រណ៍ស្ទែមនៅក្នុងសាលារៀនមួយឆ្នាំម្តងហើយអញ្ជើញគ្រួសារសិស្ស និងសាលារៀនក្នុងតំបន់។ | រៀបចំពិព័រណ៍ស្ទែមនៅក្នុងសាលារៀនមួយឆ្នាំម្តងហើយអញ្ជើញគ្រួសារសិស្ស ,សាលារៀន និងអាជីវករក្នុងតំបន់ ព្រមទាំងមន្ទីរអេ.យ.ក។ បង្កើតសម្ភារសម្រាប់ព្រឹត្តិការណ៍ពិព័រណ៍ស្ទែម និងចែករំលែកតាមរយៈសហគមន៍សិក្សាវិជ្ជាជីវៈ (ឧ. ការណែនាំសុវត្ថិភាព, គំរូពាក្យស្នើសុំ, និទ្ទេសបទ) |

| | | | | | |
|---|---|---|---|---|---|
| ព្រឹត្តិការណ៍ស្ទែម និងការប្រកួតប្រជែងស្ទែម | សាលារៀនរៀបចំព្រឹត្តិការណ៍ស្ទែម នៅពេលសមស្របណាមួយ។ វាអាចជាការប្រកួតប្រជែងជាលក្ខណៈអនឡាញ ឬដោយផ្ទាល់។ ក្រុមសកម្មភាពស្ទែមរៀបចំសិស្សនិងគ្រូខ្លះឱ្យចូលរួម។ ការចូលរួមដោយផ្ទាល់អាចត្រូវការថវិកា និងមានអនុញ្ញាតពីក្រសួងអ.យ.ក និងអ្នកអាណាព្យាបាល។ សូមរៀបចំការរៃអង្គាសសម្រាប់ការចំណាយ បើសិនជាចាំបាច់។ សូមចែករំលែកការរៀនសូត្រ និងបទពិសោធន៍ទៅកាន់គ្រូ និងសិស្សក្នុងការរៀបចំសម្រាប់ការចូលរួមក្នុងឆ្នាំខាងមុខ។ សូមមើលតំណភ្ជាប់ខាងក្រោមក្នុងការរៀបចំ។ | ចូលរួមព្រឹត្តិការណ៍ស្ទែម។ ត្រៀមចូលរួមនៅឆ្នាំក្រោយ | | | |
| | សាលារៀនជំរុញសិស្សមួយចំនួន ឬទាំងអស់ឱ្យចូលរួមក្នុងព្រឹត្តិការណ៍ស្ទែម។ ក្រុមអនុវត្តសកម្មភាពស្ទែមជួយក្នុងការរៀបចំ យល់អំពីតម្រូវការក្នុងការចូលរួមឬការងារផ្សេងៗ រៀបចំសិស្សឱ្យប្រជុំគ្នា ប្រសិនបើពួកគេត្រូវការអនុវត្តក្នុងការរៀបចំព្រឹត្តិការណ៍ស្ទែម។ វាអាចត្រូវការឱ្យតំណាងសាលារៀនដើរតួជាអ្នកប្រឹក្សាឬអ្នកគ្រប់គ្រងផ្ទាល់។ វាអាចត្រូវការថវិកាបន្ថែម។ | | សិស្សមួយចំនួនចូលរួមក្នុងព្រឹត្តិការណ៍ស្ទែម | សិស្សទាំងអស់ចូលរួមក្នុងព្រឹត្តិការណ៍ស្ទែម | |
| | សាលារៀនគាំទ្រក្នុងការផ្ដល់រង្វាន់ដល់សិស្សដែលឈ្នះ និងអាចចូលប្រកួតក្នុងលក្ខណៈអន្តរជាតិ។ សូមអបអរសាទរចំពោះស្នាដៃរបស់ពួកគេ និងជំរុញសហគមន៍សាលារៀនឱ្យគាំទ្រ ពីព្រោះពួកគាត់គឺតំណាងសាលារៀន។ | | | ✓ | ✓ |
| | សាលារៀនគាំទ្រក្នុងការជួយនិងរៀបចំពិព័រណ៍ស្ទែម។ វាអាចជាពិព័រណ៍ស្នាដៃដែលត្រូវបានអញ្ជើញដោយសាលារៀន ឬក៏ការគាំទ្រពីស្ថាប័នស្ទែម ដោយផ្ដល់ជាទីកន្លែងសម្រាប់ធ្វើព្រឹត្តិការណ៍ស្ទែមនេះ។ | | | | សាលារៀនជួយរៀបចំព្រឹត្តិការណ៍ស្ទែម |
| ប្រភពធនធាន | **ក្លឹបសិក្សាស្ទែម៖**<br>STEMEOC STEM Sisters Cambodia: Download STEM Club instructions from Cycle 1 and 2:https://stemcambodia.ngo/cycle-1-2019/<br><br>**ធនធានជាភាសាខ្មែរបន្ថែមទៀត ឬតំណភ្ជាប់ទាក់នឹងក្លឹបសិក្សាស្ទែម។** | | | | |

# ជំហានទី៥៖ ឧបករណ៍ពិនិត្យតាមដានវឌ្ឍនភាពក្របខណ្ឌអប់រំស្ទែមកម្រិតសាលារៀន




## ជំហានទី ៥៖ ឧបករណ៍ពិនិត្យតាមដានវឌ្ឍនភាពក្របខណ្ឌអប់រំស្ទែមកម្រិតសាលារៀន

## សមាសភាគទី១ ដល់ ៥

| | |
|---|---|
| **សមាសភាគ** | ទី១ ដល់ ៥ |
| **អ្នកទទួលខុសត្រូវ** | ក្រុមអនុវត្តសកម្មភាពស្ទែម – សមាជិកបង្គោល។ ប្រធានក្រុមអនុវត្តសកម្មភាពស្ទែម និងសមាជិកបង្គោលទទួលខុសត្រូវក្នុងការបំពេញឧបករណ៍នេះដោយធ្វើការត្រួតពិនិត្យវឌ្ឍនភាពពាក់កណ្ដាលឆ្នាំ និងពេញមួយឆ្នាំ។ ពួកគាត់គួរតែរៀបចំកិច្ចប្រជុំជាមួយសមាជិកគាំទ្រ និងគណៈគ្រប់គ្រងសាលារៀន រាយការណ៍អំពីវឌ្ឍនភាព ពិភាក្សារៀនសូត្រ និងសម្រេចលើគោលដៅសម្រាប់ឆ្នាំក្រោយ។ |
| **ឆ្នាំទី** | ( ឧ. ឆ្នាំទី១ ៖ ឆ្នាំសិក្សា២០២៤-២០២៥ ) |
| **ដំណើរការ** | <br>ក្របខណ្ឌអប់រំស្ទែមកម្រិតសាលារៀនមាន ៥ជំហានដើម្បីគាំទ្រសាលារៀនក្នុងការបង្រៀន និងរៀនមុខវិជ្ជាស្ទែម។ ឧបករណ៍ពិនិត្យតាមដានវឌ្ឍនភាពជាជំហានទី៥ នៃដំណើរការ ៥ជំហានរបស់ក្របខណ្ឌ។ ដើម្បីប្រើប្រាស់ឧបករណ៍នេះមានប្រសិទ្ធិភាព លោក លោកស្រីត្រូវអនុវត្តជំហានទី១ ដល់ ៤ ឱ្យបានរួចរាល់។<br><br>ឧបករណ៍តាមដានវឌ្ឍនភាពនេះ ប្រើប្រាស់សម្រាប់គ្រប់សមាសភាគពី១ ដល់ ៥៖<br>1. លទ្ធផលការសិក្សារបស់សិស្ស<br>2. ការបង្រៀន និងរៀន<br>3. អភិបាលកិច្ចសាលារៀន |

| | |
|---|---|
| | 4. ការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធ<br>5. ការចូលរួមរបស់សហគមន៍ |
| **គោលបំណងរបស់ឧបករណ៍** | ឧបករណ៍តាមដានវឌ្ឍនភាពត្រូវបានរៀបចំឡើងដើម្បីជួយដល់ក្រុមអនុវត្តសកម្មភាពស្នែមរបស់សាលារៀនលោក លោកស្រី ដើម្បីតាមដានវឌ្ឍនភាពពាក់កណ្តាលឆ្នាំ ព្រមទាំងការពិនិត្យឡើងវិញនូវវឌ្ឍនភាពស៊ីជម្រៅប្រចាំឆ្នាំដែលពាក់ព័ន្ធនឹងការឆ្លុះបញ្ចាំងពេញលេញទៅលើសមាសភាគទាំង៥ (ដោយអនុវត្តជំហានទី២ ម្តងទៀត) និងការកំណត់គោលដៅសម្រាប់ឆ្នាំបន្ទាប់ (ដោយអនុវត្តជំហានទី៣ ម្តងទៀត)។ |
| **ការណែនាំ** | 1. ក្រុមអនុវត្តសកម្មភាពស្នែមត្រួតពិនិត្យការរីកចម្រើននៅពាក់កណ្តាលឆ្នាំ និងកត់ត្រានៅក្នុងតារាងទី២៥<br>2. ក្រុមអនុវត្តសកម្មភាពស្នែមត្រួតពិនិត្យការរីកចម្រើនពេញមួយឆ្នាំដោយអនុវត្តឡើងវិញនូវជំហានទី២ និង៣៖<br>ក. កំណត់កម្រិតអភិវឌ្ឍន៍តាមសមាសភាគ (DDL) និង កម្រិតអភិវឌ្ឍន៍សរុប (ODL) ឡើងវិញ ដោយបំពេញឧបករណ៍សម្រាប់ជំហានទី២ និង ៣<br>ខ.កត់ត្រាកម្រិតអភិវឌ្ឍន៍សរុប (ODL) ចុងឆ្នាំ និងប្រៀបធៀបកម្រិតអភិវឌ្ឍន៍សរុប (ODL) ដើមឆ្នាំ ដោយប្រើតារាងទី២០<br>គ. ពិនិត្យវឌ្ឍនភាពទៅតាមសមាសភាគនីមួយៗដោយប្រើតារាងទី២៦ និងកំណត់ថាតើមានវឌ្ឍនភាពដែរឬទេ<br>ឃ. កំណត់គោលដៅសម្រាប់ឆ្នាំបន្ទាប់ ដោយប្រើឧបករណ៍ក្នុងជំហានទី៣ និងកំណត់ផែនការសកម្មភាពដែលត្រូវអនុវត្ត<br>3. អនុវត្តជារៀងរាល់ឆ្នាំ។ |

## ការត្រួតពិនិត្យវឌ្ឍនភាព

### ១-ការត្រួតពិនិត្យពាក់កណ្តាលឆ្នាំ

- ពាក់កណ្តាលឆ្នាំសិក្សា សមាជិកបង្គោលនៃក្រុមអនុវត្តសកម្មភាពស្នែមត្រូវកំណត់ពេលវេលាដើម្បីពិនិត្យវឌ្ឍនភាព។
- ពិចារណាលើសមាសភាគដែលសាលារៀនរបស់លោក លោកស្រីផ្តោត។ ពិនិត្យមើលសកម្មភាពដែលបានដាក់ចេញដូចបានកំណត់នៅក្នុងជំហានទី៤ និងផែនការសកម្មភាពស្នែម។

- បញ្ជាក់វឌ្ឍនភាពរបស់សាលារៀនលោក លោកស្រីក្នុងការអនុវត្តសកម្មភាព នៅក្នុងតារាងទី២៥ ដូចជា៖ មិនបានចាប់ផ្តើម (×) បានចាប់ផ្តើម (⇒) ឬបញ្ចប់ (✓)។
- បំពេញតែជួរឈរ ឬជួរដេកសម្រាប់កម្រិត ឬសមាសភាគដែលទាក់ទងនឹងសាលារៀនរបស់លោក លោកស្រី។ សូមទុកឱ្យនៅទំនេរត្រង់ចំណុចផ្សេងទៀតដែលមិនពាក់ព័ន្ធ។ (ឧទាហរណ៍៖ ប្រសិនបើលោក លោកស្រីកំពុងធ្វើការនៅកម្រិតសាលារៀនទី១ ដល់ ២ សម្រាប់សមាសភាគណាមួយ សូមទុកចន្លោះជួរឈរសម្រាប់ កម្រិតសាលារៀនទី២ ដល់ ៣, កម្រិតសាលារៀនទី៣ ដល់ ៤, កម្រិតសាលារៀនទី៤ ដល់ ៥ ឱ្យនៅទទេ)។
- អបអរសាទរចំពោះសកម្មភាពដែលបានបញ្ចប់។ វាមិនងាយស្រួលទេក្នុងការធ្វើឱ្យមានការប្រែប្រួលកម្រិតអភិវឌ្ឍន៍។ សូមទុកពេលមួយរយៈ ដើម្បីសន្សំសមិទ្ធផលរបស់លោក លោកស្រីក្នុងនាមជាក្រុម ។
- ចំពោះសកម្មភាពដែលមិនទាន់ចាប់ផ្តើម ត្រូវកំណត់នូវបញ្ហាប្រឈមឬឧបសគ្គ។ សូមពិភាក្សានៅក្នុងក្រុមអំពីរបៀបដែលអាចយកដោះស្រាយបញ្ហាទាំងនេះ។ សូមព្រាងគំនិត គាំទ្រគ្នាទៅវិញទៅមក ប្រើឱកាសនេះដើម្បីធ្វើឱ្យការអប់រំស្ទែម នៅសាលារៀនរបស់លោក លោកស្រីមានការប្រសើរឡើង។

**តារាងទី 12៖ ការពិនិត្យមើលការរីកចម្រើនពាក់កណ្តាលឆ្នាំ**

| ល.រ | សមាសភាគ | ល.រ | សមាសភាគរង | ល.រ | *ដំណើរការ<br>មិនបានចាប់ផ្តើម× បានចាប់ផ្តើម ⇒ បញ្ចប់ ✓ | | | | |
|---|---|---|---|---|---|---|---|---|---|
| | | | | | ប្រធានបទ | កម្រិតសាលារៀនទី១ ដល់ ២ | កម្រិតសាលារៀនទី១ ដល់ ២ | កម្រិតសាលារៀនទី១ ដល់ ២ | កម្រិតសាលារៀនទី១ ដល់ ២ |
| ១ | លទ្ធផលការសិក្សារបស់សិស្ស | ១.១ | ការប្រមូលសិស្សឱ្យចូលរៀន | ១.១.១ | ការចុះឈ្មោះចូលរៀនរបស់សិស្សស្រីក្នុងបណ្តុំវិទ្យាសាស្ត្រ | | | | |
| | | | | ១.១.២ | ការចុះឈ្មោះចូលរៀនរបស់សិស្សប្រុសក្នុងបណ្តុំវិទ្យាសាស្ត្រ | | | | |
| | | ១.២ | ការរក្សាសិស្សបានគង់វង្សក្នុងសាលារៀន | ១.២.១ | ការមិនបន្តរៀនរបស់សិស្សស្រីក្នុងបណ្តុំវិទ្យាសាស្ត្រ | | | | |
| | | | | ១.២.២ | ការមិនបន្តរៀនរបស់សិស្សប្រុសក្នុង | | | | |

| | | | | | | | | | |
|---|---|---|---|---|---|---|---|---|---|
| | | | | | បណ្ដុំវិទ្យាសាស្ត្រ | | | | |
| | | ១.៣ | លទ្ធផលការសិក្សា | ១.៣.១ | លទ្ធផលសិក្សារបស់សិស្សស្រីក្នុងបណ្ដុំវិទ្យាសាស្ត្រ | | | | |
| | | | | ១.៣.២ | លទ្ធផលសិក្សារបស់សិស្សប្រុសក្នុងបណ្ដុំវិទ្យាសាស្ត្រ | | | | |
| ២ | ការបង្រៀន និងរៀន | ២.១ | ការអភិវឌ្ឍវិជ្ជាជីវៈជាប្រចាំ | ២.១.១ | លទ្ធភាពទទួលបានការអភិវឌ្ឍវិជ្ជាជីវៈជាប្រចាំ | | | | |
| | | | | ២.១.២ | ខ្លឹមសារបណ្ដុះបណ្ដាល | | | | |
| | | | | ២.១.៣ | ប្រធានបទពិសេស | | | | |
| | | | | ២.១.៤ | គុណភាព | | | | |
| | | | | ២.១.៥ | ការឆ្លើយតបនឹងយេនឌ័រ | | | | |
| | | ២.២ | បំណិនឌីជីថល | ២.២.១ | បំណិនឌីជីថលសម្រាប់គ្រូបង្រៀនស្ទែម | | | | |
| | | ២.៣ | ការពង្រឹងកម្មវិធីសិក្សា | ២.៣.១ | សម្ភារគាំទ្រ | | | | |
| | | | | ២.៣.២ | ការបញ្ចូលខ្លឹមសារកម្មវិធីសិក្សាស្ទែម | | | | |
| | | | | ២.៣.៣ | បទពិសោធន៍រៀនស្ទែមជាក់ស្ដែង | | | | |
| | | | | ២.៣.៤ | ការសម្របតាមសមត្ថភាពសិស្ស | | | | |
| | | ២.៤ | ការបញ្ចូលបច្ចេកវិទ្យា | ២.៤.១ | បច្ចេកវិទ្យានៅក្នុងថ្នាក់រៀន | | | | |
| | | | | ២.៤.២ | ធនធានឌីជីថល | | | | |
| | | | | ២.៤.៣ | បច្ចេកវិទ្យាអប់រំ | | | | |
| | | ២.៥ | ការជួយគាំទ្រសិស្ស | ២.៥.១ | ការរៀបចំសៀវភៅកិច្ចការផ្ទះ | | | | |
| | | | | ២.៥.២ | ការបំប៉នសិស្សក្រៅម៉ោងសិក្សា | | | | |
| | | ២.៦ | ការផ្សារភ្ជាប់ទៅនឹងជីវភាពរស់នៅ | ២.៦.១ | បរិបទជីវភាពរស់នៅ | | | | |
| | | | | ២.៦.២ | ការយល់ដឹងអាជីពស្ទែមក្នុង និងក្រៅថ្នាក់រៀន | | | | |
| | | ២.៧ | វង្វាយតម្លៃ | ២.៧.១ | វិធីសាស្ត្រវង្វាយតម្លៃ | | | | |
| | | | | ២.៧.២ | លក្ខណៈវិនិច្ឆ័យនៃវង្វាយតម្លៃ | | | | |

| | | | | | | | | | |
|---|---|---|---|---|---|---|---|---|---|
| | | | | ២.៧.៣ | ការឆ្លុះបញ្ចាំង និងព័ត៌មានត្រឡប់ | | | | |
| | | | | ២.៧.៤ | ការធ្វើបទបង្ហាញរបស់សិស្ស | | | | |
| | | | | ២.៧.៥ | ការវាយតម្លៃតាមអេឡិចត្រូនិក | | | | |
| | | ២.៨ | ការធ្វើអធិការកិច្ចផ្ទៃក្នុង | ២.៨.១ | ការសង្កេតថ្នាក់រៀន | | | | |
| | | | | ២.៨.២ | ការប្រឹក្សា | | | | |
| | | | | ២.៨.៣ | ការរៀបចំថ្នាក់និទស្សន៍ | | | | |
| | | ២.៩ | សហគមន៍សិក្សាវិជ្ជាជីវៈ | ២.៩.១ | សហគមន៍វិជ្ជាជីវៈ | | | | |
| | | ២.១០ | ការបង្រៀន | ២.១០.១ | ការបង្រៀនក្នុងថ្នាក់រៀន | | | | |
| | | | | ២.១០.២ | ការអនុវត្តការបង្រៀនតាមបែបទំនើប | | | | |
| | | | | ២.១០.៣ | គោលវិធីអន្តរមុខវិជ្ជា | | | | |
| | | | | ២.១០.៤ | ការប្រើប្រាស់ធនធាន | | | | |
| | | | | ២.១០.៥ | សកម្មភាពស្ទែមជាក់ស្តែង | | | | |
| | | | | ២.១០.៦ | ការឆ្លើយតបនឹងយេនឌ័រ | | | | |
| ៣ | អភិបាលកិច្ចសាលារៀន | ៣.១ | វប្បធម៌ស្ទែម | ៣.១.១ | ឥរិយាបថ និងការប្តេជ្ញាចិត្ត៖ របៀបវារៈស្ទែម | | | | |
| | | | | ៣.១.២ | ឥរិយាបថ និងការប្តេជ្ញាចិត្ត៖ ទំនាក់ទំនង | | | | |
| | | | | ៣.១.៣ | ឥរិយាបថ និងការប្តេជ្ញាចិត្ត៖ បុគ្គលិក | | | | |
| | | ៣.២ | ភាពជាអ្នកដឹកនាំសាលារៀន | ៣.២.១ | ការយល់ដឹង | | | | |
| | | | | ៣.២.២ | តួនាទី | | | | |
| | | | | ៣.២.៣ | ការគ្រប់គ្រងទីកន្លែងនៅក្នុងសាលារៀន | | | | |
| | | | | ៣.២.៤ | ការគ្រប់គ្រងពេលវេលា | | | | |
| | | | | ៣.២.៥ | បំណិនឌីជីថល និងបញ្ញាសិប្បនិម្មិត | | | | |
| | | | | ៣.២.៦ | ការយល់ដឹងយេនឌ័រ | | | | |
| | | ៣.៣ | ការរៀបចំផែនការអភិវឌ្ឍសាលារៀន | ៣.៣.១ | ការរៀបចំផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍សាលា | | | | |

| | | | | | | | | | |
|---|---|---|---|---|---|---|---|---|---|
| | | ៣.៤ | រចនាសម្ព័ន្ធគាំទ្រ | ៣.៤.១ | ក្រុមគ្រូបង្រៀន/សហគមន៍សិក្សាវិជ្ជាជីវៈ | | | | |
| | | | | ៣.៤.២ | សហគមន៍សិក្សាវិជ្ជាជីវៈសម្រាប់គណៈគ្រប់គ្រង | | | | |
| | | | | ៣.៤.៣ | ការប្រឹក្សា ឬការបង្វឹក | | | | |
| | | ៣.៥ | ការគ្រប់គ្រងធនធាន | ៣.៥.១ | ការបែងចែកថវិកា | | | | |
| | | | | ៣.៥.២ | ភាពជាដៃគូជាមួយអ្នកខាងក្រៅ | | | | |
| | | | | ៣.៥.៣ | ការវិភាជថវិកា | | | | |
| | | ៣.៦ | ការគ្រប់គ្រងទិន្នន័យ | ៣.៦.១ | ការគ្រប់គ្រងទិន្នន័យ | | | | |
| | | | | ៣.៦.២ | ទិន្នន័យតាមក្រុម | | | | |
| | | ៣.៧ | ការវាយតម្លៃ | ៣.៧.១ | ការវាយតម្លៃការងារបុគ្គលិក | | | | |
| | | | | ៣.៧.២ | ការរៀបចំតេស្តស្តង់ដា | | | | |
| | | ៣.៨ | ការទទួលស្គាល់ពីថ្នាក់ជាតិ | ៣.៨.១ | ការវាយតម្លៃសាលាប្រចាំឆ្នាំ | | | | |
| ៤ | ការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធ | ៤.១ | សម្ភារបរិក្ខារ | ៤.១.១ | សម្ភាររូបវិទ្យាស្វែម | | | | |
| | | | | ៤.១.២ | សម្ភាររូបវិទ្យាបច្ចេកវិទ្យា | | | | |
| | | | | ៤.១.៣ | បណ្ណាល័យ | | | | |
| | | | | ៤.១.៤ | សុវត្ថិភាព | | | | |
| | | | | ៤.១.៥ | ការឆ្លើយតបនឹងយេនឌ័រ | | | | |
| | | ៤.២ | លទ្ធភាពប្រើប្រាស់ | ៤.២.១ | លទ្ធភាពចូលប្រើប្រាស់បន្ទប់ពិសោធន៍ ឬបន្ទប់រៀនវិទ្យាសាស្ត្រ | | | | |
| | | | | ៤.២.២ | លទ្ធភាពចូលប្រើប្រាស់បន្ទប់ ICT | | | | |
| | | | | ៤.២.៣ | លទ្ធភាពចូលប្រើប្រាស់ប្រកបដោយបរិយាបន្ន | | | | |
| | | ៤.៣ | បរិក្ខារ | ៤.៣.១ | បរិក្ខារស្វែម | | | | |
| | | | | ៤.៣.២ | សម្ភារគម្រោងស្វែម | | | | |
| | | | | ៤.៣.៣ | សម្ភារស្វែមប្រើបានតែម្តង | | | | |

| | | | | | | | | | |
|---|---|---|---|---|---|---|---|---|---|
| | | | | ៤.៣.៤ | បរិក្ខារបច្ចេកវិទ្យាអប់រំ | | | | |
| | | ៤.៤ | ការភ្ជាប់សេវាសាធារណៈ | ៤.៤.១ | អគ្គិសនី | | | | |
| | | | | ៤.៤.២ | អ៊ីនធឺណិត | | | | |
| | | | | ៤.៤.៣ | អនាម័យ ការសម្អាត និងទឹក | | | | |
| ៥ | ការចូលរួមរបស់សហគមន៍ | ៥.១ | ការចូលរួម និងគាំទ្ររបស់សហគមន៍ | ៥.១.១ | ការប្រាស្រ័យទាក់ទង | | | | |
| | | | | ៥.១.២ | ការចូលរួមគាំទ្រ | | | | |
| | | | | ៥.១.៣ | គ្រួសារ និងផ្នត់គំនិតអំពីយេនឌ័រក្នុងស្ទែម | | | | |
| | | ៥.២ | ភាពជាដៃគូយុទ្ធសាស្ត្រ | ៥.២.១ | ភាពជាដៃគូស្ទែម | | | | |
| | | | | ៥.២.២ | ការប្រាស្រ័យទាក់ទងជាមួយអ្នកពាក់ព័ន្ធស្ទែម | | | | |
| | | | | ៥.២.៣ | ភាពជាដៃគូជាមួយសាលារៀនផ្សេងៗ | | | | |
| | | ៥.៣ | សកម្មភាពស្ទែមក្រៅម៉ោងសិក្សា | ៥.៣.១ | ក្លឹបសិក្សាស្ទែមក្រៅសាលារៀន | | | | |
| | | | | ៥.៣.២ | ការតាំងពិពណ៌ស្ទែមនៅក្នុងសាលារៀន | | | | |
| | | | | ៥.៣.៣ | ព្រឹត្តិការណ៍ស្ទែម ឬការប្រកួតប្រជែងស្ទែម | | | | |

*ការតាមដានវឌ្ឍនភាព៖ កត់ត្រាវឌ្ឍនភាពនៃសកម្មភាពនៅក្នុងផែនការសកម្មភាពស្ទែម ដូចជា មិនបានចាប់ផ្តើម (×) បានចាប់ផ្តើម (⇒) ឬ បញ្ចប់ (✓)។ សូមបំពេញតែជួរឈរ ឬជួរដេកសម្រាប់កម្រិត ឬសមាសភាគដែលទាក់ទងនឹងសាលារៀនរបស់លោក លោកស្រី។ សូមទុកឱ្យនៅទំនេរត្រង់ចំណុចផ្សេងទៀតដែលមិនពាក់ព័ន្ធ។ (ឧទាហរណ៍៖ ប្រសិនបើលោកលោកស្រីកំពុងធ្វើការនៅកម្រិតសាលារៀនទី១ ដល់ ២ សម្រាប់សមាសភាគណាមួយ សូមទុកចន្លោះជួរឈរសម្រាប់កម្រិតសាលារៀនទី២ ដល់ ៣, កម្រិតសាលារៀនទី៣ ដល់ ៤, កម្រិតសាលារៀនទី៤ ដល់ ៥ ឱ្យនៅទទេ)។

## ២-ការត្រួតពិនិត្យវឌ្ឍនភាពនៅចុងឆ្នាំ

### ក. នៅចុងឆ្នាំ ប្រធានក្រុមអនុវត្តសកម្មភាពស្ទែមកំណត់ពេលវេលារៀបចំកិច្ចប្រជុំប្រចាំឆ្នាំ សម្រាប់សមាជិកបង្គោលទាំងអស់៖

ក. មុនកិច្ចប្រជុំ ប្រធានក្រុមអនុវត្តសកម្មភាពស្ទែមចាត់តាំងសមាជិកបង្គោលនីមួយៗឱ្យវាយតម្លៃសមាសភាគស្ទែមនីមួយៗ ។

ខ. សមាជិកបង្គោលអនុវត្តជំហានទី២ ម្តងទៀត ដើម្បីឆ្លុះបញ្ចាំងអំពីវឌ្ឍនភាពក្នុងការអនុវត្តស្ទែមនៅក្នុងសាលារៀនរបស់ពួកគាត់ ចំពោះសមាសភាគដែលចាត់ឱ្យពួកគាត់ទទួលខុសត្រូវ ព្រមទាំងធ្វើបច្ចុប្បន្នកម្មកម្រិតអភិវឌ្ឍតាមសមាសភាគ (DDLs) ។

គ. ក្នុងអំឡុងពេលកិច្ចប្រជុំ សមាជិកបង្គោលរាយការណ៍កម្រិតអភិវឌ្ឍតាមសមាសភាគ (DDLs) ដែលបានធ្វើបច្ចុប្បន្នកម្ម។ ក្រុមការងារពិនិត្យពីវឌ្ឍនភាព ដោយធ្វើការប្រៀបធៀបកម្រិតអភិវឌ្ឍតាមសមាសភាគ (DDLs) នៅដើមឆ្នាំ និងចុងឆ្នាំនេះ ព្រមទាំងកំណត់កម្រិតអភិវឌ្ឍន៍សរុប (ODL) ឡើងវិញ (គណនាមធ្យម ) ដោយប្រើតារាងទី21។

ឃ. កំណត់គោលដៅសម្រាប់ឆ្នាំថ្មីដោយប្រើជំហានទី៣ និងកំណត់សកម្មភាពដែលត្រូវអនុវត្ត។ ការអនុវត្តបែបនេះបង្កើតជាវដ្តប្រចាំឆ្នាំ។

ង. ចំណាំ៖ ក្រុមអនុវត្តសកម្មភាពស្ទែមអាចជ្រើសរើស ដោយបញ្ចូលគណៈគ្រប់គ្រងសាលារៀន ឬសមាជិកគាំទ្រនៅក្នុងការត្រួតពិនិត្យវឌ្ឍនភាពនៅចុងឆ្នាំ ។

**តារាងទី 13៖ ការប្រៀបធៀបកម្រិតអភិវឌ្ឍន៍តាមសមាសភាពស្ទែមនៅដើមឆ្នាំ និងចុងឆ្នាំ**

| ល.រ | សមាសភាគ | សមាសភាគត្រូវផ្តោត * | តម្លៃ DDL នៅដើមឆ្នាំ | តម្លៃ DDL នៅចុងឆ្នាំ | តើសមាសភាគណាមួយមានការរីកចម្រើន ? |
|---|---|---|---|---|---|
| 1 | លទ្ធផលការសិក្សារបស់សិស្ស | ☐ | | | ☐ |
| 2 | ការបង្រៀន និងរៀន | ☐ | | | ☐ |
| 3 | អភិបាលកិច្ចសាលារៀន | ☐ | | | ☐ |
| 4 | ការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធ | ☐ | | | ☐ |
| 5 | ការចូលរួមរបស់សហគមន៍ | ☐ | | | ☐ |
| | | សរុប | | | |
| | | **តម្លៃ ODL** (តម្លៃមធ្យម=តម្លៃសរុប/5) | | | |

* ជួរឈរនេះបង្ហាញថាសមាសភាគស្ទែមណាមួយត្រូវបានផ្តោតលើ ប៉ុន្តែសមាសភាគទាំង៥ គួរតែត្រូវបានកត់ត្រាតម្លៃ DDL នៅដើមឆ្នាំ និងចុងឆ្នាំ។

## ខ. តើការរីកចម្រើនអាចសម្រេចបានឬទេ?

គោលបំណងសម្រាប់សាលារៀនដែលចូលរួមក្នុងកម្មវិធីអនុវត្តក្របខណ្ឌអប់រំស្តែមកម្រិតសាលារៀន គឺដើម្បីសម្រេចបាននូវការរីកចម្រើន។ យោងតាមលទ្ធផលដែលបានសង្ខេបនៅក្នុងតារាងខាងលើ តើលោក លោកស្រីបានសម្រេចគោលដៅដែលបានជ្រើសរើសពីមុន ដែរឬទេ (បានជ្រើសរើសនៅដើមឆ្នាំក្នុងជំហានទី៣)?

**តារាងទី 14៖ ការត្រួតពិនិត្យវឌ្ឍនភាព**

| រំឭកពីគោលដៅរបស់យើងបានកំណត់ឆ្នាំមុន៖ (ជ្រើសរើសយកជម្រើសមួយ) | | សមាសភាគស្តែម ដែលត្រូវពង្រឹង | លទ្ធផល | បើមិនសម្រេច តើសាលារៀនរបស់លោក លោកស្រីសម្រេចបានអ្វីខ្លះ? * |
|---|---|---|---|---|
| ☐ | **ជម្រើសទី១៖** សម្រេចបានលទ្ធផលប្រហាក់ប្រហែលគ្នានៅក្នុងចំណោមសមាសភាគទាំង៥ ដោយព្យាយាមពង្រឹងលើ សមាសភាគដែលខ្សោយ។ (ជ្រើសរើសសមាសភាគស្តែមដែលបានកំណត់ថាខ្សោយនៅក្នុងតារាងទី២៦) | ☐ លទ្ធផលការសិក្សារបស់សិស្ស<br>☐ ការបង្រៀន និងរៀន<br>☐ អភិបាលកិច្ចសាលារៀន<br>☐ ការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធ<br>☐ ការចូលរួមរបស់សហគមន៍ | តើសម្រេចគោលដៅដែរឬទេ?<br>☐ សម្រេច<br>☐ មិនសម្រេច | |
| ឬ | | | | |
| ☐ | **ជម្រើសទី២៖** សម្រេចបានកម្រិតបន្ទាប់ នៃកម្រិតអភិវឌ្ឍនៅក្នុងសមាសភាគចំនួន៣ | ☐ លទ្ធផលការសិក្សារបស់សិស្ស<br>☐ ការបង្រៀន និងរៀន<br>☐ អភិបាលកិច្ចសាលារៀន<br>☐ ការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធ<br>☐ ការចូលរួមរបស់សហគមន៍ | តើសម្រេចគោលដៅដែរឬទេ?<br>☐ សម្រេច<br>☐ មិនសម្រេច | |

* អាចប្រើតារាងមួយផ្សេងទៀតបាន។

## គ. ការតាមដានវឌ្ឍនភាពជាប្រចាំ

សូមប្រើតារាងទី២៨ ដើម្បីតាមដានវឌ្ឍនភាពរបស់លោក លោកស្រី តាមរយៈកត់ត្រាម្លៃកម្រិតអភិវឌ្ឍន៍សរុប (ODL) ឆ្នាំនីមួយៗ។

**តារាងទី 15៖ វឌ្ឍនភាពផ្អែកលើតម្លៃកម្រិតអភិវឌ្ឍន៍សរុប (ODL) ដែលបានវាយតម្លៃជាច្រើនដង**

| ពេលវេលា | កម្រិតអភិវឌ្ឍន៍សរុប (ODL) |
|---|---|
| ពេលដើម = 0 | |
| ចុងឆ្នាំទី១ | |
| ចុងឆ្នាំទី២ | |
| ចុងឆ្នាំទី៣ | |
| ចុងឆ្នាំទី៤ | |

# ឧបសម្ព័ន្ធ ខៈ សទ្ទានុក្រមរបស់ក្របខណ្ឌអប់រំស្ទែមកម្រិតសាលារៀន

| | |
|---|---|
| **ការវាយតម្លៃជាក់ស្តែង** (Authentic assessments) | ការវាយតម្លៃដែលពិនិត្យដានសមត្ថភាពសិស្សក្នុងការប្រើប្រាស់និងអនុវត្តចំណេះដឹង/បំណិននៅក្នុងស្ថានភាពជាក់ស្តែង។ ឧទាហរណ៍នៃការវាយតម្លៃជាក់ស្តែងរួមមាន៖ គម្រោង កម្រងស្នាដៃសិស្ស បទបង្ហាញផ្ទាល់មាត់ និងកាលិកបត្រ ។ល។ |
| **បទពិសោធន៍សិក្សាស្ទែមជាក់ស្តែង** (Authentic STEM learning experiences) | សកម្មភាពឬគម្រោងដែលឱ្យសិស្សចូលរួមក្នុងជីវភាពជាក់ស្តែង អនុវត្តជាក់ស្តែងលើបញ្ញត្តិស្ទែម។ ឧទាហរណ៍៖ការសិក្សាបែបគម្រោង ឬការសិក្សាផ្អែកលើបញ្ហា ការគ្រោងប្លង់និងការកសាងគំរូដើមសហការជាមួយអ្នកដទៃ គម្រោងសហគមន៍ឱកាសជួបជាមួយអ្នកជំនាញនិងឧស្សាហកម្មស្ទែម។ |
| **វិទ្យាសាស្ត្រពលរដ្ឋ** (Citizen Science) | **វិទ្យាសាស្ត្រពលរដ្ឋ**គឺជាអ្នកពាក់ព័ន្ធចូលរួមជាសាធារណៈនិងការសហការក្នុងការស្រាវជ្រាវផ្នែកវិទ្យាសាស្ត្រ ទោះបុគ្គលនោះមិនបានទទួលការបណ្តុះបណ្តាលពីវិទ្យាសាស្ត្រជាផ្លូវការក៏អនុញ្ញាតឱ្យចូលរួមប្រមូល វិភាគ និងការផ្សព្វផ្សាយទិន្នន័យបានដែរ។ គោលវិធីនេះប្រើប្រាស់អានុភាពទិន្នន័យពីក្រុមមនុស្សផ្សេងៗគ្នាដែលជាហេតុធ្វើឱ្យទិន្នន័យមានទ្រង់ទ្រាយធំពេញលេញហើយបង្កើនការចូលរួមជាសាធារណៈក្នុងការស្រាវជ្រាវវិទ្យាសាស្ត្រ ដើម្បីឆ្លើយទៅនឹងសំណួរវិទ្យាសាស្ត្រលំបាកៗ។ |
| **គ្រូបង្វឹក** (Coach) | • គ្រូបង្រៀនស្ទែមមានបទពិសោធន៍ជួយកំណត់បានពីតម្រូវការរយៈពេលខ្លី/មធ្យមនិងគម្លាតចំណេះដឹងនិងជំនាញ ជួយអភិវឌ្ឍផែនការសកម្មភាពនិងពង្រឹងជំនាញស្ទែម សម្រាប់គ្រូបង្រៀនមានបទពិសោធន៍តិចតួច។<br>• ការបង្វឹកអាចរួមបញ្ចូលទាំងការសង្កេតថ្នាក់រៀន ការផ្តល់ការណែនាំ ការសហការគ្នាបង្រៀន កិច្ចប្រជុំទៀងទាត់ ការចែករំលែកធនធាន ។ល។<br>• គ្រូបង្វឹកគឺខុសពីគ្រូប្រឹក្សា។ ជាទូទៅ គ្រូប្រឹក្សាគាំទ្រការអភិវឌ្ឍអាជីពរបស់គ្រូបង្រៀនរយៈពេលវែង ហើយមិនសូវផ្តោតលើការគាំទ្រតម្រូវការបច្ចេកទេសនិងគរុកោសល្យរយៈពេលខ្លីទេ។ |
| **គម្រោងសហគមន៍** (Community Project) | ជាគម្រោងសហការដែលប្រើប្រាស់ចំណេះដឹងនិងបំណិនស្ទែមដើម្បីដោះស្រាយបញ្ហាឬតម្រូវការតាមមូលដ្ឋាន។គម្រោងនេះជាទូទៅឱ្យសិស្សចូលរួមអនុវត្តនូវអ្វីដែលបានរៀនសូត្រពីមុខវិជ្ជាស្ទែមដើម្បីដោះ |

| | |
|---|---|
| | ស្រាយបញ្ហា ធ្វើនវានុវត្តដំណោះស្រាយឬធ្វើឱ្យលក្ខខណ្ឌកាន់តែប្រសើរឡើងនៅតាមសហគមន៍។ តាមរយៈគម្រោងនេះ ឱ្យសិស្សចូលរួមជាមួយសមាជិកសហគមន៍ អង្គការឬឧស្សាហកម្មតាមមូលដ្ឋានដើម្បីបណ្តុះស្មារតីទទួលខុសត្រូវនិងបទពិសោធន៍ជាក់ស្តែងនៅខណៈបង្កើនការយល់ដឹងនិងការអនុវត្តបញ្ញត្តិស្ទែម។ |
| **រង្វាយតម្លៃផ្អែកលើសមត្ថភាព** (Competency-based assessment) | វិធីវាយតម្លៃដោយផ្តោតទៅភាពម្ចាស់ការបាននៃសមត្ថភាពឬបំណិនជាក់លាក់។ឧទាហរណ៍៖ ការវាយតម្លៃជាក់ស្តែង ការវាយតម្លៃលើកម្រងស្នាដៃ ការសង្កេត គម្រោង និងការវាយតម្លៃផ្អែកនិទ្ទេសបទ។ |
| **សម្ភារស្ទែមប្រើបានតែម្តង** (Consumables) | សម្ភារស្ទែមប្រើបានតែម្តងគឺជាសម្ភារ ឬបរិក្ខារដែលប្រាស់ប្រាស់បានតែម្តង។ នៅពេលវាអស់ ឬប្រើរួចហើយត្រូវបញ្ចូល ឬជំនួសមកវិញ។ ឧទាហរណ៍ ប្លាស្ទិក បំពង់ សារធាតុគីមី ស្រោមដៃ និងក្រដាស pH ។ល។ |
| **ការអភិវឌ្ឍវិជ្ជាជីវៈជាប្រចាំ** (Continuous professional development (CPD)) | នៅក្នុងបរិបទនៃក្របខណ្ឌរបស់ការអភិវឌ្ឍវិជ្ជាជីវៈជាប្រចាំ សំដៅលើការបណ្តុះបណ្តាលដែលរៀបចំឡើងដោយស្ថានប័នផ្តល់សេវាពីខាងក្រៅអង្គភាពរបស់ខ្លួន ឧ. ក្រសួងអ.យ.ក, វិទ្យាស្ថានជាតិអប់រំ, អង្គការ VSO ។ល។ (មានន័យថាមិនមែនអង្គភាពខ្លួនផ្ទាល់ជាអ្នករៀបចំវគ្គបណ្តុះបណ្តាលឬវគ្គបំប៉ន) |
| **បញ្ជីឈ្មោះជាឌីជីថល** (Digital catalog) | បញ្ជីឈ្មោះនៃធនធានទាំងអស់ដែលអាចប្រើប្រាស់សម្រាប់ស្រាវជ្រាវបាននៅក្នុងបណ្ណាល័យតាមប្រធានបទ/ចំណងជើង/អ្នកនិពន្ធ |
| **ធនធានឌីជីថល** (Digital resources) | ធនធានអនឡាញ ឧទាហរណ៍៖ អត្ថបទ រូបភាព វីដេអូ លំនាំគំរូត្រាប់តាម(simulations) និងសកម្មភាពអន្តរកម្ម |
| **ការវាយតម្លៃតាមអេឡិចត្រូនិក** (E-assessment) | ការវាយតម្លៃដែលត្រូវបានបង្កើត សរសេរ ចែកចាយ និងកែដោយបច្ចេកវិទ្យា ជាធម្មតាជាថ្នាលឯកទេសវាយតម្លៃ។ ឧទាហរណ៍៖ លំហាត់ ឬការស្ទង់មតិតាមអនឡាញ រង្វាយតម្លៃដែលអាចកែសម្រួល ឧបករណ៍វាយតម្លៃកម្រងស្នាដៃសិស្ស។ល។ |
| **បរិក្ខារបច្ចេកវិទ្យាអប់រំ** (EdTech Equipment) | សំដៅលើកុំព្យូទ័រ ឧបករណ៍តូចៗអាចកាន់ដៃបាន កញ្ចប់គ្រឿងផ្គុំ ម៉ាស៊ីនបោះពុម្ព3D ជាដើម ដែលប្រើសម្រាប់គោលបំណងអប់រំ។ |

| | |
|---|---|
| **ឧបករណ៍បច្ចេកវិទ្យាអប់រំ** (EdTech Tools) | ឧបករណ៍ឌីជីថល(ផ្នែករឹង ផ្នែនទន់ ឬថ្នាល) ធ្វើឱ្យប្រសើរឡើង ឬតាមដានការបង្រៀននិងរៀន ឧទាហរណ៍៖ Moodle, Google Classroom, Scratch, ថ្នាលបង្កើតល្បែងសិក្សា (gamification platforms) បន្ទះបណ្ដុំគ្រឿងអេឡិចត្រូនិក (Arduino) និង កញ្ចប់គ្រឿងផ្គុំ (Maker Kits) ជាដើម។ |
| **សកម្មភាពស្ទែមក្រៅកម្មវិធីសិក្សា** (Extracurricular STEM activities) | សកម្មភាពស្ទែមក្រៅកម្មវិធីសិក្សាគឺជាសកម្មភាពទាក់ទងទៅនឹងស្ទែមដែលកើតមាននៅកន្លែងណាមួយខុសពីថ្ងៃសិក្សាធម្មតា ហើយពង្រឹងការបង្រៀន និងរៀនមុខវិជ្ជាស្ទែម។ ឧទាហរណ៍៖ ក្លឹបសិក្សារៀនបន្ទាប់ពីម៉ោងរៀននៅសាលា កម្មវិធីបរវេសនកាល ការតាំងពិព័រណ៍ស្ទែម ការប្រឡងប្រណាំងស្ទែម ការពិភាក្សាអាជីពការងារស្ទែម ។ល។ ក្លឹបសិក្សានៅក្រៅម៉ោងសិស្សាដែលបានបញ្ចូលការប្រៀនបែបឧទ្ទេសអំពីទ្រឹស្ដីស្ទែមគឺមិនចាត់ទុកថាជាសកម្មភាពស្ទែមក្រៅកម្មវិធីសិក្សាទេនៅក្នុងបរិបទនេះ។ |
| **សកម្មភាអនុវត្តជាក់ស្តែង** (Hands-on activities) | សកម្មភាពដែលឱ្យសិស្សចូលរួមដោយប្រើដៃរបស់ពួកគេផ្ទាល់ ជាធម្មតាធ្វើការជាក្រុមនិងមានចលនានៅក្នុងថ្នាក់ អាចប្រើប្រាស់វត្ថុមកសម្ដែងជាចលនា(props)/ឧបករណ៍/ក្រដាស/ក្រដាសរឹង ធ្វើពិសោធន៍ដោយប្រើបរិក្ខារបន្ទប់ពិសោធន៍ ការធ្វើសកម្មភាពប្រើប្រាស់របស់របរផ្សេងៗពីធម្មជាតិឬពីផ្សារនៅក្នុងតំបន់។ល។ |
| **បច្ចេកវិទ្យា ព័ត៌មានវិទ្យា និងសារគមនាគមន៍** (ICT) | ឧបករណ៍អេឡិចត្រូនិក ឧបករណ៍តម្លើងបណ្ដាញ កម្មវិធីនិងប្រព័ន្ធដែលតភ្ជាប់គ្នា ដែលអាចឱ្យសិស្សនិងសាលារៀនធ្វើអន្តរកម្មក្នុងពិភពឌីជីថល។ |
| **បន្ទប់** ICT (ICT Lab) | បន្ទប់ ឬកន្លែងដែលបំពាក់នូវកុំព្យូទ័រ កម្មវិធី និងបណ្ដាញសម្រាប់គោលបំណងអប់រំ។ បន្ទប់នេះផ្ដល់ឱ្យសិស្សប្រើប្រាស់បច្ចេកវិទ្យានិងឧបករណ៍សម្រាប់រៀននិងអនុវត្តបំណិនឌីជីថល។ |
| **បច្ចេកវិទ្យានវានុវត្តន៍** (Innovative technologies) | សំដៅលើម៉ាស៊ីនបោះពុម្ព3D កញ្ចប់គ្រឿងបង្គុំតូចៗ ការសរសេរកូដ ជាដើម។ |
| **អ៊ីនត្រាណិត** (Intranet) | បណ្ដាញឯកជនដែលអនុញ្ញាតឱ្យសិស្សនិងបុគ្គលិកចែករំលែកធនធាន សហការ និងទំនាក់ទំនងជាមួយសាលារៀន។ វាអាចផ្ដល់ប្រយោជន៍ដល់សាលារៀនដោយផ្ដល់នូវការប្រើសប្រាស់សម្ភារអប់រំ ជួយឱ្យសហការគ្នាលើគម្រោងនិងគាំទ្រមុខងាររដ្ឋបាលទាំងអស់ ដោយមិនចាំបាច់មានការតភ្ជាប់អ៊ីនធឺណិតឡើយ ។ ដើម្បីរៀបចំតម្លើងប្រព័ន្ធអ៊ីនត្រាណិតគួរត្រូវមានឧបករណ៍ដូចខាងក្រោម៖<br>• ម៉ាស៊ីនមេ (Server)៖ ប្រព័ន្ធកុំព្យូទ័រដើម្បីរៀបចំមាតិកានិងកម្មវិធីអ៊ីនត្រាណិត។<br>• ដុំតបំបែក(Network Switch)៖ សម្រាប់តភ្ជាប់ឧបករណ៍(កុំព្យូទ័រ)ច្រើនបង្កើតជាបណ្ដាញ។<br>• ដុំតភ្ជាប់សេវា(Router)៖ សម្រាប់គ្រប់គ្រងនិងដឹកនាំចរាចរណ៍ទិន្នន័យក្នុងបណ្ដាញផ្ទាល់។ |

| | |
|---|---|
| | • ខ្សែតអ៊ីនធើណិតមានក្បាលតំណ(Ethernet Cables)៖ សម្រាប់តភ្ជាប់ជាមួយឧបករណ៍ (ឬដុំឧបករណ៍)។<br>•ដុំតភ្ជាប់បណ្តាញមិនប្រើខ្សែ(Wireless Access Points)៖ សម្រាប់តភ្ជាប់ទៅនឹងឧបករណ៍ដោយមិនប្រើខ្សែ។<br>• កុំព្យូទ័រ/ឧបករណ៍៖ សម្រាប់សិស្សនិងបុគ្គលិកប្រើប្រាស់ជាអ៊ីនត្រាណិត។<br>•ដុំផ្ទុកទិន្នន័យណិតវើក(Network Storage)៖ សម្រាប់រក្សាទុកនិងគ្រប់គ្រងឯកសារនិងធនធានដែលបានចែករំលែក។<br>•ដុំរក្សាសុវត្ថិភាពបណ្តាញ(Firewall)៖ សម្រាប់រក្សាសុវត្ថិភាពនិងការការពារបណ្តាញ។ |
| **ការរៀនតាមបែបរិះរក**<br>(Inquiry-based learning) | គោលវិធីអប់រំដែលផ្តោតលើ ការសួរសំណួរ ការរិះរក និងការសង្កេត។ គោលវិធីនេះធ្វើឱ្យសិស្សចូលរួមយ៉ាងសកម្មក្នុងដំណើរការសិក្សាដោយចោទជាសំណួរ ធ្វើការស្រាវជ្រាវ និងដោះស្រាយបញ្ហាជាជាងទទួលបានព័ត៌មានតាមបែបអកម្ម។ វិធីនេះជំរុញឱ្យមាន ការគិតបានល្អិតល្អន់ ការគិតច្នៃបង្កើត និងការយល់ដឹងបានស៊ីជម្រៅពីខ្លឹមសារមុខវិជ្ជា។ |
| **ការបញ្ចូលខ្លឹមសារនៃមុខវិជ្ជាស្ទែម** (Integration of STEM subject content) | សំដៅទៅលើការបញ្ចូលមុខវិជ្ជាស្ទែម ដោយមានគោលបំណងនិងផែនការជាក់លាក់ ហើយខុសពីភាពត្រួតស៊ីគ្នាកើតមានឡើងក្នុងពេលបង្រៀននិងរៀនមុខវិជ្ជាទាំងនេះតាមវិធីសាស្ត្របង្រៀនបែបបុរាណ។ |
| **អន្តរមុខវិជ្ជា**<br>(Interdisciplinary) | គោលវិធីបង្រៀនមានបញ្ចូលសកម្មភាពដែលរួមបញ្ចូលចាប់ពីពីរបណ្តុំមុខវិជ្ជា ឬមុខវិជ្ជាស្ទែមនៅក្នុងបទពិសោធន៍សិក្សាដោយរលូន។ ប្រភេទសកម្មភាពដែលអាចជាអន្តរមុខវិជ្ជា៖ ការសិក្សាផ្តោតលើគម្រោងឬការសិក្សាផ្តោតលើបញ្ហា។<br>ប្រសិនបើសាលាចាប់ផ្តើមឈ្វេងយល់ការបង្រៀនអន្តរមុខវិជ្ជា និងចាប់ផ្តើមដោយបញ្ចូលខ្លឹមសារនៃមុខវិជ្ជាទាំងពីរក្នុងពេលជាមួយគ្នា។ យើងអាចចាត់ជាក្រុម៦មុខវិជ្ជាស្ទែមផ្អែកលើភាពត្រួតស៊ីគ្នាហើយ និងមុខជ្ជាដែលមានខ្លឹមសារបំពេញគ្នាទៅវិញទៅមក។ ខាងក្រោមនេះគឺមុខវិជ្ជាបានស្នើឡើងសម្រាប់ជាគូនឹងគ្នា៖<br>• គណិតវិទ្យា និងរូបវិទ្យា៖ មុខវិជ្ជាទាំងពីរនេះមានទំនាក់ទំនង ព្រោះរូបវិទ្យាពឹងផ្អែកយ៉ាងខ្លាំងទៅលើគោលការណ៍គណិតវិទ្យា និងទិចនិកដើម្បីពន្យល់បាតុភូតរូបវិទ្យា។ |

| | |
|---|---|
| | • គីមីវិទ្យា និងជីវៈវិទ្យា៖ មុខវិជ្ជាទាំងពីរនេះត្រួតស៊ីគ្នាវាងដូចជា គីមីជីវៈ ជីវម៉ូលេគុល និងការសិក្សាពីបាតុភូតគីមីនៅក្នុងសារពាង្គកាយភាវរស់មានជីវិត។<br>• បរិស្ថានវិទ្យា និងជីវវិទ្យា៖ មុខវិជ្ជាទាំងពីរនេះអាចបញ្ចូលគ្នាប្រកបដោយប្រសិទ្ធភាពក្នុងការសិក្សាពីប្រព័ន្ធអេកូឡូស៊ី ជីវៈចម្រុះ និងផលជះនៃសកម្មភាពរបស់មនុស្សនៅលើបរិស្ថាន។<br>• ICT និងគណិតវិទ្យា៖ បច្ចេកវិទ្យា ព័ត៌មានវិទ្យា និងសារគមនាគមន៍ (ICT) តែងតែប្រើបញ្ញត្តិគណិវិទ្យាសម្រាប់សរសេរកម្មវិធី វិភាគទិន្នន័យ និងរៀបចំក្បួនគណនា។<br>• រូបវិទ្យា និងបរិស្ថានវិទ្យា៖ មុខវិជ្ជាទាំងពីរនេះអាចបញ្ចូលគ្នាជាប្រធានបទសិក្សាដូចជា ថាមពល ការផ្លាស់ប្តូរអាកាសធាតុ និងគោលការណ៍រូបវិទ្យាដើម្បីរំលេចឱ្យឃើញលំនាំបរិស្ថាន។<br>• គីមីវិទ្យា និងបរិស្ថានវិទ្យា៖ មុខវិជ្ជាទាំងនេះអាចបញ្ចូលគ្នាដើម្បីសិក្សាពីលំនាំគីមីនៅក្នុងបរិស្ថាន ការបំពុលបរិស្ថាន និងផលជះនៃជាតុគីមីទៅក្នុងប្រព័ន្ធអេកូឡូស៊ី។<br>ដោយការចាប់ផ្តើមផ្គូរមុខវិជ្ជាខាងលើ យើងអាចបង្កើតមេរៀនជាអន្តរមុខវិជ្ជាដែលមានភាពទាក់ទងគ្នាពីមុខវិជ្ជាមួយទៅមុខវិជ្ជាមួយទៀតដែលធ្វើឱ្យលំនាំបញ្ចូលកាន់តែរលូន និងមានប្រសិទ្ធភាព។ |
| **គោលវិធីសិស្សមជ្ឈមណ្ឌល** (Learner-centered approach) | គោលវិធីសិស្សមជ្ឈមណ្ឌលមានទស្សនៈថាការសិក្សាជាលំនាំមួយមានលក្ខណៈបន្តបន្ទាប់ និងសហការចូលរួមពីគ្រូបង្រៀននិងសិស្ស។ គោលវិធីនេះផ្តោតលើការទទួលខុសត្រូវរួមគ្នា គ្រូដើរតួជាអ្នកសម្របសម្រួលឬណែនាំជាជាងជាអ្នកគ្រាន់តែផ្ទេរចំណេះដឹង ជាពិសេសគោលវិធីនេះពាក់ព័ន្ធទៅនឹងការរៀនដោយសកម្ម ការរុករក និងសិស្សមានស្វ័យភាពម្ចាស់ការ។ |
| **បរិក្ខារស្ទែមរោងជាង** (Makerspace equipment) | សំដៅបរិក្ខារដែលមានលក្ខណៈបច្ចេកវិទ្យាខ្ពស់ជាងសម្ភារមូលដ្ឋានគម្រោងស្ទែម ឧទាហរណ៍៖ ម៉ាស៊ីនបោះពុម្ព3-D កញ្ចប់គ្រឿងផ្គុំបន្ទះអេឡិចត្រូនិក កញ្ចប់គ្រឿងក្បាលផ្សារសំណ។ល។ |
| **គ្រូប្រឹក្សា** (Mentor) | អ្នកណែនាំរយៈពេលវែង (ប្រៀបធៀបទៅនឹងគ្រូបង្វឹក) សម្រាប់វឌ្ឍនភាពអាជីព ឧទាហរណ៍៖ អ្នកដែលបានបណ្តុះបណ្តាលនៅមជ្ឈមណ្ឌលស្រាវជ្រាវគរុកោសល្យជំនាន់ថ្មី (NGPRC)។ |
| **គោលវិធីបង្រៀនបែបទំនើប/ការបង្រៀនបែបទំនើប** | ឧទាហរណ៍នៃគោលវិធីបង្រៀនទំនើប៖ គោលវិធីបង្រៀនតាមបែបរិះរក អន្តរមុខវិជ្ជា។ ការបង្រៀនតាមបែបទំនើបបញ្ចូលការសិក្សាផ្តោតលើគម្រោង ការសិក្សាផ្តោតលើបញ្ហា សកម្មភាពអនុវត្តជាក់ស្តែង ការងារក្រុម |

| | |
|---|---|
| (Modern teaching approaches/practices) | ការរៀនតាមបែបសហការ ថ្នាក់រៀនចម្រុះទីកន្លែង(flipped classroom)និងល្បែងសិក្សា (gamification)។ |
| **ការសិក្សាស្ទែមនៅទីតាំងក្រៅសាលារៀន** (Off-site STEM learning) | សំដៅលើសកម្មភាពសិក្សាស្ទែមនៅក្រៅបរិវេណសាលារៀន។ ឧទាហរណ៍រួមមាន៖ ទស្សនកិច្ចពិព័រណ៍ស្ទែមថ្នាក់ជាតិ អាជីវកម្ម/ឧស្សាហកម្មស្ទែមនៅក្នុងតំបន់ ព្រឹត្តិការណ៍ការងារ ទស្សនកិច្ចសិក្សាគ្រឹះស្ថានឧត្តមសិក្សា និងមជ្ឈមណ្ឌលវិទ្យាសាស្ត្រ និងបច្ចេកវិទ្យា (CSTC)។ |
| **ការសិក្សាតាមលក្ខណៈបុគ្គល (ភាពខុសគ្នា)** (Personalized learning (Differentiation)) | ដាក់បញ្ចូលខ្លឹមសារផ្សេងៗគ្នាស្របតាមតម្រូវការសិស្សទាំងអស់ ដូចជារបៀបរៀនសូត្រ សមត្ថភាព និងចំណូលចិត្តរបស់សិស្ស។ គ្រូបង្រៀនអាចកែតម្រូវវិធីសាស្ត្របង្រៀន សម្ភារ និងធនធានដើម្បីសផ្តល់ឱ្យស្របទៅតាមភាពខុសៗគ្នារបស់សិស្ស ជាឧទាហរណ៍៖ ការផ្តល់នូវអត្ថបទផ្សេងៗ ការដាក់កិច្ចខុសៗគ្នា ឬការលៃតម្រូវទៅតាមល្បឿនឬភាពលំបាកនៃការបង្រៀន។ |
| **សហគមន៍សិក្សាវិជ្ជាជីវៈ** (Professional Learning Community-PLC) | សហគមន៍សិក្សាវិជ្ជាជីវៈជាក្រុមអ្នកអប់រំដែលសហការគ្នាដើម្បីកែលម្អការអនុវត្តការបង្រៀននិងការសិក្សារបស់សិស្ស។ សហគមន៍សិក្សាវិជ្ជាជីវៈចែករំលែកបទពិសោធន៍ យុទ្ធសាស្ត្រនិងទិន្នន័យ ចូលរួមពិភាក្សាឆ្លុះបញ្ចាំងនិងគាំទ្រវឌ្ឍនភាពវិជ្ជាជីវៈគ្នាទៅវិញទៅមក។ គោលបំណងរបស់សហគមន៍សិក្សាវិជ្ជាជីវៈគឺដើម្បីពង្រឹងវប្បធម៌កែលម្អជាប្រចាំ ទទួលខុសត្រូវរួម និងគាំទ្រគ្នាទៅវិញទៅមកក្នុងកាធ្វើឱ្យប្រសើរឡើងនូវលទ្ធផលអប់រំសម្រាប់សិស្សទាំងអស់គ្នា។ |
| **សម្ភារសុវត្ថិភាព** (Safety features) | រួមមានស្លាកសញ្ញាសុវត្ថិភាព ភួយពន្លត់ភ្លើង កន្លែងខ្យល់ចេញចូល ទូបឺតផ្សែង/ឧស្ម័ន ឧបករណ៍លាងខ្លួនប្រាណ កន្លែងលុបមុខ កញ្ចប់សង្គ្រោះបឋម ទូដាក់សារធាតុគីមី។ |
| **បន្ទប់រៀនវិទ្យាសាស្ត្រ** (Science Classroom) | បន្ទប់រៀនដែលរៀបចំឡើងមានគោលបំណងដាក់លាក់ប្រើសម្រាប់ទាំងការបង្រៀនទ្រឹស្តីទូទៅនិងសកម្មភាពអនុវត្តស្ទែម ឧទាហរណ៍៖ បន្ទប់រៀនវិទ្យាសាស្ត្រនៅសាលារៀនជំនាន់ថ្មី។ |
| **បន្ទប់ពិសោធន៍វិទ្យាសាស្ត្រ/បន្ទប់ស្ទែម** (Science/STEM Laboratory) | បន្ទប់រៀនដែលរៀបចំឡើងមានលក្ខណៈពិសេសសម្រាប់សកម្មភាពឬពិសោធន៍ឬការងារអនុវត្តស្ទែម។ ជាទូទៅបន្ទប់នេះត្រូវប្រើទាំងក្នុងម៉ោងអនុវត្តជាក់ស្តែង និងម៉ោងរៀនទ្រឹស្តី។ |
| **ការច្នៃប្រឌិតវិទ្យាសាស្ត្រ** (Science Improvisation) | ការច្នៃប្រឌិតវិទ្យាសាស្ត្រគឺជាការប្រើប្រាស់មានលក្ខណៈច្នៃបង្កើតជារៀងរាល់ថ្ងៃនូវសម្ភារផ្សេងៗដើម្បីធ្វើការពិសោធន៍វិទ្យាសាស្ត្រនៅពេលគ្មានបរិក្ខារបន្ទប់ពិសោធន៍តាមស្តង់ដា។ ការច្នៃប្រឌិតនេះជំរុញឱ្យមានការ |

| | |
|---|---|
| | សិក្សាតាមបែបអនុវត្តជាក់ស្តែង ការដោះស្រាយបញ្ហា និងការច្នៃបង្កើតដោយប្រើប្រាស់ធនធានក្នុងតំបន់ ដើម្បីរុករកបញ្ញត្តិវិទ្យាសាស្ត្រ។ |
| **បន្ទប់រៀនឆ្លាតវៃ** (Smart classroom) | បន្ទប់រៀនដែលបំពាក់ដោយបរិក្ខារបច្ចេកវិទ្យាដូចជាម៉ាស៊ីនបញ្ចាំងស្លាយ អេក្រង់បញ្ចាំង កុំព្យូទ័រ UPS និងប្រព័ន្ធសម្លេង |
| **បន្ទប់រៀនធម្មតា** (Standard Classroom) | បន្ទប់រៀនដែលមានបរិក្ខារពិសេសៗសម្រាប់ការបង្រៀនស្ទែម។ បន្ទប់ប្រភេទនេះអាចបង្រៀនមុខវិជ្ជាមិនមែនស្ទែមបានផងដែរ។ |
| **ស្ទែម** (STEM) | វិទ្យាសាស្ត្រ បច្ចេកវិទ្យា វិស្វកម្ម និងគណិតវិទ្យា។ |
| **សកម្មភាពស្ទែម** (STEM activities) | សកម្មភាពធ្វើដោយដៃ ឬសកម្មភាពអនុវត្តដែលធ្វើបានប្រសើរឡើងតារយៈបច្ចេកវិទ្យាស្របទៅនឹងគោលវិធីអប់រំស្ទែមនៅមធ្យមសិក្សាទុតិយភូមិ។ |
| **វប្បធម៌ស្ទែម** (STEM culture) | សាលារៀនជំរុញឱ្យមានបរិស្ថានអំណោយផលដល់គោលវិធីស្ទែមដើម្បីលើកកម្ពស់ការអនុវត្តអន្តរមុខវិជ្ជា ការសហការបែបនវានុវត្តន៍ ការគាំទ្រការបង្រៀនបែបសិស្សមជ្ឈមណ្ឌល អក្ខរកម្មឌីជីថល និងការសិក្សាផ្តោតលើគម្រោង។ |
| **ការអប់រំស្ទែម** (STEM Education) | ការពង្រឹងការបង្រៀននិងរៀនមុខវិជ្ជាស្ទែមតាមរយៈការដាក់បញ្ចូលទ្រឹស្តីទៅក្នុងបរិបទជាក់ស្តែង ការចាប់ប្រើគោលវិធីបង្រៀនទំនើប ការជំរុញឱ្យមានវឌ្ឍនភាពជាបណ្តើរៗសំដៅទៅគោលវិធីអន្តរមុវិជ្ជា ចំណុចសំខាន់ចំពោះគោលវិធីនេះគឺសកម្មភាពបណ្តុះបណ្តាលបំណិនសតវត្សរ៍ទី២១ រួមមានសកម្មភាពផ្តោតលើគម្រោង សកម្មភាពផ្តោតលើបញ្ហា និងសកម្មភាពអនុវត្តជាក់ស្តែង ដែលធ្វើឱ្យប្រសើរឡើងតាមរយៈបច្ចេកវិទ្យា(ICT)និងដាក់បញ្ចូលគោលការណ៍សិល្បៈ ឬការរចនានៅពេលណាសមស្រប។ |
| **បរិក្ខារស្ទែម** (STEM Equipment) | បរិក្ខារត្រូវបានប្រើប្រាស់សម្រាប់ពិសោធន៍វិទ្យាសាស្ត្រ ឧ.កែវសម្រាប់ធ្វើពិសោធន៍វិទ្យាសាស្ត្រ បរិក្ខារអេឡិចត្រូនិក មីក្រូទស្សន៍ និង pH ម៉ែត្រ ។ល។ |
| **សម្ភារូបវន្តស្ទែម** (STEM Facility) | បន្ទប់ឯកទេសណាមួយ ឬកន្លែងពិសេសបំពាក់ធនធាននិងបរិក្ខាសម្រាប់ការបង្រៀននិងការរៀនមុខវិជ្ជាស្ទែមរួមមាន៖ បន្ទប់ពិសោធន៍ រោងជាង និងកន្លែងផ្សេងទៀត ដើម្បីជួយសម្រួលដល់សកម្មភាពអនុវត្តជាក់ស្តែង ការធ្វើពិសោធន៍ក្នុងមុខវិជ្ជាស្ទែម។ មិនមានបញ្ចូលក្នុងថ្នាក់រៀនធម្មតា។ |
| **គ្រូប្រឹក្សាស្ទែម** (STEM Mentor) | គ្រូប្រឹក្សាស្ទែមមានបំណិនមួយចំនួន ដូចគ្រូប្រឹក្សាធម្មតាដែរ ដូចជាចំណេះដឹងគរុកោសល្យស្ទែម បំណិនបច្ចេកទេសស្ទែម ល្បិចបង្រៀនផ្ទាល់ដៃ និងចំណេះដឹងពីប្រព័ន្ធសុវត្ថិភាព។ល។ |

| | |
|---|---|
| **ការអនុវត្តស្ទែម**<br>(STEM Practices) | ការអនុវត្តការបង្រៀនឬសកម្មភាពស្ទែមដែលស្របទៅនឹងគោលវិធីអប់រំស្ទែមនៅមធ្យមសិក្សាទុតិយភូមិ មានដូចជាសកម្មភាពស្ទែមជាក់ស្តែង ការធ្វើពិសោធន៍ ការប្រើបច្ចេកវិទ្យាសកម្មភាពសហការឬក្រុម សកម្មភាពអន្តរមុខវិជ្ជា គម្រោងស្ទែម ការដោះស្រាយបញ្ហាក្នុងជីវភាពជាក់ស្តែង គម្រោងសហគមន៍ ការផ្សាភ្ជាប់ខ្លឹមសារទៅនឹងបរិបទជាក់ស្តែងនិងអាជីពការងារ ការបញ្ចូលគោលការណ៍សិល្បៈឬរចនា។ល។ ចូរកត់សម្គាល់ថាសកម្មភាពដែលមិនចាំបាច់ត្រូវធ្វើជាអន្តរមុខវិជ្ជាគួរត្រូវពិចារណាក្នុងការអនុវត្តស្ទែមប៉ុន្តែ ត្រូវតែស្របទៅតាមគោលវិធីអប់រំស្ទែមនៅមធ្យមសិក្សាទុតិយភូមិដូចបានរៀបរាប់ខាងលើ។ ឧទាហរណ៍៖ ការបង្ហាញតាមវីដេអូដើម្បីពង្រីកប្រធានបទស្ទែមចាត់ទុកថាជាការអនុវត្តស្ទែម។ |
| **បរិក្ខារឬសម្ភារគម្រោងស្ទែម**<br>(STEM Project Equipment/Materials) | បរិក្ខារ ឬសម្ភារសម្រាប់បង្កើតគម្រោងស្ទែមមានច្រើនប្រភេទ ឧ.កេសក្រដាសរឹងៗ សម្ភារការិយាល័យ ថ្នាំព៌ណ(លាប ផាត់) ជ័រកាវ សម្ភារកាកសំណល់ល្អៗ ដប កន្ត្រៃ ប្រដាប់កិប ស្កុត ។ល។ |
| **ភាគីពាក់ព័ន្ធស្ទែម**<br>(STEM stakeholder) | បុគ្គល អង្គការ ឬក្រុមហ៊ុនដែលមានចំណាប់អារម្មណ៍ជួយស្ទែម។ ឧ.សមាជិកគ្រួសារធ្វើការជាវិជ្ជាជីវៈស្ទែម សាលារៀនផ្សេងៗទៀត អង្គការនៅតាមសហគមន៍ក្នុងតំបន់ អ្នកធុរៈកិច្ច គ្រឹះស្ថានអប់រំឧត្តមសិក្សា អង្គការអន្តរជាតិ និងមជ្ឈមណ្ឌលវិទ្យាសាស្ត្រ និងបច្ចេកវិទ្យា(CSTC)។ |
| **មុខវិជ្ជាស្ទែម**<br>(STEM Subject) | មុខវិជ្ជាស្ទែមនៅមធ្យមសិក្សាទុតិយភូមិ រួមមាន គណិតវិទ្យា រូបវិទ្យា គីមីវិទ្យា ជីវៈវិទ្យា បច្ចេកវិទ្យា(ICT) និងផែនដីវិទ្យា។ |
| **បន្ទប់បង្រៀនស្ទែម**<br>(STEM Teaching Classroom) | បន្ទប់សម្រាប់បង្រៀនស្ទែម(អាចបង្កើតឡើងដោយមានគោលបំណងជា បន្ទប់រៀនវិទ្យាសាស្ត្រ ឬបន្ទប់រៀន ធម្មតាដែលសម្រាប់បង្រៀនមុខវិជ្ជាស្ទែម)។ |
| **ការបំពេញប្រវត្តិរូបរបស់សិស្ស**<br>(Student profiling) | ការប្រមូលព័ត៌មានស្តីពីសមត្ថភាពសិក្សា របៀបរៀន ភាពខ្លាំង ការប្រឈម និងតម្រូវការរបស់សិស្ស តាមរយៈការស្ទង់មតិ/សង្កេត/ការពិនិត្យការសិក្សាដើម្បីផ្តល់ការគាំទ្រអប់រំត្រូវតាមសិស្សម្នាក់ៗ។ |
| **គោលវិធីគ្រូមជ្ឈមណ្ឌល**<br>(Teacher-centered approach) | ជារបៀបបង្រៀនតាមទម្លាប់ ក្នុងទម្រង់អកម្ម ដោយគ្រូបង្រៀនផ្តោតតែទៅលើមេរៀន បង្រៀនតែខ្លឹមសារ និងដឹកនាំសកម្មភាព ការរៀននិងបង្រៀនផ្អែកលើការចងចាំជាចម្បង។ |

| | |
|---|---|
| **សម្ភារបរិក្ខារបច្ចេកវិទ្យា** (Technology facilities) | បន្ទប់គាំទ្រចំពោះកិច្ចណាមួយ ដែលប្រើប្រាស់ក្នុងគោលបំណងតែមួយគត់ក្នុងការបំពាក់បរិក្ខារបច្ចេកវិទ្យា។ សំដៅទៅលើបន្ទប់បំពាក់ដោយបរិក្ខារបច្ចេកវិទ្យា (មិនមែនគ្រាន់តែគ្រឿងបន្លាស់/គ្រឿងបង្គុំទេ)។ ឧទាហរណ៍ បន្ទប់ពិសោធន៍ បន្ទប់ ICT បន្ទប់រៀនឆ្លាតវៃ។ |
| **មុខវិជ្ជាថ្មីកើតពីបន្សំមុខវិជ្ជាច្រើន** (Transdisciplinary) | សំដៅលើគោលវិធីបង្រៀនដោយបញ្ចូលមុខវិជ្ជាចាប់ពី ២មុខវិជ្ជាឡើងទៅ តាមរយៈ ការបន្សី បទពិសោធន៍សិក្សាដោយរលូន។ ជាទូទៅមុខវិជ្ជានេះបង្កើតឡើងរវាងបណ្ដុំមុខវិជ្ជាស្ទែម និង បណ្ដុំមុខវិជ្ជាមិនមែនស្ទែម ឬបរិបទជីវិតប្រចាំថ្ងៃ ដោយបង្ហាញពីបញ្ហាប្រឈម និងដំណោះស្រាយ ជាក់ស្ដែងដែលមិនអាចដោះស្រាយបានពីមុខវិជ្ជាមួយ។ |

# ឧបសម្ព័ន្ធ គ៖ បញ្ជីឈ្មោះសាលារៀនគោលដៅ

## បញ្ជីឈ្មោះវិទ្យាល័យ ៣០ សម្រាប់ការអនុវត្តសាកល្បងក្របខណ្ឌអប់រំស្វែមកម្រិតសាលារៀន ក្រោមគម្រោង STEP UP

| ល.រ | ឈ្មោះសាលា | ឈ្មោះនាយក | លេខទូរសព្ទ | ស្រុក | ខេត្ត | ប្រភេទសាលា |
|---|---|---|---|---|---|---|
| 1 | វិ. បវេល | ល.ហួរ វុទ្ធី | 012 348 736 | បវេល | បាត់ដំបង | ធនធាន |
| 2 | វិ. ហស ស្គន់ | ល.ហ៊ត់ គឹមហុង | 012 283 213 | ជើងព្រៃ | កំពង់ចាម | ធនធាន |
| 3 | វិ. កំពង់ថ្ម | ល.តុប ធីរិទ្ធ | 012 585 394 | សន្ទុក | កំពង់ធំ | ធនធាន |
| 4 | វិ. ហស កោះធំ | ល.ស្រួយ រឿន | 081 493 659 | កោះធំ | កណ្ដាល | ធនធាន |
| 5 | វិ. ហស សម្ភុះបុរៈ | ល.ប៉ៃ គឹមឡាយ | 031 222 2351 | សម្ភុះបុរៈ | ក្រចេះ | ធនធាន |
| 6 | វិ.ហស មណ្ឌលគីរី | ល.យុន គូ | 012 228 245 | សែនមនោរម្យ | មណ្ឌលគីរី | ធនធាន |
| 7 | វិ. រវៀង | ល.បេ នាង | 071 753 2222 | រវៀង | ព្រះវិហារ | ធនធាន |
| 8 | វិ. ហ៊ុន សែន កំពង់ពពិល | ល.ម៉ង់ ធុន | 012 860 176 | ពារាំង | ព្រៃវែង | ធនធាន |
| 9 | វិ. សម្ដេចឪ សម្ដេចម៉ែ | ល.មាស ផាន្នី | 012 500 328 | បានលុង | រតនគីរី | ធនធាន |
| 10 | វិ. អង្គរ | ល.លី វណ្ណៈ | 078 675 775 | សៀមរាប | សៀមរាប | ធនធាន |
| 11 | វិ. ហ៊ុន សែន ចំការដូង | ល. ឡុង សោភា | 011 250 101 | ដំណាក់ចង្អើរ | កែប | ធនធាន |
| 12 | វិ. ហស ប្រសូត្រ | ល.ចាន់ គឹមសែន | 011 711 054 | ស្វាយទាប | ស្វាយរៀង | ធនធាន |
| 13 | វិ. សម្ដេចឪ | លស.ជា សុខខេង | 092 707 572 | សំរោង | តាកែវ | ធនធាន |
| 14 | វិ. ហស ក្រុងទេពនិមិត្ត | ល.ខាំ យ៉ារិន | 078 527 373 | ប៉ៃលិន | ប៉ៃលិន | ធនធាន |
| 15 | វិ. អន្លង់វែង | ល.ស្រេង កុមារ | 012 478 988 | អន្លង់វែង | ឧត្ដរមានជ័យ | ធនធាន |
| 16 | វិ. ហស រលាប្អៀ | ល. សោម ឡូត | 012 494 303 | រលាប្អៀ | កំពង់ឆ្នាំង | បណ្ដាញ |
| 17 | វិ. សម្ដេចឪ | ល. ស៊ុយ ប៊ុនធឿន | 011 259 848 | សិរីសោភ័ណ | ប.មានជ័យ | បណ្ដាញ |
| 18 | វិ. សម្ដេច ហស រលាំងឈូក | ល. ផ្លុង សឿន | 015 35 45 11 | សំរោងទង | កំពង់ស្ពឺ | បណ្ដាញ |
| 19 | វិ. បឹងត្របែក | ល.ផេង សុវណ្ណារ៉ា | 017 509 998 | ចំការមន | ភ្នំពេញ | បណ្ដាញ |
| 20 | វិ. ប៊ុន រ៉ានី ហ៊ុនសែន វត្តភ្នំ | ល. សោម សុផល្លា | 012 947 719 | ដូនពេញ | ភ្នំពេញ | បណ្ដាញ |
| 21 | វិ. ភ្នំក្រវ៉ាញ | ល. ខេង ម៉ៅ | 012 338 327 | ភ្នំក្រវ៉ាញ | ពោធិសាត់ | បណ្ដាញ |
| 22 | វិ. ហស ឃ្លាំងលើ | ល.សៀង រឹម | 070 808 086 | ព្រះសីហនុ | ព្រះសីហនុ | បណ្ដាញ |
| 23 | វិ. បុរីអូរស្វាយសែនជ័យ | ល. ណែម ណុំ | 097 741 080 3 | បុរីអូរស្វាយសែនជ័យ | ស្ទឹងត្រែង | បណ្ដាញ |
| 24 | វិ. ហស វត្តស្វាយ | ល.ភិនសុវណ្ណារិទ្ធ | 012 945 791 | សៀមរាប | សៀមរាប | បណ្ដាញ |
| 25 | វិ. ពាមជាំង | ល.សារ៉េត មាន | 012 968 166 | អូរាំងឪ | ត្បូងឃ្មុំ | បណ្ដាញ |
| 26 | វិ. ហស.ព្រែកត្នោត | ល.មាស បូរ៉ាត់ | 012 330 242 | បូកគោ | កំពត | ទូទៅ |
| 27 | វិ. បូទុមសាគរ | ល. អឿង សុធី | 016 683 425 | បូទុមសាគរ | កោះកុង | ទូទៅ |

| | | | | | | |
|---|---|---|---|---|---|---|
| 28 | វិ.មោងឫស្សី | ល.សែត ម៉ានី | 092 909 251 | មោងឫស្សី | បាត់ដំបង | ទូទៅ |
| 29 | វិ.កោះសូទិន | ល.មួក សារី | 092 910 975 | កោះសូទិន | កំពង់ចាម | ទូទៅ |
| 30 | វិ.ហេងសំរិន ព្រៃល្វា | ល.អ៊ិយ សុជាតិ | 012 208 649 | ព្រៃកប្បាស | តាកែវ | ទូទៅ |

# ឧបសម្ព័ន្ធ ឃះ ក្របខណ្ឌអភិវឌ្ឍការអប់រំស្ទែមកម្រិតសាលារៀន

## ១- គោលនយោបាយស្តីពីការអប់រំស្ទែម

នៅក្នុងសម័យបច្ចុប្បន្នដែលវិទ្យាសាស្ត្រ និងបច្ចេកវិទ្យាកំពុងរីកចម្រើនយ៉ាងឆាប់រហ័ស ការបង្កើតធនធានមនុស្សដែលមានជំនាញខ្ពស់គឺជាកត្តាសំខាន់សម្រាប់ការអភិវឌ្ឍប្រទេសជាតិ។ ជាពិសេស ការអប់រំក្នុងវិស័យវិទ្យាសាស្ត្រ បច្ចេកវិទ្យា វិស្វកម្ម និងគណិតវិទ្យា (STEM) មានសារៈសំខាន់ក្នុងការបណ្តុះបណ្តាលកម្លាំងពលកម្មដែលឆ្លើយតបទៅនឹងតម្រូវការទីផ្សារការងារនាពេលអនាគត និងជម្រុញការច្នៃប្រឌិតនិងការបង្កើតថ្មី។

កម្ពុជាបាននិងកំពុងឆ្លងកាត់សម័យកាលសកលភាវូបនីយកម្ម និងការធ្វើសមាហរណកម្មទៅក្នុងសហគមន៍អាស៊ាន ដែលចាំបាច់កម្ពុជាត្រូវជានាឱ្យបាននូវការអភិវឌ្ឍសេដ្ឋកិច្ចប្រកបដោយចីរភាព និងសមភាព។ វិទ្យាសាស្ត្រ ផ្តល់ដល់យើងនូវលទ្ធភាពក្នុងការបង្កើតឧបករណ៍ជាច្រើនសម្រាប់បម្រើដល់ការរស់រាន និងការវិវត្តរបស់មនុស្សព្រមទាំងបង្កើតនូវកោលានុវត្តភាព និងវេទិកាថ្មីសម្រាប់បច្ចេកវិទ្យាថ្មីៗ និងកាន់តែជឿនលឿនជាងមុន នេះតម្រូវឱ្យកម្ពុជាត្រូវការបណ្តុះបណ្តាលអ្នកជំនាញវិទ្យាសាស្ត្រ បច្ចេកវិទ្យា វិស្វកម្ម និងគណិតវិទ្យាជាច្រើនបន្ថែមទៀត។

ដោយមើលឃើញនូវតម្រូវការចាំបាច់ក្នុងការអភិវឌ្ឍវិស័យវិទ្យសាស្ត្រ បច្ចេកវិទ្យា វិស្វកម្ម និងគណិតវិទ្យា រាជរដ្ឋាភិបាលកម្ពុជា តាមរយៈក្រសួងអប់រំ យុវជន និងកីឡាបានពង្រីក និងលើកទឹកចិត្តចំពោះការអប់រំវិទ្យាសាស្ត្រ បច្ចេកវិទ្យា វិស្វកម្ម និងគណិតវិទ្យា ក្នុងកម្រិតមូលដ្ឋាន និងកម្រិតខ្ពស់។ ក្រសួងអប់រំ យុវជន និងកីឡាមានតួនាទីដ៏សំខាន់ក្នុងការបណ្តុះបណ្តាលធនធានមនុស្សលើជំនាញទាំងនេះ ដើម្បីគាំទ្រដល់ការអភិវឌ្ឍប្រទេសជាតិ។ ក្រសួងមានបេសកកម្មក្នុងការផ្សារភ្ជាប់ខ្លឹមសារមេរៀនទៅនឹងជីវភាពរស់នៅរបស់ប្រជាពលរដ្ឋ ដោយផ្តោតលើការអភិវឌ្ឍជំនាញសតវត្សទី ២១។ នៅកម្រិតឧត្តមសិក្សា ធុរកិច្ចនៃការស្រាវជ្រាវនិងអភិវឌ្ឍ នឹងត្រូវជំរុញឱ្យកាន់តែជិតគ្នានូវសហប្រតិបត្តិការរវាងសាកលវិទ្យាល័យ មន្ទីរពិសោធន៍រដ្ឋ ក្រុមហ៊ុនឯកជន និងអង្គការសង្គមស៊ីវិល ព្រមទាំងជំរុញការអភិវឌ្ឍធនធានមនុស្សផ្នែកវិទ្យាសាស្ត្រ បច្ចេកវិទ្យា និងពង្រឹងការអនុវត្តកម្មសិទ្ធិបញ្ញា ដែលនឹងផ្តល់ការលើកទឹកចិត្តដល់ការធ្វើវិនិយោគផ្នែកនវានុវត្តន៍ជាមួយគ្នានឹងការជំរុញផ្សព្វផ្សាយចំណេះដឹងផ្នែកវិទ្យាសាស្ត្រ និងបច្ចេកវិទ្យា។ បញ្ហាប្រឈមទាំងនេះនឹងត្រូវបានដោះស្រាយដើម្បីឆ្លើយតបតម្រូវការ និងអត្ថប្រយោជន៍របស់ភាគីចូលរួម និងជានាថាការអប់រំវិទ្យាសាស្ត្រ បច្ចេកវិទ្យា វិស្វកម្ម និងគណិតវិទ្យាបានដំណើរការប្រកបដោយសក្តិសិទ្ធិភាព និងផ្តល់នូវដំណោះស្រាយប្រកបដោយប្រសិទ្ធភាពក្នុងការអភិវឌ្ឍសេដ្ឋកិច្ចប្រទេសប្រកបដោយចីរភាព និងសមភាព ជាមួយគ្នានោះ បានកាត់បន្ថយជាអតិបរមានូវហានិភ័យរបស់សង្គមវប្បធម៌ និងបរិស្ថាន។

ហេតុដូច្នេះ ការរៀបចំគោលនយោបាយស្តីពីការអប់រំវិទ្យាសាស្ត្រ បច្ចេកវិទ្យា វិស្វកម្ម និងគណិតវិទ្យា[1] មានភាពចាំបាច់ និងបន្ទាន់បំផុត សម្រាប់ចង្អុលបង្ហាញជាយុទ្ធសាស្ត្រ និងជាផែនទីបង្ហាញផ្លូវសម្រាប់រាល់សកម្មភាពអប់រំ និងស្រាវជ្រាវវិទ្យាសាស្ត្រ បច្ចេកវិទ្យា វិស្វកម្ម និងគណិតវិទ្យា។ ប្រការនេះ កាន់តែធ្វើឱ្យការអភិវឌ្ឍធនធានមនុស្សមានការគាំទ្រកាន់តែខ្លាំងដល់ការសម្រេចដោយជោគជ័យផែនការយុទ្ធសាស្ត្រអភិវឌ្ឍជាតិ គោលនយោបាយអភិវឌ្ឍវិស័យឧស្សាហកម្មកម្ពុជា និងការពង្រីកកិច្ចសហប្រតិបត្តិការផ្នែកវិទ្យាសាស្ត្រ និងបច្ចេកវិទ្យា ជាមួយសហគមន៍អន្តរជាតិ។

[1] ដកស្រង់ចេញពី គោលនយោបាយគោលនយោបាយស្តីពីការអប់រំវិទ្យាសាស្ត្រ បច្ចេកវិទ្យា វិស្វកម្ម និងគណិតវិទ្យា ឆ្នាំ២០១៦

## ចក្ខុវិស័យ

គោលនយោបាយនេះមានចក្ខុវិស័យ អភិវឌ្ឍធនធានមនុស្សប្រកបដោយគុណភាព និងគុណធម៌ លើផ្នែកវិទ្យាសាស្ត្រ បច្ចេកវិទ្យា វិស្វកម្ម និងគណិតវិទ្យា ដើម្បីអភិវឌ្ឍប្រទេសកម្ពុជាប្រកបដោយចីរភាព និងស្មើភាពស្មើសិទ្ធិជាមួយអន្តរជាតិ។

## គោលបំណង

គោលនយោបាយនេះមានគោលបំណង អភិវឌ្ឍសិស្សានុសិស្សនៅកម្រិតអប់រំចំណេះទូទៅ និងនិស្សិតឧត្តមសិក្សា ឱ្យមានសមត្ថភាពផ្នែកវិទ្យាសាស្ត្រ បច្ចេកវិទ្យា វិស្វកម្ម និងគណិតវិទ្យា ឆ្លើយតបនឹងតម្រូវការទីផ្សារការងារក្នុងសហគមន៍ជាតិ តំបន់ និងអន្តរជាតិ។

## គោលដៅ

គោលនយោបាយនេះមានគោលដៅ៖

- បង្កើតលក្ខខណ្ឌ និងបរិស្ថានសមស្របសម្រាប់អភិវឌ្ឍសមត្ថភាពរបស់សិស្ស និស្សិត ក្នុងការសិក្សានិងស្រាវជ្រាវលើមុខវិជ្ជាវិទ្យាសាស្ត្រ បច្ចេកវិទ្យា វិស្វកម្ម និងគណិតវិទ្យា
- ផ្តល់នូវក្របខណ្ឌការងារសម្រាប់ការអភិវឌ្ឍ និងការអនុវត្តកម្មវិធីវិទ្យាសាស្ត្រ បច្ចេកវិទ្យា វិស្វកម្ម និងគណិតវិទ្យានៅគ្រប់កម្រិតសិក្សា
- ជំរុញការសិក្សាមុខវិជ្ជាវិទ្យាសាស្ត្រ បច្ចេកវិទ្យា វិស្វកម្ម និងគណិតវិទ្យា និងផ្សារភ្ជាប់ការសិក្សាមុខវិជ្ជាវិទ្យាសាស្ត្រ បច្ចេកវិទ្យា វិស្វកម្ម និងគណិតវិទ្យា ទៅក្នុងជីវភាពរស់នៅ និងការអប់រំបំណិនជីវិត
- អភិវឌ្ឍសមត្ថភាពគ្រូ និងអ្នកស្រាវជ្រាវផ្នែកវិទ្យាសាស្ត្រ បច្ចេកវិទ្យា វិស្វកម្ម និងគណិតវិទ្យា
- បង្កើនការចូលរួម និងបង្កើនប្រសិទ្ធភាពក្នុងការធ្វើសមាហរណកម្មវិទ្យាសាស្ត្រ បច្ចេកវិទ្យា វិស្វកម្ម និងគណិតវិទ្យាក្នុងការអភិវឌ្ឍសង្គម សេដ្ឋកិច្ច ដោយមានការចូលរួមពេញលេញពីគ្រប់ភាគីពាក់ព័ន្ធ។

## យុទ្ធសាស្ត្រ

### ១. អភិវឌ្ឍក្របខណ្ឌច្បាប់និងយន្តការ

- បង្កើតក្របខណ្ឌច្បាប់ និងលិខិតបទដ្ឋានគតិយុត្តសម្រាប់ជំរុញនិងលើកកម្ពស់ការអប់រំ និងស្រាវជ្រាវវិទ្យាសាស្ត្រ បច្ចេកវិទ្យា វិស្វកម្ម និងគណិតវិទ្យា
- ពិនិត្យឡើងវិញតួនាទី និងភារកិច្ចរបស់នាយកដ្ឋានពាក់ព័ន្ធ
- រៀបចំផែនការសកម្មភាពដើម្បីពង្រឹងសកម្មភាពអប់រំវិទ្យាសាស្ត្រ បច្ចេកវិទ្យា វិស្វកម្ម និងគណិតវិទ្យា
- ចងក្រងធនធានទិន្នន័យ និងបណ្តាញព័ត៌មាន ដើម្បីសម្របសម្រួលនិងតាមដានសកម្មភាពអប់រំ និងស្រាវជ្រាវវិទ្យាសាស្ត្រ បច្ចេកវិទ្យា វិស្វកម្ម និងគណិតវិទ្យា
- អភិវឌ្ឍសមត្ថភាពស្ថាប័ន និងគ្រឹះស្ថានសិក្សាក្នុងការលើកសំណើគម្រោងអប់រំ និងស្រាវជ្រាវវិទ្យាសាស្ត្រ បច្ចេកវិទ្យា វិស្វកម្ម និងគណិតវិទ្យា
- បង្កើតប្រព័ន្ធតាមដាន និងវាយតម្លៃសកម្មភាពអប់រំ និងសកម្មភាពស្រាវជ្រាវអំពីវិទ្យាសាស្ត្រ បច្ចេកវិទ្យា វិស្វកម្ម និងគណិតវិទ្យា

- កសាងសមត្ថភាព និងយន្តការប្រកបដោយប្រសិទ្ធភាព សម្រាប់ការភ្ជាប់ទំនាក់ទំនងរវាងស្ថាប័នរដ្ឋាភិបាល គ្រឹះស្ថានសិក្សា និងវិស័យឯកជន ព្រមទាំងការចែករំលែកការផ្សព្វផ្សាយបច្ចេកវិទ្យា ការការពារកម្មសិទ្ធិបញ្ញា និងកិច្ចសហប្រតិបត្តិការវិស័យបច្ចេកវិទ្យា និងនវានុវត្តន៍។

## ២. អភិវឌ្ឍគ្រឹះស្ថានសិក្សាផ្នែកវិទ្យាសាស្ត្រ បច្ចេកវិទ្យា វិស្វកម្ម និងគណិតវិទ្យា

- អភិវឌ្ឍកម្មវិធីសិក្សាផ្នែកវិទ្យាសាស្ត្រ បច្ចេកវិទ្យា វិស្វកម្ម និងគណិតវិទ្យា
- អភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធអប់រំ ឆ្លើយតបនឹងការអប់រំនិងស្រាវជ្រាវវិទ្យាសាស្ត្រ បច្ចេកវិទ្យា វិស្វកម្ម និងគណិតវិទ្យា
- ផ្តល់មធ្យោបាយ និងធនធានសម្រាប់សកម្មភាពអប់រំ និងស្រាវជ្រាវវិទ្យាសាស្ត្រ បច្ចេកវិទ្យា វិស្វកម្ម និងគណិតវិទ្យា

## ៣. អភិវឌ្ឍសមត្ថភាពបុគ្គលិកអប់រំផ្នែកវិទ្យាសាស្ត្រ បច្ចេកវិទ្យា វិស្វកម្ម និងគណិតវិទ្យា

- ផ្តល់ការអប់រំអំពីវិទ្យាសាស្ត្រដល់សិស្ស និស្សិតនៅក្នុងប្រព័ន្ធអប់រំ ចាប់ពីបឋមសិក្សារហូតដល់ឧត្តមសិក្សា ទាំងផ្នែកសាធារណៈ និងឯកជន
- អភិវឌ្ឍចំណេះដឹងផ្នែកវិទ្យាសាស្ត្រ បច្ចេកវិទ្យា វិស្វកម្ម និងគណិតវិទ្យា ដល់បុគ្គលិកអប់រំ និងគ្រូបង្រៀនផ្នែកវិទ្យាសាស្ត្រ បច្ចេកវិទ្យា វិស្វកម្ម និងគណិតវិទ្យា
- ជំរុញ និងផ្សព្វផ្សាយការស្រាវជ្រាវ ការរកឃើញថ្មី និងការស្រាវជ្រាវដែលអាចទទួលយកបាន ដើម្បីពង្រឹងសមត្ថភាពអ្នកវិទ្យាសាស្ត្រ និងអ្នកស្រាវជ្រាវជាស្ត្រី
- ជំរុញការបង្កើតទម្លាប់ និងការគិតគូរពីវិទ្យាសាស្ត្រ និងនវានុវត្តន៍នៅក្នុងស្ថាប័ន និងគ្រឹះស្ថានសិក្សា
- បង្កើតមូលនិធិប្រាក់កម្ចីសម្រាប់សិស្ស និស្សិតពូកែ ដើម្បីទទួលបានការសិក្សានៅក្រៅប្រទេសលើជំនាញវិទ្យាសាស្ត្រ បច្ចេកវិទ្យា វិស្វកម្ម និងគណិតវិទ្យា។

## ៤. លើកកម្ពស់សមភាពយេនឌ័រក្នុងការអប់រំវិទ្យាសាស្ត្រ បច្ចេកវិទ្យា វិស្វកម្ម និង គណិតវិទ្យា

- ផ្តល់ការលើកទឹកចិត្តជាពិសេសសិស្សស្រី និងនិស្សិតនារី ចូលរួមសកម្មភាពអប់រំ និងស្រាវជ្រាវវិទ្យាសាស្ត្រ បច្ចេកវិទ្យា វិស្វកម្ម និងគណិតវិទ្យា
- ផ្តល់កាលានុវត្តភាពដល់ស្ត្រី និងបុរស និងស្ថាប័នដែលធ្វើការអប់រំ និងស្រាវជ្រាវវិទ្យាសាស្ត្រ បច្ចេកវិទ្យា វិស្វកម្ម និងគណិតវិទ្យា
- ផ្តល់ការណែនាំតម្រង់ទិសដល់អ្នកសិក្សា និងអ្នកស្រាវជ្រាវលើផ្នែកវិទ្យាសាស្ត្រ បច្ចេកវិទ្យា វិស្វកម្ម និងគណិតវិទ្យា
- ចាត់ចែងនិងសម្របសម្រួលដល់គ្រប់គ្រឹះស្ថានសិក្សាលើការអប់រំនិងស្រាវជ្រាវវិទ្យា សាស្ត្រ បច្ចេកវិទ្យា វិស្វកម្ម និងគណិតវិទ្យា

## ៥. លើកកម្ពស់កិច្ចសហប្រតិបត្តិការអប់រំវិទ្យាសាស្ត្រ បច្ចេកវិទ្យា វិស្វកម្ម និងគណិតវិទ្យា

- បញ្ចូលការអប់រំវិទ្យាសាស្ត្រ បច្ចេកវិទ្យា វិស្វកម្ម និងគណិតវិទ្យាទៅក្នុងប្រព័ន្ធអប់រំទូទៅ និងការយល់ដឹងជាសាធារណៈ
- ផ្តល់ការលើកទឹកចិត្តសម្រាប់ការបង្កើតលទ្ធផល និងសកម្មភាពស្រាវជ្រាវវិទ្យាសាស្ត្រ បច្ចេកវិទ្យា វិស្វកម្ម និងគណិតវិទ្យា

- កៀរគរធនធានពីដៃគូអភិវឌ្ឍ និងអ្នកពាក់ព័ន្ធ ដើម្បីគាំទ្រគំនិតផ្តួចផ្តើមរៀបចំវេទិកា និងសកម្មភាពវិទ្យាសាស្ត្រ បច្ចេកវិទ្យា វិស្វកម្ម និងគណិតវិទ្យា
- អភិវឌ្ឍ និងណែនាំដល់គ្រប់គ្រឹះស្ថានសិក្សាផ្នែកវិទ្យាសាស្ត្រ បច្ចេកវិទ្យា វិស្វកម្ម និង គណិតវិទ្យា។

# ២- ឯកសារប្រតិបត្តិការអប់រំស្ទែម

## ២.១- អភិបាលកិច្ចសាលារៀនស្ទែម

### ក. រចនាសម្ព័ន្ធគ្រប់គ្រងការអប់រំស្ទែម[2]

ក្នុងការគ្រប់គ្រងសាលារៀនស្ទែម សាលារៀនត្រូវរៀបចំរចនាសម្ព័ន្ធគ្រប់គ្រងដោយមានការចូលរួមពីភាគី ដូចជាក្រុមប្រឹក្សាភិបាល គណៈកម្មការទ្រទ្រង់សាលារៀន នាយក ឬនាយករងទទួលបន្ទុកការងារស្ទែម គ្រូប្រឹក្សាឬគ្រូគាំទ្រ និងលោកគ្រូ អ្នកគ្រូឯកទេសស្ទែម។ ខាងក្រោមនេះ ជាតារាងបង្ហាញពីរចនាសម្ព័ន្ធនៃការអប់រំស្ទែម។

**រូបទី 2៖ រចនាសម្ព័ន្ធគ្រប់គ្រងការអប់រំស្ទែម**




[2] ដកស្រង់ចេញពីបទពិសោធន៍របស់វិទ្យាល័យព្រះស៊ីសុវត្ថិ សាលារៀនជំនាន់ថ្មី

## ២. តួនាទីភារកិច្ចនាយករងទទួលបន្ទុកស្ទែម

នាយករងទទួលបន្ទុកស្ទែម មានតួនាទី និងភារកិច្ចលម្អិត ដូចបង្ហាញក្នុងតារាងទី3។

**រូបទី 3៖ តួនាទីរបស់នាយករងទទួលបន្ទុកស្ទែម**




## ២.២- ការបង្រៀនតាមបែបស្ទែម

ដើម្បីឱ្យការបង្រៀនតាមបែបស្ទែមមានប្រសិទ្ធភាព វិធីសាស្ត្របង្រៀនត្រូវតែអនុវត្តតាមបែបស្ថាបនានិយម បែបសហការ ដែលជាវិធីសាស្ត្រសកម្ម សិស្សរៀនទ្រឹស្តីតិច ផ្សារភ្ជាប់នឹងការអនុវត្ត និងពិសោធន៍ច្រើន ហើយគ្រូបង្រៀនដើរតួជាអ្នកសម្របសម្រួល។ ក្នុងការបង្រៀនបែបនេះ សិស្សត្រូវបានបង្រៀនបែបស្រាវជ្រាវ ធ្វើការងារគម្រោង និងធ្វើទស្សនកិច្ចសិក្សាទៅទីតាំងផ្ទាល់។ ម្យ៉ាងវិញទៀត ការបង្រៀនក៏ត្រូវផ្តោតសំខាន់លើការអប់រំវិរិយាបថ សីលធម៌ និងសុជីវធម៌ផងដែរ។ ការរៀបចំកម្មវិធីសិក្សាប្រចាំឆ្នាំ និងកម្មវិធីសិក្សាលម្អិតតាមមុខវិជ្ជា កម្មវិធីសិក្សាពិសោធន៍ ក៏រួមចំណែកយ៉ាងសកម្មក្នុងការបង្រៀនបែបស្ទែម ដែលកម្មវិធីសិក្សាបង្ហាញពីសកម្មភាពក្នុងម៉ោងសិក្សា និងក្រៅម៉ោងសិក្សា បូកបន្ថែមការពិសោធន៍ និងការងារគម្រោង។ បន្ទាប់ពីការបង្រៀន និងការអនុវត្ត ការវាយតម្លៃការងារគម្រោង និងការស្រាវជ្រាវជាប្រចាំត្រូវមានគណៈកម្មការដែលបានចាត់តាំង ដោយមានឧទ្ទេសនាមសម្រាប់ដឹកនាំ ណែនាំ និងវាយតម្លៃផងដែរ។

ក្រៅពីការរៀននៅក្នុងថ្នាក់ សិស្សានុសិស្សត្រូវបានលើកទឹកចិត្តក្នុងការចូលរួមប្រកួតប្រជែងក្នុង និងក្រៅប្រទេស ដើម្បីឱ្យសិស្សស្វែងយល់បន្ថែមពីពិភពខាងក្រៅសាលារៀន និងរៀនសូត្របន្ថែម។ ក្នុងនោះដែរ ទំនាក់ទំនងអាណាព្យាបាលសិស្ស ការតាមដានការសិក្សារបស់សិស្ស ការស្រង់វត្តមានគ្រូ-សិស្សជាប្រចាំដោយគ្រូប្រឹក្សាអាជីព និងការប្រឹក្សាគ្រូថ្មីៗ និងមានតម្រូវការបន្ថែមពីការបង្រៀនដោយគ្រូប្រឹក្សាគរុកោសល្យ ជាចំណុចសំខាន់ដើម្បីឱ្យដំណើរការរៀន និងបង្រៀនកាន់តែមានប្រសិទ្ធភាព។

សម្រាប់គ្រូបង្រៀន ត្រូវមានការប្រជុំបច្ចេកទេស ប្រជុំប្រចាំខែ PLC ជាប្រចាំ ត្រូវវិភាគលទ្ធផលសិក្សារបស់សិស្សតាមកម្រិតថ្នាក់ និងតាមមុខវិជ្ជា ដើម្បីរៀបចំផែនការបន្ត។ ក្នុងករណីសិស្សត្រូវការជំនួយផ្នែកស្ទែមបន្ថែម ត្រូវបង្កើតកម្មវិធីបំប៉នបន្ថែមលើសិស្សតម្រូវការពិសេស តាមរយៈគ្រូមុខវិជ្ជាស្ទែម។

## ២.៣- ការអនុវត្តកម្មវិធីសិក្សា និងម៉ោងសិក្សាមុខវិជ្ជាស្ទែម

ខាងក្រោមនេះជាតារាងសង្ខេបពីម៉ោងបង្រៀន និងមុខវិជ្ជាស្ទែមតាមកម្រិតថ្នាក់នីមួយៗ។

**តារាងទី 16៖ ម៉ោងសិក្សាមុខវិជ្ជាស្ទែម**

| ល.រ | មុខវិជ្ជា | ថ្នាក់ទី៧ (h/w) | ថ្នាក់ទី៨ (h/w) | ថ្នាក់ទី៩ (h/w) | ថ្នាក់ទី១០ (h/w) | ថ្នាក់ទី១១ (h/w) | ថ្នាក់ទី១២ (h/w) |
|---|---|---|---|---|---|---|---|
| ១ | គណិតវិទ្យា | 6 | 6 | 6 | 6 | 6 | 7 |
| ២ | រូបវិទ្យា | 4 | 4 | 4 | 4 | 4 | 5 |
| ៣ | គីមីវិទ្យា | 4 | 4 | 4 | 4 | 4 | 5 |
| ៤ | ជីវវិទ្យា | 4 | 4 | 4 | 4 | 4 | 5 |
| ៥ | ផែនដីវិទ្យា | 1 | 1 | 1 | 1 | 1 | 1 |

* * h/w= ម៉ោង/សប្តាហ៍

1. គណិតវិទ្យា៖ រៀន៦ ម៉ោង ឬ៧ ម៉ោង(ថ្នាក់ទី១២) ដែលមានទាំងទ្រឹស្តី និងការអនុវត្តក្នុងជីវភាពរស់នៅប្រចាំថ្ងៃ ស្រាវជ្រាវលើបំណិនជីវិត។
2. រូបវិទ្យា៖ រៀន៤ ម៉ោងក្នុងមួយសប្តាហ៍ទៅតាមក្តីស្រមៃរបស់សិស្សដែលចង់ក្លាយជាវិស្វករ អ្នកវិទ្យាសាស្ត្រ។ កម្មវិធីសិក្សានេះជាការរៀនទ្រឹស្តីផ្សារភ្ជាប់នឹងការអនុវត្តពិសោធន៍ជាក់ស្តែងក្នុង និងក្រៅថ្នាក់រៀន។ លើសពីនោះទៀតសិស្សអាចយកទ្រឹស្តីដែលបានរៀន មកធ្វើការងារគម្រោងផងដែរ។
3. គីមីវិទ្យា៖ រៀន៤ ម៉ោង ក្នុងមួយសប្តាហ៍ ទៅតាមក្តីស្រមៃរបស់សិស្សដែលចង់ក្លាយជាវិស្វករ អ្នកវិទ្យាសាស្ត្រ ឬផ្នែកគ្រូពេទ្យ ឱសថសាស្ត្រ។ កម្មវិធីសិក្សានេះជាការរៀនទ្រឹស្តីផ្សារភ្ជាប់នឹងការអនុវត្តពិសោធន៍ជាក់ស្តែងក្នុង និងក្រៅថ្នាក់រៀន។ លើសពីនោះទៀត សិស្សអាចយកទ្រឹស្តីដែលបានរៀន មកធ្វើការងារគម្រោងផងដែរ។
4. ជីវវិទ្យា៖ រៀន៤ ម៉ោង ក្នុងមួយសប្តាហ៍ ទៅតាមក្តីស្រមៃរបស់សិស្សដែលចង់ក្លាយជាវិស្វករ អ្នកស្រាវជ្រាវវិទ្យាសាស្ត្រ វេជ្ជសាស្ត្រ ឬគ្រូពេទ្យ។ កម្មវិធីសិក្សានេះ ជាការរៀនទ្រឹស្តី ផ្សារភ្ជាប់នឹងការអនុវត្តពិសោធន៍ជាក់ស្តែងក្នុង និងក្រៅថ្នាក់រៀន។ លើសពីនោះទៀតសិស្សអាចយកទ្រឹស្តីដែលបានរៀន មកធ្វើការងារគម្រោងផងដែរ។

5. ផែនដីវិទ្យាៈ រៀន1 ម៉ោងក្នុងមួយសប្តាហ៍ ដែលរួមបញ្ចូលការសិក្សាពីរូបភាពជាក់ស្តែងក្នុងថ្នាក់រៀន និងតាមរយៈទស្សនកិច្ចសិក្សាទៅទីតាំងផ្ទាល់ ឬការប្រើប្រាស់សម្ភារឧបទេសផ្សេងៗ។ ពេលត្រឡប់មកវិញ សិស្សត្រូវមានរបាយការណ៍ និងការរៀបចំសិក្ខាសាលាចែករំលែកនូវអ្វីដែលបានរៀនសូត្រ។

*** ការអនុវត្តៈ 3 ម៉ោងក្នុងមួយសប្តាហ៍ ជាពេលដែលសិស្សអាចចូលបណ្ណាល័យ ធ្វើស្វ័យសិក្សា រៀនបំណិនជីវិត ឬអប់រំសុខភាព ឬធ្វើការងារគម្រោង ឬជួបជាមួយគ្រូប្រឹក្សាអាជីព។ ការបន្ថែមម៉ោង និងបញ្ចូលការសិក្សាក្រៅប្រព័ន្ធ គឺដើម្បីឱ្យសិស្សមានបំណិនសតវត្សទី២១ ដូចជា ការធ្វើទំនាក់ទំនង ការសហការ គំនិតច្នៃប្រឌិត និងការបង្កើតថ្មី។

## ២.៤- ការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធស្ទែម

ដើម្បីឱ្យសិស្សចល័តថ្នាក់ទៅតាមកាលវិភាគជាក់ស្តែងបាន សាលារៀនត្រូវរៀបចំបន្ទប់ទៅតាមមុខវិជ្ជា ហើយតាមបន្ទប់នីមួយៗត្រូវបំពាក់ដោយសម្ភារឧបទេស តម្រូវការតាមមុខវិជ្ជានីមួយៗ បណ្តាញអ៊ិនធឺណិតគ្រប់គ្រាន់ និងការជួសជុលជាប្រចាំទៅតាមតម្រូវការ និងភាពចាំបាច់។ គ្រូបង្រៀន និងបុគ្គលិកអប់រំទាំងអស់ មានកុំព្យូទ័រយួរដៃសម្រាប់ប្រើប្រើប្រាស់បច្ចេកវិទ្យាក្នុងការបង្រៀន ហើយសិស្សត្រូវបានលើកទឹកចិត្តឱ្យមានកុំព្យូទ័រប្រើ ដើម្បីអនុវត្តបន្ថែមនៅផ្ទះ។

## ២.៥- ការចូលរួមរបស់សហគមន៍

ការរៀបចំឱ្យមានគណៈកម្មការគ្រប់គ្រងសាលារៀន ដែលជាតំណាងអាណាព្យាបាលសិស្សស្ម័គ្រចិត្ត ដែលត្រូវបានជ្រើសរើសជារៀងរាល់ឆ្នាំ ជាកត្តាក្នុងការតាមដាន និងរៀបចំដំណើរការសាលារៀនឱ្យមាននិរន្តរភាព។ ក្នុងនោះដែរ សាលារៀនត្រូវរៀបចំការប្រជុំអាណាព្យាបាលយ៉ាងតិច២ ដងក្នុង១ ឆ្នាំ (ធមាសទី១ ម្តង និងប្រចាំឆ្នាំម្តង) ដើម្បីផ្តល់ព័ត៌មានផ្សេងៗពីការសិក្សារបស់កូនៗគាត់។ សាលារៀនក៏គួរតែរៀបចំសិក្ខាសាលាចែករំលែកពីអាណាព្យាបាលដែលមានជំនាញត្រូវនឹងសម្រង់អាជីពសិស្ស និងស្វះស្វែងរកដៃគូសហការផ្សេងៗក្នុង និងក្រៅប្រទេស ដែលផ្តល់អត្ថប្រយោជន៍ដល់សិស្ស ក្នុងការចូលរួមកម្មវិធីផ្សេងៗផងដែរ។ គណៈកម្មការទ្រទ្រង់សាលារៀន ត្រូវបានលើកទឹកចិត្តក្នុងការចូលរួមរៀបចំកម្មវិធីប្រចាំសាលាដូចជា ការតាំងបង្ហាញស្នាដៃសិស្សប្រចាំឆ្នាំ ការរៀបចំកម្មវិធីសង្ក្រាន្តឆ្នាំថ្មី និងទិវារំលឹកគុណគ្រូបង្រៀនជាដើម។

## ២.៦- ការជ្រើសរើសសិស្សចូលរួមនៅក្នុងសាលារៀនស្ទែម

ការជ្រើសរើសសិស្សចូលរួមនៅក្នុងសាលារៀនស្ទែម ចែកចេញជាបីជំហាន ដូចបង្ហាញក្នុងរូបខាងក្រោម។

**រូបទី 4៖ នីតិវិធីនៃការចូលរៀន**



**ដំណាក់កាលជ្រើសរើសសិស្សចូលរៀន៖**

- ជំហានទី១៖ ការប្រកាសជ្រើសរើសសិស្សក្នុងសាលារៀន អាចមើលលើពិន្ទុមុខវិជ្ជាស្ទែម និងពិន្ទុប្រចាំខែ
- ជំហានទី២៖ ការសម្ភាសសិស្សដែលមានការតាំងចិត្ត និងឆន្ទៈក្នុងការរៀន មានសីលធម៌ វិន័យ និងឥរិយាបថល្អ ចូលចិត្តស្រាវជ្រាវ មានទេពកោសល្យ មានការច្នៃប្រឌិតថ្មី និងការប្រកួតប្រជែង និងមានភាពជាអ្នកដឹកនាំ។ ដើម្បីឱ្យដំណើរការនេះមានប្រសិទ្ធភាព សាលារៀនត្រូវរៀបចំគណៈកម្មការស្ទែមជាមុន។
- ជំហានទី៣៖ សិស្សប្រឡងវិញ្ញាសាលើមុខវិជ្ជាស្ទែម រួមមាន គណិតវិទ្យា វិទ្យាសាស្ត្រ និងភាសាខ្មែរ។
- ជំហានទី៤៖ សិស្សដែលប្រឡងជាប់ ត្រូវចុះឈ្មោះចូលរៀន រៀបចំថ្នាក់រៀនតាមចំនួនសិស្ស និងទៅតាមមុខជំនាញដែលត្រូវនឹងចំណាប់អារម្មណ៍របស់ខ្លួន (រូបវិទ្យា គីមីវិទ្យា ឬជីវវិទ្យា)។